ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- ការពិភាក្សាជុំវិញ [illegible] ខ្មែរក្រហម
- ប្រធានាធិបតីសហរដ្ឋអាមេរិក ជិមមី ខាតធ័រ៖ សិទ្ធិមនុស្ស និង កម្ពុជា

[illegible]

លេខ១០៩ ខែ មករា ឆ្នាំ២០០៩

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

ស្វែងរកការពិត

លេខ៤៩ ខែមករា ឆ្នាំ២០០៤

## មាតិកា


◆ សំបុត្រ ៖ ការពិភាក្សាជុំវិញបញ្ហាថវិកា ........................................១

**ផ្នែកឯកសារ**

◆ តូ ធីភាគ ប្រធានមន្ទីរក-១៥ ........................................២

◆ បញ្ជីឈ្មោះជនរងគ្រោះ ........................................៦

◆ ផែនការស្រាវជ្រាវប្រចាំឆ្នាំ២០០៤ ........................................៨

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ រឿងពិតរបស់ ប្រាក់ យឿន........................................២៣

◆ ប្រធានាធិបតីសហរដ្ឋអាមេរិក ជីមមី ខាតធ័រ........................................២៧

**ផ្នែកច្បាប់**

◆ ករណីយុទ្ធសាស្ត្រនៅក្នុងតុលាការ ........................................៣៩

**វេទិកាពិភាក្សាសាធារណៈ**

◆ លិខិតចំហទីពីររបស់ ខៀវ សំផន ........................................៤៤

◆ ការវិវឌ្ឍន៍ថ្មីនៃដំណើរការតុលាការកាត់ទោស........................................៤៨

◆ អន្តរទំនាក់ទំនងរវាងយុត្តិធម៌និងការផ្សះផ្សាជាតិ........................................៥០

◆ ដំណោះស្រាយក្រោយជម្លោះ ........................................៥៣

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ដើមឆ្នាំនិងបដិវត្តន៍វប្បធម៌របស់ប្រទេសចិន ........................................៥៨




ខៀវ សំផន



នួន ជា



អៀង សារី


## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា



អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងពត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងពត៌មាន
លេខ ០២៩១៣ម,៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ៖** សូ ហ្វារីណា, ខេនគុន ក្ហេម័រ, ខេលលី អាសគីន, ខៀវ សំផន, ដួង សុភារិទ្ធ, អៀ ម៉េងទ្រី, កាវ ឈីងកួ និង យិន នាន **អ្នកនិពន្ធនិងស្រាវជ្រាវ៖** លី សុផល, ផាត រចនា **ជំនួយការនិពន្ធនាយក៖** សាន់ កល្យាណ **និពន្ធនាយករង៖** សួ ប៊ុនស៊ូ **អ្នកបកប្រែ៖** អេង កុកថាយ **និពន្ធនាយកទូទៅ៖** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រ៖** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយ៖** មាស ប៊ុនថាន

*សំបុត្រៈ*

# ការពិភាក្សាជុំវិញបញ្ហាថវិកាក្នុងការបង្កើតសាលាជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម

*ខ្ញុំមានក្តីរីករាយណាស់ដែលអង្គការសហប្រជាជាតិបានមកទីក្រុងភ្នំពេញកាលពីខែធ្នូ ដើម្បីពិភាក្សាអំពីការបង្កើតសាលាជំនុំជម្រះក្តីអតីតមេដឹកនាំខ្មែរក្រហម ។ ប៉ុន្តែក្នុងពេលជាមួយគ្នានេះដែរ ខ្ញុំក៏មានការព្រួយបារម្ភអំពីគម្រោងចំណាយសម្រាប់ដំណើរការបង្កើតសាលាក្តីនេះ ។ ថវិកាដែលត្រូវចំណាយទៅលើខ្ទង់ចំណាយមួយចំនួនហាក់បីដូចជាខ្ពស់ហួសប្រមាណ ដូចជាត្រូវចំណាយប្រាក់មួយលានពីរសែនដុល្លារសម្រាប់សម្ភារៈការិយាល័យ ដែលក្នុងនោះប្រាក់ប្រាំសែនដុល្លារត្រូវចំណាយតែទៅលើការធ្វើដំណើរតែមួយមុខ ។ ម្យ៉ាងវិញទៀត ជាជាងការសាងសង់អគារថ្មី យើងអាចយកទីតាំងដែលមានស្រាប់ធ្វើសាលាក្តីបានដែរ ឧទាហរណ៍ដូចជាសាលមហោស្រពចតុមុខនិងអគារគណៈកម្មការទន្លេមេគង្គជាដើម ។*

*នៅពេលដែលអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាប៉ាន់ស្មានប្រាក់ចំណាយសន្ទឹកសន្ធាប់បែបនេះ និងជាប្រការមួយនឹងអាចបណ្តាលឲ្យមានការពន្យារពេលក្នុងការរកថវិកា ហើយថែមទាំងបង្អាក់ទឹកចិត្តម្ចាស់ជំនួយសំខាន់ៗក្នុងការផ្តល់ថវិកាដើម្បីបង្កើតសាលាក្តីទៀតផង ។*

*រាជរដ្ឋាភិបាលនិងអង្គការសហប្រជាជាតិគួរតែធ្វើការចំណាយឲ្យបានតិចបំផុតតាមការចាំបាច់ជាក់ស្តែង ដើម្បីសម្តែងអំពីភាពបន្ទាន់និងឆន្ទៈក្នុងការជួយដល់ជនរងគ្រោះ ។ រាជរដ្ឋាភិបាលកម្ពុជាគួរតែបង្ហាញអំពីសុឆន្ទៈរបស់ខ្លួនក្នុងការបង្កើតសាលាក្តីតាមរយៈការប្រើប្រាស់ប្រាក់បំណាច់ពីធនធានផ្ទាល់ ដែលគឺជាការចំណាយតាមកម្រិតក្នុងស្រុកប្រសើរជាងការពឹងផ្អែកទាំងស្រុងទៅលើប្រភពធនធានដែលមិនច្បាស់លាស់ពីបរទេស ។ ប្រការនេះនឹងអាចបង្ហាញអំពីឆន្ទៈម៉ឺងម៉ាត់របស់រាជរដ្ឋាភិបាលក្នុងការបង្កើតសាលាក្តីចំពោះសហគមន៍អន្តរជាតិដែលជាម្ចាស់ជំនួយសំខាន់ៗ ។ រាជរដ្ឋាភិបាលកម្ពុជាគួរយកជនរងគ្រោះជាបញ្ហាចម្បងជាជាងផលប្រយោជន៍ផ្ទាល់ខ្លួន ។*

*ខ្ទង់ចំណាយខ្ពស់មួយចំនួន(ដកស្រង់ចេញពីគម្រោងថវិការៀបរៀងដោយរាជរដ្ឋាភិបាលកម្ពុជា) មានដូចជា ÷ គ្រឿងសម្ភារការិយាល័យ (មួយលានពីរសែនដុល្លារ) , យានជំនិះ (ប្រាំសែនដុល្លារ) , ការចងក្រងឯកសារនិងស្រាវជ្រាវ (បីសែនប្រាំម៉ឺនដុល្លារ) , គ្រឿងសង្ហារិមសម្រាប់តុលាការ (ប្រាំបីសែនប្រាំម៉ឺនដុល្លារ) , គ្រឿងសង្ហារិមការិយាល័យ (ប្រាំពីរសែនប្រាំម៉ឺនដុល្លារ) , ឧបករណ៍សម្រាប់ឃុំខ្លួន (ប្រាំមួយសែនដុល្លារ) និងកន្លែងស្នាក់នៅសម្រាប់សាក្សី (បីសែនប្រាំម៉ឺនដុល្លារ) ។*

**ឆាំង យុ**



*ធនាគារជាតិ (រូបថតឆ្នាំ១៩៧៩)*

*អត្ថបទសង្ខេបចេញពីចម្លើយសារភាព*

# គូ ធីភាគ ប្រធានមន្ទីរ ក-១៥ បឹងត្របែក

គូ ធីភាគ កើតក្នុងត្រកូលអាជីវករឪពុកឈ្មោះ គូ ហយ និង ម្តាយឈ្មោះ អៀប ភៀង ។ ធីភាគ មានស្រុកកំណើតនៅភូមិស្វាយប៉ោ ឃុំសង្កែ ស្រុកសង្កែ ខេត្តបាត់ដំបង ។ ឪពុករបស់ ធីភាគ ប្រកបរបររត់ពន្ធស្ករសពីភ្នំពេញទៅលក់នៅបាត់ដំបង ។ នៅក្នុងឆ្នាំ១៩៤២ ឪពុកម្តាយរបស់ ធីភាគ បានលែងលះគ្នា ប៉ុន្តែ ធីភាគ នៅបន្តការសិក្សានៅខេត្តបាត់ដំបងរហូតដល់ឆ្នាំ ១៩៥៧ ទើបផ្លាស់មករស់នៅភ្នំពេញជាមួយម្តាយ ហើយបន្តការសិក្សានៅសាលាចិន ម៉េង-សែ ដែលមានទីតាំងនៅជួរមាត់ទន្លេ ខាងជើងពេទ្យធំ ។

ពេលសិក្សានៅសាលា ចាងហ្វាងសាលានិងគ្រូៗតែងតែអប់រំឲ្យ ធីភាគ និងសិស្សដទៃទៀតយល់ពីនយោបាយអាក្រក់របស់លទ្ធិកុម្មុយនិស្តដែលបំបិទសេរីភាពប្រជាជន និងលើកសរសើរអង្គការក្កុកមីងតាំងដែលយកចិត្តទុកដាក់ និងគិតផលប្រយោជន៍របស់ប្រជាជន ។ នៅឆ្នាំ១៩៥៩ ធីភាគ ត្រូវបានជ្រើសរើសឲ្យចូលជាសមាជិកអង្គការក្កុកមីងតាំង ដោយសារ ទីមួយ ៈ ធីភាគ មានឪពុកនិងឪពុកមាជាខ្សែរយៈបក្សក្កុកមីងតាំងស្រាប់ដែលបង្កលក្ខណៈងាយស្រួលក្នុងការបំពេញសកម្មភាព និងទីពីរៈ ធីភាគ មានលក្ខណៈសម្បត្តិល្អដោយសារចេះនិយាយភាសាខ្មែរនិងចិនងាយស្រួលក្នុងការឃោសនាប្រឆាំងនឹងបក្សកុម្មុយនិស្តកម្ពុជា (ដែលស្គាល់ជាទូទៅថាខ្មែរក្រហម) ។ ធីភាគ បញ្ជាក់ថា ទង់សញ្ញារបស់បក្សក្កុកមីងតាំងមានផ្ទៃពណ៌ខៀវនិងមានព្រះអាទិត្យពណ៌សនៅចំកណ្តាល ។ សូ ជា ជាអ្នកនាំ ធីភាគ ឲ្យចូលក្នុងបក្សក្កុកមីងតាំង ហើយ លីន ចុងអាន ជាអ្នកខទ្មេសនាម ។ លីន ចុងអាន និង សូ ជា បានទូន្មាន ធីភាគ ឲ្យឃោសនាប្រជាជនឲ្យធ្ងើចលនាប្រឆាំងនឹងពួកកុម្មុយនិស្តដើម្បីជួយជំរុញឲ្យប្រទេសវៀតណាមរំដោះប្រទេសកាន់តែឆាប់ដើម្បីឲ្យវៀតណាម កម្ពុជា និងឡាវ ក្លាយទៅជាសហព័ន្ធឥណ្ឌូចិន ក្រោមការដឹកនាំរបស់វៀតណាម ។ បន្ទាប់ពីខទ្មេសនាមឲ្យចូលជាសមាជិកបក្សហើយ លីន ចុងអាន បានណែនាំឲ្យ ធីភាគ ទាក់ទងជាមួយខ្សែរបស់បក្ស៤នាក់ទៀតគឺ ឈីវ ជីនហុង, គើក ឡេង, តាន់ សម្បត្តិ និងតាន់ សំប៊ុន ។

ឆ្នាំ១៩៦០ ធីភាគ ឈប់សិក្សានៅសាលា ម៉េង-សែ ហើយប្រមូលសិស្សមានសញ្ជាតិខ្មែរកាត់ចិន៨នាក់បង្កើតជាចលនាមួយ ។ ក្រោយមកក្នុងឆ្នាំ១៩៦១ ធីភាគ បានប្រលងជាប់ចូលរៀននៅវិទ្យាល័យយុគន្ធរ ។ ដោយសារ លីន ចុងអាន ពេញចិត្តចំពោះជោគជ័យរបស់ ធីភាគ, ចុងអាន បាននាំ ធីភាគ ឲ្យចូលក្នុងក្រុម សេ.អ៊ី.អា ក្នុងឆ្នាំ១៩៦២ ។ បន្ទាប់មក ចុងអាន បានណែនាំ ធីភាគ ឲ្យស្គាល់ ខូវ ប៊ុនហុក ដែលជានិស្សិតទើបត្រឡប់មកពីប្រទេសអាមេរិក និងជាគ្រូបង្រៀនភាសាអង់គ្លេសនៅវិទ្យាល័យយុគន្ធរ ។ បន្ទាប់ពីពិធីខទ្មេសនាម ធីភាគ ចូលជាសមាជិកសេ.អ៊ី.អានៅវិទ្យាល័យយុគន្ធរដែលរៀបចំឡើងដោយ ទេស សារ៉ាវុទ្ធ និងការចូលរួមពីសំណាក់សមាជិកក្រុមជាច្រើនទៀតរួចមក សារ៉ាវុទ្ធ បានប្រកាស


ការប្រជុំមហាសន្និបាតបក្សនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ប្រាប់ ធីភាគ ឲ្យទាក់ទងជាមួយខ្មែរសេ.អ៊ី.អាផ្សេងទៀត មាន ត្រាំ អ៊ីវតឹក, មី ជិនតឹក (អតីតនិស្សិត) និង លិម ឆ្នូនប៊ុនគ្រុយ ។

ធីភាគ តែងតែទាក់ទងជាមួយសមាជិកក្រុមសេ.អ៊ី.អា ដែល សារ៉ាវុទ្ធ បានណែនាំ ដើម្បីតាមដានសកម្មភាពរបស់ខ្មែរក្រហម ។ ដោយសារកម្លាំងមិនគ្រប់គ្រាន់ ធីភាគ ក៏ចាប់ផ្តើមឃោសនាគៀងគរសិស្សនៅក្នុងសាលា ។ ក្នុងឆ្នាំ១៩៦៣ ធីភាគ ឃោសនាបានសមាជិក៣រូបទៀត គឺ តាំង ដៃ , តាន់ តៅស្រុន និង ហ៊ុយ អ៊ីវម៉េង ដើម្បីបង្កប់នៅក្នុងចំណោមមហាជនក្នុងគោលបំណងឲ្យខ្មែរបង្កប់ទាំងនោះរាយការណ៍ដល់ ធីភាគ ផ្ទាល់ និង សារ៉ាវុទ្ធ ។ ក្រោយមក ហ៊ុយ អ៊ីវម៉េង បានរាយការណ៍ពីឈ្មោះ ជន និង សារ៉ាត ដែលជាអ្នកដឹកនាំបាតុកម្មវាយស្ថានទូតអាមេរិក ។

ក្នុងឆ្នាំ១៩៦៤ ធីភាគ បានផ្អាកការងារដោយសារជាប់រវល់ត្រៀមខ្លួនប្រលងឌីប្លូម ប៉ុន្តែនៅបន្តការចូលរួមប្រជុំក្នុងក្រុមសេ.អ៊ី.អាដដែល ។ រាល់ការប្រជុំ ធុច រិន និង ថាច់ ចាន់ តែងតែរិះគៀនខ្មែរក្រហមដែលមានទស្សនៈចង្អៀតចង្អល់ចំពោះប្រទេសជិតខាង មើលឃើញតែវង់កម្ពុជាខ្លួនឯង ។ ផ្ទុយទៅវិញ តែងតែអួតសសើរពីទស្សនៈរបស់រណសិរ្សឥណ្ឌូចិនដែលមានកិច្ចសហការណ៍ល្អជាមួយប្រទេសជិតខាង ។ ដូច្នេះត្រូវខិតខំឃោសនារកកម្លាំងគាំទ្រក្រុមសេ.អ៊ី.អាឲ្យបានកាន់តែច្រើន ដែលនឹងធ្វើឲ្យប្រទេសកម្ពុជាអាចចូលជាសមាជិកសហព័ន្ធឥណ្ឌូចិនដែលនឹងគ្រប់គ្រងដោយប្រទេសវៀតណាម ។ ថ្វីត្បិតតែប្រទេសវៀតណាមជាប្រទេសកុម្មុយនិស្ត ប៉ុន្តែវៀតណាមស្គាល់មិត្ត ស្គាល់សត្រូវ សមាជិកមានសិទ្ធិស្មើគ្នា ដូច្នេះ ប្រទេសក្នុងសហព័ន្ធឥណ្ឌូចិននឹងសម្បូរសប្បាយនៅថ្ងៃអនាគត ។ សមាជិកទាំងអស់មិនត្រូវផ្តាច់ទំនាក់ទំនងជាមួយសមាជិក ទោះបីជាត្រូវចេញទៅទីកន្លែងផ្សេងក៏ដោយ ត្រូវខិតខំបន្តបង្កើនកម្លាំងប្រឆាំងឲ្យបានកាន់តែច្រើនដើម្បីបំផុសបំផុលមហាជនកុំឲ្យមានជំនឿទុកចិត្តទៅលើខ្មែរក្រហម ។



កម្លាំងខ្មែរក្រហមនៅក្នុងសាលាយុគន្ធរកាន់តែមានសភាពពុះកញ្ជ្រោលខ្លាំងឡើងៗពីមួយថ្ងៃទៅមួយថ្ងៃ ។ ក្រុមទាំងនេះមិនរៀនសូត្រ គិតតែពីប្រជុំ ឃោសនាអូសទាញកម្លាំង ។ ក្នុងចំណោមអ្នកទាំងនោះ មួយចំនួនត្រូវសាលាបញ្ជូនឈ្មោះទៅតុលាការដែលជាហេតុធ្វើឲ្យមានការជ្រួលច្របល់កាន់តែខ្លាំង ខ្លះរត់ចូលព្រៃ ខ្លះឈប់រៀន និងខ្លះទៀតត្រូវចាប់ខ្លួន ។ ដូច្នេះ ទេស សារ៉ាវុទ្ធ បានស្នើសុំឲ្យក្រសួងអប់រំបិទសាលាមួយរយៈ ប៉ុន្តែក្រសួងអប់រំពុំសម្រេចឲ្យបិទឡើយ ។

ឆ្នាំ១៩៦៥ ធីភាគ រៀនចប់នៅសាលាយុគន្ធរ ។ ដល់ឆ្នាំ១៩៦៩ ធីភាគ បានចេញទៅបន្តការសិក្សាជំនាញពេទ្យនៅប្រទេសបារាំងក្រោមការឧបត្ថម្ភពីឪពុកនៅក្នុងឆ្នាំសិក្សាដំបូង ។ នៅប្រទេសបារាំង ធីភាគ មិនទាន់បង្កសកម្មភាពភ្លាមទេ រហូតដល់រដ្ឋប្រហារឆ្នាំ១៩៧០ ទើបទាក់ទងជាមួយ ចៅ សេង ដើម្បីសុំចូលជាសមាជិករណសិរ្សនៅប្រទេសបារាំង ។ បន្ទាប់ពីចូលជាសមាជិកហើយរណសិរ្សបានឲ្យអាហារូបករណ៍ ធីភាគ បន្តសិក្សារហូតដល់ចប់ ។ ក្រោយមក តាមរយៈ ចៅ សេង, ធីភាគ បានជួបជាមួយ ដួន មុំ ដែលជាប្រធាន ក្រុមសេ.អ៊ី.អាប្រចាំប្រទេសបារាំង ហើយ ដួន មុំ បានរៀបរាប់ឈ្មោះសមាជិកសេ.អ៊ី.អា ទាំងអស់ដែលធ្លាប់ធ្វើការជាមួយ ។ ក្នុងពេលប្រជុំ ដួន មុំ បានពន្យល់ប្រាប់សមាជិកថាសកម្មភាពប្រឆាំងនឹងបដិវត្តន៍ក្នុងប្រទេសចាំបាច់ត្រូវតែសមាជិកក្នុងក្រុមខិតខំឃោសនាខាងផ្នែកសតិអារម្មណ៍ដើម្បីបណ្តុះកម្លាំង

ប្រឆាំងនិងគួរយកគំរូតាមប្រទេសសូវៀត ។ បដិវត្តន៍កម្ពុជាជាបដិវត្តន៍របៀបចិន គ្ររហេមរហាម គ្មានកាំភ្លើង គ្មានឡាន ដូច្នេះបើមិនព្រមទទួលជំនួយពីសូវៀតនឹងមិនងាយរំដោះប្រទេសបានទេ ។ ផ្ទុយទៅវិញ ប្រទេសសូវៀតជាប្រទេសសង្គមនិយមទី១មានលក្ខណៈខ្លាំងពូកែខាងនយោបាយ មាគ៌ាដឹកនាំត្រឹមត្រូវ ប្រជាជនធូរធារ ហើយការដឹកនាំប្រទេសគឺស្ថិតនៅលើបញ្ញាជន ។ ដូច្នេះសមាជិកទាំងអស់ត្រូវពន្យល់បងប្អូនខ្មែរនៅប្រទេសបារាំង ជាពិសេស បញ្ញាជនឲ្យគាំទ្រការដឹកនាំប្រទេសបែបប្រទេសសូវៀត ហើយប្រឆាំងនឹងបដិវត្តន៍នៅក្នុងប្រទេស ។ ដួន មុំ បានឲ្យ ធីភាគ ធ្វើការជាមួយខ្មែរក្នុងក្រុមរណសិរ្សនៅប្រទេសបារាំងដើម្បីធ្វើសកម្មភាពក្បត់ចុះពន្យល់ឃោសនាក្នុងចំណោមនិស្សិតបញ្ញាជនឲ្យចូលក្នុងខ្សែ ដួន មុំ ដែលក្នុងនោះមាន គើក គឹមសែ(ឈ្មោះពិតប្រាកដគឺ កែ គឹមសែ អ្នកបកប្រែឲ្យ អៀង សារី ពីឆ្នាំ១៩៧៥-១៩៧៩) គើក គឹមសែ មានប្រពន្ធជាជនជាតិវៀតណាម (អ្នកទាំងពីរជានិស្សិតប្រទេសបារាំង) កែម ធី (និស្សិតប្រទេសបារាំង), តាន់ ម៉េង និងប្រពន្ធឈ្មោះ ពៅ វិមុល (និស្សិតប្រទេសបារាំង) និង ទ្រី វ៉ាន់ និងប្រពន្ធឈ្មោះ ណៃ ស៊ីម (និស្សិតប្រទេសបារាំង) ។

ឆ្នាំ១៩៧១ ដួន មុំ បានបញ្ជូន ធីភាគ ឲ្យទៅរៀននៅខេត្តគ្រឺណូប ស្ថិតនៅភាគខាងកើតឆៀងខាងត្បូងប្រទេសបារាំង ហើយភារកិច្ចរបស់ ធីភាគ គឺអូសទាញនិស្សិតនៅ គ្រឺណូប ឲ្យរួមចំណែកធ្វើសកម្មភាពឃោសនាប្រឆាំងបដិវត្តន៍ក្នុងប្រទេស ។ ក្នុងរយៈពេលមួយឆ្នាំនៅខេត្ត គ្រឺណូប ធីភាគ បានអូសទាញនិស្សិតខ្មែរនៅទីនោះ៥រូបគឺ ប៊ី ដុងទី, ហុង វ៉ាន់នេត, យ៉ង់ ស៊ុយម៉ាណូ, ដួន ឥទ្ធិរិទ្ធ, និង តាន់ សារ៉េ ។ បន្ទាប់ពីបញ្ចប់ភារកិច្ចនៅខេត្តគ្រឺណូប ធីភាគ បានទៅធ្វើការនៅខេត្តប្រឺតាញស្ថិតនៅភាគខាងលិចប្រទេសបារាំងនៅក្នុងឆ្នាំ១៩៧២ ។ ចាប់តាំងពីដើមឆ្នាំ១៩៧៣ រហូតដល់ខែ៦ ឆ្នាំ១៩៧៣ ធីភាគ ពុំបានធ្វើសកម្មភាពក្បត់ទេ ដោយមូលហេតុមានជំងឺសួត ។ បន្ទាប់ពីព្យាបាលជាសះស្បើយ ធីភាគ ក៏បានទទួលអាហារូបករណ៍ទៅសិក្សានៅប្រទេសចិនជាមួយនិស្សិតដទៃទៀតជាច្រើនដែលសុទ្ធតែជាខ្សែរបស់ ដួន មុំ មានដូចជា លុច គឹមបែន, ហេង ហាំខេង, លួង ថាវរៈ, ម៉ែន សេរីសិទ្ធិ, ម៉ែន សេរីបុទ្ធី, ពេជ្រ ប៊ុនរុង, គើក គឹមលាន (ភេទស្រី), និង ពៅ វីមួន (ភេទស្រី) ហើយនិស្សិតទាំងអស់ត្រូវបានទទួលដោយតំណាងរដ្ឋាភិបាលរណសិរ្ស ។ ម៉ែន ម៉ុល (អនុគណៈរណៈសិរ្សនៅទីក្រុងប៉ារីស) ជាអ្នកគ្រប់គ្រងលើនិស្សិតទាំងអស់នេះ ហើយក្រោយមក ដួន ប្រាសិទ្ធ (អតីតជារដ្ឋមន្ត្រីនៃរដ្ឋាភិបាលរណសិរ្សខាងការទាក់ទងក្នុងប្រទេសនិងក្រៅប្រទេស) ធ្វើការនៅក្រសួងការបរទេសជាអ្នកដឹកនាំវិញ ។

មុននឹងទៅរៀននៅប្រទេសចិន និស្សិតត្រូវរៀនភាសាចិនរយៈពេល៦ខែ ។ បន្ទាប់ពីរៀនភាសាចិនចប់ និស្សិតទាំងអស់ត្រូវបែងចែកជាពីរក្រុម គឺមួយក្រុមត្រូវទៅរៀនពេទ្យនៅក័ងតុង និងមួយក្រុមទៀតត្រូវទៅទីក្រុងប៉េកាំង ។ នៅក្នុងខែ១១ ឆ្នាំ១៩៧៤ ដួន ប្រាសិទ្ធ និង គួច ខាំឡឿន បានទៅសួរសុខទុក្ខនិស្សិតអាហារូបករណ៍នៅប្រទេសចិន ហើយប្រកាសថា និស្សិតមួយចំនួននឹងត្រូវត្រឡប់ទៅប្រទេសកម្ពុជាវិញក្នុងពេលឆាប់ៗនេះ ពុំចាំបាច់រៀនរហូតដល់ចប់ទេ ព្រោះតំបន់រំដោះត្រូវការកម្លាំងខ្លះ ។ ពេលដែលប្រទេសត្រូវរំដោះបានទាំងស្រុងហើយ កម្លាំងនេះនឹងឡើងធ្វើជាកម្មាភិបាលក្តាប់អំណាចដឹកនាំតាមមន្ទីរក្រសួងនានា ។



បន្ទាប់ពីខ្មែរក្រហមរំដោះប្រទេសកម្ពុជាទាំងមូលបានរយៈពេល៤ខែ ទើបមានសេចក្តីប្រកាសពីឈ្មោះ នូ ម៉ុងលី ដោយឲ្យនិស្សិតខ្មែរនៅទីក្រុងប៉េកាំង ត្រឡប់ចូលប្រទេសនៅដើមខែធ្នូ ឆ្នាំ១៩៧៥ ចំណែកនិស្សិតដែលនៅក័ងតុងត្រូវត្រឡប់ចូលនៅឆ្នាំ១៩៧៦ ។ ក្នុងរយៈពេលកំពុងរង់ចាំការកោះហៅឲ្យចូលប្រទេស ធីភាគ បានជួបជាមួយឈ្មោះ សូ ជា ជាឪពុកមាដែលមកបំពេញភារកិច្ចនៅ ក័ងតុង ។ សូ ជា បានប្រាប់ថា “ដួន មុំ និងបញ្ញាជនដទៃទៀតដែលវិលត្រឡប់ចូលស្រុកមិនមានតួនាទីក្នុងថ្នាក់ដឹកនាំដូចដែលសង្ឃឹមនោះទេ គឺត្រូវធ្វើការនៅតាមរោងចក្រសិន ដោយសារប្រទេសទើបងើបពីសង្គ្រាម ខ្វះខាតស្បៀង ដូច្នេះត្រូវសម្រុកបង្កបង្កើនផលជាមុនសិន ។ ២ទៅ៣ឆ្នាំខាងមុខទៀត ទើបបញ្ញាជនពីក្រៅប្រទេសអាចចូលកាន់រដ្ឋអំណាចបាន” ។

នៅថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៧៦ ធីភាគ និងនិស្សិត៦រូបទៀត ដែលសិក្សានៅក័ងតុងបានធ្វើដំណើរវិលត្រឡប់មកប្រទេសកម្ពុជាវិញ ។

ពេលមកដល់ទីក្រុងភ្នំពេញ ធីភាគ បានទៅក្រសួងការបរទេសនិងបំពេញប្រវត្តិរូប ។ មួយសប្តាហ៍ក្រោយមក ធីភាគ ត្រូវបញ្ជូនទៅមន្ទីរ ក-១៥ នៅបឹងត្របែកដែលមាន សារ៉ីន ជាអ្នកគ្រប់គ្រង ។ រយៈពេលដប់ថ្ងៃក្រោយមក ធីភាគ បានផ្លាស់មកធ្វើការនៅកសិដ្ឋានរដ្ឋតាឡី រយៈពេលពីរខែ ហើយក៏ត្រឡប់ទៅមន្ទីរក-១៥ម្តងទៀត ។

ខែមេសា ឆ្នាំ១៩៧៧ សារ៉ីន បានហៅ ធីភាគ មកដើម្បីប្រគល់ភារកិច្ចឲ្យ ធីភាគ ធ្វើជាអ្នកផ្ញើផែនការអន្តរជាតិរបស់ ប៉ាំង (អ្នកដឹកនាំខ្ពស់មួយរូបក្នុងអង្គការ) ទៅអ្នកធ្វើការនៅក្រសួងការបរទេសដែលជាខ្សែទាក់ទងរបស់ ជួន ប្រាសិទ្ធ ។ សារ៉ីន បញ្ជាក់ថា ផែនការរបស់ ប៉ាំង ជាផែនការដំបូងលើឆាកអន្តរជាតិ ហើយមានទិសដៅសម្រុកវាយប្រហារកម្ពុជាខាងនយោបាយ ដើម្បីឲ្យមតិអន្តរជាតិយល់ពីការបែកបាក់នៅក្នុងប្រទេសកម្ពុជាគាំទ្រគំនិតរបស់ ប៉ាំង និងបើកដៃឲ្យវៀតណាមវាយកម្ពុជាឲ្យឈ្នះ ដូច្នេះ ប៉ាំង នឹងអាចគ្រប់គ្រងប្រទេសទាំងមូលក្រោមការដឹកនាំរបស់ប្រទេសវៀតណាម ។ គម្រោងនៃផែនការគឺ ទី១) ផ្ទៃក្នុងដឹកនាំមិនឯកភាពគ្នា ទី២) ប្រជាជនរស់នៅពិបាកវេទនា មិនចង់ធ្វើសង្គ្រាម ទី៣) យុទ្ធជនមិនចង់ទៅសមរភូមិ ទី៤) កម្ពុជាខ្វះខាតខាងសម្ភារយុទ្ធភណ្ឌ និងទី៥) ប្រជាជនមិនឯកភាពជាមួយនឹងអ្នកដឹកនាំ ។ ខែកុម្ភៈ ឆ្នាំ១៩៧៨ ធីភាគ ឡើងជាប្រធានមន្ទីរក-១៥ ដោយសារ ម៉ន ជាប្រធានមន្ទីរមុនត្រូវអង្គការចាប់ខ្លួន ។ បន្ទាប់ពីអង្គការចាប់ខ្លួន សារ៉ីន (ខែឧសភា ឆ្នាំ១៩៧៨) ធីភាគ ក៏ត្រូវអង្គការចាប់ខ្លួនបញ្ជូនមកមន្ទីរស២១ (គុកទួលស្លែង) នៅថ្ងៃទី១០ ខែ៦ ឆ្នាំ១៩៧៨ ។

ខាងលើនេះជាសេចក្តីសង្ខេបដកស្រង់ចេញពីចម្លើយសារភាពរបស់ ធីភាគ ដែលកត់ត្រាដោយអ្នកឯកសារឈ្មោះ អ៊ឹម អឿន ។ ធីភាគ ត្រូវបានសួរចម្លើយចាប់តាំងពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ១៩៧៨ រហូតដល់ថ្ងៃទី១ ខែសីហា ឆ្នាំ១៩៧៨ ។

**ផាត រចនា**

ជំនាញការចិន និងកងការពារ (ថតនៅមុខប្រាសាទអង្គរវត្ត)



# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១ (គុកទួលស្លែង)

រៀបចំនិងចងក្រងដោយៈ យិន នាន

(តពីលេខមុន)

| លរ | ឈ្មោះ | តួនាទី | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|
| ១១៣១ | អ៊ឹង គឿន | យុទ្ធជន | ២១យ | ២៦-១០-៧៦ | ២៧-១០-៧៦ |
| ១១៣២ | សោម គី | យុទ្ធជន | ២១យ | ២៦-១០-៧៦ | ២៧-១០-៧៦ |
| ១១៣៣ | ចែម សារឿន | យុទ្ធជន | ២១យ | ២៦-១០-៧៦ | ២៧-១០-៧៦ |
| ១១៣៤ | ប៉ាវ ឆេង | យុទ្ធជន | ២១យ | ២៦-១០-៧៦ | ២៧-១០-៧៦ |
| ១១៣៥ | ហុង ចិន | យុទ្ធជន | ២១យ | ២៦-១០-៧៦ | ២៧-១០-៧៦ |
| ១១៣៦ | នង សាន | យុទ្ធជន | ២១យ | ២៦-១០-៧៦ | ២៧-១០-៧៦ |
| ១១៣៧ | សៅ វ៉ុន ហៅ រឿន | យុទ្ធជន | ២១យ | ២៦-១០-៧៦ | ២៧-១០-៧៦ |
| ១១៣៨ | ជីម កុកហួ | ទូត | ស្រុកបារាំង | ២៣-១០-៧៦ | ២៩-១០-៧៦ |
| ១១៣៩ | ជុំ សូខន | ប្តី សួង សាខន | រទេះភ្លើង | ២៨-១០-៧៦ | ៣០-១០-៧៦ |
| ១១៤០ | នៅ លីមអេង | ប្តី លី ភាគរ៉ុន | រទេះភ្លើង | ២៨-១០-៧៦ | ៣០-១០-៧៦ |
| ១១៤១ | គីម ប៉ាវ | ប្តី ស៊ុន សាលី | រទេះភ្លើង | ២៨-១០-៧៦ | ៣០-១០-៧៦ |
| ១១៤២ | មួង ផង់ | ប្តី អ៊ុម ធុល | រទេះភ្លើង | ២៨-១០-៧៦ | ៣០-១០-៧៦ |
| ១១៤៣ | ចក់ ហៀប | ប្តី អ៊ុំ លីម | រទេះភ្លើង | ២៨-១០-៧៦ | ៣០-១០-៧៦ |
| ១១៤៤ | សេង ឌឿន | ប្តី ប៊ុត រ៉េត | រទេះភ្លើង | ២៨-១០-៧៦ | ៣០-១០-៧៦ |
| ១១៤៥ | យិន ណែម | ប្តី ណុម ស៊ី | រទេះភ្លើង | ២៨-១០-៧៦ | ៣០-១០-៧៦ |
| ១១៤៦ | ជិន សុន | ប្តី ជេង ហួយ | រទេះភ្លើង | ២៨-១០-៧៦ | ៣០-១០-៧៦ |
| ១១៤៧ | ព្រាប តូ | ប្តី ឡាយ គីមហេង | រោងចក្រ ប-៤ | ២៨-១០-៧៦ | ៣០-១០-៧៦ |
| ១១៤៨ | សាំង សៀន | ប្តី ប៉ាក អួន | រោងចក្រអារឈើ | ២៨-១០-៧៦ | ៣០-១០-៧៦ |
| ១១៤៩ | អ៊ឹង តឹក | ប្តី តាន់ ហួយ ចិន | រោងចក្រ គ-៦ | ២៨-១០-៧៦ | ៣០-១០-៧៦ |
| ១១៥០ | អ៊ុក សារី (ស្រី) | ប្រពន្ធ រដ្ឋ ឈុន | រទេះភ្លើង | ២៨-១០-៧៦ | ៣០-១០-៧៦ |
| ១១៥១ | លី រ៉េត (ស្រី) | ប្រពន្ធ យ៉ត ផន | រទេះភ្លើង | ២៨-១០-៧៦ | ៣០-១០-៧៦ |
| ១១៥២ | សួង សោខន (ស្រី) | ប្រពន្ធ ជុំ សុខុន | រទេះភ្លើង | ២៨-១០-៧៦ | ៣០-១០-៧៦ |
| ១១៥៣ | លី ភាគរ៉ុន (ស្រី) | ប្រពន្ធ នៅ លីមអេង | រទេះភ្លើង | ២៨-១០-៧៦ | ៣០-១០-៧៦ |
| ១១៥៤ | ស៊ុន សាលី (ស្រី) | ប្រពន្ធ គីម ប៉ាវ | រទេះភ្លើង | ២៨-១០-៧៦ | ៣០-១០-៧៦ |
| ១១៥៥ | សួន ផល្លី (ស្រី) | ប្រពន្ធ ឆើយ ណារ៉ាង | រទេះភ្លើង | ២៨-១០-៧៦ | ៣០-១០-៧៦ |
| ១១៥៦ | ចាន់ សាយ (ស្រី) | ប្រពន្ធ ឈួន ឈឿន | រទេះភ្លើង | ២៨-១០-៧៦ | ៣០-១០-៧៦ |
| ១១៥៧ | អ៊ុម ធុល (ស្រី) | ប្រពន្ធ មួង ផង់ | រទេះភ្លើង | ២៨-១០-៧៦ | ៣០-១០-៧៦ |
| ១១៥៨ | កៀន វណ្ណា (ស្រី) | ប្រពន្ធ អ៊ុក វុទ្ធី | រទេះភ្លើង | ២៨-១០-៧៦ | ៣០-១០-៧៦ |

| | | | | | |
|---|---|---|---|---|---|
| ១១៥៩ | ប៊ុល សឿន (ស្រី) | ប្រពន្ធ កាយា | រទេះភ្លើង | ២៨-១០-៧៦ | ៣០-១០-៧៦ |
| ១១៦០ | ម៉ក់ មុត (ស្រី) | ប្រពន្ធ អែម សេង | រទេះភ្លើង | ២៨-១០-៧៦ | ៣០-១០-៧៦ |
| ១១៦១ | អ៊ុំ លីម (ស្រី) | ប្រពន្ធ ចក់ ហៀប | រទេះភ្លើង | ២៨-១០-៧៦ | ៣០-១០-៧៦ |
| ១១៦២ | ហុក សេងហុង (ស្រី) | ប្រពន្ធ ម៉ុក សាមឿន | រទេះភ្លើង | ២៨-១០-៧៦ | ៣០-១០-៧៦ |
| ១១៦៣ | ឡុង រ៉ានី (ស្រី) | ប្រពន្ធ មួង សារឿន | រទេះភ្លើង | ២៨-១០-៧៦ | ៣០-១០-៧៦ |
| ១១៦៤ | ង៉ូវ ណៃអៀង (ស្រី) | ប្រពន្ធ ជុំខ្សាន | រទេះភ្លើង | ២៨-១០-៧៦ | ៣០-១០-៧៦ |
| ១១៦៥ | កង សារឿន (ស្រី) | ប្រពន្ធ យស់ សារឿន | រទេះភ្លើង | ២៨-១០-៧៦ | ៣០-១០-៧៦ |
| ១១៦៦ | កៅ សៀង ហៅ សាន (ស្រី) | ប្រពន្ធ ប៉ាត ប៊ុន | រទេះភ្លើង | ២៨-១០-៧៦ | ៣០-១០-៧៦ |
| ១១៦៧ | ប៊ុត រ៉េត (ស្រី) | ប្រពន្ធ សេង ឡឿន | រទេះភ្លើង | ២៨-១០-៧៦ | ៣០-១០-៧៦ |
| ១១៦៨ | ណុម ស៊ី (ស្រី) | ប្រពន្ធ ឃិន ណៃម | រទេះភ្លើង | ២៨-១០-៧៦ | ៣០-១០-៧៦ |
| ១១៦៩ | ជឹម សុង (ស្រី) | ប្រពន្ធ ផេង ហួយ | រទេះភ្លើង | ២៨-១០-៧៦ | ៣០-១០-៧៦ |
| ១១៧០ | ឡាយ គីមហេង (ស្រី) | ប្រពន្ធ ផេង គួ | រោងចក្រ ប-៤ | ២៨-១០-៧៦ | ៣០-១០-៧៦ |
| ១១៧១ | ប៉ាន សុខន (ស្រី) | ប្រពន្ធ អែម ចាន់សំរ៉ែង | រោងចក្រ ប-៤ | ២៨-១០-៧៦ | ៣០-១០-៧៦ |
| ១១៧២ | ងិន រឿន (ស្រី) | ប្រពន្ធ ញ៉ែម នេន | រទេះភ្លើង | ២៨-១០-៧៦ | ៣០-១០-៧៦ |
| ១១៧៣ | គាន់ ហួយ (ស្រី) | ចិន | ចិន | ២០-១០-៧៦ | ៣០-១០-៧៦ |
| ១១៧៤ | ប៉ាក់ អួន (ស្រី) | ប្រពន្ធ សាំង សៀន | រោងចក្រអារឈើ | ១៩-១០-៧៦ | ៣០-១០-៧៦ |
| ១១៧៥ | ព្រុំ ស៊ឹម (ស្រី) | ម្ដាយ សួង សៅខន | រទេះភ្លើង | ២៨-១០-៧៦ | ៣០-១០-៧៦ |
| ១១៧៦ | គាំ ឆែម (ស្រី) | ម្ដាយ ហុក សេងហុង | រទេះភ្លើង | ២៨-១០-៧៦ | ៣០-១០-៧៦ |
| ១១៧៧ | ស៊ិន គួ (ស្រី) | ម្ដាយ កង សារឿន | រទេះភ្លើង | ២៨-១០-៧៦ | ៣០-១០-៧៦ |
| ១១៧៨ | ជា ស៊ុម (ស្រី) | ម្ដាយ ឡាយ គីមហេង | រោងចក្រ ប-៤ | ២០-១០-៧៦ | ៣០-១០-៧៦ |
| ១១៧៩ | ជុំ នុណាក់ (ស្រី) | កូន ជុំ ខ្សាន | រទេះភ្លើង | ២៨-១០-៧៦ | ៣១-១០-៧៦ |
| ១១៨០ | ង៉ូវ ស៊ីជូ (ស្រី) | ប្រពន្ធ អ៊ូ សារុន | អគ្គិសនីទី២ | ៣០-១០-៧៦ | ៣១-១០-៧៦ |
| ១១៨១ | ព្រាប រ៉េន (ស្រី) | ប្រពន្ធ អ៊ុម ស៊ុន | អគ្គិសនីទី២ | ៣០-១០-៧៦ | ៣១-១០-៧៦ |
| ១១៨២ | ខ្ញឹង ស៊ីហៀង (ស្រី) | ប្រពន្ធ គុម ស៊ុមសារ៉ុង | អគ្គិសនីទី២ | ៣០-១០-៧៦ | ៣១-១០-៧៦ |
| ១១៨៣ | ឡុច សុភី (ស្រី) | កូន ឡុច ឈុន | អគ្គិសនីទី២ | ៣០-១០-៧៦ | ៣១-១០-៧៦ |
| ១១៨៤ | ស្រី រុន (ស្រី) | ប្រពន្ធ ឡុច ឈុន | អគ្គិសនីទី២ | ៣០-១០-៧៦ | ៣១-១០-៧៦ |
| ១១៨៥ | សៀង ប៊ិន (ស្រី) | ប្រពន្ធ អ៊ូ ខុន | អគ្គិសនីទី២ | ៣០-១០-៧៦ | ៣១-១០-៧៦ |
| ១១៨៦ | នង យ៉ាន (ស្រី) | ប្រពន្ធ ហែម ដៃ | អគ្គិសនីទី២ | ៣០-១០-៧៦ | ៣១-១០-៧៦ |
| ១១៨៧ | ឈិត គីមនី (ស្រី) | ប្រពន្ធ ឃឹម ងីហេង | អគ្គិសនីទី២ | ៣០-១០-៧៦ | ៣១-១០-៧៦ |
| ១១៨៨ | ង៉ិប សេង (ស្រី) | ប្រពន្ធ គុប ម៉ុង | អគ្គិសនីទី២ | ៣០-១០-៧៦ | ៣១-១០-៧៦ |
| ១១៨៩ | គុប ស្រ៊ុន | ឪ គុប ម៉ុង និង ង៉ិប សេង | អគ្គិសនីទី២ | ៣០-១០-៧៦ | ៣១-១០-៧៦ |
| ១១៩០ | ឡុច ចំរើន | កូន ឡុច ឈុន | អគ្គិសនីទី៣ | ៣០-១០-៧៦ | ៣១-១០-៧៦ |

# ផែនការស្រាវជ្រាវប្រចាំឆ្នាំ២០០៤ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា

ឆ្នាំ២០០៣គឺជាឆ្នាំដែលមានជោគជ័យបំផុតសម្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ យើងបានសម្រេចលទ្ធផលការងារល្អជាងមុនចំពោះគម្រោងការដែលមានស្រាប់ និងបានពង្រីកការងារបន្ថែមជាច្រើនទៀត ។ ការងារចងក្រងឯកសារនិងគម្រោងការជំរុញឲ្យមានការទទួលខុសត្រូវ បានក្លាយទៅជាគំរូមានតម្លៃសម្រាប់ប្រទេសជាច្រើន និងត្រូវបានទទួលស្គាល់ថាមានប្រយោជន៍ខ្ពស់សម្រាប់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលនឹងត្រូវបង្កើតឡើងនាពេលឆាប់ៗខាងមុខនេះ ។ យើងបានបញ្ចប់គម្រោងការបង្កើតផែនទីទីតាំងរណ្តៅសាកសពជនរងគ្រោះមួយភាគធំ និងបានបន្ថែមការវិភាគបែបកោសល្យ-វិច័យដ៏មានប្រយោជន៍មួយទៀត ដោយមានកិច្ចសហការពីអ្នកជំនាញការកោសល្យវិច័យអន្តរជាតិ ។ ទស្សនាវដ្តីស្វែងរកការពិតអត្ថបទស្រាវជ្រាវដែលបានបោះពុម្ពផ្សាយ និងសៀវភៅរបស់ប្រវត្តិវិទូបរទេសដែលយើងបានបកប្រែ បន្តទទួលបានការគាំទ្រយ៉ាងពេញទំហឹងពីសំណាក់សាធារណជន ។ យើងបានបញ្ចូលកម្មវិធីចុះតាមមូលដ្ឋាន ដែលរួមមានផ្តល់ការពិគ្រោះយោបល់ជាមួយជនរងគ្រោះដោយអំពើទារុណកម្ម អតីតកម្មាភិបាលខ្មែរក្រហម និងជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ដើម្បីបង្ហាញការងាររបស់យើងដល់សាធារណជន យើងបានរួមចំណែកជួយផលិតភាពយន្តឯកសារមួយដែលទទួលបានពានរង្វាន់អន្តរជាតិនិងបានធ្វើពិព័រណ៍រូបភាពជាច្រើនដងទាំងនៅក្នុងប្រទេសកម្ពុជានិងនៅឯបរទេស ហើយនិងបានបង្កើតកម្មវិធីអានឯកសារតាមវិទ្យុដ៏មានប្រជាប្រិយភាពមួយ ។ ជាងពេលណាៗទាំងអស់ មជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវបានទទួលស្គាល់ជាសាធារណៈចំពោះវិភាគទានជាវិជ្ជមានរបស់ខ្លួននៅក្នុងសង្គមកម្ពុជានិងអន្តរជាតិ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាអាចបំពេញការងារទាំងនេះបានដោយជោគជ័យក៏ដោយសារតែមានការគាំទ្រយ៉ាងរឹងមាំពីសំណាក់អ្នកផ្តល់ជំនួយនិងការជួយជ្រោមជ្រែងពីបុគ្គលិកស្ម័គ្រចិត្តជាតិនិងអន្តរជាតិជាច្រើនរូប ជាពិសេសប្រជាជនកម្ពុជានៅតាមស្រុកស្រែចម្ការ ។ ជាលទ្ធផល យើងមានការពេញចិត្តណាស់ក្នុងការរាយការណ៍ជូនសាធារណជនឲ្យជ្រាបថា ក្នុងឆ្នាំនេះអ្នកផ្តល់ជំនួយសំខាន់ៗរបស់យើងជាច្រើនអង្គភាពបានលើកតម្កើងមជ្ឈ-មណ្ឌលឯកសារកម្ពុជាថា ជាអង្គការក្រៅរដ្ឋាភិបាលមួយដែលសម្រេចបានប្រសិទ្ធភាពក្នុងការអនុវត្តការងារនិងតម្លាភាពហិរញ្ញវត្ថុខ្ពស់បំផុត ។ នេះគឺជាឆ្នាំដ៏ប្រពៃរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ទោះជាយ៉ាងណាក៏ដោយ យើងទាំងអស់គ្នាដែលជាបុគ្គលិកនិងអ្នកស្ម័គ្រចិត្តនៅមជ្ឈមណ្ឌលឯកសារកម្ពុជាដឹងថាអង្គភាពដ៏ជោគជ័យមួយត្រូវតែវិវត្តជាប់ជានិច្ចដើម្បីសម្របខ្លួនទៅតាមកាលៈទេសៈនិងតម្រូវការការងារជាក់ស្តែង ។ ដើម្បីធានាឲ្យបានថាមជ្ឈមណ្ឌលឯកសារកម្ពុជាបន្តអភិវឌ្ឍន៍និងទទួលបានលទ្ធផលការងារល្អឥតខ្ចោះនៅក្នុងឆ្នាំ២០០៤ យើងបានបើកអង្គប្រជុំប្រចាំឆ្នាំមួយនៅថ្ងៃទី១៤និង១៥ខែវិច្ឆិកា ហើយបានបង្កើតយុទ្ធសាស្ត្រសម្រាប់ឆ្នាំ២០០៤ ។ បុគ្គលិកម្នាក់ៗបានរាយការណ៍អំពីការងាររបស់ខ្លួននៅក្នុងឆ្នាំ២០០៣ និងផ្តល់យោបល់សម្រាប់ការអភិវឌ្ឍន៍បន្ថែមនៅក្នុងឆ្នាំ២០០៤ ។ អនុស្សារណៈនេះគឺជាសេចក្តីសម្រេចអំពីវិធីដ៏ល្អបំផុតដើម្បីអនុវត្តតាមនិងជាគម្រោងការងារទូទៅសម្រាប់ឆ្នាំ២០០៤របស់មជ្ឈ-មណ្ឌលឯកសារកម្ពុជា ។

## លក្ខណៈទូទៅនៃគម្រោងការងារសម្រាប់ឆ្នាំ២០០៤

យើងរំពឹងថា ឆ្នាំ២០០៤នឹងជាឆ្នាំដែលពោរពេញទៅដោយភាពមមាញឹកសម្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា ដោយតុលាការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមជិតត្រូវបានបង្កើតឡើង និងដោយមានគម្រោងការជាច្រើនទៀតដែលត្រូវបំពេញ ។

យើងមានសុទិដ្ឋិនិយមបំផុតចំពោះលទ្ធភាពរបស់យើងក្នុងការសម្រេចភារកិច្ចដែលបានគ្រោងទុក ហើយតាមរយៈនេះ នឹងអាចរួមចំណែកបន្ថែមទៀតទៅលើការជំរុញឲ្យមានយុត្តិធម៌និងការចងចាំនៅក្នុងប្រទេសកម្ពុជា ។ នៅក្នុងដំណើរការប្រជុំបុគ្គលិកប្រចាំឆ្នាំ យើងបានទទួលការយល់ព្រមជាឯកច្ឆ័នថា ឆ្នាំ២០០៤ គួរតែជាឆ្នាំដែលនាំមកនូវលទ្ធផលជាក់ស្តែងជាបន្តបន្ទាប់និងការផ្លាស់ប្តូរផ្សេងៗនៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជា ។ យើងមានគម្រោងមួយចំនួនដែលគួរអនុវត្តបន្តដោយពុំចាំបាច់មានការកែប្រែច្រើននៅក្នុងឆ្នាំ២០០៤នោះទេ ។ គម្រោងការទាំងនេះរួមមាន÷

១) ការចងក្រងឯកសារនិងថតមីក្រូហ្វីល

២) ការវិភាគកោសល្យវិច័យសហការជាមួយអ្នកជំនាញការអន្តរជាតិ

៣) គម្រោងការបង្កើតបណ្ណសាររូបថតឌីជីថល

៤) ការងារផលិតកម្មភាពយន្តឯកសារ (រួមទាំងភាពយន្តមួយស្តីអំពីស្ត្រីជាជនរងគ្រោះនៃការរំលោភ)

៥) ការចាក់ផ្សាយការអានឯកសារតាមវិទ្យុចំនួនពីរលើកក្នុងមួយសប្តាហ៍

៦) ការងារស្រាវជ្រាវប្រវត្តិសាស្ត្រនិងបោះពុម្ព

៧) ការបកប្រែនិងបោះពុម្ពសៀវភៅប្រវត្តិសាស្ត្រស្តីអំពីរបបខ្មែរក្រហមជាភាសាខ្មែរ

៨) ការអភិវឌ្ឍផលិតភាពបុគ្គលិកតាមរយៈការហ្វឹកហ្វឺននៅបរទេស

៩) ការផ្តល់ឯកសារនិងការងារដល់អ្នកស្ម័គ្រចិត្តនិងអ្នកស្រាវជ្រាវខ្មែរនិងបរទេស

សកម្មភាពទាំងអស់ខាងលើនឹងបន្តនៅក្នុងឆ្នាំ២០០៤ ប៉ុន្តែសកម្មភាពទាំងនេះនឹងឆ្លងកាត់ការកែប្រែសំខាន់ៗមួយចំនួនដែលនឹងរៀបរាប់នៅខាងក្រោម ដើម្បីធានាថាយើងសម្រេចការងារបានលទ្ធផលខ្ពស់និងមានប្រសិទ្ធភាពបំផុតតាមដែលអាចធ្វើទៅបាន ។ យើងបានកត់សម្គាល់ឃើញឱកាសល្អជាច្រើនសម្រាប់ការរីកដុះដាលនិងអភិវឌ្ឍន៍នៅក្នុងផ្នែកថ្មីៗជាច្រើនទៀតគឺ÷

១) ធ្វើជាបង្អែកសម្រាប់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលនឹងបង្កើតនាពេលខាងមុខ

២) ផ្តល់ការហ្វឹកហ្វឺនផ្នែកច្បាប់សម្រាប់សិស្សានុសិស្សកម្ពុជា អ្នកដឹកនាំអង្គការក្រៅរដ្ឋាភិបាល និងមន្ត្រីជួរការរបស់រាជរដ្ឋាភិបាល

៣) ពង្រីកនិងអភិវឌ្ឍន៍បន្ថែមនូវគេហទំព័រក្នុងអ៊ីនធឺណែត

៤) វិភាគទៅលើឯកសារកិច្ចសម្ភាសន៍ជាមួយអតីតកម្មា-ភិបាលខ្មែរក្រហម

៥) ផ្តល់សេវាកម្មសាធារណៈតាមរយៈការផ្តល់ប្រឹក្សាយោបល់ទៅជនរងគ្រោះដោយអំពើទារុណកម្ម អតីតកម្មាភិបាលខ្មែរក្រហម និងជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យ

៦) ការងារផ្តល់កិច្ចប្រឹក្សាយោបល់ទៅមជ្ឈមណ្ឌលចងក្រងឯកសារបរទេសនិងកម្មវិធីផ្សេងៗ

៧) ការផ្តល់កម្មសិក្សាអប់រំនិងសកម្មភាពអប់រំផ្សេងទៀតនៅក្នុងប្រទេសកម្ពុជា

៨) បង្កើត«បន្ទប់ពត៏មានសាធារណៈ»

៩) ស្ថាបនា មជ្ឈមណ្ឌលឯកសារកម្ពុជា ជាអចិន្ត្រៃយ៍ ។

ខាងក្រោមគឺជាសេចក្តីសង្ខេបពិស្តារនៃផែនការប្រចាំឆ្នាំ ២០០៤នៅក្នុងផ្នែកនីមួយៗនៃប្រតិបត្តិការងាររបស់យើង៖

## I, ការងារចងក្រងឯកសារ

ការចាប់អារម្មណ៍ទីមួយនៃគម្រោងការងារដ៏មមាញឹករបស់យើងគឺការចងក្រងប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម ។ អភិរក្សការចងចាំនៃអំពើឃោរឃៅរបស់របបកម្ពុជាប្រជាធិបតេយ្យនិងផលវិបាកនៃរបបនេះគឺមានសារសំខាន់ណាស់ ប្រសិនបើប្រជាជនកម្ពុជាត្រូវធ្វើដំណើរទៅមុខឆ្ពោះទៅអនាគតកាន់តែរុងរឿងនិងសុខុមាលភាពមួយ ។ ការចងក្រងឯកសារគឺជាការងារស្នូលនិងជាការងារដំបូងបង្អស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយវានៅតែជាមូលដ្ឋានរបស់កិច្ចការដែលយើងធ្វើបច្ចុប្បន្ននិងទៅអនាគត ។ ការងារចងក្រងឯកសាររួមមានការប្រមូល ការរៀបចំការថែរក្សា ការថតចម្លង និងការដាក់បង្ហាញជាសាធារណៈនូវឯកសារទាក់ទងនឹងរបបខ្មែរក្រហមដ៏ច្រើនសន្ធឹកសន្ធាប់ទាំងនេះ ។

### ១) ការចុះលេខឯកសារនិងការគ្រប់គ្រងទិន្នន័យ

ផ្នែកទីមួយនៃការងារចងក្រងឯកសាររបស់យើង គឺការប្រមូលនិងចុះលេខឯកសារ និងបង្កើតទិន្នន័យកុំព្យូទ័រធំៗពីរគឺ «ទិន្នន័យគន្ថនិទ្ទេសអំពើប្រល័យពូជសាសន៍កម្ពុជា» «ទិន្នន័យប្រវត្តិរូបអំពើប្រល័យពូជសាសន៍កម្ពុជា» ។ នៅក្នុងទិន្នន័យកុំព្យូទ័រទាំងពីរនេះដែលត្រូវបានបង្កើតឡើងតាមរយៈកិច្ចសហការ

ជាមួយ“កម្មវិធីស្រាវជ្រាវអំពើប្រល័យពូជសាសន៍នៅកម្ពុជា” នៃសាកលវិទ្យាល័យយែលនិងសាកលវិទ្យាល័យញូវសៅវែល មានពត៌មានពិស្តារអំពីអតីតមេដឹកនាំនិងកម្មាភិបាលខ្មែរក្រហម ។ ទិន្នន័យកុំព្យូទ័រទាំងពីរនេះ ជាប្រភពពត៌មានស្តីអំពីរបបកម្ពុជាប្រជាធិបតេយ្យនិងជនរងគ្រោះនៃរបបនេះដែលមានការរៀបចំយ៉ាងល្អនិងងាយស្រួលស្រាវជ្រាវតាមប្រព័ន្ធអ៊ីនធឺនែត ។ កម្មវិធីទាំងពីរនេះជាជំនួយដ៏សំខាន់សម្រាប់កម្មវិធីស្វែងរកគ្រួសារដែលអ្នកនៅរស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យអាចស្រាវជ្រាវរកពត៌មាន ទាក់ទងនឹងញាតិសន្តានដែលបានបាត់ខ្លួន ។ រស់ សមពៅ ដឹកនាំកិច្ច ប្រឹងប្រែងចងក្រងឯកសារនិងបញ្ចូលទិន្នន័យដោយមានជំនួយពី ឆេង វ៉េង, យិន ឆាយ, ឃួយ វិសាលមុនី, លី សុខឃាង, និង លឹម គី ។

### ◆ ការបញ្ចូលទិន្នន័យកុំព្យូទ័រទាំងពីរនេះទៅក្នុងអ៊ីនធឺនែត

នៅក្នុងឆ្នាំ២០០៤ ការរីកចម្រើនគួរឲ្យសរសើរនៃការងារបញ្ចូលទិន្នន័យគឺការបញ្ចូលទិន្នន័យដែលអាចស្រាវជ្រាវបាន (តាមរយៈឈ្មោះឬអាយុ) ទៅក្នុងប្រព័ន្ធអ៊ីនធឺនែត ។ រស់ សមពៅ កំពុងតែទាក់ទងជាមួយក្រុមហ៊ុន“ខ្មែរហូស្ទីង” ដើម្បីធ្វើឲ្យទិន្នន័យទាំងពីរនេះអាចប្រើប្រាស់បានជាសាធារណៈដែលនឹងបង្កើនលទ្ធភាពរបស់យើងក្នុងការផ្លាស់ប្តូរកិច្ចការចងក្រងឯកសារជាមួយបញ្ញាជននិងបុគ្គលផ្សេងទៀតនៅក្នុងពិភពលោកដែលមានការចាប់អារម្មណ៍ ។ ថ្មីៗនេះ យើងបានចុះកិច្ចសន្យាជាមួយក្រុមហ៊ុន “ខ្មែរហូស្ទីង” ដើម្បីបង្កើនទំហំតម្កល់ពត៌មាននៅក្នុងអ៊ីនធឺនែត ។ ក្រុមហ៊ុននេះនឹងជួយផ្នែកបច្ចេកទេសក្នុងការកែប្រែនិងពង្រីកគេហទំព័ររបស់យើង ។

## ២) ពិព័រណ៍រូបថត

បន្ថែមទៅលើឯកសារសរសេរដៃនិងវាយដោយអង្គុលីលេខ និងឯកសារថតសម្លេង មជ្ឈមណ្ឌលឯកសារកម្ពុជាមានតម្កល់រូបថតមួយចំនួនធំទាក់ទងទៅនឹងរបបខ្មែរក្រហម ។ ដើម្បីបង្ហាញការងាររបស់យើងដល់សាធារណជន យើងនឹងបន្តរៀបចំដាក់តាំងជាសាធារណនូវរូបថតមួយចំនួនក្នុងបណ្ណសាររបស់យើងនៅក្នុងឆ្នាំ២០០៤ ។ នៅក្នុងឆ្នាំ២០០៣ យើងបានរៀបចំពិព័រណ៍មួយនៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងដែលយើងបានផ្ញើទៅបរទេសជាផ្នែកមួយនៃគម្រោងការ“រូបភាពនៃអាស៊ី”នៅប្រទេសដាណឺម៉ាក ។ រូបថតទាំងនេះកំពុងត្រូវដាក់តាំងនៅក្នុងសារមន្ទីរទួលស្លែង ហើយនឹងបន្តដាក់នៅទីនោះរហូតដល់ដំណាច់ឆ្នាំ២០០៤ ។ ពិព័រណ៍នេះបង្ហាញអំពីរូបថតនៅក្នុងសម័យខ្មែរក្រហមនិងរូបថតអំពីជីវិតបច្ចុប្បន្នរបស់អតីតយុទ្ធជនខ្មែរក្រហមក្នុងគោលបំណងបង្ហាញអំពីតថភាពនៃបដិវត្តន៍របស់ខ្មែរក្រហមនិងផលវិបាករបស់បដិវត្តន៍នេះនិងបង្កើនការចាប់អារម្មណ៍និងបង្ហាញអំពីភាពលំបាកនៃការផ្សះផ្សាជាតិ ។ បុគ្គលិកទាំងអស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានរួមចំណែកយ៉ាងសកម្មនិងសហការជាមួយអ្នកថតរូបល្បីឈ្មោះម្នាក់របស់ប្រទេសកម្ពុជាគឺ ហេង ស៊ីនិត្យ ដើម្បីធ្វើឲ្យពិព័រណ៍នេះ មានដំណើរការល្អនិងសម្រេចបានលទ្ធផលខ្ពស់ ។

## ៣) គម្រោងការថតភាពយន្តឯកសារ

ដោយទទួលបានការពិគ្រោះយោបល់ពីសំណាក់មជ្ឈមណ្ឌលពត៌មានស្ត្រីកម្ពុជា យើងបានចាប់ផ្តើមគម្រោងការថតភាពយន្តថ្មីមួយនៅក្នុងពាក់កណ្តាលឆ្នាំ២០០៣ ។ ដាត រចនា និង លី សុផល ជាអ្នកទទួលបន្ទុកការងារនេះ ។ ភាពយន្តឯកសារនេះគឺផ្អែកទៅលើរឿងរ៉ាវពិត ហើយមានបំណងបង្ហាញអំពីជីវិតរបស់ស្ត្រីដែលបានរងគ្រោះពីការរំលោភបំពានផ្លូវភេទនៅក្នុងសម័យខ្មែរក្រហម បានតស៊ូចិញ្ចឹមបីបាច់កូនកំព្រា និងរួមចំណែកក្នុងការធ្វើឲ្យកម្ពុជាមានអនាគតថ្មីថ្កើង ។ យើងបានរកឃើញស្ត្រីរងគ្រោះទាំងនេះ និងបានស្រាវជ្រាវយ៉ាងទូលំទូលាយអំពីប្រវត្តិរបស់គាត់រួចរាល់ហើយ ។ យើងគ្រោងដាក់បញ្ចាំងភាពយន្តនេះនៅក្នុងឆ្នាំ ២០០៤ ដើម្បីបង្ហាញអំពីវិធីដែលស្ត្រីត្រូវទទួលរងការរំលោភបំពានផ្លូវភេទ និងបានរួមចំណែកក្នុងការផ្សះផ្សានៅក្នុងប្រទេសកម្ពុជាតាំងពីសម័យខ្មែរក្រហមត្រូវបានផ្តួលរំលំ ។

នៅក្នុងឆ្នាំ២០០៤ យើងនឹងបន្តសហការជាមួយអ្នកដឹកនាំរឿងដ៏ល្បីម្នាក់គឺ រិទ្ធី ប៉ាន់ ដែលបានសហការថតភាពយន្តឯកសារជាលើកដំបូងមានចំណងជើងថា“ស-២១: ក្បាលម៉ាស៊ីនសម្លាប់មនុស្សរបស់ខ្មែរក្រហម” ។ ភាពយន្តនេះត្រូវបានទទួលស្គាល់ជាអន្តរជាតិ ។ ថ្មីៗនេះ រិទ្ធី ប៉ាន់បានបញ្ចប់ការថតភាពយន្តមួយទៀតរបស់លោកដោយមានការជួយជ្រោមជ្រែងជាយោបល់ពីមជ្ឈមណ្ឌលឯកសារកម្ពុជា មានចំណងជើងថា “ប្រជាជនទីក្រុងអង្គរ” ។ នេះជាស្នាដៃប្រវត្តិសាស្ត្រផ្ទាល់មាត់មួយអំពីប្រាសាទអង្គរវត្តដ៏ល្បីល្បាញដោយផ្អែកទៅលើការរៀបរាប់របស់ព្រឹទ្ធាចារ្យ

និងអ្នកស្រុកដែលរស់នៅជុំវិញតំបន់អង្គរ ។ ភាពយន្តមួយទៀតរបស់លោកនៅក្នុងឆ្នាំ២០០៤ ដែលនឹងទទួលការគាំទ្រពីយើងដែរនោះ មានចំណងជើងថា "ព្រះអាទិត្យហៀបអស្តង្គត" ។ ជាចុងក្រោយ យើងបានទាក់ទងជាមួយអ្នកដឹកនាំរឿងនិងជាចាងហ្វាងផលិតកម្មអាមេរិកដ៏ល្បីឈ្មោះម្នាក់គឺ ស្ទីវិន ស្ពៀលប៊ឺក ដើម្បីស្នើសុំឲ្យមានការគាំទ្រចំពោះការថតភាពយន្តឯកសារទាក់ទងទៅនឹងជនរងគ្រោះក្រោមរបបខ្មែរក្រហម ។

### ៤) គម្រោងការបង្កើតបណ្ណសាររូបថតឌីជីថល

នៅពាក់កណ្តាលឆ្នាំ២០០៣ យើងបានចាប់ផ្តើមគម្រោង-ការមួយមានអំឡុងពេលមួយឆ្នាំអំពីការបង្កើតបណ្ណសាររូបថតឌីជីថល ដើម្បីធ្វើជាជំនួយដល់ការថែរក្សាការចងចាំអំពីរបបខ្មែរក្រហមតាមរយៈរូបថតដ៏មានឥទ្ធិពលមួយចំនួន ។ គម្រោងការនេះរួមមានការស្កេនរូបថតសម័យខ្មែរក្រហម ហើយដាក់បង្ហាញរូបថតទាំងនេះនៅក្នុងអ៊ីនធឺណែតសម្រាប់សេចក្តីត្រូវការរបស់សាធារណជន ។ ប៉ាង ពីវ៉ែន, វ៉ា នៃវ៉ាន់ និង ស៊ឹម សុភ័ក្រ្ត ជាអ្នកទទួលបន្ទុកការងារនេះ ។ នៅក្នុងឆ្នាំ២០០៤ បុគ្គលិកទាំងបីរូបនេះនឹងបន្តពិនិត្យជ្រើសរើសនិងស្កេនរូបថតនៃជីវិតរបស់គ្រួសារកម្មាភិបាលខ្មែរក្រហម ដែលថតមុន នៅក្នុង និងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ។ រូបថតភាគច្រើនគឺប្រមូលបានពីការចុះស្រាវជ្រាវតាមខេត្តនានារបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយរូបថតមួយចំនួនទៀតជារបស់បណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ដើម្បីបង្ហាញរូបថតទាំងនេះឲ្យមានឥទ្ធិពលនិងទាក់ទាញសាធារណជន បុគ្គលិកទាំងបីរូបខាងលើបានគ្រោងចូលរួមនៅក្នុងវគ្គហ្វឹកហ្វឺនផ្នែកកុំព្យូទ័រមួយអំពីវិធីសាស្ត្រប្រើប្រាស់រូបថតនៅក្នុងសៀវភៅបុទស្សនាវដ្តី ។ បុគ្គលិកទាំងបីរូបនេះកំពុងតែរៀបចំដាក់ពាក្យសុំចូលរៀននៅក្នុងមជ្ឈមណ្ឌល"វើសឡេក" នៅទីក្រុងវ៉ាស៊ីនតោន សហរដ្ឋអាមេរិក ។

នៅក្នុងឆ្នាំ២០០៤ វេនី ខូវហ្គៀល ដែលនឹងមកបម្រើការងារស្ម័គ្រចិត្តនៅមជ្ឈមណ្ឌលឯកសារកម្ពុជា នឹងសរសេរអត្ថបទមួយដើម្បីភ្ជាប់ជាមួយសៀវភៅរូបថតដែលនឹងត្រូវបោះពុម្ពផ្សាយ ។

### ៥) ការងារថតមីក្រូហ្វីល

ដើម្បីអភិរក្សឯកសារប្រវត្តិសាស្ត្រទាក់ទងទៅនឹងរបបខ្មែរក្រហម មជ្ឈមណ្ឌលឯកសារកម្ពុជាបានថតចម្លងឯកសារទាំងនេះជាមីក្រូហ្វីល ។ យិន នាន ជាអ្នកទទួលខុសត្រូវក្នុងផ្នែកនេះ ។ ការងារនេះអនុញ្ញាតឲ្យអ្នកស្រាវជ្រាវនិងអ្នកស៊ើបអង្កេតផ្នែកច្បាប់ប្រើប្រាស់ពត៌មាននៅក្នុងបណ្ណសាររបស់យើងដោយពុំចាំបាច់ប្រើប្រាស់ឯកសារដើមដែលមួយភាគធំបានទទួលរងការពុកផុយដោយកង្វះការថែទាំពីមុនមកអស់រយៈពេលជាច្រើនឆ្នាំ ។ នៅក្នុងឆ្នាំ២០០៣ យើងបានបន្តផ្ញើមីក្រូហ្វីលទៅបណ្ណាល័យ"ស្ទើលលីងម៉េម៉ូរៀល"របស់សាកលវិទ្យាល័យយែល ដើម្បីលាងហ្វីល ។ វិធានការនេះត្រូវចំណាយអស់ថវិកាច្រើន ។ ដូចនេះហើយទើបយើងតែងតែពុំបានទទួលហ្វីលដែលលាងរួចរាល់ឲ្យទាន់ពេលវេលានោះទេ ។ មកទល់ចុងឆ្នាំ២០០៣ យើងបានផ្ញើហ្វីលចំនួន៤៥២ដុំទៅសាកលវិទ្យាល័យយែល ប៉ុន្តែយើងទើបតែទទួលបាន១៦៦ដុំប៉ុណ្ណោះ ។ យើងបានសាកល្បងយកហ្វីលទៅលាងនៅបណ្ណសារដ្ឋានជាតិកម្ពុជា ប៉ុន្តែឧបករណ៍នៅទីនោះមិនបំពេញតាមបទដ្ឋានគុណភាពដែលយើងត្រូវការ ។ នៅទីបំផុត យើងបានសម្រេចចិត្តថាជម្រើសដែលមានប្រសិទ្ធភាពថ្លៃបំផុត ហើយបំពេញតាមតម្រូវការគុណភាពរបស់យើងគឺការទិញម៉ាស៊ីនលាងហ្វីលមួយសម្រាប់ប្រើប្រាស់ដោយខ្លួនឯង ។ ក្នុងពេលនេះយើងកំពុងតែពិចារណាលក់មីក្រូហ្វីលដែលលាងហើយទៅឲ្យអតិថិជនដែលមានចំណាប់អារម្មណ៍ដើម្បីរំលោះការចំណាយទៅលើការថតមីក្រូហ្វីលបន្តទៀត ។ យើងនឹងបន្តផ្ញើហ្វីលថតចម្លងទៅសាកលវិទ្យាល័យយែលដើម្បីបន្តធានាសុវត្ថិភាពពត៌មាននៅក្នុងបណ្ណសារដ្ឋានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។

### ៦) ការប្រមូលឯកសារនិងទិន្នន័យបន្ថែម

ទោះជាយើងប្រមូលបានវត្ថុតាងជាឯកសារមួយចំនួនធំក៏ដោយ មជ្ឈមណ្ឌលឯកសារកម្ពុជាតែងតែស្វះស្វែងរកឯកសារថ្មីៗថែមទៀត ។ នៅក្នុងឆ្នាំ២០០៤ យើងនឹងបន្តស្រាវជ្រាវរកវត្ថុតាងជាឯកសារថ្មីៗពីស្ថាប័ននិងបុគ្គលនៅក្នុងប្រទេសកម្ពុជានិងបរទេស ។

## II. ការជំរុញឲ្យមានការទទួលខុសត្រូវ និង វិធាននៃច្បាប់

គោលដៅសំខាន់ទីពីររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាគឺការជំរុញឲ្យមានការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដ៏រន្ធត់ដែលប្រព្រឹត្តឡើងនៅក្នុងរបបខ្មែរក្រហម ។ ដើម្បីបញ្ចប់អតីតកាល ប្រជាជនកម្ពុជាត្រូវការជាចាំបាច់នូវយុត្តិធម៌សម្រាប់ទង្វើល្មើសនឹងច្បាប់

ដែលបានប្រព្រឹត្តចំពោះខ្លួននិងក្រុមគ្រួសារ ។ ដំណើរការទទួលខុសត្រូវចំពោះអ្វីដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ត្រូវតែដើរតួនាទីជាស្ពានទៅកាន់វិធាននៃច្បាប់កាន់តែរឹងមាំនៅក្នុងប្រទេសកម្ពុជា និងរៀបចំសម្រាប់អនាគតកាន់តែរុងរឿង ។

## ១) ការទ្រទ្រង់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម

ដោយសារអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាកំពុងតែរៀបចំការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម មជ្ឈមណ្ឌលឯកសារកម្ពុជាក៏កំពុងតែរិះរកមធ្យោបាយដើម្បីទ្រទ្រង់តុលាការខ្មែរក្រហម ។ យើងបានពិភាក្សាជាមួយក្រុមប្រឹក្សាផ្នែកច្បាប់របស់យើង ដើម្បីបង្កើតនិងដាក់ចេញនូវនីតិវិធីនិងសេចក្ដីណែនាំសម្រាប់ការប្រើប្រាស់ឯកសាររបស់យើងនៅពេលដែលតុលាការចាប់ដំណើរការ ។ យើងបានផ្ដល់រួចរាល់ហើយនូវទម្រង់ការនេះទៅឲ្យអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ។ ជារួមយើងមានផែនការផ្ដល់ដល់តុលាការនិងមន្ត្រីរដ្ឋការដែលមានអភ័យឯកសិទ្ធិនូវសិទ្ធិពេញលេញក្នុងការប្រើប្រាស់ឯកសាររបស់យើង ។ យើងក៏បានបង្កើតនូវបែបបទមួយច្បាស់លាស់សម្រាប់ផ្ដល់ឲ្យអ្នកជំនាញឬអ្នកស្រាវជ្រាវដែលបានទទួលសិទ្ធិប្រើប្រាស់ឯកសារ ។ សេចក្ដីណែនាំរបស់យើងត្រូវបានបង្កើតឡើងដើម្បីធានាឲ្យបានច្បាស់លាស់ថាឯកសាររបស់យើងមានជាស្រេចសម្រាប់ការប្រើប្រាស់និងការពារកុំឲ្យបាត់បង់ឬខូចខាតតាមដែលអាចធ្វើទៅបាន ។ នៅពេលដែលដំណើរការរបស់តុលាការចាប់ផ្ដើម យើងនឹងបង្កើតបទបញ្ជាមួយកាន់តែជាក់លាក់ថែមទៀតដើម្បីធានាឲ្យបានថា យើងជួយដំណើរការតុលាការឲ្យមានប្រសិទ្ធភាពបំផុត ។

យើងគ្រោងបង្កើត"ក្រុមទំនាក់ទំនងការងារតុលាការ" ដែលចូលរួមដោយទីប្រឹក្សាច្បាប់និងបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមានការយល់ដឹងខ្ពស់អំពីឯកសារកំពុងតម្កល់ទុកនៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជានិងការងារជំរុញឲ្យមានការទទួលខុសត្រូវ ។ ក្រុមការងារនេះនឹងត្រូវរៀបចំជាស្រេចដើម្បីជួយតុលាការនិងមន្ត្រីរដ្ឋការដែលមានសិទ្ធិ ដើម្បីអនុវត្តការស្រាវជ្រាវរបស់ខ្លួននិងត្រួតពិនិត្យឯកសារទៅតាមតម្រូវការ ។ ស្វ ប៊ុនស៊ូ នឹងដឹកនាំក្រុមអ្នកបកប្រែដែលនឹងប្រែសម្រួលឯកសារបន្ថែមជាភាសាអង់គ្លេសមុនពេលតុលាការចាប់ផ្ដើម ។

## ២) គម្រោងការជំរុញឲ្យមានការទទួលខុសត្រូវ

គម្រោងការជំរុញឲ្យមានការទទួលខុសត្រូវផ្ដោតទៅលើការស្វែងរកហេតុការណ៍ពិតមុនពេលដែលតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមចាប់ផ្ដើម ។ លើសពីនេះ គម្រោងនេះមានបំណងបង្កឲ្យមានយល់ដឹងកាន់តែជ្រៅជ្រះជាងមុនអំពីការគ្រប់គ្រងរបបកម្ពុជាប្រជាធិបតេយ្យ ។ គម្រោងរៀបចំបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនៅក្នុងឆ្នាំ២០០៤ បានបន្ថែមទៅលើសារប្រយោជន៍និងភាពចាំបាច់នៃគម្រោងការជំរុញឲ្យមានការទទួលខុសត្រូវ ។ នៅក្នុងឆ្នាំ២០០៣ សកម្មភាពចម្បងរបស់យើងគឺចុះធ្វើសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហមនៅតាមភូមិស្រុក ។ តាមរយៈការប្រើប្រាស់ព័ត៌មានពីបណ្ណសារនិងអត្ថបទសម្ភាសន៍ពីមុន ក្រុមការងារធ្វើដំណើរទៅតាមតំបន់ ដើម្បីធ្វើសម្ភាសន៍ប្រជាជនដែលធ្លាប់បានបម្រើការងារជាកម្មាភិបាលរបស់របបកម្ពុជាប្រជាធិបតេយ្យ ។ វិធីសាស្ត្រទូទៅរបស់យើងគឺ កត់សម្គាល់និងត្រួតពិនិត្យរាល់ឯកសារប្រវត្តិរូបពាក់ព័ន្ធទាំងអស់ដែលមានស្រុកកំណើតនៅក្នុងតំបន់ណាមួយជាក់លាក់ ។ ដើម្បីបំពេញការងារនេះ យើងបង្កើតការិយាល័យនៅតាមខេត្តចំនួនបួនគឺ ខេត្តកណ្ដាល តាកែវ កំពង់ធំ និងកំពង់ចាម ។

នៅក្នុងឆ្នាំ២០០៤ យើងមានផែនការពង្រីកនិងបន្តការងារចុះធ្វើសម្ភាសន៍នៅខេត្តព្រៃវែង កំពង់ធំ កំពត និង តាកែវ បន្ថែមទៀត ។ មកទល់បច្ចុប្បន្ន យើងសម្រេចបានសម្ភាសន៍ចំនួន១៩៨៦ ដែលវាយចេញជា១៦៦៨៣ទំព័រនៃអត្ថបទសម្ភាសន៍ជាភាសាខ្មែរ ។ អ៊ីសា ឧស្មាន, ឡុង ដានី, ដាន់ សុជា និង ដេង ពង្សរ៉ាស៊ី នឹងដឹកនាំក្រុមសម្ភាសន៍ ។ អែម សុខឃីម និង អឿ រតនា នឹងចាត់ចែងការងារវាយចេញជាអត្ថបទនិងចុះលេខនៅការិយាល័យកណ្ដាលរបស់យើងតាំងនៅទីក្រុងភ្នំពេញ ។

ការងារបន្តទៀតគឺយើងនឹងបញ្ចូលពត៌មានទាក់ទងសម្ភាសន៍ទៅក្នុង"ទិន្នន័យជំរុញឲ្យមានការទទួលខុសត្រូវ" ដែលរៀបរាប់អំពីឈ្មោះ លំនៅដ្ឋាន និងពត៌មានសង្ខេបអំពីប្រវត្តិរូបផ្សេងទៀតរបស់អតីតកម្មាភិបាលខ្មែរក្រហមគ្រប់រូបដែលយើងបានធ្វើសម្ភាសន៍ ។ ឌី ខាំបូលី និង សូ ហ្វារីណា នឹងរៀបចំទិន្នន័យទាំងនេះដែលអាចមានសារសំខាន់ណាស់សម្រាប់ព្រះរាជអាជ្ញានៅក្នុងដំណើរការតុលាការខ្មែរក្រហមចាប់ផ្ដើមក្នុងពេលឆាប់ៗខាងមុខ ។

លើសពីនេះ យើងគ្រោងដើរមួយជំហានទៅមុខទៀតនៅក្នុងគម្រោងការជំរុញឲ្យមានការទទួលខុសត្រូវ គឺការបកប្រែជាភាសាអង់គ្លេសនិងវិភាគឯកសារបទសម្ភាសន៍ដែលយើងប្រមូលបាន ។ ដើម្បីបំពេញភារកិច្ចនេះ យើងបានទាក់ទងជាមួយបណ្ឌិត ស៊ីវ ហេងឌ័រ ដែលជាសាស្ត្រាចារ្យផ្នែកសិក្សាអំពីអាស៊ីបូព៌ានិងអាហ្វ្រិក នៃសាកលវិទ្យាល័យទីក្រុងឡុងដ៍ ។ ស៊ីវ ហេងឌ័រ ជាបញ្ញាជននាំមុខមួយរូបលើពិភពលោកផ្នែកប្រវត្តិសាស្ត្រប្រទេសកម្ពុជាសម័យទំនើប ។ យើងមានគម្រោងសហការជាមួយសាស្ត្រាចារ្យរូបនេះក្នុងការបកប្រែនិងវិភាគឯកសារសម្ភាសន៍ ហើយសរសេរអត្ថបទស្រាវជ្រាវមួយជាមួយទីប្រឹក្សាច្បាប់របស់យើង (ចន ឆរឆីអារី) ដែលអត្ថបទនេះនឹងរៀបរាប់ពិស្តារអំពីការរកឃើញរបស់គម្រោងការនេះពីដើមមកទល់បច្ចុប្បន្ន ។ អ៊ុ សំភី នឹងជាជំនួយការរបស់បញ្ញាជនទាំងពីររូបនេះនៅទីក្រុងភ្នំពេញ ។

### ៣) គម្រោងការហ្វឹកហ្វឺនផ្នែកច្បាប់

ផ្នែកដ៏សំខាន់មួយនៃការជំរុញឲ្យមានការទទួលខុសត្រូវនិងវិធាននៃច្បាប់នៅក្នុងប្រទេសកម្ពុជា គឺហ្វឹកហាត់អ្នកដឹកនាំថ្នាក់តំបន់និងថ្នាក់ជាតិអំពីច្បាប់សិទ្ធិមនុស្សនិងបញ្ហាទាក់ទងនឹងយុត្តិធម៌សម័យអន្តរកាល ។ នៅឆ្នាំ១៩៩៥ និង ១៩៩៦ មជ្ឈមណ្ឌលឯកសារកម្ពុជានិងមហាវិទ្យាល័យនីតិសាស្ត្ររបស់សាកលវិទ្យាល័យយែល បានបង្កើតវគ្គសិក្សាពីរដ៏មានជោគជ័យនៅទីក្រុងភ្នំពេញ ចូលរួមដោយមេដឹកនាំវ័យក្មេងៗមកពីមជ្ឈដ្ឋានរដ្ឋាភិបាលសហគមន៍អ្នកសិក្សាស្រាវជ្រាវ និងអង្គការក្រៅរដ្ឋាភិបាល ។ អស់រយៈពេលជាច្រើនឆ្នាំមកហើយ កត្តាកំណត់នៃការផ្តល់ជំនួយថវិកាបានរារាំងយើងមិនឲ្យអនុវត្តកម្មវិធីហ្វឹកហ្វឺនផ្នែកច្បាប់ ។ ទោះជាយ៉ាងណាក៏ដោយ ជំនួយថវិកាដែលយើងទទួលបានក្នុងឆ្នាំនេះនឹងអនុញ្ញាតឲ្យយើងចាប់អនុវត្តសាឡើងវិញនូវ“គម្រោងការហ្វឹកហ្វឺនផ្នែកច្បាប់” នៅក្នុងឆ្នាំ២០០៤ ។ នៅក្នុងខែកក្កដានិងខែសីហា យើងនឹងបើកវគ្គសិក្សាផ្នែកច្បាប់រយៈពេល៦សប្តាហ៍ ដឹកនាំដោយ ចន ឆរឆីអារី មេធាវីអន្តរជាតិមួយរូបដែលទទួលការរៀនសូត្រពីសាកលវិទ្យាល័យហាវ៉ាតនិងអក់ហ្វត ។

យើងនឹងអញ្ជើញសិក្ខាកាមប្រមាណ២០រូបឲ្យចូលរួមសិក្សាអំពីទ្រង់ទ្រាយជាមូលដ្ឋាននៃច្បាប់សិទ្ធិមនុស្សនិងប្រធានបទពាក់ព័ន្ធមួយចំនួនទៀត ដូចជាការដាក់ឲ្យមានការទទួលខុសត្រូវនិងការផ្សះផ្សានៅក្នុងប្រទេសកម្ពុជា ។ លើសពីនេះ យើងនឹងបោះពុម្ពផ្សាយអត្ថបទណែនាំខ្លីមួយដើម្បីពន្យល់អ្នកអានឲ្យយល់អំពីមូលដ្ឋានគ្រឹះនៃច្បាប់សិទ្ធិមនុស្សទាក់ទងទៅនឹងយុត្តិធម៌និងការផ្សះផ្សានៅក្នុងប្រទេសកម្ពុជា ។ យើងក៏បានគ្រោងទុកបន្ថែមទៀតដែរដើម្បីឲ្យមានការចូលរួមពីទីប្រឹក្សាផ្នែកច្បាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជានិងកម្មសិក្សាការីផ្នែកច្បាប់មកពីសាកលវិទ្យាល័យហាវ៉ាត និងយែល និងមហាវិទ្យាល័យច្បាប់កម្ពុជា ។ សុខា អ៊ីរ៉ែន និង នង លីណា នឹងសហការជាមួយ ចន ឆរឆីអារី ក្នុងការរៀបចំវគ្គសិក្សានេះនិងជ្រើសរើសសិក្ខាកាម ។

### ៤) គម្រោងការបង្កើតផែនទីទីតាំងរណ្តៅសាកសពជនរងគ្រោះ

ចាប់តាំងពីឆ្នាំ១៩៩៥ គម្រោងការធ្វើផែនទីជាផ្នែកដ៏លេចធ្លោមួយនៃការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយជាភារកិច្ចស្នូលក្នុងចំណោមគម្រោងការទាំងអស់របស់យើង ។ រហូតមកទល់បច្ចុប្បន្ននេះ យើងបានស្រាវជ្រាវរករណ្តៅសពជនរងគ្រោះដែលបន្សល់ទុកពីរបបខ្មែរក្រហមស្ទើរតែពាសពេញប្រទេសកម្ពុជាទៅហើយ ។ ហេតុដូច្នេះការស្រាវជ្រាវបន្តនឹងពុំសូវទទួលលទ្ធផលប៉ុន្មានទេ ។ មកទល់ខែកញ្ញា ឆ្នាំ២០០៣ មជ្ឈមណ្ឌលឯកសារកម្ពុជាបានរកឃើញរណ្តៅសពរួមចំនួន១៩.៥២១ គុកខ្មែរក្រហមចំនួន១៩៤ និងបូជនីយដ្ឋានប្រល័យពូជសាសន៍ចំនួន៨១កន្លែង ។ យើងជឿជាក់ថា យើងបានរកឃើញរណ្តៅសពអតីតគុកខ្មែរក្រហមនិងបូជនីយដ្ឋានប្រល័យពូជសាសន៍មួយភាគធំហើយ ។ ហេតុនេះមជ្ឈមណ្ឌលឯកសារកម្ពុជាមានបំណងបំបែរការចាប់អារម្មណ៍របស់យើងចេញពីការធ្វើផែនទីនេះនៅក្នុងឆ្នាំ២០០៤ ។ យើងនឹងបន្តស្វែងរករណ្តៅសពរួមនិងទីតាំងផ្សេងទៀតនៅក្នុងពេលចុះទៅធ្វើសម្ភាសន៍របស់គម្រោងការជំរុញឲ្យមានការទទួលខុសត្រូវនិងការស្រាវជ្រាវអំពីប្រវត្តិសាស្ត្រតាមជនបទ ។ ចំណែកបុគ្គលិកដែលធ្លាប់ទទួលបន្ទុកការងារបង្កើតផែនទី ត្រូវប្តូរទៅធ្វើការនៅក្នុងគម្រោងការវិភាគកោសល្យវិច័យវិញនៅក្នុងឆ្នាំ២០០៤ ។

យើងសង្ឃឹមថាមធ្យោបាយដ៏ល្អបំផុតដើម្បីធ្វើឲ្យការងារបង្កើតផែនទីមានដំណើរការទៅមុខ គឺត្រូវវិភាគនិងពន្យល់អំពីទិន្នន័យដែលបានប្រមូលរួចហើយឲ្យមានប្រសិទ្ធភាពជាងនេះ ។ នៅក្នុងឆ្នាំ២០០៤ យើងមានបំណងបញ្ចូលពត៌មានបន្ថែមទៅ

ក្នុងផែនទីបច្ចុប្បន្នរបស់យើង ។ យើងគ្រោងធ្វើការជាមួយអ្នកជំនាញការមកពីសាកលវិទ្យាល័យស៊ីដនី និងក្រុមហ៊ុនខ្មែរហ្វូស៊ីង ដើម្បីបញ្ចូលផែនទីប្រព័ន្ធពត៌មានភូមិសាស្ត្ររបស់យើងទៅក្នុងអ៊ីនធឺណែតឲ្យបានច្រើន ។ តាមរយៈកម្មវិធីកុំព្យូទ័រ "អេ.អ.ស៊ី.វ្យូ" ផែនទីទាំងនោះអនុញ្ញាតឲ្យអ្នកប្រើប្រាស់បង្រួមឬពង្រីកមើលខេត្ត ស្រុក ឬភូមិណាមួយតាមចំណង់ ដើម្បីមើលទីតាំងពិតប្រាកដនៃរណ្តៅសពនិងទីតាំងផ្សេងទៀត ។ យើងសង្ឃឹមថានឹងសហការជាមួយអ្នកជំនាញការបរទេសដើម្បីវិភាគឯកសារនិងការសម្ភាសន៍សម្រាប់ការស្រាវជ្រាវក្នុងគោលបំណងបង្កើត"ផែនទី"ដែលបង្ហាញអំពីការវិវត្តន៍ផ្នែកភូមិសាស្ត្ររបស់ចលនាខ្មែរក្រហមនិងបាតុភូតផ្សេងៗ ។ អ្នកជំនាញការមកពីសាកលវិទ្យាល័យស៊ីដនីបានបង្កើតកម្មវិធីកុំព្យូទ័រសម្រាប់ប្រើប្រាស់ជាមួយ"ផែនទី" និងបានបញ្ជាក់អំពីការពេញចិត្តក្នុងការសហការជាមួយយើង ។

## ៥) គម្រោងការវិភាគកោសល្យវិច័យ

ដើម្បីបំពេញឲ្យការងារផែនទី យើងបានចាប់ផ្តើមការវិភាគបែបកោសល្យវិច័យនៅក្នុងឆ្នាំ២០០២ ។ ក្នុងចំណោមគោលបំណងផ្សេងទៀត គម្រោងការនេះលាតត្រដាងអំពីបែបបទដែលជនរងគ្រោះត្រូវសម្លាប់ឬទទួលទារុណកម្មក្នុងរបបខ្មែរក្រហម ។ មជ្ឈមណ្ឌលឯកសារកម្ពុជាសហការជាមួយបណ្ឌិតគ្រេក អិចឆេសាន់, បណ្ឌិត ម៉ៃឃើល ប៉ូលានិន និង បណ្ឌិតកាសារិន ហ្រួសស្មៀរ ។ នៅក្នុងឆ្នាំ២០០៣ យើងបានបញ្ចប់ដំណាក់កាលទី១ និងទី២ នៃគម្រោងការនេះ ។ ដំណាក់កាលទី១ ទាក់ទងនឹងការកំណត់ថាតើគម្រោងការនេះអាចសម្រេចបានឬទេ និងការប្រមូលសំណល់ឆ្អឹងធ្វើជាគំរូដើម្បីយកមកដាក់តាំងបង្ហាញនិងអភិរក្សនៅក្នុងសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ។ ដំណាក់កាលទី២ ទាក់ទងនឹងការស្រាវជ្រាវរករណ្តៅសាកសពដែលមិនទាន់គាស់ ដើម្បីជីកវិភាគតាមបែបវិទ្យាសាស្ត្រ ក៏ដូចជាការប្រមូលនិងអភិរក្សគំរូនៃសំណល់ឆ្អឹងសាកសពដែលមានស្លាកស្នាមរបួស ។ ក្រុមការងារនៃគម្រោងនេះបានរកឃើញរណ្តៅសាកសពចំនួន៦កន្លែងនៅក្នុងខេត្តកំពង់ចាមដែលមិនទាន់គាស់កកាយនៅឡើយ ។

ដំណាក់កាលទី៣ កំពុងតែដំណើរការ ។ នៅក្នុងដំណាក់កាលនេះ ការវិភាគបែបកោសល្យវិច័យដែលប្រើប្រាស់ច្រើនជំនាញទៅលើគំរូនៃរណ្តៅសពទូទៅនឹងត្រូវអនុវត្ត ។ នៅក្នុងឆ្នាំ២០០៤ យើងមានបំណងបញ្ចប់ការងារនៅក្នុងដំណាក់កាលទីបី និងដើម្បីអនុវត្តគម្រោងការរយៈពេលវែងមួយ ប្រសិនបើមានថវិកាគ្រប់គ្រាន់ ។ ការងាររបស់យើងនៅក្នុងឆ្នាំ២០០៤ នឹងរួមបញ្ចូលការធ្វើដំណើរទៅខេត្តចំនួន៥គឺ ព្រៃវែង កំពង់ចាម កណ្តាល តាកែវ កំពង់ស្ពឺ និង ភ្នំពេញ ។ ផេង ពង្សរ៉ាស៊ី, ស៊ុនឃិន និង អ៊ូច សំអឿន នឹងអនុវត្តការចុះស្រាវជ្រាវតាមខេត្តជាមួយអ្នកជំនាញការកោសល្យវិច័យ ។

## ៦) ការផ្តល់ប្រឹក្សាយោបល់ទៅឲ្យរដ្ឋាភិបាលនិងស្ថាប័នបរទេស

នៅក្នុងឆ្នាំ២០០៤ យើងមានគម្រោងបន្តផ្តល់សេវាកម្មទៅឲ្យអង្គការក្រៅរដ្ឋាភិបាលនិងរដ្ឋាភិបាលនៅទូទាំងពិភពលោកដែលមានការប្តេជ្ញាចំពោះការលាតត្រដាងការពិតនិងការធានាឲ្យមានការទទួលខុសត្រូវចំពោះបទរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ។ នៅខែមករាឆ្នាំ២០០៤ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា (ឆាំង យុ) នឹងធ្វើដំណើរទៅប្រទេសអ៊ីរ៉ាក់ដើម្បីជួយអង្គការក្រៅរដ្ឋាភិបាលអាជ្ញាធរសម្ព័ន្ធមិត្តបណ្តោះ-អាសន្ន និងក្រុមប្រឹក្សាគ្រប់គ្រងប្រទេសអ៊ីរ៉ាក់ដើម្បីរៀបចំផែនការសម្រាប់ការប្រមែប្រមូលឯកសារក្នុងគោលបំណងលាតត្រដាងអំពើហិង្សាប្រព្រឹត្តដោយអតីតរបបបាប់ទិស ។ យើងមានការជឿជាក់យ៉ាងមុតមាំថាមេរៀនដែលយើងបានរៀនសូត្រនៅក្នុងប្រទេសកម្ពុជានឹងជួយប្រជាជនអ៊ីរ៉ាក់នៅក្នុងកិច្ចប្រឹងប្រែងរៀបចំដំណើរការចងក្រងឯកសារមួយដែលមានភាពនឹងនគួរឲ្យទុកចិត្តបាននិងមានប្រសិទ្ធភាព ។ ជាក់ស្តែង មជ្ឈមណ្ឌលឯកសារកម្ពុជាមានបំណងផ្តល់ដល់ប្រទេសអ៊ីរ៉ាក់ នូវបទពិសោធន៍អំពីការប្រមូលការរៀបចំទុកដាក់និងការថែរក្សាឯកសារ ។ យើងបានគ្រោងអនុវត្តការហ្វឹកហ្វឺនផ្នែកច្បាប់ប្រសិនបើចាំបាច់ ដើម្បីជួយពលរដ្ឋអ៊ីរ៉ាក់អនុវត្តគម្រោងការជំរុញឲ្យមានការទទួលខុសត្រូវមួយស្រដៀងគ្នានឹងគម្រោងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែរ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាក៏មានភាពសកម្មក្នុងការផ្តល់យោបល់ទៅឲ្យអង្គការផ្សេងទៀតនៅជុំវិញពិភពលោក ។ នៅពាក់កណ្តាលឆ្នាំ២០០៤ យើងមានគម្រោងជួយ"វិទ្យាស្ថានអប់រំសិទ្ធិមនុស្សនៃប្រទេសភូមា" រៀបចំនិងអនុវត្តការងារប្រមូលឯកសារ

តូចមួយ នៅក្នុងតំបន់ដែលគ្រប់គ្រងដោយជនជាតិភាគតិចនៅក្នុងប្រទេសភូមា ។ យើងត្រូវបានអញ្ជើញឲ្យចូលរួមនៅក្នុងសិក្ខាសិលាណែនាំមួយ នៅទីក្រុងឈៀងម៉ៃ ប្រទេសថៃ ក្នុងខែមិថុនា និងអមដំណើរបុគ្គលិករបស់វិទ្យាស្ថានអប់រំខាងលើនៅក្នុងការចុះស្រាវជ្រាវតាមតំបន់ជាលើកដំបូង ។ ជាថ្មីម្តងទៀត កិច្ចការជំរុញឲ្យមានការទទួលខុសត្រូវមានប្រយោជន៍ធ្វើជាគំរូដ៏មានតម្លៃនិងជាប្រភពនៃបទពិសោធន៍ក្នុងការងារជំរុញឲ្យមានការទទួលខុសត្រូវ ។

ណាតាសា កាន់ឌិក នៃមជ្ឈមណ្ឌលច្បាប់មនុស្សធម៌នៅទីក្រុងបែលក្រាដបានមកទាក់ទងជាមួយយើងដើម្បីសុំដំបូន្មានអំពីការបង្កើតប្រព័ន្ធការិយាល័យប្រមូលឯកសារនៅក្នុងអតីតប្រទេសយូហ្គោស្លាវី ។ ឆាំង យុ និង ចន ឆរឆីអារី គ្រោងនឹងប្រជុំជាមួយ កាន់ឌិក និងបុគ្គលិករបស់គាត់ នៅក្នុងខែមករា ឆ្នាំ២០០៤ ដើម្បីជួយដល់ការអនុវត្តគម្រោងរបស់មជ្ឈមណ្ឌលច្បាប់មនុស្សធម៌ ។

## III. ការស្រាវជ្រាវនិងការបោះពុម្ពផ្សាយ

កិច្ចការចម្បងទីបីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាគឺការស្រាវជ្រាវនិងការបោះពុម្ពផ្សាយ ។ តាមរយៈសៀវភៅអត្ថបទស្រាវជ្រាវខ្លីៗ និងទស្សនាវដ្តីប្រចាំខែ(ស្វែងរកការពិត) យើងព្យាយាមលាតត្រដាងប្រវត្តិសាស្ត្រខ្មែរក្រហម វិភាគពត៌មានដែលប្រមូលបាន និងបង្ហាញប្រវត្តិសាស្ត្រដ៏សំខាន់នេះដល់មិត្តអ្នកអានរបស់យើងនៅប្រទេសកម្ពុជានិងបរទេស ។ តាមរយៈការបោះពុម្ពផ្សាយ យើងមានបំណងជំរុញឲ្យមានការជជែកពិភាក្សាដ៏មានអត្ថន័យជាសាធារណៈ និងនៅតាមមហាវិទ្យាល័យនៅក្នុងប្រទេសកម្ពុជាអំពីប្រធានបទទាក់ទងទៅនឹងខ្មែរក្រហមក្នុងផ្នែកច្បាប់ នយោបាយ និង សីលធម៌ ។

### ១) ទស្សនាវដ្តីស្វែងរកការពិត

ចាប់តាំងពីឆ្នាំ២០០០ ទស្សនាវដ្តីស្វែងរកការពិតរបស់យើងបានចែកចាយលទ្ធផលការងាររបស់យើងទៅកាន់សាធារណជន និងបានជួយសម្រួលដល់ការពិភាក្សាជាសាធារណៈអំពីបញ្ហាខ្មែរក្រហម ។ ទស្សនាវដ្តីស្វែងរកការពិតមានប្រាំផ្នែក គឺ ១) ផ្នែកឯកសារ ២) ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ ៣) ផ្នែកច្បាប់ ៤) វេទិកាពិភាក្សាសាធារណៈ និង ៥) ទំព័រស្វែងរកគ្រួសារ ។ អត្ថបទនៅក្នុងផ្នែកឯកសារបង្ហាញនិងវិភាគដោយសង្ខេបនូវឯកសារនៅក្នុងបណ្ណសាររបស់យើង ។ ផ្នែកប្រវត្តិសាស្ត្រចុះផ្សាយអំពីជីវប្រវត្តិផ្ទាល់ខ្លួនរបស់ប្រជាជនខ្មែរនៅក្នុងរបបខ្មែរក្រហម ។ នៅក្នុងផ្នែកច្បាប់ យើងបោះពុម្ពផ្សាយពត៌មានអំពីច្បាប់សិទ្ធិមនុស្សនិងយុត្តិធម៌សម័យអន្តរកាល ដើម្បីណែនាំមិត្តអ្នកអានអំពីទ្រឹស្តីច្បាប់ជុំវិញបញ្ហាយុត្តិធម៌និងការផ្សះផ្សានៅក្នុងប្រទេសកម្ពុជា ។ នៅក្នុងផ្នែកវេទិកាពិភាក្សាសាធារណៈ យើងបោះពុម្ពផ្សាយទស្សនៈផ្សេងៗជុំវិញរឿងរ៉ាវនយោបាយតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម និងការអប់រំប្រវត្តិសាស្ត្រខ្មែរក្រហមនៅក្នុងថ្នាក់រៀនទូទៅ ។ នៅក្នុងទំព័រស្វែងរកគ្រួសារ មជ្ឈមណ្ឌលឯកសារកម្ពុជាឆ្លើយតបទៅនឹងសំណូមពររបស់ប្រជាជនកម្ពុជាដែលមានទុក្ខសោកដ៏ធំធេង ដោយការបោះពុម្ពផ្សាយពត៌មានទាក់ទងនឹងញាតិសន្តានដែលបានបាត់ខ្លួនឬស្លាប់នៅក្នុងរបបខ្មែរក្រហម ។ ស្វែងរកការពិតជាភាសាខ្មែរដឹកនាំដោយ សាន់ កល្យាណ, លី សុដល និង ដាត រចនា ។ ស៊ឹម សុភ័ក្ត្រ ទទួលខុសត្រូវផ្នែកក្រាហ្វិកកុំព្យូទ័រ ។ ចំណែក សួ ប៊ុនស៊ូ និង អេង កុកថាយ ជាសហនិពន្ធនាយកទស្សនាវដ្តីស្វែងរកការពិតជាភាសាអង់គ្លេស ។

#### ក) ទស្សនាវដ្តីស្វែងរកការពិតជាភាសាខ្មែរបោះពុម្ពប្រចាំខែ

មកទល់បច្ចុប្បន្ន យើងបានបោះពុម្ពនិងចែកចាយស្វែងរកការពិតចំនួនប្រមាណ៤សែនច្បាប់ហើយទៅកាន់ប្រជាជនទូទាំងប្រទេសកម្ពុជា ។ នៅក្នុងឆ្នាំ២០០៣ យើងបានបោះពុម្ពស្វែងរកការពិតចំនួន៧០០០ច្បាប់ក្នុងមួយខែ សរុបមានចំនួន៨៤០០០ច្បាប់(ប្រចាំឆ្នាំ) និងបានចែកចាយ៨០ភាគរយនៃចំនួននេះដោយឥតគិតថ្លៃជូនដល់ប្រជាជននៅតាមជនបទ ។ យើងបានបន្តសហការជាមួយអង្គការលីកាដូ ប៉ាឌិក ដៃគូអភិវឌ្ឍន៍ និងអង្គការផ្សេងៗទៀតដើម្បីចែកចាយស្វែងរកការពិត ។ អ្នកស្រាវជ្រាវតាមខេត្តរបស់យើងបាននាំយកទស្សនាវដ្តីខ្លះទៅចែកឲ្យអាជ្ញាធរក្នុងតំបន់និងអ្នកភូមិដែលមានការចាប់អារម្មណ៍ខ្ពស់ ។ នៅក្នុងឆ្នាំ២០០៤ យើងនឹងបោះពុម្ពលេខ៤៩ដល់លេខ៦០ជាភាសាខ្មែរ ។ ប្រសិនបើមានថវិកាគ្រប់គ្រាន់យើងសង្ឃឹមថានឹងពង្រីកការបោះពុម្ពផ្សាយទស្សនាវដ្តីនេះបន្ថែម ដើម្បីបំពេញតម្រូវការចំពោះស្វែងរកការពិតដែលចេះតែកើនឡើងជារៀងរាល់ថ្ងៃ ។

#### ខ) ទស្សនាវដ្តីស្វែងរកការពិតជាភាសាអង់គ្លេសបោះពុម្ពប្រចាំត្រីមាស

នៅក្នុងឆ្នាំ២០០៣ យើងបានប្រើប្រាស់យុទ្ធសាស្ត្រថ្មីគឺបោះពុម្ពផ្សាយស្វែងរកការពិតជាភាសាអង់គ្លេសប្រចាំត្រីមាស ។ នៅក្នុងត្រីមាសនីមួយៗយើងបោះពុម្ពចំនួន៧០០ច្បាប់ ហើយយកទៅដាក់លក់នៅទូទាំងទីក្រុងភ្នំពេញ ។ យើងនឹងបន្តធ្វើដូច្នេះនៅក្នុងឆ្នាំ២០០៤ ។ តាំងពីខែខសកា ឆ្នាំ២០០៣ បុគ្គលិកស្ម័គ្រចិត្ត ចេហ្ស្ត្រាកា បានជួយដល់ សួ ប៊ុនស៊ូ និង អេង កុកថាយ ក្នុងការកែសម្រួលអត្ថបទក្នុងទស្សនាវដ្ដីជាភាសាអង់គ្លេស ។ លេខនីមួយៗនឹងបង្ហាញអំពីផ្ទៃរឿងពិសេសមួយ ហើយយើងនឹងបន្តដាក់លក់ទស្សនាវដ្ដីរបស់យើងនៅតាមតូបលក់កាសែតនានាជុំវិញទីក្រុងភ្នំពេញ និងតាមរយៈហាងលក់សៀវភៅអន្តរជាតិនៅកម្ពុជា ។ យើងក៏បានបោះពុម្ពទស្សនាវដ្ដីទាំងពីរភាសា (ខ្មែរ និងអង់គ្លេស) នៅលើគេហទំព័ររបស់យើងដែរ ។

### ឥ) ការផ្សព្វផ្សាយតាមវិទ្យុ

ដើម្បីចែកចាយពត៌មានខ្មែរក្រហមទៅកាន់សាធារណជនឲ្យបានកាន់តែទូលំទូលាយនៅក្នុងឆ្នាំ២០០៤ យើងនឹងបន្តអានអត្ថបទជ្រើសរើសពិសេសពីទស្សនាវដ្ដីស្វែងរកការពិតដើម្បីយកទៅផ្សាយតាមវិទ្យុអែហ្វអឹម១០២មេហ្គាហឺត របស់មជ្ឈមណ្ឌលពត៌មានស្ត្រីកម្ពុជា ។ ដាត រចនា គឺជាអ្នកអានអត្ថបទពីរពេលក្នុងមួយសប្តាហ៍ ហើយការចាក់ផ្សាយត្រូវធ្វើឡើងនៅថ្ងៃពុធនិងថ្ងៃព្រហស្បតិ៍វេលាម៉ោង៣ៈ៣០នាទីដល់ម៉ោង៣ៈ៤៥នាទីរសៀល ។ មកដល់ពេលនេះ ដាត រចនា បានអានចំនួន៩៧ អត្ថបទរួចហើយ ។ លី សុផល ជាអ្នកពិនិត្យនិងជ្រើសរើសអត្ថបទសម្រាប់ការអាន ។ កម្មវិធីវិទ្យុនេះអាចស្តាប់បាននៅស្ទើរគ្រប់ខេត្តនៅក្នុងប្រទេសកម្ពុជានិងតំបន់ខ្លះនៅបរទេស ។

## ២) ការស្រាវជ្រាវនិងសំណេរប្រវត្តិសាស្ត្រ

គោលដៅសំខាន់មួយរបស់យើង គឺថែរក្សាការចងចាំអំពើឃោរឃៅនៃរបបខ្មែរក្រហមតាមរយៈការកត់ត្រានិងវិភាគប្រវត្តិនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ យើងបានព្យាយាមចែកចាយប្រវត្តិសាស្ត្រនេះដើម្បីជួយឲ្យប្រជាជនកម្ពុជាយល់អំពីអតីតកាល និងសម្រេចបានការផ្សះផ្សាជាតិពិតប្រាកដ ។ លើសពីនេះ ការស្រាវជ្រាវរបស់យើងផ្តល់ដល់បញ្ញាជនខ្មែរជំនាន់ក្រោយនូវបទពិសោធន៍ដ៏មានតម្លៃ និងជួយអ្នកទាំងនោះឲ្យមានទំនាក់ទំនងជាមួយបញ្ញាជនមកពីបរទេស ។ ការធ្វើដូចនេះស្ថាបនាដោយផ្ទាល់នូវសមត្ថភាពសម្រាប់ប្រជាជនកម្ពុជាក្នុងការសិក្សានិងប្រឈមមុខនឹងអតីតកាល និងដើម្បីចូលរួមនៅក្នុងការជជែកពិភាក្សាជាសាធារណនិងពោរពេញទៅដោយការយល់ដឹងក្នុងទ្រង់ទ្រាយមួយកាន់តែធំ ។ រវាងឆ្នាំ១៩៧៥និង១៩៧៩ របបខ្មែរក្រហមបានវាយប្រហារនិងលុបបំបាត់យ៉ាងធ្ងន់ធ្ងរទៅលើវណ្ណៈបញ្ញវន្តខ្មែរ ។ ហេតុដូច្នេះ ការកសាងឡើងវិញនូវសហគមន៍សិក្សាអប់រំ គឺជាជំហានដ៏សំខាន់មួយទៅកាន់ការកសាងនិងអភិវឌ្ឍន៍ជាតិ ។

### ក) ការបោះពុម្ពផ្សាយសៀវភៅប្រវត្តិសាស្ត្រ

ផលិតផលចម្បងនៃការស្រាវជ្រាវរបស់យើងលេចចេញក្នុងទម្រង់ជាសៀវភៅប្រវត្តិសាស្ត្រអំពីបដិវត្តន៍និងការដឹកនាំរបស់ខ្មែរក្រហមនិងផលវិបាកនៃរបបនេះ ។ នៅក្នុងឆ្នាំ២០០៣ យើងបានបោះពុម្ពសៀវភៅសរសេរដោយ ហ៊ុយ វណ្ណៈ មានចំណងជើងថា "កងពលខ្មែរក្រហមលេខ៧០៣ ៈ ពីជ័យជម្នះឆ្ពោះទៅការបំផ្លាញខ្លួនឯង" ។ សម្រាប់ឆ្នាំ២០០៤ យើងគ្រោងបោះពុម្ពយ៉ាងហោចណាស់ក៏៤សៀវភៅទៀតដែរ ដែលនិពន្ធដោយបុគ្គលិកស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា÷

១) ស្ត្រីជាជនដែលដល់ ដោយ ប៉ាំង ពីរ៉ែន (ជាភាសាខ្មែរ)

២) ការបះបោររបស់ជនជាតិចាម ដោយ អ៊ីសា ឧស្មាន (ជាភាសាខ្មែរ)

៣) ខ្មែរក្រោមនៅក្នុងភូមិរំលេច ដោយ គឹម កែវកន្និដ្ឋា (ជាភាសាខ្មែរ)

៤) ជនជាតិភាគតិចតាមតំបន់ភ្នំនៅក្នុងរបបខ្មែរក្រហម ដោយ សឹម សុរិយា និង សារ៉ា ខូម (ជាភាសាអង់គ្លេស)

៥) ប្រព័ន្ធសន្តិសុខភូមិភាគនិរតី ដោយ អៀ ម៉េងទ្រី (ជាភាសាអង់គ្លេស) ។

ការស្រាវជ្រាវទៅលើប្រធានបទទាំងអស់ខាងលើបានឈានដល់ដំណាក់កាលចុងក្រោយហើយ ។ យើងនឹងកែសម្រួលបន្ថែមនិងរចនារូបរាងទូទៅនៃសៀវភៅទាំងនេះឲ្យរួចរាល់ ដើម្បីបោះពុម្ពនៅក្នុង២០០៤ឲ្យបានមួយភាគធំ ។ យើងនឹងបោះពុម្ពសៀវភៅ "បេក្ខជន៧រូបសម្រាប់កាត់ទោស" ដោយ ស៊្វី ហេដឌ័រ និង ប្រាយអិន ទីតថិម៉ ដែលជាការសិក្សាពិស្តារទៅលើភ័ស្តុតាងជាឯកសារប្រឆាំងនឹងអតីតមេដឹកនាំខ្មែរក្រហមចំនួន៧រូប ។

**ខ) គម្រោងការរួមអំពីព្រះពុទ្ធសាសនានិងលទ្ធិកុម្មុយនិស្តនៅក្នុងប្រទេស**

កម្ពុជានៅក្នុងឆ្នាំ២០០៣ យើងបានចាប់ផ្តើមធ្វើការជាមួយបណ្ឌិត អៀន ហារីស មកពីសាកលវិទ្យាល័យអក់ហ៊្វត និង លែនខេស្ទ័រ នៃចក្រភពអង់គ្លេស អំពីការសិក្សាទៅលើព្រះពុទ្ធសាសនានិងលទ្ធិកុម្មុយនិស្តនៅក្នុងប្រទេសកម្ពុជាពីឆ្នាំ១៩៧០ ទៅឆ្នាំ១៩៩០ ។ លទ្ធផលដែលទទួលបានរបស់គម្រោងការនេះនឹងត្រូវបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ព្រំ ផល្លា ជំនួយការបណ្ឌិត ហារីស ក្នុងការស្រាវជ្រាវទៅលើបណ្ណសាររបស់ក្រសួងធម្មការនិងកិច្ចការសាសនា និងការវិភាគឯកសារទាក់ទងនឹងព្រះពុទ្ធសាសនានៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ នៅក្នុងឆ្នាំ២០០៤ យើងគ្រោងធ្វើជាម្ចាស់ផ្ទះសម្រាប់ឲ្យបណ្ឌិត ហារីស មកស្រាវជ្រាវចំនួនពាងដងថែមទៀត គឺនៅខែមករា ខែឧសភា និងខែកញ្ញា ។

**គ) របាយការណ៍ស្តីអំពីការស្ទាបស្ទង់មតិលើការផ្សះផ្សាជាតិ**

ស៊ូហ្សាណា លីនតុន បានបញ្ចប់ការវិភាគយ៉ាងពិស្តារតាមរយៈការប្រើប្រាស់ជំនាញច្រើនបែបអំពីយុត្តិធម៌សម័យអន្តរកាលនៅក្នុងប្រទេសកម្ពុជា ដោយមានការចាប់អារម្មណ៍ពិសេសទៅលើការផ្សះផ្សានិងខ្មែរក្រហម ។ ការវិភាគនេះផ្អែកទៅលើការបកស្រាយទិន្នន័យដ៏ទូលំទូលាយដែលប្រមូលបានតាមរយៈទស្សនាវដ្តីស្វែងរកការពិតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងដំណាក់កាលស្ទាបស្ទង់មតិអ្នកអានជាតិនៅក្នុងឆ្នាំ២០០២ ។ ការស្ទាបស្ទង់នេះធ្វើឲ្យយើងយល់ច្បាស់អំពីអាកប្បកិរិយា និងទស្សនៈរបស់ប្រជាជនខ្មែរទូទៅអំពីប្រធានបទជាច្រើនទាក់ទងទៅនឹងរបបខ្មែរក្រហម ដូចជាការទទួលខុសត្រូវ ការសងសឹក ការអត់ឱន ការផ្សះផ្សា និងទស្សនវិស័យរបស់ប្រជាជនអំពីអនាគតកាល ។ របាយការណ៍នៃការវិភាគកំពុងត្រូវបានត្រួតពិនិត្យដោយអ្នកជំនាញការផ្នែកប្រទេសកម្ពុជា ហើយយើងមានគម្រោងបោះពុម្ពនៅដើមឆ្នាំ២០០៤ ។

**ឃ) សៀវភៅអំពីជនជាតិផ្សេងៗនៅក្នុងប្រទេសកម្ពុជា**

នៅក្នុងឆ្នាំ២០០៤ យើងនឹងចាប់ផ្តើមគម្រោងការសរសេរសៀវភៅមួយមានរយៈពេល២ឆ្នាំ ដែលរៀបរាប់ពិស្តារនិងប្រៀបធៀបអំពីការប្រព្រឹត្តិទៅលើក្រុមជនជាតិភាគតិចផ្សេងៗនៅប្រទេសកម្ពុជានៅរបបកម្ពុជាប្រជាធិបតេយ្យ ។ គម្រោងការនេះត្រូវបានរៀបចំឡើងដើម្បីឆ្លុះបញ្ចាំងបន្ថែមទៀតអំពីបទពិសោធន៍ជាក់លាក់របស់ជនជាតិភាគតិចនៅកម្ពុជា ប៉ុន្តែក៏មានបំណងជំរុញឲ្យមានការផ្សះផ្សាតាមរយៈការចងក្រងបង្ហាញអំពីភាពស្រដៀងគ្នានៃទុក្ខវេទនារបស់ជនជាតិទាំងអស់ដែលរស់នៅក្នុងប្រទេសកម្ពុជា ។ យើងបានបង្កើតក្រុមមួយដែលមានសមាជិក១០នាក់ ហើយសមាជិកនីមួយៗនឹងចំណាយឆ្នាំទីមួយ(២០០៤)នៃគម្រោងការនេះដើម្បីស្រាវជ្រាវនិងសរសេរសេចក្តីព្រាង ។ សៀវភៅនេះនឹងចែកចេញជាច្រើនជំពូកទៅតាមជនជាតិផ្សេងៗគឺៈ កុលសម្ព័ន្ធនៅព្រៃភ្នំ ចាម វៀតណាម ខ្មែរកម្ពុជាក្រោម កូឡា ឡាវ ថៃ អារ៉ាប់និងអាស៊ីខាងត្បូង ភូមា មន និង ចិន ។

**ង) សៀវភៅអំពីប្រទេសចិននិងរបបខ្មែរក្រហម**

នៅក្នុងឆ្នាំ២០០៣ ចន ឆរឆីអារី បានចាប់ផ្តើមស្រាវជ្រាវអំពីទំនាក់ទំនងរវាងសាធារណរដ្ឋប្រជាមានិតចិននិងកម្ពុជាប្រជាធិបតេយ្យ ។ ឆរឆីអារី គឺជាបញ្ញាជនស្រាវជ្រាវជាន់ខ្ពស់របស់មជ្ឈមណ្ឌលសិក្សាអំពីអាស៊ីនៃសាកលវិទ្យាល័យអក់ហ៊្វត ។ អេង កុកថាយ បានជួយ ឆរឆីអារី ក្នុងការចុះស្រាវជ្រាវតាមខេត្ត ។ យើងមានគម្រោងបោះពុម្ពអត្ថបទស្រាវជ្រាវនេះនៅក្នុងឆ្នាំ២០០៤ ។ តាមរយៈឯកសារនិងសម្ភាសន៍តាមខេត្ត ឆរឆីអារី បកស្រាយអំពីតួនាទីរបស់កុម្មុយនិស្តចិនក្នុងការកំណត់ទ្រង់ទ្រាយនយោបាយក្នុងនិងក្រៅប្រទេសរបស់កម្ពុជាប្រជាធិបតេយ្យ ។

**ច) ការស្ទាបស្ទង់មតិអំពីសៀវភៅ«កំណត់ហេតុរបស់អាន់ ហ្វ្រែង»**

ការបោះពុម្ពផ្សាយដ៏មានប្រជាប្រិយភាពមួយរបស់ យើង គឺការបកប្រែសៀវភៅកំណត់ហេតុប្រចាំថ្ងៃរបស់ អាន់ ហ្វ្រែង ជាភាសាខ្មែរដោយ សើ សាយ្យាណា ។ សាយ្យាណា បានផ្តល់ការបកស្រាយអំពីសៀវភៅនេះនៅតាមវិទ្យាល័យ ហើយបានចែកចាយបញ្ជីសំណួរស្ទាបស្ទង់មតិទៅកាន់សិស្សានុសិស្សរាប់រយនាក់នៅក្នុងទីក្រុងភ្នំពេញ ។ ការស្ទាបស្ទង់មានគោលបំណងស្វែងយល់អំពីទស្សនៈរបស់សិស្ស អ្នកអាន ចំពោះ អាន់ ហ្វ្រែង អំពីសោកនាដកម្ម ដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា និង

អំពីវិធីដែលនាំទៅរកយុត្តិធម៌និងការផ្សះផ្សាជាតិ ។ នៅក្នុងឆ្នាំ ២០០៤ យើងមានបំណងធ្វើការវិភាគកម្រងសំណួរដែលប្រមូលបានមកវិញ រួចបោះពុម្ពការវិភាគនេះ ។ លើសពីនេះ ក្នុងអំឡុងពេលដែល សាយ្យាណា ណែនាំសៀវភៅរបស់កញ្ញានៅតាមវិទ្យាល័យ យើងបានអនុញ្ញាតឲ្យសិស្សានុសិស្សសរសេរអំពីចម្ងល់របស់ខ្លួនទាក់ទងទៅនឹងសៀវភៅ«មុនដំបូងខ្មែរក្រហមសម្លាប់ប៉ារបស់ខ្ញុំ» និពន្ធដោយ លឿង អ៊ឹង និងបកប្រែជាភាសាខ្មែរដោយ នន លីណា ។ សៀវភៅនេះជាស្នាដៃដ៏ជោគជ័យមួយអំពីជីវប្រវត្តិផ្ទាល់ខ្លួនរបស់ក្មេងស្រីម្នាក់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ អឿ រតនា និង អេង កុកថាយ បានប្រមូលសំណួរទាំងនេះរួចផ្ញើទៅឲ្យ លឿង អ៊ឹង ដែលបានឆ្លើយតបមកវិញយ៉ាងឆាប់រហ័ស ។ យើងនឹងបន្តកិច្ចសហការនេះជាមួយ លឿង អ៊ឹង នៅក្នុងឆ្នាំ២០០៤ ។ លឿង អ៊ឹង កំពុងតែសរសេរថ្មីមួយទៀតដែលមានចំណងជើងថាៈ «កូនដែលមានភ័ព្វសំណាង» ។

### ២) ការស្ទាបស្ទង់អំពីដំណើរការនិងឥទ្ធិពលរបស់តុលាការខ្មែរក្រហម

សម្រាប់ឆ្នាំ២០០៤ យើងមានបំណងចែកចាយ ប្រមូល និងវិភាគ ការស្ទាបស្ទង់មតិថ្មីមួយទៀតអំពីហេតុការណ៍ផ្សេងៗជុំវិញតុលាការខ្មែរក្រហម និងអាកប្បកិរិយារបស់ប្រជាជនខ្មែរអំពីយុត្តិធម៌និងការផ្សះផ្សានៅក្នុងប្រទេសកម្ពុជា ។ យើងនឹងចែកចាយកម្រងសំណួរតាមរយៈទស្សនាវដ្តីស្វែងរកការពិត និងគេហទំព័រដែលចេះតែរីកធំធាត់របស់យើង ។ សមាជិកការងារទស្សនាវដ្តីរបស់យើងនឹងរៀបចំកម្រងសំណួរនេះបន្ទាប់ពីសុំយោបល់ពីអ្នកជំនាញការជាតិនិងអន្តរជាតិ ។ តាមរយៈការវិភាគលទ្ធផលនៃការស្ទាបស្ទង់និងបោះពុម្ពផ្សាយរបាយការណ៍នេះ យើងមានបំណងធ្វើឲ្យសាធារណជនរួមចំណែកយ៉ាងសកម្មនៅក្នុងដំណើរការទទួលខុសត្រូវ ។

### ៣) ការបោះពុម្ពផ្សាយសៀវភៅបកប្រែ

បន្ថែមទៅលើស្នាដៃស្រាវជ្រាវផ្ទាល់របស់យើង មជ្ឈមណ្ឌលឯកសារកម្ពុជាបានបកប្រែសៀវភៅសំខាន់ៗដែលនិពន្ធដោយប្រវត្តិវិទូបរទេសជាភាសាខ្មែរ ហើយបោះពុម្ពការបកប្រែនេះសម្រាប់ឲ្យប្រជាជនកម្ពុជាអាន សិក្សា និងស្វែងយល់ ។ នៅក្នុងឆ្នាំ ២០០៣ យើងបានបោះពុម្ពការបកប្រែសៀវភៅ«សំឡេងពីមន្ទីរស-២១» ដោយប្រវត្តិវិទូ ដេវីដ ឆេនដល័រ ។ សៀវភៅនេះជាស្នាដៃត្រិះរិះអំពីមន្ទីរសន្តិសុខនាំមុខនៃរបបកម្ពុជាប្រជា-ធិបតេយ្យ ។ នៅក្នុងឆ្នាំ២០០៤ យើងមានផែនការបោះពុម្ពសៀវភៅ«សត្រូវបងប្អូនឯង»ដោយ ណាយ៉ាន់ ចាន់ដា ដែលជាស្នាដៃនិពន្ធដ៏ប្រណីតមួយអំពីប្រវត្តិសាស្ត្រឥណ្ឌូចិនបន្ទាប់ពីការបញ្ចប់សង្គ្រាមវៀតណាម ។ ទេព ម៉េងឃាន បានបកប្រែសៀវភៅនេះរួចរាល់ហើយ ហើយកំពុងតែកែសម្រួលឃ្លោងឃ្លានិងរចនាក្របដែលនឹងបញ្ចប់នៅក្នុងឆ្នាំ២០០៤ ។ លើសពីនេះទៀត អេង កុកថាយ កំពុងរៀបចំបកប្រែសៀវភៅ «ដំណើរទៅកាន់ក្តីសង្ឃឹម» ដោយ វ៉ានី យឹមស៊ុត ដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ។ កុកថាយ រំពឹងថានឹងបញ្ចប់ការបកប្រែនេះនៅក្នុងឆ្នាំ២០០៤ ។

## IX. ការអប់រំសាធារណជន និង ការផ្តល់សេវាកម្មដល់មូលដ្ឋាន

ការងាររបស់យើងមានសារសំខាន់បំផុត ប្រសិនបើការងារទាំងនេះត្រូវបានដឹងឮយ៉ាងទូលំទូលាយដោយសាធារណជន ហើយរួមវិភាគទានទៅឲ្យការរីកចម្រើនជាក់ស្តែងនៅក្នុងជីវិតរបស់ប្រជាជនទូទៅ ។ ការបោះពុម្ពផ្សាយរបស់យើងជាមធ្យោបាយមួយដែលយើងអាចទាក់ទងជាមួយសាធារណជន និងជួយអប់រំប្រជាជនអំពីរបបខ្មែរក្រហមនិងបញ្ហាផ្សេងៗទាក់ទងនឹងច្បាប់ ប្រវត្តិសាស្ត្រ និងនយោបាយ ។ ទោះជាយ៉ាងណាក៏ដោយ យើងមានការប្តេជ្ញាចិត្តចំពោះការពង្រីកវិសាលភាពនៃវេទិកាដែលយើងអាចចែកចាយពត៌មាន ។ យើងកំពុងតែបង្កើនសកម្មភាពផ្តល់សេវាកម្មសាធារណៈដែលប្រើប្រាស់ការរកឃើញនិងការយល់ដឹងរបស់យើងអំពីរបបខ្មែរក្រហម ទៅជួយបុគ្គលនិងសហគមន៍ដែលទទួលរងការឈឺចាប់ ។ កិច្ចប្រឹងប្រែងក្នុងការអប់រំនិងការផ្តល់សេវាកម្មដល់មូលដ្ឋានជួយយើងក្នុងការជំរុញការផ្សះផ្សាពិតប្រាកដនៅក្នុងប្រទេសកម្ពុជា ។

### ១) គម្រោងការជនរងគ្រោះនៃទារុណកម្ម

នៅក្នុងឆ្នាំ២០០៣ យើងបានចាប់ផ្តើមគម្រោងការមួយមានឈ្មោះថា«ជនរងគ្រោះដោយអំពើទារុណកម្ម» ។ គម្រោងការនេះមានបំណងផ្តល់ការពិគ្រោះយោបល់អំពីជំងឺផ្លូវចិត្តទៅឲ្យប្រជាជនដែលទទួលរងការធ្វើទុក្ខទោសនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ និងជាពិសេស ជាផ្នែកមួយនៃដំណើរការព្យាបាល

និងផ្សះផ្សារបស់ប្រទេសកម្ពុជា ។ គម្រោងនេះត្រូវបានធ្វើឡើងដើម្បីជួយជនរងគ្រោះនៃរបបខ្មែរក្រហមឲ្យចេះគ្រប់គ្រងប្រវត្តិឈឺចាប់ផ្ទាល់ខ្លួន និងដើម្បីដះពន្លឺទៅលើផលប៉ះពាល់ទូទៅនៃសម័យកាលទទួលរងទណ្ឌកម្មទៅលើអ្នកនៅរស់រានមានជីវិត ។ គម្រោងការនេះនឹងដំណើរការរហូតដល់ឆ្នាំ២០០៥ ហើយត្រូវបានសហការជាមួយ«អង្គការចិត្តសង្គមអន្តរវប្បធម៌» ។ ក្រុមការងារនៃគម្រោងនេះធ្វើការជាមួយអ្នកចិត្តសាស្ត្រដែលមានការហ្វឹកហ្វឺនត្រឹមត្រូវមកពីអង្គការចិត្តសាស្ត្រខាងលើ ដើម្បីផ្តល់ការពិគ្រោះយោបល់និងសម្ភាសន៍ ។ យើងបានជ្រើសរើសតំបន់ភូមិសាស្ត្របីទីតាំងសម្រាប់អនុវត្តកិច្ចការនេះ គឺខេត្តកណ្តាល កំពត និងតាកែវ ។ ទីតាំងទាំងបីធ្លាប់ជាកន្លែងដែលធ្លាប់មានអំពើឃោរឃៅនៅក្នុងរបបខ្មែរក្រហម ។

នៅក្នុងឆ្នាំ២០០៤ ក្រុមការងារនៃគម្រោងនេះមានសមាជិកបីរូបគឺ អៀ ម៉េងទ្រី, ជួង សុភារិទ្ធ និង នង ឧត្តតារា ។ ម៉េងទ្រី និង សុភារិទ្ធ នឹងអនុវត្តការចុះស្រាវជ្រាវតាមតំបន់មួយភាគធំ ចំណែក ឧត្តតារា នឹងចូលរួមការចុះស្រាវជ្រាវខ្លះៗ ហើយវាយចេញជាអត្ថបទនៃបទសម្ភាសន៍ដែលបានថតទុក ។ បន្ថែមពីនេះ យើងនឹងបន្តការងាររបស់យើងជាមួយកូនចៅនិងញាតិសន្តានរបស់ជនរងគ្រោះ ដើម្បីជួយឲ្យអ្នកទាំងនេះចេះគ្រប់គ្រងការលំបាកផ្សេងៗដែលអាចជាលទ្ធផលនៃបញ្ហាផ្លូវចិត្តរបស់ឪពុកម្តាយ ។ បន្ទាប់មក អង្គការចិត្តសាស្ត្រនឹងប្រើប្រាស់អត្ថបទ-សម្ភាសន៍ ដើម្បីសិក្សាអំពីឥទ្ធិពលនៃរបបកម្ពុជាប្រជាធិបតេយ្យទៅលើអ្នកនៅរស់ រួមទាំងជំងឺ«បាក់ស្បាត»(កើតមានចំពោះអ្នកដែលបានឆ្លងកាត់សង្គ្រាមឬព្រឹត្តិការណ៍រន្ធត់ផ្សេងៗ) និងជំងឺចិត្តសាស្ត្រផ្សេងទៀត ។ យើងនឹងរក្សាខ្លឹមសារសម្ភាសន៍ជាការសម្ងាត់ ដើម្បីការពារសិទ្ធិរបស់ជនរងគ្រោះ និងប្រើប្រាស់សម្ភាសន៍នេះដោយចំហនៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជានិងអង្គការចិត្តសង្គមអន្តរវប្បធម៌ ។

## ២) គម្រោងអភិវឌ្ឍន៍និងផ្សះផ្សានៅក្នុងឃុំកោះស្លា

នៅចុងឆ្នាំ២០០៣ យើងបានចាប់ផ្តើមគម្រោងការផ្តល់សេវាកម្មសង្គមមួយដែលបង្កើតឡើងដោយអង្គការយូណេស្កូ ដែលជ្រើសរើសអ្នកចូលរួមចំនួន១២.០០០នាក់ រស់នៅក្នុងឃុំកោះស្លា ខេត្តកំពត ជាឃុំដែលអតីតកម្មាភិបាលខ្មែរក្រហមភាគច្រើនរស់នៅ ។ គម្រោងការនេះត្រូវបានរៀបចំឡើងដើម្បីបញ្ចូលអតីតកម្មាភិបាលខ្មែរក្រហមទៅក្នុងចរន្តជីវិតប្រជាជនកម្ពុជាទូទៅដែលនាំឲ្យមានការផ្សះផ្សានៅក្នុងស្រុកនិងអភិវឌ្ឍន៍ ។ តាមរយៈជំនាញរបស់យើងក្នុងផ្នែកខ្មែរក្រហមនិងការយល់ដឹងផ្នែកសន្តិភាពនិងការផ្សះផ្សារបស់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា យើងនឹងពិគ្រោះយោបល់អប់រំនិងជួយជ្រោមជ្រែងតាមមធ្យោបាយផ្សេងៗដល់សហមគន៍ឃុំកោះស្លាដែលមិនមានការចុះសម្រុងគ្នា ។ យើងកំពុងតែបង្កើតកម្រងសំណួរដើម្បីយកទៅវាយតម្លៃតម្រូវការរបស់ប្រជាជន និងកំណត់អំពីវិធីសាស្ត្រដ៏ល្អបំផុតសម្រាប់ជួយប្រជាជនទាំងនេះនៅក្នុងឆ្នាំ២០០៤ ។ ម៉េងទ្រី និង សុភារិទ្ធ ដឹកនាំការងារនេះដែលប្រជាជនឃុំកោះស្លាបានបង្ហាញការស្វាគមន៍យ៉ាងកក់ក្តៅ ។

## ៣) គម្រោងការ«ថវិកាថែរក្សាការចងចាំប្រវត្តិសាស្ត្រ»

ចាប់តាំងពីពាក់កណ្តាលឆ្នាំ២០០៣ យើងបានសហការជាមួយសមាគមអ្នកនិពន្ធខ្មែរទៅលើកិច្ចការមួយដែលមានបំណងកត់ត្រាប្រវត្តិសាស្ត្រសម័យខ្មែរក្រហមឲ្យបានកាន់តែពេញលេញសម្រាប់កូនខ្មែរជំនាន់ក្រោយ ។ ការងារនេះត្រូវបានដឹកនាំដោយហ៊ុយ វណ្ណៈ ហើយមានគោលដៅប្រមូលអត្ថបទសរសេរពីសាធា-រណជន ដោយប្រកាសផ្សាយតាមប្រព័ន្ធសារពត៌មាន ។ តាមរយៈការសរសេរអត្ថបទ អ្នកនៅរស់រានមានជីវិតពីរបបខ្មែរក្រហមជួយថែរក្សាការចងចាំប្រវត្តិសាស្ត្រ ដែលនឹងជួយទប់ស្កាត់បទឧក្រិដ្ឋមិនឲ្យកើតមាននៅក្នុងពេលអនាគត ។ ដំណើរការនេះផ្តល់ឱកាសឲ្យអ្នកនៅរស់ពីរបបខ្មែរក្រហមបានបញ្ចេញសំឡេងនិងបង្កឲ្យមានការរសាយចិត្តនិងការផ្សះផ្សា ។ នៅក្នុងករណីខ្លះ អត្ថបទរបស់ប្រជាជនអាចរួមវិភាគទានក្នុងការស្វែងរកយុត្តិធម៌ ។ នៅក្នុងឆ្នាំ២០០៣ យើងទទួលបានអត្ថបទចំនួនប្រហែល៤០ដែលភាគច្រើនគួរឲ្យចាប់អារម្មណ៍ និងសរសេរដោយការផ្ចិតផ្ចង់ខ្ពស់ ។ យើងបានជ្រើសរើសអត្ថបទដើម្បីចុះផ្សាយនៅក្នុងទស្សនាវដ្តីស្វែងរកការពិតនៅដើមឆ្នាំ២០០៤ ។ ឥឡូវនេះ វណ្ណៈ កំពុងតែខំប្រឹងប្រមូលអត្ថបទបន្ថែមទៀតសម្រាប់ដំណាក់កាលបន្ទាប់នៃគម្រោង ហើយ វណ្ណៈ នឹងជ្រើសរើសយកអត្ថបទដែលមានស្នាដៃល្អបំផុត ដើម្បីយកទៅបោះពុម្ពផ្សាយនៅក្នុងខែមេសា ឆ្នាំ២០០៤ ។ យើងបានសម្រេចយកការងារនេះជាផ្នែកអចិន្ត្រៃយ៍

មួយនៃកិច្ចខិតខំប្រឹងប្រែងជួយជនរងគ្រោះនៃរបបខ្មែរក្រហមបញ្ចេញទស្សនៈផ្ទាល់ខ្លួន និងព្យាបាលដំបៅពីអតីតកាល ។

### ៤) អភិវឌ្ឍន៍គេហទំព័រ

នៅក្នុងឆ្នាំ២០០៤ ផ្នែកមួយដែលត្រូវអភិវឌ្ឍបន្ថែម គឺការផ្សព្វផ្សាយពត៌មានតាមអ៊ីនធឺណែត ។ យើងបានកត់សម្គាល់ឃើញថា គេហទំព័ររបស់យើងផ្តល់មធ្យោបាយងាយស្រួលបំផុតសម្រាប់ឲ្យប្រជាជនចូលរួមតាមដានការងាររបស់យើង ហើយវាមានសារសំខាន់ណាស់សម្រាប់បុគ្គលទាំងឡាយដែលមានការចាប់អារម្មណ៍ដូចជាជនជាតិខ្មែរ សិស្ស និស្សិត និង បញ្ញាជន ។ អ្នកទាំងអស់អាចអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតនិងរបាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាលក្ខណៈអេឡិច-ត្រូនិច ។ នៅក្នុងឆ្នាំ២០០៣ គេហទំព័ររបស់យើងមានអ្នកចូលទស្សនាច្រើនជាងនៅឆ្នាំមុនៗ ហើយយើងសង្កេតឃើញមានឱកាសជាច្រើនដើម្បីដាក់បង្ហាញលទ្ធផលការងារនៃគម្រោងរបស់យើងនិងឯកសារផ្សេងៗតាមអ៊ីនធឺណែត ។ នៅចុងឆ្នាំ២០០៣ យើងបានពង្រីកទំហំគេហទំព័ររបស់យើង ។ រស់ សមពៅ ទទួលខុសត្រូវការពង្រីកវិសាលភាពគេហទំព័រនេះ ។ ទំហំបន្ថែមនេះនឹងអនុញ្ញាតឲ្យយើងដាក់បង្ហាញឯកសារ អត្ថបទ និងរូបថតបន្ថែមនៅក្នុងឆ្នាំ២០០៤ ។

### ៥) ការផ្សព្វផ្សាយតាមប្រព័ន្ធសារពត៌មាន អត្ថបទ និងសម្ភាសន៍

ដើម្បីបង្ហាញការងាររបស់យើង និងបញ្ចូលបុគ្គលិកយើងទៅក្នុងការពិភាក្សាសាធារណៈនៅក្នុងប្រទេសកម្ពុជានិងបរទេស យើងបានព្យាយាមអស់ពេលជាយូរមកហើយដើម្បីឆ្លើយតបទៅនឹងការសាកសួរពីអ្នកសារពត៌មានចំពោះការងាររបស់យើង និងដើម្បីផ្តល់សម្ភាសន៍នៅពេលណាដែលអាចធ្វើបាន ។ លោកនាយកមជ្ឈមណ្ឌលឯកសារកម្ពុជា(ឆាំង យុ) បុគ្គលិក និងទីប្រឹក្សានៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានរួមចំណែកជាញឹកញាយនៅក្នុងការពិភាក្សាសាធារណៈ និងការអប់រំតាមរយៈការសរសេរអត្ថបទដាក់កាសែតជាតិនិងអន្តរជាតិ ។ នៅក្នុងឆ្នាំ២០០៣ យើងសម្រេចបានកម្រិតខ្ពស់បំផុតនៃការផ្សព្វផ្សាយតាមកាសែតនិងការបោះពុម្ពផ្សាយ ។ នង ឧត្តគារា និង ស៊ឹម សុភ័ក្រ្ត ជាអ្នករក្សាអត្ថបទកាសែតជាតិនិងអន្តរជាតិទាក់ទងនឹងការងាររបស់យើងឬបញ្ហាខ្មែរក្រហមដែលនេះជាធនធានបន្ថែមមួយកម្រិតទៀតសម្រាប់អ្នកមកទស្សនានិងបុគ្គលិកស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។

នៅក្នុងឆ្នាំ២០០៤ យើងនឹងបន្តជំរុញឲ្យបុគ្គលិកសរសេរអត្ថបទបន្ថែមទៀតសម្រាប់ចុះក្នុងកាសែតនិងទស្សនាវដ្តី ។ យើងនឹងបើកចំហជានិច្ចសម្រាប់ការស៊ើបសួរពីអ្នកសារពត៌មាន ។ ដោយសារតុលាការខ្មែរក្រហមជិតត្រូវបានបង្កើត យើងរំពឹងថានឹងមានកំណើនទំនាក់ទំនងជាមួយអ្នកសារពត៌មាន ។ ជាលទ្ធផលយើងគ្រោងចាត់តាំងបុគ្គលមានសមត្ថភាពមួយរូបដើម្បីដើរតួនាទីជាអ្នកទាក់ទងជាមួយអ្នកសារពត៌មាននៅពេលតុលាការមានដំណើរការ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងតែស្វែងរកបុគ្គលមួយរូបដែលមានកម្រិតវប្បធម៌ភាសាអង់គ្លេសនិងខ្មែរខ្ពស់ ហើយគ្រោងប្រកាសជ្រើសរើសមុនពេលដំណើរការតុលាការចាប់ផ្តើម ។

### ៦) ការអប់រំជាសាធារណៈអត្ថបទស្រាវជ្រាវសម្រាប់សន្និសីទនិងសិក្ខាសាលា

នៅក្នុងឆ្នាំ២០០៣ យើងបានព្យាយាមបង្កើនសកម្មភាពអប់រំជាសាធារណៈតាមរយៈការរៀបចំបង្កើតវគ្គអប់រំនិងសិក្ខា-សាលាដាច់តែឯង និងតាមរយៈការបញ្ជូនបុគ្គលិកទៅចូលរួមនៅក្នុងសន្និសីទផ្សេងៗដោយពាំនាំជាមួយនូវអត្ថបទស្រាវជ្រាវពីមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ព្រឹត្តិការណ៍ទាំងនេះផ្តល់ឱកាសមួយឲ្យយើងបង្ហាញការងាររបស់យើង និងដើម្បីពង្រីកចំណេះដឹងបុគ្គលិកទាំងក្នុងការសរសេរនិងការបញ្ចេញយោបល់ ។ នៅក្នុងឆ្នាំ២០០៤ យើងមានបំណងធ្វើឲ្យសកម្មភាពនេះជាផ្នែកដ៏រឹងមាំមួយនៃការងាររបស់យើង ។ យើងនឹងបន្តជំរុញនិងសម្របសម្រួលការចូលរួមរបស់បុគ្គលិកនៅក្នុងវគ្គសិក្សា សន្និសីទ និងសិក្ខាសាលា ។ ទោះជាយ៉ាងណាក៏ដោយ យើងក៏មានគម្រោងរៀបចំដងដែរនូវវគ្គសិក្សាសាធារណៈរៀងរាល់ពីរសប្តាហ៍ម្តង ដើម្បីអប់រំសិស្សា-នុសិស្សនិងសាធារណជនដែលចាប់អារម្មណ៍អំពីផ្នែកផ្សេងៗនៃប្រវត្តិសាស្ត្រខ្មែរក្រហមនិងបញ្ហាពាក់ព័ន្ធ ។

## V. ការអភិវឌ្ឍន៍បុគ្គលិកនិងធនធាន

ផ្នែកចុងក្រោយបង្អស់នៃការងាររបស់យើងគឺការគ្រប់គ្រងធនធានហិរញ្ញវត្ថុនិងធនធានមនុស្សក្នុងអង្គភាព ។ ការគ្រប់គ្រងថវិកាជំនួយយ៉ាងមានប្រសិទ្ធភាពគឺជាការចាំបាច់ ប្រសិនបើយើង

ចង់សម្រេចការកិច្ចទាំងអស់ខាងលើឲ្យបានជោគជ័យ ។ ការអភិវឌ្ឍន៍និងប្រើប្រាស់ធនធានមនុស្សមានភាពចាំបាច់ដូចគ្នាដែលអនុញ្ញាតឲ្យយើងបំពេញការងារនិងហ្វឹកហ្វឺនពលរដ្ឋកម្ពុជាវ័យក្មេងៗជាច្រើនរូប ហើយយកចំណេះដឹងនេះទៅបម្រើសហគមន៍និងរួមចំណែកក្នុងការកសាងសង្គមស៊ីវិលមួយកាន់តែស្វាហាប់នៅក្នុងប្រទេស ។

### ១) អ្នកចុះកម្មសិក្សា និង បុគ្គលិកស្ម័គ្រចិត្ត

ចាប់តាំងពីពេលដែលមជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវបានបង្កើត យើងបានទទួលប្រយោជន៍យ៉ាងសន្ធឹកសន្ធាប់ពីនិស្សិតចុះកម្មសិក្សានិងអ្នកស្ម័គ្រចិត្តខ្មែរនិងបរទេស ។ គ្រប់បុគ្គលិកទាំងអស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាសុទ្ធតែចាប់ផ្តើមឡើងពីការងារស្ម័គ្រចិត្តជាច្រើនខែ ។ យើងនៅតែរក្សាវប្បធម៌អង្គភាពបែបនេះ ដើម្បីធានាថាបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាមានការប្តេជ្ញាចិត្តខ្ពស់ចំពោះគោលដៅរួមរបស់អង្គភាព ។ សម្រាប់ឆ្នាំ ២០០៤ យើងគ្រោងទទួលអ្នកស្ម័គ្រចិត្តជនជាតិខ្មែរ ចំនួន៩រូប និងអ្នកស្ម័គ្រចិត្តអន្តរជាតិជាច្រើនរូបទៀតដូចជា វេនី ខូវហ្សៀល, ចន ឆរឆីអារី, ចេហ្ស ស្ត្រាកា និងអ្នកផ្សេងទៀត ។

### ២) បញ្ញាជន និង អ្នកស្រាវជ្រាវមកពីអង្គភាពផ្សេងៗ

យើងតែងតែព្យាយាមធ្វើឲ្យឧបករណ៍និងធនធានរបស់យើងអាចប្រើប្រាស់បានដោយបញ្ញាជនជាតិនិងអន្តរជាតិដែលមានការចាប់អារម្មណ៍ឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន ។ តាមរយៈការជំរុញឲ្យមានការមកស្រាវជ្រាវនៅមជ្ឈមណ្ឌលឯកសារកម្ពុជា យើងសង្ឃឹមថាអាចចែកចាយដោយប្រយោលនូវការរកឃើញរបស់យើង និងបង្កឲ្យមានការពិភាក្សាយ៉ាងសកម្មទៅលើប្រធានបទផ្សេងៗទាក់ទងនឹងរបបកម្ពុជាប្រជា-ធិបតេយ្យនិងផលវិបាកនៃរបបនេះ ។ នៅក្នុងឆ្នាំ២០០៣ យើងបានទទួលភ្ញៀវជាច្រើនរូបមកអានឯកសាររបស់យើង ដែលមានតម្កល់ទុកនៅក្នុងបន្ទប់ដាក់ឯកសារនៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ។ យើងគ្រោងធ្វើដូចនេះទៀតនៅក្នុងឆ្នាំ ២០០៤ ។ ដូចដែលបានរៀបរាប់កន្លងមកនៅក្នុងរបាយការណ៍នេះ យើងនឹងសហការជាមួយបញ្ញាជនបរទេសជាច្រើនរូបដើម្បីសម្រេចការកិច្ចថ្មីៗទៀតនៅក្នុងឆ្នាំ២០០៤ ។ បន្ទប់«ព័ត៌មានសាធារណៈ»របស់យើងនឹងជួយសម្រួលមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការផ្តល់សិទ្ធិអានដល់ភ្ញៀវ ។

### ៣) ការអភិវឌ្ឍន៍បុគ្គលិកខ្មែរនិងការសិក្សានៅបរទេស

ជាយូរមកហើយ យើងជឿជាក់ថាការអភិវឌ្ឍន៍បុគ្គលិកជាបន្តបន្ទាប់គឺជាការចាំបាច់ប្រសិនបើយើងត្រូវបង្កើនជាអតិបរមានូវប្រសិទ្ធភាពនិងគុណភាពការងារ ។ ការសិក្សានៅបរទេស គឺជាមធ្យោបាយសំខាន់បំផុតមួយនៃការអភិវឌ្ឍន៍បុគ្គលិក ការបង្កើនជំនាញនិយោជក ការផ្តល់ឱកាសឲ្យនិយោជកទទួលគំនិតនិងទ្រឹស្តីថ្មី និងការអនុញ្ញាតឲ្យបុគ្គលិកផ្សព្វផ្សាយការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅបរទេស ។ សម្រាប់ឆ្នាំ២០០៤ យើងមានផែនការបញ្ជូនឲ្យបុគ្គលិកខ្លះទៅសិក្សានៅបរទេស ។ មកទល់ខែមករា ឆ្នាំ២០០៤ បុគ្គលិកខាងក្រោមកំពុងបំពេញការសិក្សានៅបរទេស ៖

- ដាត កុសល សិក្សាជំនាញ «ទំនាក់ទំនងអន្តរជាតិ» ថ្នាក់បណ្ឌិត នៅសាកលវិទ្យាល័យសៅដឹនកាលីហ្វ័រញ៉ា (សហរដ្ឋអាមេរិក)
- វ៉ាន់ថាន់ ពៅដារ៉ា សិក្សាជំនាញ «ច្បាប់សិទ្ធិមនុស្ស» ថ្នាក់អនុបណ្ឌិត នៅសាកលវិទ្យាល័យណតត្រឹដាំ(សហរដ្ឋអាមេរិក)
- គីម កែវកញ្ញិដ្ឋា សិក្សាជំនាញ «សន្តិភាពនិងការផ្សះផ្សារ» ថ្នាក់អនុបណ្ឌិត នៅសាកលវិទ្យាល័យខៅវិនទ្រី (ចក្រភពអង់គ្លេស)
- សើ សាយព្យាណា សិក្សាជំនាញ «ទេសចរណ៍និងសារមន្ទីរ» ថ្នាក់អនុបណ្ឌិត (ប្រទេសហូល្ង់)
- អ៊ីសា ឧស្មាន កំពុងតែបន្តការសិក្សាយកជំនាញភាសាអង់គ្លេសថ្នាក់បរិញ្ញាបត្រនៅសាកលវិទ្យាល័យបៀលប្រាយនៅទីក្រុងភ្នំពេញ ។

ប្រសិនបើមានជំនួយថវិកាគ្រប់គ្រាន់ បុគ្គលិកផ្សេងទៀតអាចទៅបន្តការសិក្សានៅបរទេសនៅក្នុងខែកញ្ញាឆ្នាំ២០០៤ខាងមុខ ។

### ៤) អគារ ដីធ្លី និង ឧបករណ៍ប្រើប្រាស់

នៅក្នុងឆ្នាំ២០០៣ យើងបានពង្រីកការិយាល័យកណ្តាលនៅទីក្រុងភ្នំពេញ ។ បន្ទប់ថ្មីនេះត្រូវបានប្រើប្រាស់ជាបន្ទប់រដ្ឋបាលនិងគណនេយ្យ ហើយបុគ្គលិកខ្លះក្នុងផ្នែកទស្សនាវដ្តី និងផ្នែក«ជនរងគ្រោះដោយអំពើទារុណកម្ម»ក៏មកធ្វើការនៅក្នុងបន្ទប់នេះដែរ ។ ទោះជាយ៉ាងណាក៏ដោយ យើងនៅតែពុំមាន

កន្លែងគ្រប់គ្រាន់សម្រាប់ឲ្យភ្ញៀវអ្នកមកសិក្សាស្រាវជ្រាវធ្វើការឲ្យបានស្រួលនោះដែរ ។ នៅក្នុងឆ្នាំ២០០៤ យើងគ្រោងពង្រីកការិយាល័យនេះបន្ថែមទៀតដោយជួលបន្ទប់មួយនៅជាប់ការិយាល័យផ្នែកខាងក្រោម ។ បន្ទប់ការិយាល័យថ្មីនេះនឹងត្រូវប្រើប្រាស់ជាពិសេស សម្រាប់ឲ្យអ្នកច្បាប់មកពិនិត្យឯកសារនៅពេលដែលតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមចាប់ដំណើរការ ។ នេះជាពេលដែលយើងរំពឹងថានឹងមានភ្ញៀវមកអានឯកសារច្រើន ។ យើងនឹងចាត់ចែងបុគ្គលិកឲ្យនៅចាំថតចម្លងនិងរកឯកសារសម្រាប់ភ្ញៀវ ។ មួយផ្នែកនៃបន្ទប់នេះនឹងត្រូវទុកឲ្យទីប្រឹក្សាផ្នែកច្បាប់ធ្វើការ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងស្វែងរកជម្រើសសម្រាប់សាងសង់មជ្ឈមណ្ឌលអចិន្ត្រៃយ៍ ។ នៅក្នុងឆ្នាំ២០០៣ គម្រោងសាងសង់នេះត្រូវអាក់ខានដោយសារមានបញ្ហាដីធ្លី ។ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់ដីមួយកន្លែងនៅក្រោយសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ដោយមានការណែនាំពីអង្គការអន្តរជាតិនិងអង្គការក្រៅរដ្ឋាភិបាលមួយចំនួន បច្ចុប្បន្ននៅលើដីនេះប្រជាពលរដ្ឋបានសាងសង់ផ្ទះសម្បែងនិងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ហើយរស់នៅដោយល្មើសច្បាប់យ៉ាងកកកុញ ។ ទោះជាមជ្ឈមណ្ឌលឯកសារកម្ពុជាជាម្ចាស់កម្មសិទ្ធិស្របច្បាប់នៃដីនេះ ហើយបានប្តឹងតវ៉ាអំពីទង្វើរបស់អង្គការមួយចំនួនដែលពាក់ព័ន្ធ យើងក៏មានការខ្វាយខ្វល់ចំពោះតម្រូវការរបស់ប្រជាជនដែលកំពុងរស់នៅលើដីនេះដែរ ។ នៅក្នុងឆ្នាំ២០០៤ យើងនឹងបន្តយ៉ាងសកម្មស្វែងរកដំណោះស្រាយដើម្បីទាមទារដីនេះមកវិញ (ឬទីតាំងផ្សេង) ដោយពុំចាំបាច់បង្កឲ្យមានការប៉ះពាល់ដល់ប្រជាពលរដ្ឋរស់នៅមិនស្របច្បាប់ឡើយ ។

## ៥) ហិរញ្ញវត្ថុ និង គណនេយ្យ

សម្រាប់ឆ្នាំ២០០៣ យើងមានអំណួតខ្លាំងណាស់ដែលត្រូវបានជ្រើសតាំងដោយអ្នកផ្តល់ជំនួយថាជាអង្គការក្រៅរដ្ឋាភិបាលមួយដែលប្រព័ន្ធគណនេយ្យមានប្រសិទ្ធភាពនិងមានតម្លាភាពខ្ពស់បំផុត ។ យើងត្រូវបានទទួលស្គាល់ជាផ្លូវការពីអង្គការ"ទីភ្នាក់ងារអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ(យូ.អេស.អេ.អាយ.ឌី)" និងការទទួលស្គាល់មិនផ្លូវការពីរដ្ឋាភិបាលប្រទេសស៊ុយអែដ ហូល្លង់ និងប្រទេសផ្សេងទៀត ។ សុខា អ៊ីរ៉ែន គឺជាហិរញ្ញិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយគ្រប់គ្រងលើគណនេយ្យកររបស់យើង ។ ហ៊ុយ សោភ័ណ, លី សុខចំរើន, មាស ប៊ុនថន និង សម មករា បំពេញការងារផ្នែករដ្ឋបាលនិងការងារទាក់ទងនឹងការបើកប្រាក់បៀវត្សរ៍បុគ្គលិកគ្រប់គ្រងវិក្កយបត្រ ការទិញ និងការចំណាយ ។ នៅក្នុងឆ្នាំ២០០៤ យើងនឹងខិតខំប្រឹងប្រែងរក្សាឲ្យបាននូវបទដ្ឋានខ្ពស់និងបន្តធ្វើឲ្យបានប្រសើរជាងនេះ ។

នៅក្នុងឆ្នាំ២០០៣ យើងបានបន្តប្រឈមមុខការកិច្ចដ៏ពិបាកក្នុងការស្វែងរកជំនួយ ដោយសារយើងពុំមានបុគ្គលិកដែលមានជំនាញច្បាស់លាស់ខាងផ្នែករៃអង្គាសថវិកា ហើយត្រូវតែប្រើប្រាស់ពេលវេលាមានកំណត់របស់ទីប្រឹក្សាច្បាប់និងផ្នែកសិក្សាស្រាវជ្រាវ ។ នៅក្នុងឆ្នាំ២០០៤ យើងមានបំណងពង្រីកដំណើរការរៃអង្គាសថវិកាដោយសហការជាមួយ វេនី ខូវហៀល ដែលនឹងមកធ្វើការនៅមជ្ឈមណ្ឌលឯកសារកម្ពុជារយៈពេល ៩ខែ នៅក្នុងឆ្នាំ២០០៤ ដើម្បីជួយរៃអង្គាសថវិកា ។ បន្ថែមទៅលើថវិកាដើម្បីផ្គត់ផ្គង់គម្រោងការកំពុងដំណើរការរាល់ថ្ងៃ យើងកំពុងតែស្នើសុំថវិកាដើម្បីសាងសង់មជ្ឈមណ្ឌលឯកសារកម្ពុជាជាអចិន្ត្រៃយ៍ ។

## សេចក្តីបញ្ចប់

ប្រសិនបើយើងអាចបំពេញភារកិច្ចទាំងអស់ដូចបានគ្រោងទុក ឆ្នាំ២០០៤នឹងជាឆ្នាំដ៏ជោគជ័យមួយទៀតសម្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយវានឹងជួយយើងឲ្យខិតកាន់តែជិតទៅរកការសម្រេចគោលដៅស្នូលរបស់យើង ។ តាមរយៈសប្បុរសធម៌មិនដាច់ពីអ្នកផ្តល់ជំនួយនិងការគាំទ្រពីសំណាក់ប្រជាជននៅតាមស្រុកស្រែចម្ការ យើងមានជំនឿយ៉ាងមុតមាំថាយើងនឹងអាចសម្រេចគម្រោងការទាំងអស់ខាងលើបានមែន ។ ពីអតីតកាលមកទល់បច្ចុប្បន្ន តួនាទីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទាំងនៅក្នុងសង្គមជាតិនិងអន្តរជាតិ បានកើនឡើង ហើយការទទួលខុសត្រូវរបស់យើងក៏កើនក្នុងពេលជាមួយគ្នាដែរ ។ ទាំងនៅក្នុងប្រទេសកម្ពុជានិងនៅបរទេស ក្នុងពេលមានដំណើរការតុលាការខ្មែរក្រហម និងក្រោយតុលាការខ្មែរក្រហម យើងនឹងបន្តរួមវិភាគទានតាមមធ្យោបាយគ្រប់បែបយ៉ាង ដើម្បីស្វែងរកការពិត យុត្តិធម៌ និងធ្វើឲ្យប្រទេសកម្ពុជាក្លាយទៅជានីតិរដ្ឋ ។

**មជ្ឈមណ្ឌលឯកសារកម្ពុជា**

# រឿងពិតរបស់ប្រាក់យឿន


ប្រាក់ យឿន (បច្ចុប្បន្ន)

ប្រាក់ យឿន មានឈ្មោះបដិវត្តន៍ អ៊ី ជាអតីតយុទ្ធជនក្នុងកងវរសេនាធំលេខ១១ កងពលលេខ៣១០ ។ យឿន ត្រូវបានអង្គការបញ្ជូនឲ្យទៅលត់ដំដោយធ្វើការយ៉ាងលំបាកស្ទើរគេចមិនផុតពីសេចក្តីស្លាប់ដោយសារត្រូវអង្គការចោទប្រកាន់ថាបានចូលរួមក្នុងចលនាក្បត់បដិវត្តន៍ ។ សំណាងល្អ យឿន រស់រានមានជីវិតដល់បច្ចុប្បន្ន ។

ប្រាក់ យឿន មានកំណើតនៅស្រុកព្រៃឈរ ខេត្តកំពង់ចាម ។ បច្ចុប្បន្ន យឿន មានអាយុ៤៧ឆ្នាំ រស់នៅស្រុកព្រៃឈរ ខេត្តកំពង់ចាម ។ យឿន ជាកូនច្បងក្នុងចំណោមបងប្អូនចំនួន៦នាក់ ប្រុស៥នាក់ ស្រី១ (ស្លាប់) ។ ឪពុករបស់ យឿន ឈ្មោះ ប្រាក់ យីនស្លាប់នៅឆ្នាំ១៩៧៦ ។ ម្តាយឈ្មោះ ឡាច ភី សព្វថ្ងៃរស់នៅ ភូមិវាល ។ យឿន មានប្រពន្ធឈ្មោះ យឹម ម៉ៅ អាយុ៤៣ឆ្នាំ ព្រមទាំងមានកូនប្រុសចំនួន៤នាក់ ។

កាលពីកុមារភាព យឿន បានចូលរៀននៅសាលាបឋមសិក្សាប្រិមប្រិយបានត្រឹមថ្នាក់ទី៨ចាស់ (ស្មើនឹងថ្នាក់ទី៥បច្ចុប្បន្ន) ។ ក្នុងឆ្នាំ១៩៧០ យឿន ក៏ឈប់រៀន ។ យឿន បានចូលរៀនម្តងទៀតក្នុងអំឡុងឆ្នាំដដែល ។ រៀនមិនបានយូរប៉ុន្មាន យឿន ក៏ឈប់រៀនវិញព្រោះគ្មានគ្រូបង្រៀននិងគួបផ្សំមានព្រឹត្តិការណ៍រដ្ឋប្រហារ ១៨មីនា ។ យឿន ធ្វើស្រែចម្ការ ជាមួយឪពុកម្តាយរហូតដល់ឆ្នាំ១៩៧៤ ក៏ត្រូវប្រធានភូមិឈ្មោះ វ៉ន ចុចឈ្មោះ បញ្ជូនទៅសមរភូមិមុខ ។ កាលណោះក្រុមគ្រួសារ របស់ យឿន មិនចង់ឲ្យ យឿន ទៅទាល់តែសោះ ប៉ុន្តែដោយសារប្រកែកមិនបាន យឿន បានសុំលាឪពុកម្តាយ ហើយរួមដំណើរទៅជាមួយកូនអ្នកភូមិជាច្រើននាក់ឆ្ពោះទៅវត្តតាមាក់ ភូមិព្រៃទទឹង ស្រុកព្រៃឈរ ខេត្តកំពង់ចាម ។ ក្នុងចំណោមអ្នកទាំងនោះក៏មានបងជីដូនមួយរបស់ យឿន ឈ្មោះ ប្រាក់ លៀប ទៅជាមួយដែរ ។ គាត់បានហាត់រៀនខាងបច្ចេកទេសទ័ព ។ នៅវត្តតាមាក់រយៈពេលប្រហែលជា២ខែ ក៏អង្គការបញ្ជូនគាត់ទៅរៀបចំមូលដ្ឋានទ័ពនៅវត្តបាធាយ ។ នៅចុងឆ្នាំ១៩៧៤ យឿន ត្រូវចាត់តាំងឲ្យចុះទៅសមរភូមិប្រយុទ្ធនៅជ្រោយសំបួរ ។ នេះជាលើកដំបូងដែលគាត់ចូលសមរភូមិប្រយុទ្ធ ។ យឿន ភ័យខ្លាចខ្លាំងណាស់ ម្យ៉ាងទៀត ក៏នឹករឭកម្តាយឪពុកខ្លាំងណាស់ដែរ ។ យឿន ជាយុទ្ធជនក្នុងកងវរសេនាតូចនៃកងពលលេខ៣១០ ប្រចាំភូមិភាគឧត្តរដែលមានឈ្មោះ អឿន ជាប្រធានកងពលនិងឈ្មោះ វឿន ជាអនុប្រធាន ។ មកដល់ឆ្នាំ១៩៧៥ ប្រាក់ យឿន បានទទួលបញ្ជាឲ្យវាយនៅភាគខាងជើងទីក្រុងភ្នំពេញ នៅម្តុំភូមិធំត្រពាំងព្រាយ ។ ក្នុងឆ្នាំ១៩៧៥ដដែល យឿន ត្រូវបានចាត់ចូលក្នុងកងវរសេនាតូច កងពិសេសលេខ ៥៩ដែលមាន អឿន ជាប្រធានកងពិសេស (ផ្សេងពី អឿន ប្រធាន កងពល) និង ព្រឹង ជាអនុប្រធាន ។ កងពិសេសមាននាទីស៊ើបការណ៍ឲ្យដឹងជាមុនពីស្ថានការណ៍ខ្មាំង និងត្រួតពិនិត្យមើលភូមិសាស្ត្រមុនពេលបើកការវាយលុក ។ ក្រោយពីពិនិត្យរួចរាល់ហើយទើបប្រធានកងពិសេសបញ្ជាទ័ពចូលទៅមុខទៀត ។

យឿន បានជួបប្រទះហេតុការណ៍ប្រយុទ្ធគ្នាយ៉ាងខ្លាំងជាមួយទាហានខាង លន់ ណុល ។ យុទ្ធជននៅក្នុងក្រុមរបស់ យឿន ដែល មានគ្នា៣៦នាក់ត្រូវស្លាប់បាត់បង់ជីវិតនៅសល់គ្នាតែ៩នាក់ ។ ចំណែក យឿន ស្ទើរតែគេចមិនផុតពីគ្រាប់កាំភ្លើង ។ ការប្រយុទ្ធគ្នានេះមានសភាពស៊ុតស្វាញណាស់ ។ ដោយទប់ទល់តទៅទៀតមិនបាន ប្រធានកងពលរបស់ យឿន បានបញ្ជាឲ្យកងទ័ពរបស់ខ្លួនដកថយមកក្រោយ ។ ក្រោយមក យឿន បានត្រូវផ្លាស់ឲ្យមកនៅក្នុងកងវរសេនាធំវិញ មានតួនាទីជានីរសាររបស់ប្រធានកងវរសេនាធំឈ្មោះ ឆន ។ មិនយូរប៉ុន្មានកងទ័ពខ្មែរក្រហមដណ្តើមបានទីក្រុងភ្នំពេញក្នុងខែមេសា ឆ្នាំ១៩៧៥ ។ យឿន មិនបានចូលសមរភូមិទៀតឡើយ ដោយសារ យឿន ខណៈនោះមានជំងឺ

ក្រុនចាញ់ ហើយត្រូវថ្នាក់លើចាត់ឲ្យទៅនៅកន្លែងដាំបាយ ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ យឿន បានចូលដល់ទីក្រុងភ្នំពេញ ។ យឿន ប្រាប់ថា ពេលនោះហើយដែលគាត់បានឃើញទិដ្ឋភាពគ្រប់បែបយ៉ាង ។ ប្រជាជនត្រូវកងទ័ពខ្មែរក្រហមបង្ខំឲ្យចាកចេញពីទីលំនៅឋាន ហើយធ្វើដំណើរទៅជនបទ ។ យឿន បានទទួលបញ្ជាឲ្យជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ដោយប្រាប់ប្រជាជនថា «អង្គការឲ្យចេញតែ៣ថ្ងៃទេ» ។ ខ្មែរក្រហមបានឃោសនាអំពាវនាវឲ្យអតីតទាហានគ្រប់លំដាប់ថ្នាក់ចូលមកទទួលតំណែងនិងបំពាក់ស័ក្តិឡើងវិញ ។ អ្នកខ្លះចេញផុតពីទីក្រុងទៅហើយបានចូលមកសារភាពតាមការអំពាវនាវរបស់ខ្មែរក្រហម ប៉ុន្តែអ្នកទាំងនោះមួយចំនួនត្រូវខ្មែរក្រហមសម្លាប់ ហើយមួយចំនួនទៀតត្រូវបាត់ ខ្លួន ។

ក្រោយឆ្នាំ១៩៧៥ យឿន ត្រូវបានអង្គការផ្លាស់ឲ្យទៅធ្វើស្រែនៅម្តុំឃ្លាញ ។ ជាមួយនឹងការងារបង្កបង្កើនផល យឿន ក៏ត្រូវតែមកហាត់បច្ចេកទេសយោធានៅម្តុំវត្តភ្នំបន្ថែមទៀត ។ នៅកន្លែងហ៊ឹកហ៊ឺន យឿន ត្រូវក្រោកតាំងពីម៉ោង៣ទៀបភ្លឺដើម្បីរៀនបន្ទឹសញ្ញាអាសន្ន ។ នៅកន្លែងធ្វើស្រែ ប្រធានកងពលជាអ្នកបង្រៀនអំពីនយោបាយ ជួនកាលមានការប្រជុំផ្សេងៗផង ។ អង្គការតែងតែបំពាក់បំប៉នគោលនយោបាយពង្រឹងគោលជំហរ និងបំពាក់មនោគមវិជ្ជាដល់យុទ្ធជនទាំងអស់ឲ្យស្មោះត្រង់នឹងអង្គការ ។

នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧៥ ជាថ្ងៃប្រារព្ធខួបកំណើតបក្សកុម្មុយនិស្តកម្ពុជាលើកទី១៥ ។ ពិធីនេះប្រារព្ធឡើងនៅស្តាតអូឡាំពិក ដោយមានការចូលរួមជាអធិបតីពីថ្នាក់ដឹកនាំខ្មែរក្រហមជាច្រើនរូប ។ យឿន ស្គាល់តែ ខៀវ សំផន, នួន ជា, ហ៊ូ នឹម, ទីវ អុល ហៅ ទុំ ។

ប្រធានកងពល អនុប្រធានកងពល និងមេបញ្ជាការមួយចំនួន និង យឿន ខ្លួនឯងផ្ទាល់ បានត្រូវអង្គការលើចោទថាជាសមាសភាពក្បត់ ។ កាលណោះ យឿន គ្រាន់តែជាយុទ្ធជនសាមញ្ញម្នាក់តែប៉ុណ្ណោះ ។ យឿន បានរៀបរាប់ពីដំណើររឿងទាំងឡាយដែលបានកើតឡើងថាមេបញ្ជាការខាងភូមិភាគនិរតីបានចាប់មេរបស់គាត់ពីបទមានផែនការធ្វើរដ្ឋប្រហារផ្តួលរំលំរបប ប៉ុល ពត ។ យឿន បានដឹងពីផែនការនេះដែរតាមរយៈមេក្រុមដែលប្រាប់ថា «យើងត្រូវកម្ចាត់របបនេះ ។ របបនេះជារបបអត់បាយស៊ីពិបាកណាស់ យើងត្រូវបង្កើតឲ្យមានរបបពាក់អាវពណ៌ឡើងវិញ» ។ ផែនការនេះក៏ត្រូវបែកការណ៍ ។ ទីបំផុតប្រធានកងពលឈ្មោះ អឿន បានចេញមកសារភាព ហើយត្រូវអង្គការចាប់ខ្លួននៅឆ្នាំ១៩៧៧ ។ ថ្ងៃដែលអង្គការចាប់ខ្លួន អឿន នោះ យឿន មិនបានដឹងទេ ព្រោះគាត់បានទទួលបញ្ជាឲ្យទៅរោងបាយដើម្បីដាំបបរស្ករ ។ ភាពភ្ញាក់ផ្អើលបានកើតមានឡើងនៅពេលដែល យឿន ត្រឡប់មកពីរោងបាយវិញ ស្រាប់តែឃើញមេបញ្ជាការថ្មី មកពីភូមិភាគនិរតីកាន់តំណែងជំនួសមេបញ្ជាការចាស់ ។ ពេលនោះហើយទើប យឿន ដឹងថាមេបញ្ជាការរបស់គាត់ត្រូវខាងភូមិភាគនិរតីចាប់ខ្លួន ។ នៅឆ្នាំ១៩៧៧ដដែល យឿន ត្រូវបានបញ្ជូនឲ្យទៅធ្វើស្រែដើម្បីលត់ដំនៅបឹងបាយាប ។ យឿន រស់ក្នុងសភាពលំបាកវេទនា ស្ទើរស្លាប់ស្ទើររស់ ។ គាត់ត្រូវក្រោកតាំងពីម៉ោង៣ទៀបភ្លឺ ដើម្បីស្ទូងស្រូវទាំងផោកជុំយ ថែមទាំងត្រូវសត្វទាកខាំ


សកម្មភាពលើកទំនប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ទៀត ។ យឿន ធ្វើស្រែតាំងពីព្រហាម រហូតម៉ោង៦ល្ងាច ដោយគ្មានពេលសម្រាកឡើយ ក្រៅតែពីពេលទទួលទានអាហារថ្ងៃត្រង់ ។ របបអាហារត្រូវបានកំណត់ម្នាក់១កំប៉ុងសម្រាប់១ថ្ងៃ ។ បន្ទាប់ពីអាហារពេលល្ងាច យឿន សង្ឃឹមថាពិតជាបានសម្រាក ប៉ុន្តែគាត់ត្រូវបង្ខំឲ្យធ្វើការងាររហូតដល់ម៉ោង៩យប់ ។ ការងាររបស់ យឿន គឺដាំដំណាំដើម្បីដោះស្រាយជីវភាពរបស់អង្គភាព ។ មេបញ្ជាការរបស់ យឿន បានបញ្ជាឲ្យដាំកុំឲ្យសល់ដីមួយចំអាម ។ យឿន មិនហ៊ានជំទាស់តវ៉ាឬលួចអ្វីឡើយ ទោះបីជាអត់ឃ្លានយ៉ាងណាក្តី ព្រោះគាត់ដឹងពីផលវិបាកនៃការលួចនៅពេលដែលត្រូវខ្មែរក្រហមតាមទាន់ ។ តាមដែល យឿន ធ្លាប់ដឹងអ្នកដែលត្រូវខ្មែរក្រហមចាប់បានក្នុងពេលលួចអាហារត្រូវនាំយកទៅឆ្ងាយ ហើយមិនដែលឃើញត្រឡប់មកវិញឡើយ ។ ជាក់ស្តែង ឈ្មោះ ធួន និង អ៊ី នៅក្នុងកងពលជាមួយ យឿន ដាច់ចិត្តលួចបាយ ដោយទ្រាំទ្រនូវការអត់ឃ្លានមិនបាន ហើយត្រូវអង្គការដឹងក៏ចាប់អ្នកទាំងពីរពីបទ ក្បត់នឹងអង្គការវិន័យ ។

ក្រោយពីព្រឹត្តិការណ៍ចាប់ អឿន បានប្រហែល២ខែ គឺនៅក្នុងឆ្នាំ១៩៧៧ដដែល យឿន និងយុទ្ធជនក្នុងកងពល៣១០ត្រូវថ្នាក់លើហៅទៅប្រជុំនៅវត្តភ្នំ ។ កាលណោះ យឿន នៅជាយុទ្ធជននៅឡើយ ។ ការប្រជុំគ្មានអ្វីក្រៅពីការចាក់ខ្សែអាត់ ចម្លើយសារភាពរបស់ អឿន ឲ្យយុទ្ធជនទាំងអស់ស្តាប់ឡើយ ។ នៅក្នុងចម្លើយសារភាពនោះ អឿន បាននិយាយថា "ខ្ញុំសុខចិត្តប្រគល់ខ្លួនឲ្យអង្គការ ទោះបីអង្គការឲ្យធ្វើអ្វីក៏ព្រមដែរ" ។ យឿន បានបន្ថែមថាប្រធានកងពលរបស់គាត់ត្រូវចាប់បញ្ជូនទៅជើងឯក ។ យឿន ឮយុទ្ធជននីរសានិយាយគ្នាថា បឹងជើងឯកគឺជាកន្លែងសម្លាប់មនុស្សរបស់ខ្មែរក្រហម ។

កន្លែងសម្លាប់មនុស្សធំៗរបស់អង្គការមិនសូវផ្សព្វផ្សាយឲ្យស្គាល់ឡើយ ។ មិនខុសពីយុទ្ធជនដទៃទេ យឿន មិនស្គាល់និងមិនដឹងថាមានគុកទួលស្លែងឡើយ ។ ក្រោយឆ្នាំ១៩៧៩ ទើប យឿន ដឹងថាមានគុកទួលស្លែងដែលជាកន្លែងសម្លាប់មនុស្សយ៉ាងសាហាវ ។ គ្រប់ពេលដែលឃើញឡានឡង់រ៉ូវ៉ែឃ្មុបបើកសំដៅមក យឿន មានការភិតភ័យណាស់ ពីព្រោះរាល់ពេលដែលឡាននេះបើកមកម្តងៗតែងតែមានមនុស្សត្រូវដឹកទៅវិញជានិច្ច ។ អ្នកដែលត្រូវចាប់ទៅហើយ មិនដែលឃើញត្រឡប់មកវិញទេ ។ ជាក់ស្តែងដូចជាប្រធានកង ឈ្មោះ ឯក ត្រូវអង្គការចាប់ខ្លួននៅក្នុងឆ្នាំ១៩៧៦ ។ យឿន បានឃើញខ្មែរក្រហមចាប់ចង ឯក ដោយផ្ទាល់ភ្នែក ។

យឿន បានឃើញ ប៉ុល ពត ក្នុងពេលចូលរួមមហាសន្និបាតនៅស្តាតអូឡាំពិក ។ ក្រៅពី ប៉ុល ពត យឿន ស្គាល់ តាម៉ុក ដែលមានឈ្មោះហៅក្រៅថា តា១៥ ជាលេខាបក្សភូមិភាគនិរតី ។ នៅខែ១១ យឿន ត្រូវបានបញ្ជូនឲ្យទៅធ្វើព្រលានយន្តហោះនៅខេត្តកំពង់ឆ្នាំង ។ អ្នកគ្រប់គ្រងនៅព្រលានយន្តហោះឈ្មោះ តាល្វៃ ជាប្រធានកងពល៥០២ ដោយសារ យឿន ចេះគិតលេខ ទើបថ្នាក់លើជ្រើសរើសឲ្យធ្វើការខាងវាស់ស្ទង់ជាមួយចិន ។ យឿន ធ្វើការខាងវាស់ស្ទង់ដាំបង្គោលជាមួយចិន ដោយមានអ្នកបកប្រែប្រុសម្នាក់និងស្រីម្នាក់ ។

នៅកន្លែងធ្វើការណាក៏ដោយ ក៏ចៀសមិនផុតពីការយកមនុស្សទៅសម្លាប់ដែរ ។ យឿន និយាយថា ក្នុងឆ្នាំ១៩៧៨ ខ្មែរក្រហមចាប់មនុស្សយកទៅសម្លាប់នៅជើងភ្នំ ។ អ្នកដែលត្រូវចាប់ខ្លួនយក ទៅសម្លាប់នោះមានឈ្មោះ អយ ប្រធានកងវរសេនាតូចលេខ១៧ កងពល៥០២ ។ តាអយ មានសម្តីពីរោះនិងយល់ចិត្តសមាជិកក្នុងកង ។ បើតាម យឿន សន្និដ្ឋានប្រហែលមកពីខ្មែរក្រហមមិនចូលចិត្តអ្នកមានសម្តីពិរោះនិងទៀងត្រង់ចំពោះសមាជិកហើយមើលទៅទើបសម្លាប់ តាអយ ចោល ។

ការងារនៅព្រលានយន្តហោះមិនសូវលំបាកដូចនៅបឹងបាយាបទេ ប៉ុន្តែ យឿន នៅតែហូបមិនឆ្អែតដដែល ។ យឿន បាននិយាយថាចិនដែលមកធ្វើព្រលានយន្តហោះនៅកំពង់ឆ្នាំងមានចំនួនប្រមាណ១០០នាក់(ទាំងស្រីទាំងប្រុស) ធ្វើការច្រើនជំនាញ ។ យឿន ធ្វើការនៅព្រលានយន្តហោះរហូតដល់ខែមករា ឆ្នាំ១៩៧៩ ។ នៅយប់មួយ ដើមខែមករា ឆ្នាំ១៩៧៩ យឿន បានទទួលដំណឹងថា កងទ័ពវៀតណាមចូលដល់លង្វែកហើយ ។ អ្នកធ្វើការនៅព្រលានយន្តហោះផ្អើលនាំគ្នារត់ចេញមកដល់ភ្នំក្រវាញ ។ នៅតាមផ្លូវ ក្រុមរបស់ យឿន ហេវហត់យ៉ាងខ្លាំង ព្រោះគ្មានអាហារបរិភោគ ។ មនុស្សស្លាប់ជាច្រើនដោយសារធ្វើដំណើរផ្លូវឆ្ងាយដោយគ្មានបាយគ្មានទឹក ហើយខ្មែរក្រហមនៅតែបន្តសម្លាប់មនុស្សជាហូរហែតាមផ្លូវ ។ នៅតាមផ្លូវចេញពីភ្នំក្រវាញ យឿន បានឃើញខ្មែរក្រហមសម្លាប់យុទ្ធជនភូមិភាគ

បូព៌ាដោយផ្ទាល់ភ្នែក ។ យឿន បញ្ជាក់ប្រាប់ថា កងទ័ពនិរតីបានចាប់ទ័ពខាងបូព៌ាជាច្រើននាក់យកទៅវាយសម្លាប់នឹងត្បូងចបនៅអមលាំង ។ ទ័ពខាងនិរតីចាប់ទ័ពខាងបូព៌ា៣ដងក្នុង១ថ្ងៃ ចាប់ម្តង ៧៦០នាក់យកទៅសម្លាប់អស់ ទុកត្រឹមតែអាយុ១៦ឆ្នាំចុះ ។ ខ្មែរក្រហមប្រើត្បូងចបធ្វើជាឧបករណ៍សម្លាប់មនុស្ស ។ មានអ្នកខ្លះប្រកាច់ត្រដរខ្យល់ទម្រាំតែស្លាប់ អ្នកខ្លះទៀត រត់ទៅដល់រោងបាយ ប៉ុន្តែនៅតែត្រូវចាប់បានមកវិញ ហើយសម្លាប់ចោលគ្មានប្រណី ។ ឃើញដូច្នេះ យឿន ភិតភ័យខ្លាំងណាស់ បារម្ភក្រែងណាខ្លួនត្រូវសម្លាប់ដែរ ។

បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម យឿន បានចូលសារភាពជាមួយរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ហើយបានចូលរៀនវគ្គអប់រំនៅវត្តកាពខេត្តកំពង់ឆ្នាំង ។ មិនយូរប៉ុន្មាន យឿន បានទទួលលិខិតអនុញ្ញាតឲ្យត្រឡប់មកកាន់លំនៅឋានវិញ ។

យឿន បញ្ជាក់ថា “គ្មានអ្វីលំបាកជាងជីវិតរស់នៅក្នុងរបបខ្មែរក្រហមទេ ។ ខ្ញុំឈឺចាប់និងមានវិប្បដិសារីខ្លាំងណាស់ ។ ខ្ញុំបង្ខំចិត្តលះបង់ឪពុកម្តាយបងប្អូននិងផ្ទះសម្បែងដើម្បីចូលរួមបម្រើបដិវត្តន៍ ។ នៅពេលប្រទេសជាតិបានសាន្តត្រាណ ខ្ញុំសង្ឃឹមថានឹងរស់នៅបានសុខស្រួល ប៉ុន្តែអ្វីៗទាំងអស់សុទ្ធតែជាការបោកប្រាស់ ។ ខ្ញុំរងទុក្ខលំបាកវេទនាធ្វើការធ្ងន់និងហូបចុកមិនគ្រប់គ្រាន់ ត្រូវអង្គការចោទថាក្បត់បដិវត្តន៍ រឹះតែត្រូវអង្គការយកទៅសម្លាប់ចោលទៀត” ។ ការតស៊ូរបស់ យឿន ក្នុងរបបខ្មែរក្រហមគ្មានន័យអ្វីសោះ ។ ដែលធ្វើឲ្យ យឿន មិនអាចបំភ្លេចបាននោះ គឺរឿងដែលខ្មែរក្រហមបានចាប់ឪពុករបស់គាត់យកទៅសម្លាប់ ។ ខ្មែរក្រហមគ្មានបានផ្តល់អ្វីឲ្យ យឿន ក្រៅពីបន្សល់ទុកភាពខ្លោចផ្សា និងធ្វើឲ្យម្តាយរបស់គាត់ក្លាយជាស្ត្រីមេម៉ាយ ហើយគាត់ក្លាយជាកូនកំព្រាឪពុក ។

រហូតមកដល់សព្វថ្ងៃនេះ យឿន នៅតែយករឿងរ៉ាវរបស់គាត់មកនិយាយប្រាប់ដល់ក្មេងៗឲ្យបានដឹងបានឮនូវអ្វីដែលគាត់បានឆ្លងកាត់ក្នុងរបបខ្មែរក្រហម ។ ជាងនេះទៅទៀត យឿនបានគាំទ្រឲ្យមានការបង្កើតសាលាក្តីដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម ព្រោះ យឿន យល់ថាការបង្កើតសាលាក្តីនេះពិតជាមានប្រយោជន៍ដល់ប្រជាជនក្នុងការរកយុត្តិធម៌ជូនអ្នកដែលបានស្លាប់ទៅនិងអ្នកនៅរស់ឲ្យបានរសាយចិត្តព្រមទាំងឲ្យកូនខ្មែរជំនាន់ក្រោយយល់ដឹងថា នេះពិតជារឿងរ៉ាវប្រវត្តិសាស្ត្រដែលមនុស្សហ៊ានសម្លាប់មនុស្សជាតិសាសន៍ឯងដែលជាខ្មែរដូចគ្នា និងកុំឲ្យមានរបបនេះកើតឡើងជាថ្មីម្តងទៀត ។

**សូ ហ្វារីណា**

# សេចក្តីជូនដំណឹង

សមាគមអ្នកនិពន្ធខ្មែរសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅនិងសូមជម្រាបជូនដំណឹងដល់ម្ចាស់អត្ថបទដែលបានផ្ញើរអត្ថបទមកសមាគមអ្នកនិពន្ធខ្មែរ ដើម្បីចូលរួមក្នុង “វេទិកាថែរក្សាប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ” ឲ្យបានជ្រាបថា គណៈកម្មការកំណែកំពុងពិនិត្យវាយតម្លៃស្នាដៃនីមួយៗ ។ ចំពោះលទ្ធផលសម្រេច សមាគមអ្នកនិពន្ធខ្មែរនឹងជូនដំណឹង នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៣ ។ សូមអរគុណ ។

**យូ បូ**

**ប្រធានសមាគមអ្នកនិពន្ធខ្មែរ**

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហម បាននិងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោមៈ

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: dccam@online.com.kh*

*Home page: www.dccam.org*

# ប្រធានាធិបតីសហរដ្ឋអាមេរិក ជីមមី ខាតធ័រៈ សិទ្ធិមនុស្ស និង កម្ពុជា

គោលនយោបាយការបរទេសដែលចាត់ទុកការការពារសិទ្ធិមនុស្សជាបញ្ហាសំខាន់របស់ខ្លួននោះ គឺគោលនយោបាយការបរទេសរបស់រដ្ឋការប្រធានាធិបតី ជីមមី ខាតទ័រ យ៉ាងហោចណាស់ក៏ជាវោហារសាស្ត្រដែរ ។ "ក្នុងនាមជាប្រធានាធិបតី" ជីមមី ខាតទ័រ បានសរសេរនៅក្នុងកំណត់ប្រវត្តិរបស់គាត់ថា "ខ្ញុំសង្ឃឹមនិងជឿជាក់ថា ការពង្រីកសិទ្ធិមនុស្សអាចជារលកនៃអនាគតទូទាំងពិភពលោក ហើយខ្ញុំចង់ឲ្យសហរដ្ឋអាមេរិកយកចលនាសិទ្ធិមនុស្សជាបញ្ហាសំខាន់បំផុត" ។ នៅក្នុងកាលៈទេសៈផ្សេងៗគ្នា រដ្ឋការលោកប្រធានាធិបតី ជីមមី ពិតជាបានសង្កត់ធ្ងន់ទៅលើការគិតគូរដល់បញ្ហាសិទ្ធិមនុស្សដូចជាកាលដែលខ្លួនកាត់ជំនួយទៅឲ្យរបបយោធាផ្តាច់ការនៅ អាហ្សង់ទីន ជាដើម ។ ក្នុងករណីរបប ប៉ុល ពត នៅកម្ពុជាដែល ជីមមី ខ្លួនឯងចាត់ទុកថាជា "អ្នករំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរជាងគេបំផុតនៅក្នុងពិភពលោកនាពេលបច្ចុប្បន្ន" នោះ ការគិតគូរអំពីបញ្ហាសិទ្ធិមនុស្សពិបាកនឹងជ្រៀតចូលទៅក្នុងគោលនយោបាយការបរទេសរបស់រដ្ឋការ ជីមមី ណាស់ ។ គ្មានអ្វីគួរឲ្យភ្ញាក់ផ្អើលទេថា ជីមមី កម្រនិយាយអំពីកម្ពុជានៅក្នុងកំណត់ប្រវត្តិរបស់ខ្លួនណាស់ ។

កម្ពុជាទទួលបានឯករាជ្យពីប្រទេសបារាំងនៅឆ្នាំ១៩៥៣-៥៤ ក្រោមការដឹកនាំរបស់សម្តេចព្រះនរោត្តម សីហនុ។ សម្តេច សីហនុ បន្តការដឹកនាំប្រទេសរហូតដល់ពេលដែលព្រះអង្គត្រូវបានផ្តួលរំលំដោយរដ្ឋប្រហារឆ្នាំ១៩៧០ ។ សម្តេច សីហនុ បានចាត់ចែងស្ទើរតែឥតខ្ចោះក្នុងការបញ្ចៀសសង្គ្រាមដែលកំពុងតែយាយីប្រទេសវៀតណាមឲ្យផុតពីប្រទេសកម្ពុជា បើទោះជាវៀតណាមខាងជើងនិងកងទ័ពវៀតកុងបានដកថយចូលក្នុងទឹកដីកម្ពុជា ហើយកងទ័ពអាមេរិកកាំងនិងវៀតណាមខាងត្បូងដេញតាមវាយប្រហារដល់បណ្តោយព្រំដែនប្រទេសកម្ពុជាយ៉ាងណាក៏ដោយ ។ នៅឆ្នាំ១៩៦៣ សម្តេច សីហនុ បានបញ្ឈប់ការទទួលយកជំនួយរបស់អាមេរិកទាំងអស់ ហើយនៅខែឧសភា ឆ្នាំ១៩៦៥ ទ្រង់ បានផ្តាច់ទំនាក់ទំនងការទូតជាមួយសហរដ្ឋអាមេរិក ។ នៅឆ្នាំ១៩៦៩ ប្រធានាធិបតី រីឆាត និចសុន បានបញ្ជាឲ្យទម្លាក់គ្រាប់បែកបេ-៥២ជាសម្ងាត់មកលើទីតាំងដែលហៅថា"ជម្រកលាក់ខ្លួនកម្ពុជា" ប៉ុន្តែ និចសុន ក៏បានស្តាបនាឡើងវិញនូវទំនាក់ទំនងជាមួយរដ្ឋាភិបាលសម្តេច សីហនុ ដែរ ។ ការទម្លាប់គ្រាប់បែកមិនបានបញ្ឈប់ជនកុម្មុយនិស្តមិនឲ្យប្រើប្រាស់ទឹកដីកម្ពុជាទេ ហេតុដូចនេះហើយបានជារដ្ឋការរបស់ និចសុន ឆ្លៀតឱកាសដែល លន់ ណុល ធ្វើរដ្ឋប្រហារទម្លាក់សម្តេច សីហនុ នៅខែមីនា ឆ្នាំ១៩៧០ នោះដើម្បីចូលមកលុកលុយប្រទេសកម្ពុជាក្នុងគោលបំណងកម្ទេចទីតាំងកងទ័ពសំខាន់ៗរបស់បច្ចាមិត្រ ។ ទង្វើនេះបានពង្រីកសង្គ្រាមកាន់តែធំទៅៗ ហើយបាននាំកម្ពុជាឲ្យធ្លាក់ចូលទៅក្នុងបញ្ហាស្មុគស្មាញជាមួយវៀតណាម ។ អស់រយៈពេល៥ឆ្នាំក្រោយមក សង្គ្រាមឃោរឃៅមួយលេចរូបរាងពិតប្រាកដឡើងនៅពេលដែលរដ្ឋាភិបាលវៀតណាមខាងជើងដែលគាំទ្រដោយរដ្ឋាភិបាលអាមេរិកចាញ់សង្គ្រាម ហើយបង្កើនកុប្បកម្មនៅក្នុងជួរខ្មាំមកុម្មុយនិស្តកម្ពុជា ពោលគឺខ្មែរក្រហមនេះឯង ។ ប្រជាជនកម្ពុជារាប់សែននាក់បានបាត់បង់ជីវិត ។ នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានកាន់កាប់អំណាច ជម្លៀសប្រជាជនទីក្រុងឲ្យទៅជនបទ ហើយបង្កើតនូវរបបមួយមានឈ្មោះថាកម្ពុជាប្រជាធិបតេយ្យ ជារបបមួយមានចរិតឃោរឃៅរហូតដល់ឆក់យកជីវិតប្រជាជនកម្ពុជាប្រមាណ១លាន៧សែននាក់ក្នុងចំណោមប្រជាជនសរុប៧លាននាក់ ។

ជីមមី ខាតធ័រ ចូលកាន់តំណែងប្រធានាធិបតីនៃសហរដ្ឋ-អាមេរិកនៅខែមករា ឆ្នាំ១៩៧៧ ។ ក្រោយពេលចូលកាន់តំណែងភ្លាម លោកបានបញ្ជាក់អំពីបញ្ហាដែលនៅសេសសល់ពីសង្គ្រាមវៀតណាម ។ ប្រធានាធិបតីថ្មីបានសុំអភ័យទោសចំពោះអ្នកដែលបានទទូចចង់ឲ្យមានសេចក្តីព្រាង និងបានចាប់ផ្តើមស្តារទំនាក់ទំនងការទូតជាមួយវៀតណាម ប៉ុន្តែចំពោះបញ្ហាការទូតជាមួយកម្ពុជាវិញ មានការរីកចម្រើនតិចតួចណាស់ ។ ក្រៅពីការសម្រេចចិត្តដ៏គួរឲ្យចាប់អារម្មណ៍នៅក្នុងឆ្នាំ១៩៧៧ ក្នុងការយល់ព្រមផ្តល់នូវអាជ្ញាប័ណ្ណចំនួន៣ដើម្បីដឹកជញ្ជូនម្សៅថ្នាំសម្លាប់សត្វល្អិតមកកម្ពុជាសម្រាប់ជួយកាត់បន្ថយបញ្ហាជំងឺគ្រុនចាញ់នៅក្នុងប្រទេស

នេះ (ដែលការដឹកជញ្ជូននេះត្រូវធ្វើឡើងតាមអាជ្ញាធរកម្ពុជាប្រជាធិបតេយ្យនៅទីក្រុងហុងកុង) គឺគ្មានការផ្តួចផ្តើមគំនិតបង្កើតគោលនយោបាយសំខាន់ៗ នៅឆ្នាំ១៩៧៧នេះឡើយ ។ (មន្ត្រីបន្តុបរបស់កម្ពុជាប្រជាធិបតេយ្យមិនដែលទទួលស្គាល់ថាខ្លួនបាន ទទួលមេរោគីមីនោះឡើយ) ។

យ៉ាងណាក៏ដោយ ក៏អ្នកដែលតាមដានសោកនាដកម្មដែលចេះតែកើនឡើងនៅក្នុងប្រទេសកម្ពុជា បានជំរុញឲ្យរដ្ឋការប្រធានាធិបតីជីមមី ធ្វើកិច្ចការអ្វីមួយដើម្បីផ្លាស់ប្តូរស្ថានការណ៍រំលោភសិទ្ធិមនុស្ស ។ មនុស្សកាន់តែច្រើនឡើងៗចាប់ផ្តើមគូសបញ្ជាក់ថាភាពស្ងាត់ស្ងៀមរបស់រដ្ឋការនេះចំពោះកម្ពុជាគឺជាការផ្តល់ចំណាប់អារម្មណ៍ខុសទៅលើបញ្ហាដ៏សំខាន់នៃសិទ្ធិមនុស្សនៅក្នុងគោលនយោបាយការបរទេសរបស់ខ្លួន ។ ពលរដ្ឋអាមេរិកាំងមួយរូបបានសរសេរលិខិតទៅប្រធានាធិបតីជីមីថា “ខ្ញុំឆ្ងល់ខ្លាំងណាស់ថាប្រធានាធិបតីនិងគោលនយោបាយសំខាន់របស់លោកក្នុងការការពារសិទ្ធិមនុស្សមើលមិនឃើញថា វាជាបញ្ហា“សមរម្យ” ក្នុងការនិយាយចេញការពារដល់ប្រជាជនកម្ពុជារាប់ពាន់នាក់ដែលគ្មានទីពឹង និងកំពុងតែទទួលរងការវាយដំយ៉ាងឃោរឃៅរហូតដល់បាត់បង់ជីវិតដោយគ្រាន់តែអ្នកទាំងនោះស្ថិតនៅក្នុងវណ្ណៈកណ្តាលនៃសង្គមប៉ុណ្ណោះ” ។ តំណាងពលរដ្ឋមួយរូបឈ្មោះ នរ័មែន ឌីកក៏បានអង្វរ ជីមមី ឲ្យថ្កោលទោសខ្មែរក្រហមដែល(តំណាងពលរដ្ឋនោះសរសេរថា) បានប្រព្រឹត្តអំពើឃោរឃៅដូចជា“ជនដែលបានប្រព្រឹត្តនៅជំរំណាហ្សីរបស់អាល្លឺម៉ង់នៅក្នុងសង្គ្រាមលោកលើកទី២ ការរំលោភសិទ្ធិមនុស្សនៅឈីលី, អ៊ូហាន់ដា និងសហភាពសូវៀត”ដែរ ។ ជាការឆ្លើយតបវិញ ជីមមី ខាតធ័រ បានទទូចថាសហរដ្ឋអាមេរិកអាច“បន្តនិយាយប្រឆាំងនឹងទង្វើនេះឬប្រទេសផ្សេងទៀតដែលបដិសេធជាលក្ខណៈប្រព័ន្ធនូវសិទ្ធិរស់រានមានជីវិតនិងសេចក្តីថ្លៃថ្នូរជាមូលដ្ឋានរបស់មនុស្ស” ប៉ុន្តែតាមការពិតជាក់ស្តែងគ្មានចំណាត់ការអ្វីជាដុំកំភួនឡើយ ។

ការប្រមាថជាទម្ងន់ទៅលើកង្វះចម្លើយតបទៅនឹងវិបត្តិអវិជ្ជមាននៅកម្ពុជា នាំឲ្យមានការបើកសមាជជាលើកទីមួយស្តីអំពីអភិវឌ្ឍន៍នៅកម្ពុជាចាប់តាំងពីជ័យជម្នះរបស់កម្លាំង ប៉ុល ពត នៅឆ្នាំ១៩៧៥ ។ នៅខែឧសភា ឆ្នាំ១៩៧៧ អនុគណៈកម្មការអង្គការអន្តរជាតិនៃគណៈកម្មាធិការកិច្ចការអន្តរជាតិ បានស្តាប់សម្តីរបស់សាក្សីបួនរូបៈ ទី១) ចន បារ៉ុន ជាអ្នកនិពន្ធទស្សនាវដ្តីរីដឌ័រ ដាយចេស ទី២) សហនិពន្ធសៀវភៅដែលបោះពុម្ពផ្សាយ“ឃាតកម្មនៅលើទឹកដីដ៏ទន់ភ្លន់មួយ”ដែលនិយាយលម្អិតអំពីអំពើឃោរឃៅប្រព្រឹត្តឡើងដោយខ្មែរក្រហម ទី៣) អ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ ហ្គារ៉េត ផតធ័រ ដែលលើកជារបាយការណ៍អំពីមនុស្សឃាតនិងអំពើឃោរឃៅជាទ្រង់ទ្រាយធំនិងជាប្រព័ន្ធនិងដែលបានការពារសេចក្តីសម្រេចជម្លៀសប្រជាជនពីទីក្រុងនិង ទី៤) អតីតមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក ភីតធ័រ ភូល និង ដេវីដ ឆេនដល័រ ដែលធ្លាប់បាន បម្រើការនៅក្នុងប្រទេសកម្ពុជា ។ ភូល និង ឆេនដល័រ ផ្តល់នូវការវាយតម្លៃដោយប្រយ័ត្នប្រយែងអំពីស្ថានការណ៍នៅប្រទេសកម្ពុជា ហើយបានគិតថាចំណាត់ការយោធារបស់អាមេរិកមកលើប្រទេសកម្ពុជាគឺជាការរួមចំណែកខ្លាំងបំផុតនាំឲ្យខ្មែរក្រហមមានលទ្ធភាពកាន់អំណាចក្នុងប្រទេសកម្ពុជា ។ ក្រោយពីយល់ស្របថាជំនួយមនុស្សធម៌មួយចំនួន (ដូចជាការដឹកជញ្ជូនមេរោគីមីសម្លាប់សត្វល្អិត ស្បៀងអាហារ និងថ្នាំពេទ្យ) អាចមានប្រយោជន៍ គ្មានសាក្សីណាមួយផ្តល់នូវយោបល់ថាតើធ្វើដូចម្តេចទើបសហរដ្ឋអាមេរិកអាចផ្លាស់ប្តូរស្ថានការណ៍នៅកម្ពុជាជាដុំកំភួននោះទេ ហើយសាក្សីទាំងអស់ លើកលែងតែ បារ៉ុន បានជំទាស់ទៅនឹងការថ្កោលទោសជាសាធារណៈ ។ លោកប្រធានគណៈកម្មាធិការ ដូណាល់ ហ្វ្រាសឺ ថ្លែងទាំងក្តីខកចិត្តថា “អស់លោកគ្មានអនុសាសន៍ជាក់លាក់ចំពោះគោលនយោបាយរបស់សហរដ្ឋអាមេរិកដែលអាចដាក់ចេញជាមធ្យោបាយធ្វើឲ្យប្រសើរឡើងឬជំរុញឲ្យមានលក្ខណៈសមស្របនៅក្នុងរបបនោះ” ។

ចម្លើយកសិណសាក្សីទាំងបួនរូបបានធ្វើឲ្យតំណាងពលរដ្ឋស្ទីវិន សូឡាស ញាប់ញ័រអារម្មណ៍ ។ ទោះបីជា សូឡាស ដែលក្លាយខ្លួនយ៉ាងឆាប់រហ័សជាថ្នាក់ដឹកនាំអាជ្ញាធរទាក់ទងនឹងបញ្ហាកម្ពុជានោះ បានយល់ស្របថា ការទម្លាក់គ្រាប់បែកមកលើប្រទេសកម្ពុជាគឺជាទង្វើ“គួរឲ្យស្អប់ខ្ពើមណាស់” ។ អ្វីដែលកើតឡើងនៅក្នុងប្រទេសកម្ពុជាពេលនោះគឺជា“បទឧក្រិដ្ឋមួយក្នុងចំណោមបទឧក្រិដ្ឋនានាដែលមានលក្ខណៈធ្ងន់ធ្ងរបំផុតនៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ” ។ និយាយឲ្យចំ “គឺជាការប្រកាន់ពូជសាសន៍តែម្តង” ។ លោកបានបន្តទៀតថា ប្រសិនបើជនរងគ្រោះជាជនជាតិស្បែកស សហរដ្ឋអាមេរិកនឹងមិននិយាយអំពី“ការបញ្ជូនមេរោគីមី

សម្លាប់សត្វល្អិតទៅឲ្យប្រទេសដែលខ្លួនប្រមាថមើលងាយ» ដើម្បីធ្វើឲ្យសភាពការណ៍ប្រសើរឡើងនោះឡើយ ។ សូឡាស គិតថាស្ថានការណ៍នេះគួរឲ្យខ្មាចនិងមិនដែលមានពីមុនមកសោះដែលតម្រូវឲ្យ«មានការឆ្លើយតបពិសេសនិងប្រហែលជាការឆ្លើយតបវិសាមញ្ញពីយើងទៀតផង» ។

ការពិតចេញពីសវនាការនេះបង្ហាញឲ្យឃើញថា រដ្ឋការប្រធានាធិបតី ជីមមី មិនបានផ្តល់ភាពជាអ្នកដឹកនាំឆ្លើយតបទៅនឹងហាយនភាពកម្ពុជាទេ ហើយនៅខែកក្កដា គណៈកម្មាធិការកិច្ចការអន្តរជាតិក៏បានស្តាប់នូវសម្តីរបស់ជំនួយការរដ្ឋមន្ត្រីការបរទេសទទួលបន្ទុកកិច្ចការអាស៊ីបូព៌ានិងអាស៊ីប៉ាស៊ីហ្វិក គឺ រីឆាត ហូលប្រ៊ុក និងមន្ត្រីការបរទេសដែលចេះនិយាយភាសាខ្មែរ ឆាល ថ្វាញទីង ដែលបានឃ្លាំមើលសភាពការណ៍កម្ពុជាពីទីក្រុងបាងកក ។ លោកទាំងពីរបានលើកឡើងអំពីបទល្មើសរំលោភសិទ្ធិមនុស្សជាក់ស្តែងពីសំណាក់របបកម្ពុជាប្រជាធិបតេយ្យក្នុងនោះរួមមានការសម្លាប់ជាប្រព័ន្ធដែលមានចំនួនកើនឡើងរហូតដល់រាប់សែននាក់ ។ មានប្រជាជនជាច្រើនទៀតស្លាប់ដោយធ្វើការបាក់កម្លាំង អត់អាហារ ឬជំងឺតម្កាត់ ។ ប៉ុន្តែទាំង ហូលប្រ៊ុក ទាំង ថ្វាយទីង មិន បានគិតថាសហរដ្ឋអាមេរិកត្រូវខិតខំកែប្រែសភាពការណ៍នេះឡើយ ។ ថ្វាញទីង កត់សម្គាល់ថា«ខ្ញុំមិនប្រាកដក្នុងចិត្តថា តើមេដឹកនាំកម្ពុជាសើចចំអកដែរឬទេចំពោះអ្វីដែលយើងឬអ្នកផ្សេងទៀតដែលត្រូវនិយាយអំពីបញ្ហារំលោភសិទ្ធិមនុស្ស» ។ ថ្វាញទីង ឆ្លល់ថា សូម្បីតែចិនដែលបានផ្តល់ឲ្យខ្មែរក្រហមនូវការគាំទ្រខាងការទូត បច្ចេកទេស និងសម្ភារៈនានាក៏មិនអាចផ្លាស់ប្តូរ ការប្រព្រឹត្តរបស់ខ្មែរក្រហមដែរ ។ នៅចុងបញ្ចប់ ដោយកត់សម្គាល់អំពី «អាទិភាពខ្ពស់»របស់រដ្ឋការប្រធានាធិបតី ជីមមី ទៅលើ «លក្ខខណ្ឌសិទ្ធិមនុស្សនៅជុំវិញពិភពលោក» នោះបានអនុម័តនូវសេចក្តីសម្រេចមួយជំទាស់ទៅនឹងអំពើឃោរឃៅរបស់ខ្មែរក្រហម ហើយជំរុញឲ្យរដ្ឋការប្រធានាធិបតី ជីមមី ធ្វើការជាមួយប្រជាជាតិផ្សេងៗទៀតដើម្បីព្យាយាមនាំមកនូវការបញ្ចប់«បទល្មើសជាក់ស្តែងនៃការរំលោភទៅលើសិទ្ធិមនុស្សដែលទទួលស្គាល់ជាអន្តរជាតិនៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន» ប៉ុន្តែមានចំណាត់ការតិចតួចបំផុត ។

នៅចុងឆ្នាំ១៩៧៧ ប្រហែលជាការឆ្លើយតបទៅនឹងសម្ពាធដែលចេះតែកើនឡើងទៅលើរដ្ឋការប្រធានាធិបតី ជីមមី បានជារដ្ឋការនេះចាប់អារម្មណ៍ខ្លាំងជាងមុន ។ នៅចុងឆ្នាំ១៩៧៧ ឬដើមឆ្នាំ១៩៧៨ បុគ្គលិកក្រុមប្រឹក្សាសន្តិសុខជាតិបានពិនិត្យមើលសភាពការណ៍នៅកម្ពុជា ដែលធ្វើឲ្យទីប្រឹក្សាសន្តិសុខជាតិ ឈ្មោះ ប៊ីនីវ ហ្សេហ្ស៊ីនស្គី អំពាវនាវឲ្យមានជំហររបស់អាមេរិកកាន់តែក្តៅជាងមុន ។ លោកមានប្រសាសន៍ថា សហរដ្ឋអាមេរិក«គួរតែធ្វើការឲ្យច្រើនជាងនេះ ដើម្បីទាញការយកចិត្តទុកដាក់ទៅលើការរំលោភសិទ្ធិមនុស្សនៅកម្ពុជា និងធ្វើឲ្យមានការថ្កោលទោសជាអន្តរជាតិ»ចំពោះរដ្ឋាភិបាលកម្ពុជា ។ នៅថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៧៨ រដ្ឋមន្ត្រីការបរទេសស៊ីរ៉ូស វ៉ាន់ស គ្រីស្តូហ្វ័រ បានលើកឡើងនូវការថ្កោលទោសម្តងទៀតរបស់អាមេរិកចំពោះកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែជាថ្មីម្តងទៀត ក្រសួងការបរទេសទទួលថាខ្លួនគ្មាន«អានុភាពជះឥទ្ធិពលទៅលើស្ថានការណ៍សិទ្ធិមនុស្សក្នុងប្រទេសកម្ពុជាទេ» ។

ការសម្តែងមតិដែលគ្មានពលានុភាពបែបនេះមិនបានកាត់បន្ថយការរិះគន់ឡើយ ។ ជាក់ស្តែង នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៧៨ សូឡាស បានសរសេរលិខិតដោយផ្ទាល់ទៅប្រធានាធិបតី ដោយថ្កោលទោសចំពោះការរំលោភសិទ្ធិមនុស្សជាក់ស្តែង ហើយ ជីមមី










ក៏បានបញ្ជាឲ្យមានការរៀបចំការថ្កោលទោសដ៏ខ្លាំងមួយចំពោះរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែសេចក្តីព្រាងនៃសេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេសសហរដ្ឋអាមេរិកមិនគ្រប់គ្រាន់ទេ ។ សេចក្តីព្រាងនេះផ្តោតទៅលើជនភៀសខ្លួននៅជ្រោយឥណ្ឌូចិន ហើយ មិនបានបែងចែកឲ្យបានច្បាស់ថាតើវៀតណាម ឡាវ ឬកម្ពុជា ជាអ្នកបង្កើតឲ្យមានជនភៀសខ្លួនទាំងនេះ ។ «ដើម្បីឲ្យស្មើភាព» សេចក្តីព្រាងបានបញ្ចូលការថ្កោលទោសដល់ការអនុវត្តសិទ្ធិមនុស្សនៅប្រទេសវៀតណាមនិងឡាវ(ដែលពិបាកនឹងប្រៀបធៀបជាមួយនឹងវិធានការឃោរឃៅនៅក្នុងប្រទេសកម្ពុជា) ។ កម្ពុជាត្រូវបានអ្នកផងនិយាយថា«ស្ថិតក្នុងចំណោមប្រទេសរំលោភសិទ្ធិមនុស្សខ្លាំងបំផុតនៅលើពិភពលោកនាពេលនោះ» ។

បុគ្គលិករបស់ក្រុមប្រឹក្សាសន្តិសុខបានសរសេរសេចក្តីថ្លែងការណ៍ជាថ្មីដោយលុបចោលនូវមតិយោបល់«ដែលធ្វើឲ្យមានតុល្យភាព»ទៅលើការរំលោភសិទ្ធិមនុស្សនៅវៀតណាមនិងឡាវ ប៉ុន្តែនៅតែចាប់ផ្តើមឡើងដោយសរសេរថា«ចាប់តាំងពីឆ្នាំ១៩៧៥ ជាង១ភាគ៣ក្នុងចំណោមប្រជាជន១លាននាក់នៅក្នុងប្រទេសកម្ពុជា ឡាវ និងវៀតណាម បានចាកចោលស្រុកកំណើតរបស់ខ្លួន» ។ ប៊ីនីវ ហ្សេហ្ស៊ីនគី ចាត់ទុកការសរសេរឡើងវិញរបស់បុគ្គលិកក្រុមប្រឹក្សាសន្តិសុខជាតិថា«មានលក្ខណៈខ្វះមុខពេក» ហើយក៏បានសរសេរសាជាថ្មីដោយខ្លួនលោកផ្ទាល់ ។ ជាជំនួស»ការបាត់បង់សេរីភាពនយោបាយនិងសេដ្ឋកិច្ចជាមូលដ្ឋាន»របស់ប្រជាជនដែលរត់ចោលលំនៅឋាន ទីប្រឹក្សាសន្តិសុខជាតិជំនួសវិញដោយពាក្យ«មនុស្សឃាតទ្រង់ទ្រាយធំ» ។ ជាជំនួសនឹងពាក្យរដ្ឋាភិបាលកម្ពុជាដែល«ស្ថិតនៅក្នុងចំណោមប្រទេសដែលរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរនៅលើពិភពលោក» កម្ពុជាប្រជាធិបតេយ្យត្រូវបានសរសេរមកត្រឹម«អ្នករំលោភសិទ្ធិមនុស្សខ្លាំងជាងគេនៅលើពិភពលោក» ។ ប្តូរពីរដ្ឋាភិបាល«បង្កនូវសេចក្តីលំបាកវេទនាមិនអាចប្រៀបបាន»មកត្រឹម«ត្រូវបានចោទប្រកាន់(ដោយផ្អែកលើរបាយការណ៍នានា) ថាបង្កឲ្យមនុស្សស្លាប់រាប់សែននាក់» ហើយប្រហែលជា១លានឬ២លាននាក់ដោយសារ«គោលនយោបាយប្រល័យពូជសាសន៍ដោយគ្មានអ្វីប្រៀបប្រដូចចាប់តាំងពីពេលដែលពួកណាហ្ស៊ីសម្លាប់រង្គាលជនជាតិជ្វីហ្វមក» ។

ដោយសារហេតុផលផ្សេងៗដែលមិនទាន់មានលក្ខណៈច្បាស់លាស់នៅឡើយ អត្ថបទចុងក្រោយបំផុតដែលចេញផ្សាយនៅថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៨ គឺមិនសូវមានទម្ងន់ប៉ុន្មានទេ ។ ការនិយាយយោងដល់ប្រទេសនានាក្រៅពីកម្ពុជាត្រូវបានកាត់ចេញ ហើយការថ្កោលទោសទៅលើប្រទេសកម្ពុជាថាជា«អ្នករំលោភសិទ្ធិមនុស្សជាងគេនៅក្នុងពិភពលោក»នៅទុករក្សាដដែល ។ ជនភៀសខ្លួនដែលត្រូវបាននិយាយថា«ស្លាប់រហូតដល់រាប់សែននាក់»នោះក៏ទុកនៅដដែល ប៉ុន្តែការចោទប្រកាន់ថា ប្រជាជនពី១លានទៅ២លាននាក់បានបាត់បង់ជីវិត ដោយសារនយោបាយប្រល័យពូជសាសន៍ត្រូវបានដកចេញ ។ ពាក្យថា«អំពើប្រល័យពូជសាសន៍»នៅទុកដដែលនៅផ្នែកបន្តបន្ទាប់មកទៀត ដែលជាការទាក់ទាញចំណាប់អារម្មណ៍ឲ្យមានសេចក្តីសម្រេចថ្មីៗរបស់សភាតំណាងរាស្ត្រកាណាដាដែលថ្កោលទោស«អំពើប្រល័យពូជសាសន៍»នៅកម្ពុជា ។ ជីមមី ខាតធ័រ សន្យាថានឹងគាំទ្រ«ការទាមទាររបស់អន្តរជាតិដែលចេះតែកើនឡើង»ប្រឆាំងនឹងកម្ពុជាប្រជាធិបតេយ្យកត់សម្គាល់អំពីការបើកសវនាការរបស់គណៈកម្មាធិការប្រទេសន័រវេ៉ ក៏ដូចជាសេចក្តីអំពាវនាវរបស់អង្គការអាមណាស់ស្ទីអ៊ីនធឺណាស់ស្យូណាល់ និងសេចក្តីសម្រេចរបស់គណៈកម្មការសិទ្ធិមនុស្សអន្តរជាតិសុំឲ្យរដ្ឋាភិបាលកម្ពុជាឆ្លើយតបទៅនឹងការចោទប្រកាន់នានាប្រឆាំងនឹងខ្លួន ។

ទោះជាស្ថិតក្នុងលក្ខណៈជាអត្ថបទដែលមិនសូវមានទម្ងន់ក៏ដោយ ការថ្កោលទោសទៅលើកម្ពុជាធ្វើឲ្យប្រធានាធិបតីទទួលបានការអបអរជាច្រើនពីមជ្ឈដ្ឋានអង្គការសិទ្ធិមនុស្សនិងប្រជាពលរដ្ឋទូទៅ ។ មិនយូរប៉ុន្មាន ជីមមី ខាតធ័រ បានសុំឲ្យមានអនុសាសន៍ចំពោះ«ចំណាត់វិធានការបន្ថែមដែលអាចជំរុញឲ្យរដ្ឋាភិបាលកម្ពុជាលើកកម្ពស់ការគោរពសិទ្ធិមនុស្សនៅក្នុងប្រទេសខ្លួន» ក៏ប៉ុន្តែមិនបានប៉ុន្មានការយកចិត្តទុកដាក់ក៏ងាកទៅរកជនភៀសខ្លួនដែលបានរួចពីកម្ពុជាទៅស្នាក់នៅប្រទេសថៃវិញ ។ (ជាក់ស្តែងគ្មានការចាប់អារម្មណ៍ទៅលើជនភៀសខ្លួនរាប់សែននាក់ដែលវៀតណាមកំពុងតែថែទាំនោះទេ) ។ សភាអាមេរិកក៏នាំមុខម្តងទៀតនៅក្នុងសភាទាំងពីរថ្នាក់ ក្នុងការរៀបចំអនុម័តសេចក្តីសម្រេចដែលថាជនភៀសសឹកចំនួនមួយម៉ឺនប្រាំពាន់នាក់ ត្រូវតែ

ទទួលការអនុញ្ញាតឲ្យមកតាំងទីលំនៅថ្មីនៅសហរដ្ឋអាមេរិក ។ នៅឆ្នាំ១៩៧៨ សេចក្ដីស្នើច្បាប់របស់ ដូឡាស់ ដែលធ្វើឲ្យមានការអនុញ្ញាតតាមផ្លូវច្បាប់នោះបានមកដល់សហសភាអាមេរិក ។

ប៉ុន្ដែច្បាប់ស្ដីអំពីជនភៀសខ្លួនមិនបានដោះស្រាយបញ្ហាប្រជាជនកម្ពុជារាប់លាននាក់ដែលកំពុងរស់នៅក្នុងប្រទេសកម្ពុជាក្រោមរបបគ្រប់គ្រងរបស់ខ្មែរក្រហមនោះទេ ។ ទោះបីជាមានអ្នកខ្លះដូចជា សមាជិកព្រឹទ្ធសភា ចច មែកហ្គាវើន ជាដើម អំពាវនាវឲ្យមានការធ្វើអន្ដរាគមន៍ប្រដាប់អាវុធក្នុងការបញ្ចប់សេចក្ដីឈឺចាប់នៅក្នុងប្រទេសកម្ពុជាក្ដី មនុស្សជាច្រើនទៀតដែលចង់បានចំណាត់វិធានការខ្លាំងជាងនេះជឿជាក់ថា សហរដ្ឋអាមេរិកគួរតែបញ្ចុះបញ្ចូលសាធារណរដ្ឋប្រជាមានិតចិនដែលជាសម្ព័ន្ធមិត្តតែមួយគត់របស់ខ្មែរក្រហមឲ្យបញ្ចប់នូវការគ្រប់គ្រងអំណាចពោរពេញទៅដោយភេរវកម្មនេះតទៅទៀត ។ នៅឆ្នាំ១៩៧៨ ចំណុចនេះហាក់ដូចជាកាន់តែមានលក្ខណៈច្បាស់ជាងឆ្នាំមុន ពីព្រោះរដ្ឋការប្រធានាធិបតី ជីមមី ខាតធ័រ សង្ឃឹមថានឹងបើកឡើងវិញនូវទំនាក់ទំនងការទូតដ៏ពេញលេញជាមួយសាធារណរដ្ឋប្រជាមានិតចិន ។ មិត្តភក្ដិរបស់ ប៊ីនីវ ហ្សេហ្ស៊ីនគី នៅមជ្ឈមណ្ឌលសិក្សាអំពីយុទ្ធសាស្ត្រនិងកិច្ចការអន្ដរជាតិនៅសាកលវិទ្យាល័យចចថោនសរសេរថា“សង្ឃឹមថាលោកមាន(ឬនឹងមាន) ឱកាសក្នុងការនិយាយទៅកាន់សាធារណរដ្ឋប្រជាមានិតចិនអំពីឥទ្ធិពលជុំវិញពិភពលោកដោយសារទង្វើរបស់ខ្មែរក្រហម” ។ “ជាការពិតគឺគេចង់សម្របសម្រួលបញ្ហានេះ” ។

ជីមមី ខាតធ័រ បានណែនាំដល់ ប៊ីនីវ ហ្សេហ្ស៊ីនគី ឲ្យអានសេចក្ដីថ្លែងការណ៍ចុះថ្ងៃទី២១ ខែមេសា ដែលថ្កោលទោសកម្ពុជាប្រជាធិបតេយ្យចំពោះមុខចិនដែលទីប្រឹក្សាសន្ដិសុខជាតិបានធ្វើនៅខែឧសភា ប៉ុន្ដែជាថ្មីម្ដងទៀតវាជាគំនិតរបស់សភាដែលជំរុញឲ្យមានចំណាត់ការខ្លាំងជាងមុន ។ នៅខែ កក្កដា ឆ្នាំ១៩៧៨ ក្រុមមួយដែលមានពីរបក្សនិងមានចំនួន១៧រូបនៅក្នុងសភាតំណាងពលរដ្ឋបានជំរុញឲ្យ ជីមមី ខាតធ័រ ធ្វើឲ្យកម្ពុជាក្លាយជាផ្នែកមួយនៃការពិភាក្សាក្នុងគោលបំណងធ្វើឲ្យមានទំនាក់ទំនងប្រក្រតីជាមួយប្រទេសចិន ។ សមាជិកតំណាងប្រជាពលរដ្ឋបានប្រាប់ ជីមមី ខាតធ័រ ថា “តាមវិធីផ្សេងៗ យើងបានបង្ហាញដល់ចិននូវឆន្ទៈរបស់យើងក្នុងស្មារតីសហប្រតិបត្តិការដើម្បីកាត់បន្ថយភាពតានតឹងដែលយាយីដល់ផ្នែកការទូតនៃពិភពលោក” ។ “វាក៏ជាការសមហេតុផលដែរថា ចិនខ្លួនឯងផ្ទាល់បានខិតខំប្រឹងប្រែងជាក់ស្ដែងដើម្បីបង្ហាញប្រាប់ជនជាតិអាមេរិកាំងថាចិននឹងធ្វើកិច្ចសហប្រតិបត្តិការដែរ ។ កម្ពុជាផ្ដល់នូវផ្នែកមួយច្បាស់បំផុតសម្រាប់បង្ហាញជំហរបែបនេះ ហើយជាវិធីមួយដែលរដ្ឋាភិបាលរបស់យើងអាចទទួលបាននូវផ្លែផ្កាដើម្បីឈានទៅកាត់បន្ថយទុក្ខវេទនាដ៏គួរឲ្យរន្ធត់មកលើប្រជាជនកម្ពុជា” ។ ការឆ្លើយតបរបស់ ប៊ីនីវ ហ្សេហ្ស៊ីនគី ពិតជាមានសារសំខាន់ ។ លោកថ្លែងថា លោកបានលើកបញ្ហាកម្ពុជាជាមួយចិន ប៉ុន្ដែមិនបាននិយាយអំពីការបញ្ចូលកម្ពុជាឲ្យចូលក្នុងកិច្ចចរចានានាដើម្បីបង្កើតនូវទំនាក់ទំនងការទូតពេញលេញឡើយ ។ ក្រសួងការបរទេសសហរដ្ឋអាមេរិកបានពន្យល់អំពីមូលហេតុនេះ ។ ជំនួយការរដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក ឌូក្លាស បេណេត បានសរសេរទៅសមាជិកសភាតំណាងប្រជាពលរដ្ឋអាមេរិកកាំងថា “យើងជឿ...វាជាកំហុសដ៏ធ្ងន់មួយក្នុងការបញ្ចូលការរំលោភសិទ្ធិមនុស្សនៅកម្ពុជាចូលទៅក្នុងការចរចាទ្វេភាគីអំពីប្រក្រតីភាពឡើងវិញរវាងសហរដ្ឋអាមេរិកនិងចិន នៅពេលអនាគត” ។ លោកបន្ដទៀតថា ការធ្វើដូចនេះនឹង“ធ្វើឲ្យបញ្ហាកាន់តែស្មុគស្មាញដោយគ្មានផលវិជ្ជមានដល់ស្ថានការណ៍នៅកម្ពុជាឡើយ” ។

ប៉ុន្ដែការដែលផ្ដល់អាទិភាពដំបូងទៅលើផលប្រយោជន៍ខាងនយោបាយភូមិសាស្ត្រដើម្បីឲ្យមានប្រក្រតីភាពនៃទំនាក់ទំនងធម្មតាជាមួយចិន បានកាត់បន្ថយការទទូចរបស់រដ្ឋការប្រធានាធិបតី ជីមមី ដែលការព្រួយបារម្ភអំពីបញ្ហាសិទ្ធិមនុស្សគឺជាកត្តាកំណត់នៅក្នុងគោលនយោបាយការបរទេសរបស់ខ្លួន ។ មនុស្សជាច្រើនយល់ថា គោលនយោបាយស្វែងរកប្រក្រតីភាពឡើងវិញនូវទំនាក់ទំនងជាមួយចិនដោយគ្មានអំពាវនាវដល់រដ្ឋាភិបាលរបស់ខ្លួនឲ្យដាក់សម្ពាធទៅលើខ្មែរក្រហម ហាក់ដូចជាមានលក្ខណៈលាក់ពុត ។ ចិនគឺជាប្រទេសតែមួយគត់នៅក្នុងពិភពលោកដែលប្រហែលជាអាចមានឥទ្ធិពលទៅលើរបបមួយដែល ជីមមី ខ្លួនលោកផ្ទាល់បានចោទប្រកាន់ថាជាប្រទេសរំលោភសិទ្ធិមនុស្សខ្លាំងបំផុតនៅលើពិភពលោក ។ ដោយសារមិនភ្ជាប់បញ្ហាទាំងពីរនេះជាមួយគ្នា គោលនយោបាយរបស់សហរដ្ឋអាមេរិកទំនងជាត្រូវបានគេគិតគូរផ្អែកនយោបាយជាមូលដ្ឋានសំខាន់ ជាពិសេស

បំណងប្រាថ្នាចង់លេងសន្ទឹកបៀចិននៅក្នុងសមរភូមិយុទ្ធសាស្ត្រជាមួយសហភាពសូវៀត ។

ការទប់ចិត្តមិនបានរបស់ ប៊ីនីវ ហ្សេហ្សុីនគី ជាមួយចិន ពេលខ្លះធ្វើឲ្យប្រធានាធិបតី ជីមមី មានបញ្ហា ។ លោកប្រធានាធិបតីបានសរសេរសង្ខេបនូវអត្ថបទរបស់ ប៊ីនីវ ហ្សេហ្សុីនគី ដែលគាំទ្រការពន្យារពេលធ្វើឲ្យមានប្រក្រតីភាពឡើងវិញជាមួយវៀតណាមៈ «លោកមាននិន្នាការទោរទន់ទៅលើកតម្កើងបញ្ហាសាធារណរដ្ឋប្រជាមានិតចិន» ប៉ុន្តែ ប៊ីនីវ ហ្សេហ្សុីនគី មិនផ្លាស់ប្តូរយោបល់ឡើយ ។ លោកចាត់ទុកការបង្កើតទំនាក់ទំនងការទូតជាមួយចិន ថាជាមហាជោគជ័យរបស់លោក ប៉ុន្តែវាមិនបានធ្វើឲ្យធូរស្បើយដល់កម្ពុជាផងទេ ។

ដំណើរធូរស្បើយសម្រាប់កម្ពុជាកើតឡើងនៅខែធ្នូ ឆ្នាំ ១៩៧៨ នៅពេលដែលកងទ័ពវៀតណាម (ជាមួយនឹងជនជាតិខ្មែរមួយចំនួនដែលរត់ចេញពីខ្មែរក្រហមហើយជ្រកកោននៅប្រទេសវៀតណាម) បានចូលមកដល់កម្ពុជា ហើយបានកម្ចាត់របបខ្មែរក្រហមចេញពីទីក្រុងភ្នំពេញ ។ មិនយូរប៉ុន្មាន ប៉ុល ពត បានគ្រប់គ្រងផ្នែកមួយនៃប្រទេសកម្ពុជាដែលស្ថិតនៅកៀកនឹងព្រំដែនថៃនិងជំរំជនភៀសខ្លួននៅក្នុងប្រទេសថៃ ។ វៀតណាមបានតែងតាំងឲ្យលោក ហេង សំរិន ធ្វើជានាយករដ្ឋមន្ត្រីថ្មីនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ ប៉ុន្មានខែក្រោយពីការចូលមកដល់នាយករដ្ឋមន្ត្រីវៀតណាម ផាម វ៉ាន់ដុង បាននិយាយទៅកាន់ជនជាតិអាមេរិកាំងមួយក្រុមដែលតំណាងឲ្យអង្គការ Church World Service ថាវៀតណាមធ្វើអ្វីៗកន្លងមកនេះគឺ «ដើម្បីសង្គ្រោះជាតិ...។ យើងបាននាំប្រជាជាតិកម្ពុជាឆ្លងផុតពីគ្រោះមរណៈ» ។ តាមការពិតគោលបំណងរបស់វៀតណាមមានលក្ខណៈស្មុគស្មាញណាស់ ប៉ុន្តែទោះជាយ៉ាងណាវៀតណាមបានបញ្ចប់នូវរបបវាលពិឃាតដែលគ្រប់គ្រងដោយខ្មែរក្រហមក៏ដោយ ។ ទោះជាកន្លងមកប្រជាជនកម្ពុជានិងវៀតណាមមានភាពមិនទុកចិត្តគ្នាជាប្រវត្តិសាស្ត្រក៏ដោយ ប៉ុន្តែពេលនេះសត្រូវសួរពូជបានក្លាយទៅជាអ្នករំដោះទៅវិញ ។

រដ្ឋការ ជីមមី មិនបានមើលតាមផ្លូវនេះទេ ។ ប៉ុន្មានខែមុនពេលដែលការឈ្លានពានរបស់អាមេរិកខិតជិតការធ្វើឲ្យមានប្រក្រតីភាពឡើងវិញជាមួយវៀតណាមនោះ វាបានធ្វើឲ្យ ប៊ីនីវ ហ្សេហ្សុីនគី បញ្ឈប់ដំណើរការនេះតែម្តង ។ លោកមានអារម្មណ៍ថា យកល្អគួរតែបន្តការចរចាអំពីបញ្ហាចិន ហើយការពិភាក្សាជាមួយវៀតណាមអាចធ្វើឲ្យបញ្ហាកាន់តែមានលក្ខណៈស្មុគស្មាញឡើង ។ ដូចនេះ នៅពេលដែលវៀតណាមឈ្លានពានកម្ពុជា សហរដ្ឋអាមេរិកថ្កោលទោសទង្វើនោះដោយផ្តល់ហេតុផលជាលក្ខណៈលាក់ពុត ថាជាគោលការណ៍ដែលខ្លួនមិនអាចអភ័យទោសឲ្យបុគ្គលគាំទ្រការប្រើកម្លាំងយោធាក្រៅទឹកដីរបស់ខ្លួនឡើយ ។

ចំពោះរដ្ឋការប្រធានាធិបតី ជីមមី ខាតធ័រ ជាពិសេស ប៊ីនីវ ហ្សេហ្សុីនគី សកម្មភាពរបស់វៀតណាមមានផលយាយីដល់ការពង្រីកឥទ្ធិពលរបស់សូវៀតនៅក្នុងភូមិភាគអាស៊ី-អាគ្នេយ៍ ។ របប ប៉ុល ពត គួរឲ្យស្អប់ណាស់ ប៉ុន្តែរបបនេះចងសម្ព័ន្ធភាពជាមួយចិនដែលសហរដ្ឋអាមេរិកគាំទ្រនៅអាស៊ីភាគអាគ្នេយ៍និងកន្លែងផ្សេងទៀត ។ ការដកកងទ័ពវៀតណាមចេញពីកម្ពុជាបានក្លាយជាគោលនយោបាយរបស់អាមេរិកយ៉ាងឆាប់បំផុត ។ ប៊ីនីវ ហ្សេហ្សុីនគី បានលើកឡើងនូវចំណុចមួយចំនួនសម្រាប់ឲ្យ ជីមមី ប្រើនៅពេលលោកជួបជាមួយអនុប្រធានាធិបតីចិន តេង ស៊ាវពីង នៅខែមករា ឆ្នាំ១៩៧៩«យើងត្រូវតែរក្សាសម្ងាធការទូត










ដើម្បីឲ្យវៀតណាមដកកងទ័ពចេញពីកម្ពុជា» ។

ការគិតគូរអំពីបញ្ហាការទូតបានប្រែទៅជាបញ្ហាកាន់តែស្មុគស្មាញយ៉ាងឆាប់រហ័ស ពីព្រោះនៅអំឡុងពេលទស្សនកិច្ចនៅទីក្រុងវ៉ាស៊ីនតោននៅចុងខែមករា តេង បានសួរ ជីមមី ថាសហរដ្ឋអាមេរិកត្រូវឆ្លើយតបយ៉ាងដូចម្តេចចំពោះ «វាយប្រហារជាលក្ខណៈទណ្ឌកម្មទៅលើវៀតណាម» ។ ប៊ីនីវ ហ្សេហ្សុីនគី បានរំពឹងទុកថានឹងមានបញ្ហានេះកើតឡើង ហើយមានការព្រួយបារម្ភថា ជីមមី នឹងត្រូវបញ្ចុះបញ្ចូលឲ្យ«ដាក់សម្ពាធជាអតិបរមាទៅលើចិនកុំឲ្យប្រើកម្លាំង» ប៉ុន្តែការឆ្លើយតបរបស់ ជីមមី អាចទទួលយកបានយ៉ាងពេញទំហឹងដោយ ប៊ីនីវ ហ្សេហ្សុីនគី ។ ជីមមី បាន ជំទាស់ជំហាននេះ ហើយជម្រាបទៅ តេង ស៊ាវភីង ជាបុគ្គលថា ការចាត់វិធានការបែបនេះមានគុណវិបត្តិច្រើន ។ «ខ្ញុំជំរុញឲ្យលោកកុំយល់ព្រមចំពោះបញ្ហានេះ» ប៉ុន្តែ ប៊ីនីវ ហ្សេហ្សុីនគី មានប្រសាន៍ថា សំបុត្ររបស់ជីមមី ផ្ញើទៅ តេង ស៊ាវពីង «មិនបានបញ្ឈប់សហរដ្ឋអាមេរិកឲ្យប្រកាន់ជំហរមួយដែលអាចដាក់សម្ពាធក្រោយមកទៀតក្នុងការថ្កោលទោសចិននៅអង្គការសហប្រជាជាតិឡើយ» ។

មិនយូរប៉ុន្មាន ចិនបានដាក់ពង្រាយកងទ័ពចំនួន១៧ម៉ឺននាក់និងយន្តហោះប្រយុទ្ធជាច្រើនគ្រឿងនៅតាមព្រំដែនវៀតណាម ។ ឆ្លើយនឹងសំណួរ«ដ៏ស៊ីជម្រៅមួយ»របស់អ្នកសារព័ត៌មានថាតើហេតុអ្វីបានជាមានកងទ័ពចិននៅទីនោះ ប៊ីនីវ ហ្សេហ្សុីនគី បានត្រឹមតែឆ្លើយថា«ជំហររបស់យើងគឺថា យើងរួមមតិគ្នាថាវៀតណាមគឺជាអ្នកឈ្លានពាន» ។ នៅពេលសួរថាតើចិនក៏ជាអ្នកឈ្លានពានដែរឬប្រសិនបើខ្លួនវាយប្រហារទៅលើវៀតណាម ប៊ីនីវ ហ្សេហ្សុីនគី បដិសេធមិនប្រកាន់យកជំហរណាមួយដោយមូលហេតុថាបញ្ហានេះមានលក្ខណៈមិនប្រាកដប្រជានៅឡើយ ពោលគឺវាគ្រាន់តែជាសម្មតិកម្មប៉ុណ្ណោះ ។

ដោយមានអារម្មណ៍ថាខ្លួនមានសម្ពាធតិចតួចពីសហរដ្ឋអាមេរិក កងទ័ពចិនបានចូលលុកលុយវៀតណាមនៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៧៩ ។ នៅត្រង់ចំណុចនេះ ជីមមី មានសមានចិត្តចំពោះចិន ពីព្រោះនៅថ្ងៃដែលបើកការវាយលុកចូលប្រទេសវៀតណាម ជីមមី បានជម្រាបក្រុមប្រឹក្សាសន្តិសុខជាតិថា «សូវៀតនៅពីក្រោយខ្នង...នៃការវាយលុករបស់វៀតណាមចូលទឹកដីកម្ពុជា ប្រការនេះផ្តល់ជម្រើសតិចតួចណាស់ដល់ចិនគឺគ្មានជម្រើសអ្វីក្រៅពីឈ្លានពានវៀតណាមទេ» ។ ការណ៍នេះគឺជាចំណុចស្នូលនៃទស្សនៈរបស់អាមេរិកទៅលើជ្រោយឥណ្ឌូចិន ។ ដូចដែលមន្ត្រីមួយរូបលើកឡើងថា«ការឈ្លានពានរបស់វៀតណាមមកលើទឹកដីកម្ពុជាគឺជាដើមហេតុនៃភាពគ្មានតឹងក្នុងតំបន់» ។

ស្ថិតក្នុងបរិយាកាសបែបនេះ វាស្ទើរតែគ្មានគំនិតគិតអំពីថាតើអ្វីទៅជាការល្អបំផុតសម្រាប់ប្រជាជនកម្ពុជា ពោលគឺអ្នកដែលបានទទួលការឈឺចាប់ធ្ងន់ធ្ងរក្រោមរបបខ្មែរក្រហម និងដែលបានរួចចាកផុតអំពីការឈឺចាប់នេះ ។ គ្មានអ្វីមកបញ្ជាក់ថារដ្ឋការប្រធានាធិបតី ជីមមី បានផ្តល់នូវការគិតគូរធ្វើយ៉ាងណាកុំឲ្យ ប៉ុល ពត ត្រឡប់មកកាន់អំណាចឃោរឃៅបន្តទៅទៀតឡើយ ។ តើអ្វីនឹងអាចកើតឡើងចំពោះប្រជាជនកម្ពុជាប្រសិនបើវៀតណាមដកកងទ័ពចេញពីប្រទេសកម្ពុជា? បញ្ហានេះមិនបានលើកឡើងទេ ។ ផ្ទុយទៅវិញអ្វីៗគ្រប់យ៉ាងត្រូវបានពិនិត្យតាមទស្សនៈនយោបាយភូមិសាស្ត្រទាំងអស់ ។

ផ្តើមចេញពីទស្សនៈនេះ ប្រការដែលថាកងទ័ព ប៉ុល ពត មិនត្រូវបានកម្ទេចឲ្យអស់នោះ បានធ្វើឲ្យរដ្ឋការប្រធានាធិបតី ជីមមី ត្រេកអរជាខ្លាំង ។ ជីមមី និយាយជាមួយ តេង ស៊ាវពីង ថា មូលហេតុមួយកុំឲ្យចិនវាយលុកចូលទឹកដីវៀតណាមនោះគឺថា«ប្រជាជនកម្ពុជាហាក់ដូចជាកំពុងតែធ្វើបានប្រសើរជាងអ្វីដែលបានរំពឹងទុកក្នុងឋានៈជាទ័ពព្រៃ» ។ ចំណែកនៅឯកិច្ចប្រជុំមួយរបស់គណៈកម្មាធិការសម្របសម្រួលពិសេសប្រព្រឹត្តទៅនៅថ្ងៃទី១៨ ខែកុម្ភៈ នាយក សេ.អ៊ី.អា ស្តែនហ្វៀល ធឺន័រ បានមានប្រសាសន៍ឆ្លើយតបទៅនឹងសំណួររបស់ ប៊ីនីវ ហ្សេហ្សុីនគី ថា «គ្មានដំណើរថយក្រោយដែលថាកងទ័ព ប៉ុល ពត អាចធ្វើការដោយខ្លួនឯងបានទេ» ។ ជាការសន្មត ចំណុចនេះធ្វើឲ្យទីប្រឹក្សាសន្តិសុខជាតិរីករាយមិនខាន ។ ទោះជាយ៉ាងណាក៏ដោយ ប៊ីនីវ ហ្សេហ្សុីនគី លែងគិតថាគ្មានអ្វីដែលជ្រៀតចូលទៅក្នុងទំនាក់ទំនងថ្មីដែលលោកបានបង្កើតជាមួយចិននោះហើយ ។

ជាថ្មីម្តងទៀត អាស្រ័យតែលើសភាតែប៉ុណ្ណោះក្នុងការព្យាយាមនិងដាក់វិធានការជួសមុខឲ្យប្រជាជនកម្ពុជា ។ នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៩ សូឡាស ព្រមទាំងសមាជិកសភា៨រូបផ្សេងទៀត បានអំពាវនាវឲ្យរដ្ឋការប្រធានាធិបតី ជីមមី ខាតធ័រ

ដោះស្រាយបញ្ហានៃការអាចនឹងវិលត្រឡប់មកកាន់អំណាចរបស់ខ្មែរក្រហមវិញ ។ សមាជិកសភាទាំងនោះបានសរសេរទៅកាន់ប្រធានាធិបតីសហរដ្ឋអាមេរិកថា ជំហររបស់អាមេរិកក្នុងការជំរុញឲ្យមានការដកកងទ័ពវៀតណាមចេញពីកម្ពុជាមានលក្ខណៈមិនគ្រប់គ្រាន់ទេ ។ បើទោះជាការដកថយនេះជាការប្រាថ្នាចង់បានក៏ដោយ "ភាពចាំបាច់ក្នុងការទប់ស្កាត់ការស្តារឡើងវិញនូវរបប ប៉ុល ពត នៅក្នុងប្រទេសកម្ពុជាហាក់ដូចជាត្រូវបានរដ្ឋការនេះមើលរំលង" ។ ប្រសិនបើវៀតណាមដកថយពីកម្ពុជាដោយគ្មានកម្លាំងអន្តរជាតិអមទេ "របប ប៉ុល ពត" នឹងលេចជារូបរាងឡើងវិញនៅក្នុងទីក្រុងភ្នំពេញ ហើយការឈឺចាប់របស់ប្រជាជនកម្ពុជានឹងបន្តទៅមុខទៀត ព្រមទាំងបង្កឲ្យមានអសន្តិសុខនៅក្នុងតំបន់ទៀតផង ។ សមាជិកសភាទាំងនោះសរសេរថា ជាជាងគ្រាន់តែថ្កោលទោសវៀតណាម រដ្ឋការអាមេរិកគួរតែលះបង់ថាមពលរបស់ខ្លួនធ្វើឲ្យមហាអំណាចទទួលយកនូវកម្លាំងអន្តរជាតិមួយសម្រាប់ជំនួសវៀតណាមនៅក្នុងប្រទេសកម្ពុជា និងការពារការវិលត្រឡប់មកកាន់អំណាចសាជាថ្មីរបស់ ប៉ុល ពត ។

រដ្ឋការប្រធានាធិបតី ជីមមី បានឆ្លើយតបវិញថា សំបុត្រនោះ "ផ្ទុកទៅដោយធាតុផ្សំច្រើនដែលយើងកំពុងតែស្រាវជ្រាវឲ្យចេញជាដំណោះស្រាយមួយ" ហើយប្រហែលជាថា វ៉ាន បានសួរចិនហើយថាតើគេគួរតែគាំទ្រដល់សន្និសីទអន្តរជាតិមួយស្តីអំពីបញ្ហាកម្ពុជាឬទេ ប៉ុន្តែមានភស្តុតាងតិចតួចណាស់បញ្ជាក់ថារដ្ឋការ ជីមមី បានលះបង់ថាមពលក្នុងការព្យាយាមកុំឲ្យខ្មែរក្រហមវិលត្រឡប់មកកាន់អំណាចវិញ ។ ជាក់ស្តែងនៅថ្ងៃទី១ ខែមីនា ឆ្នាំ១៩៧៩ នៅចំពោះមុខអនុគណៈកម្មាធិការទទួលបន្ទុកកិច្ចការអាស៊ីនិងប៉ាស៊ីហ្វិក, ហូលប្រ៊ុក បានអំពាវនាវឲ្យវៀតណាមដកកងទ័ពចេញពីកម្ពុជា ប៉ុន្តែមិនបាននិយាយអំពីវិធីធ្វើយ៉ាងដូចម្តេចដើម្បីទប់ស្កាត់កុំឲ្យខ្មែរក្រហមវិលត្រឡប់មកកាន់អំណាចវិញនោះទេ ។ សូឡាស ត្រូវបានចាត់ឲ្យនិយាយបញ្ជាក់ថារដ្ឋការប្រធានាធិបតី ជីមមី គ្មានផែនការទប់ស្កាត់ ប៉ុល ពត កុំឲ្យមកកាន់អំណាចក្រោយពីវៀតណាមចាកចេញពីកម្ពុជាទេ ។ គោលបំណងដ៏ធំរបស់រដ្ឋការប្រធានាធិបតី ជីមមី គឺធ្វើឲ្យវៀតណាមដកចេញពីកម្ពុជា ពីព្រោះនៅក្នុងទស្សនៈរបស់រដ្ឋការប្រធាធិបតី ជីមមី វត្តមានរបស់វៀតណាមនៅកម្ពុជានិងរបបដែលវៀតណាមចាត់តាំងនិងគាំទ្រ គឺជាការចំណេញឥទ្ធិពលសម្រាប់សូវៀតនៅក្នុងតំបន់ និងប៉ះពាល់ដល់ផលប្រយោជន៍របស់ចិនទៅវិញ ។ ផ្តើមចេញពីទស្សនៈនេះ ការទុកឲ្យកងទ័ព ប៉ុល ពត នៅក្នុងព្រៃដើម្បីប្រយុទ្ធប្រឆាំងជាមួយវៀតណាម គឺជាផលប្រយោជន៍របស់រដ្ឋការអាមេរិក ទោះជាការគាំទ្រខ្មែរក្រហមដែលជនប្រល័យពូជសាសន៍នៅអាស៊ី-អាគ្នេយ៍នេះជាការអាម៉ាស់ក៏ដោយចុះ ។ ផលប្រយោជន៍របស់ប្រជាជនកម្ពុជាទូទៅត្រូវរដ្ឋការរបស់លោកយកចិត្តទុកដាក់តិចតួចបំផុត ។

បន្តិចក្រោយមកមានការផ្តោតការយកចិត្តទុកដាក់ចំពោះជនភៀសខ្លួនឥណ្ឌូចិនរាប់សែននាក់ ។ ប្រជាជនកម្ពុជារាប់ពាន់នាក់រត់ភៀសខ្លួនទៅប្រទេសថៃដើម្បីគេចពីខ្មែរក្រហមនិងចម្បាំងដែលបន្តកើតមានមិនចេះដាច់នៅក្នុងប្រទេសកម្ពុជា ប៉ុន្តែស្ថានការណ៍ជនភៀសខ្លួននៅលើឆាកអន្តរជាតិមានលក្ខណៈស្មុគស្មាញដោយសារការហូរចូលដ៏សន្ធឹកសន្ធាប់នៃជនភៀសខ្លួនតាមទូកមកពីវៀតណាម ។ ការហូរចូលប្រជាជនតាមទូកមកពីវៀតណាមបែបនេះ ធ្វើឲ្យរដ្ឋាភិបាលវៀតណាមអាម៉ាស់មុខ ។ ជួនកាល ប្រជាជនទាំងនេះត្រជាបត្រជួសស្ទើរស្លាប់ស្ទើររស់ក្រោយពីឃ្លានៅតាមសំពៅប្ញនាវាចម្បាំងអាមេរិកជួយសង្គ្រោះចេញពីការវាយប្រហាររបស់ចោរសមុទ្រមុនពេលទៅដល់ប្រទេសម៉ាឡេស៊ី ឥណ្ឌូនេស៊ី ថៃ និងកន្លែងផ្សេងៗទៀតដែលជនភៀសខ្លួនបង្ខំចិត្តជ្រកកោននៅក្នុងជំរំជនភៀសខ្លួនប្រកបដោយទុក្ខវេទនា ។ ពេលនោះសម្រែកអំពាវនាវសុំជំនួយក៏បន្លឺឡើង ។

សម្រាប់រដ្ឋាភិបាលអាមេរិក វាងាយស្រួលផ្តោតការយកចិត្តទុកដាក់ទៅលើប្រជាជនតាមទូកជាងផ្តោតការយកចិត្តទុកដាក់លើជនភៀសខ្លួនកម្ពុជា ។ ប្រការនេះមិនមែនដោយសារជនភៀសខ្លួនវៀតណាមតាមទូកមានលក្ខណៈបន្ទាន់ជាងនោះទេ ប៉ុន្តែវាបង្កលក្ខណៈងាយស្រួលក្នុងការស្តីបន្ទោសរដ្ឋាភិបាលវៀតណាមដែលគាំទ្រសូវៀតថាជាអ្នកបង្កបញ្ហា ប៉ុន្តែជនភៀសខ្លួនកម្ពុជាមិនត្រូវបានគេបំភ្លេចចោលទាំងអស់នោះទេ ។ រឿងរ៉ាវអំពីជីវិតទុក្ខសោកក្រោមរបបខ្មែរក្រហមនិងភាពគួរឲ្យព្រឺព្រួចនៅពេលរត់ចេញពីចម្ការមីនដើម្បីឆ្លងមកទឹកដីថៃ ក៏ចាប់ផ្តើមលេចឡើងនៅក្នុងព្រឹត្តិប័ត្រចោះពុម្ពផ្សាយនានានិងលិខិតមកពីប្រជាពលរដ្ឋសាមញ្ញ ព្រមទាំងលិខិតមកពីសមាជិកសភា ។ ទាំងអស់នេះបានជំរុញឲ្យអាមេរិកមានការតាំងចិត្តខ្លាំងមួយ ដើម្បីធ្វើឲ្យធូរស្រាលដល់

ស្ថានការណ៍នេះ ។ នៅខែមិថុនា (ឆ្នាំ១៩៧៩) ប្រទេសថៃបានបង្ខំឲ្យជនភៀសខ្លួន៤ម៉ឺន៥ពាន់នាក់វិលត្រឡប់ចូលទឹកដីកម្ពុជាវិញ ដែលជាលទ្ធផលគួរឲ្យសង្វេគជាពន់ពេក ។ ពេលនោះមានការទាមទារដ៏ខ្លាំងមួយ ។ អ្នកជំនួញ ម្នាក់បានសរសេរពីទីក្រុងញូវយ៉កថា“ខ្ញុំទ្រាំមិនគិតទៀតមិនបានទេថា ទាំងខ្លួនខ្ញុំផ្ទាល់និងប្រជាពលរដ្ឋអាមេរិកមិនអាចបន្តអង្គុយស្ងៀមនៅចំពោះមុខសោកនាដកម្មដែលចេះតែបន្តទៅនោះឡើយ” ។ ប្រធានាធិបតី ជីមមី ខាតធ័រ បានស្តីបន្ទោសយ៉ាងមិនគួរឲ្យជឿទៅលើសាធារណរដ្ឋប្រជាមានិត កម្ពុជានិងវៀតណាម ប៉ុន្តែសហរដ្ឋអាមេរិកចាប់ផ្តើមធ្វើការជាមួយរដ្ឋាភិបាលថៃនិងអង្គការស្ម័គ្រចិត្តនានាដើម្បីផ្តល់ស្បៀងអាហារនិងជំនួយសង្គ្រោះបន្ទាន់ដល់ជនភៀសខ្លួនកម្ពុជានៅក្នុងដែនដីកម្ពុជា ។ ការផ្តោតការយកចិត្តលើប្រជាជនកម្ពុជាចេះតែកើនឡើងជាបន្តបន្ទាប់ នៅពេលដែលរបាយការណ៍ថាមានទុរ្ភិក្សហៀបនឹងកើតឡើងនៅក្នុងប្រទេសកម្ពុជាហើយ ។ មានការប៉ាន់ស្មានថា ប្រជាជនរាប់ម៉ឺននាក់ ប្រហែលជាឈានដល់២សែននាក់អត់អាហារជារៀងរាល់ខែ ។ គណៈប្រតិភូអង្គការ *Church World Service* ប្រចាំនៅទីក្រុងភ្នំពេញបានសរុបរបាយការណ៍ដោយត្រង់ៗថា ÷

“របបអាហារហូបចុកបើមានគឺមានតិចបំផុត ។ ការបង្កបង្កើនផលមិនអំណោយផលសោះ ។ គ្មានអ្នកណាដឹងថាដីសម្រាប់ដាំដុះមានប៉ុន្មានភាគរយទេ ប៉ុន្តែមានអ្នកខ្លះប៉ាន់ស្មានថាមានយ៉ាងច្រើន៥ភាគរយ ។ អ្នកខ្លះទៀតថាផ្ទៃដីដាំដុះមិនលើសពី២៥ភាគរយឡើយ ។ ហេតុដូចនេះហើយបានជាគ្មានសង្ឃឹមថានឹងមានកម្លាំងផលិតស្បៀងគ្រប់គ្រាន់ទេ ។ ស្ថិតក្នុងស្ថានភាពបែបនេះអត្រាកុមារស្លាប់ឡើងខ្ពស់ទោះបីជាគ្មានស្ថិតិដែលអាចយកជាការបានក៏ដោយ ។ យើងឃើញកុមាតូចៗមួយចំនួនតូចមានអាយុក្រោម៥ឆ្នាំ ។ តម្រូវការជាក់ស្តែងជាមូលដ្ឋានមានដូចជាស្បៀងអាហារ ថ្នាំសង្កូវ មុង និងវ៉ាក់សាំងការពារជំងឺ ។ ជំនួយផុតដៃផុតជើងតាមរយៈភ្នាក់ងារមនុស្សធម៌អន្តរជាតិ ជាពិសេសមកពីយូនីសេហ្វ និងគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ ដែលធ្វើការរួមគ្នានឹងភ្នាក់ងារមួយចំនួនតូចទៀត មានកម្រិតតិចណាស់បើប្រៀបធៀបទៅនឹងតម្រូវការចាំបាច់ដ៏ធំធេង ហើយការរំពឹងថានឹងមានការចែកចាយស្បៀងឲ្យបានគ្រប់គ្រាន់មិនទាន់មានពន្លឺនៅឡើយទេ...” ។

រោងចក្រផលិតអាហារ ដូចជារោងចក្រត្រីខកំប៉ុង មិនដំណើរការព្រោះគ្រឿងម៉ាស៊ីនចាស់ទ្រុឌទ្រោមដែលមិនអាចជួសជុលបាន ។ សាលារៀនទើបតែចាប់ផ្តើមបើកទ្វារប៉ុណ្ណោះ ។ សាលារៀនមួយមានគ្រូបង្រៀនតែពីរបីនាក់ ហើយកម្រមានឧបករណ៍គ្រាប់គ្រាន់សម្រាប់បង្រៀននិងរៀនណាស់ ឧទាហរណ៍ ដូចជាក្រដាសសរសេរ ប៊ិច និងខ្មៅដៃ ។ គ្មានធនធានមនុស្សសម្រាប់ស្តារនិងគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធរដ្ឋបាលរបស់ប្រទេសដែលមានលក្ខណៈផុយស្រួយនិងខ្វះសព្វខ្វះគ្រប់ឡើយ ។

ទោះបីជាមានគ្រោះជាបន្ទាន់យ៉ាងនេះក៏ដោយ រដ្ឋការប្រធានាធិបតី ជីមមី ខាតធ័រ កម្រនឹងប្រឈមមុខចាត់ចែងយកជំនួយមកឲ្យកម្ពុជាណាស់ ។ រដ្ឋការនេះបានរិះគន់របប ហេង សំរិន (និងវៀតណាម) ដែលទទូចថាជំនួយទាំងអស់គួរតែផ្តល់មកតាមសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ រដ្ឋការនេះអះអាងថា របប ហេង សំរិន ជាអ្នករារាំងការចែកចាយអំណោយ ។ អ្វីដែលសហរដ្ឋអាមេរិកព្រួយបារម្ភបំផុតនោះគឺថា ការដឹកជញ្ជូនស្បៀងអាហារកាត់តាមទីក្រុងភ្នំពេញអាចនឹងត្រូវកាត់ឲ្យទៅកងទ័ពវៀតណាមដែលមានវត្តមាននៅក្នុងប្រទេសកម្ពុជា ឬអាចត្រូវយកទៅប្រើប្រាស់ក្នុងផ្លូវផ្សេងទៀតក្នុងការគាំទ្រសាធារណរដ្ឋប្រជាមានិតកម្ពុជា ។

នៅក្នុងជួររដ្ឋាភិបាលសហរដ្ឋអាមេរិក កិច្ចខិតខំប្រឹងប្រែងនាំយកស្បៀងដោយខ្លួនឯងផ្ទាល់ត្រូវបានយកជាចំណុចសំខាន់នៅក្នុងគណៈកម្មការប្រធានាធិបតីទទួលបន្ទុកកិច្ចការទុរ្ភិក្សពិភពលោកដែលដឹកនាំដោយ សុល លីណូវីត ។ ទោះបីជាគ្រោះទុរ្ភិក្សនៅកម្ពុជាមិនមែនជាផ្នែកមួយនៃអាណត្តិរបស់គណៈកម្មការនេះក៏ដោយ នៅខែតុលា ឯកអគ្គរដ្ឋទូត លីណូ គិតថា គណៈកម្មការនេះមិនត្រូវធ្វើមិនដឹងមិនឮចំពោះបញ្ហាគ្រោះទុរ្ភិក្សធ្ងន់ធ្ងរបំផុតនៅក្នុងពិភពលោកនោះទេ ។ ជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងរបស់គណៈកម្មការនេះ ក៏ដូចជាសេចក្តីអំពាវនាវរបស់មេដឹកនាំភ្នាក់ងារផ្តល់ជំនួយសង្គ្រោះបន្ទាន់សំខាន់ៗ នៅថ្ងៃទី៨ ខែតុលា ឆ្នាំ១៩៧៩ ស៊ីរីស វ៉ាន ផ្តល់អនុសាសន៍ដល់ប្រធានាធិបតីថា សហរដ្ឋអាមេរិកបានតាំងចិត្តយ៉ាងច្បាស់លាស់រួចហើយក្នុងការគាំទ្រសេចក្តីអំពាវនាវរួមមួយដែលសង្ឃឹមថានឹងទទួលបានពីអង្គការ

យូនីសេហ្វ និងគណៈកម្មាធិការកាកបាទក្រហមកម្ពុជារៃអង្គាសប្រាក់ចំនួន១០០លានដុល្លារដើម្បីបង្កើតជាកញ្ចប់ជំនួយសង្គ្រោះបន្ទាន់មានលក្ខណៈអន្តរជាតិសម្រាប់ប្រទេសកម្ពុជាក្នុងរយៈពេល ៦ខែ ។ ស៊ីរីស វ៉ាន បានអង្វរប្រធានាធិបតី ជីមមី ខាតធ័រ ថា "ខ្ញុំជឿថាសហរដ្ឋអាមេរិក...គួរតែផ្តើមគំនិតដំបូងឲ្យមានកិច្ចប្រឹងប្រែងរួមរវាងអង្គការយូនីសេហ្វនិងគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ" ។ លោកបានសរសេរថា "ដោយមានការព្រួយបារម្ភរបស់សភានិងសារពត៌មានដែលចេះតែកើនឡើងយ៉ាងឆាប់រហ័ស និងសេចក្តីប្រកាសឲ្យចូលរួមពីសំណាក់ប្រជាជាតិនានានៅក្នុងការផ្តល់ជំនួយសង្គ្រោះបន្ទាន់នេះ ខ្ញុំជឿថាលោកចាំបាច់ត្រូវតែដឹកនាំធ្វើសន្និសីទជាមួយសេចក្តីប្រកាសសុំឲ្យមានការចូលរួមក្នុងកិច្ចការនេះ ។ ស៊ីរីស វ៉ាន ផ្តល់ជាយោបល់ថាសុំឲ្យអាមេរិកផ្តល់ថវិកា៧លានដុល្លារ ។"

ទឹកប្រាក់៧លានដុល្លារជាចំនួនតិចណាស់បើប្រៀបធៀបទៅនឹងតម្រូវការជាក់ស្តែង ហើយសមាជិកនៃគណៈកម្មការទទួលបន្ទុកកិច្ចការគ្រោះទុរ្ភិក្សពិភពលោកបានចាប់ផ្តើមជំរុញឲ្យ លីណូវីត អំពាវនាវដល់ប្រធានាធិបតីផ្តល់ថវិកាចំនួន៣០លានដុល្លារ ។ មានមនុស្សមួយចំនួនទៀតក៏បាននិយាយអំពីបញ្ហានេះដែរ ដូចជា ធីអូឌ័រ ហ៊ើសប៊ឺក នាយកសាកលវិទ្យាល័យ ន័រត្រឺដាម និងជាប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍ក្រៅប្រទេសបានអំពាវនាវដល់ក្រុមសហគមន៍សាសនានិងអង្គការមនុស្សធម៌នានាឲ្យមកពិភាក្សាអំពីស្ថានការណ៍នៅកម្ពុជា ហើយបានជំរុញឲ្យមានការសន្យាមានកម្រិតខ្ពស់មួយ ។

ទន្ទឹមនេះដែរក៏មានសម្ពាធមកលើរដ្ឋការប្រធានាធិបតី ជីមមី ខាតធ័រ ពីសំណាក់សមាជិកព្រឹទ្ធសភា អេដវ៉ាដ ខេណ្ណឺឌី ដែលជាប្រធានអនុគណៈកម្មាធិការទទួលបន្ទុកអន្តោប្រវេសន៍នៃគណៈកម្មាធិការតុលាការ និងដែលគិតចង់ប្រណាំងប្រជែងជាមួយ ជីមមី ខាតធ័រ ឲ្យមានការតែងតាំងពីគណៈបក្សប្រជាធិបតេយ្យដើម្បីឈរឈ្មោះជាប្រធានាធិបតីនៅឆ្នាំ១៩៨០ ។ នៅក្នុងសុន្ទរកថាមួយនៅឯសាកលវិទ្យាលចចថោន នៃសហរដ្ឋអាមេរិក អេដវ៉ាត ខេណ្ណឺឌី បានបន្ទោសរដ្ឋការនេះថា "ធ្វើព្រងើយកន្តើយកាលពីអតីតកាល" ចំពោះស្ថានការណ៍នៅកម្ពុជា ។ លោកបានលើកឡើងថា សហរដ្ឋអាមេរិក "មានការព្រួយបារម្ភអំពីជនផ្តាច់ការដែលអង្គុយលើអាសនៈកម្ពុជាប្រចាំអង្គការសហប្រជាជាតិ ជាជាងបារម្ភអំពីកុមារាកុមារីដែលស្ទើរស្លាប់ស្ទើររស់នៅក្នុងប្រទេសមួយដែលជនផ្តាច់ការនោះបានដឹកនាំ" ។ ការកត់សម្គាល់ចំៗរបស់ អេដវ៉ាត ខេណ្ណឺឌី ថារដ្ឋការប្រធានាធិបតី ជីមមី ខ្វះភាពរួសរាន់នោះ គឺទាក់ទងជាមួយនឹងស្ថានការណ៍នយោបាយភូមិសាស្ត្រ ហើយមានការយកចិត្តទុកដាក់មិនគ្រប់គ្រាន់ទៅលើសោកនាដកម្មមកលើមនុស្សជាតិ ។

ប្រឈមមុខនឹងសម្ពាធបែបនេះ រដ្ឋការប្រធានាធិបតី ជីមមី ខាតធ័រ ក៏សម្រេចចិត្តជាលើកចុងក្រោយក្នុងការអនុវត្តកិច្ចខិតខំប្រឹងប្រែងជួសមុខឲ្យប្រជាជនកម្ពុជាដែលកំពុងតែរងទុក្ខវេទនា ។ នៅថ្ងៃទី២៣ ខែតុលា ជីមមី ខាតធ័រ បានជួបជាមួយថ្នាក់ដឹកនាំសភា ដើម្បីសុំសេចក្តីយល់ព្រមពង្រីកខ្ទង់ថវិកាសម្រាប់ចំណាយទៅលើជំនួយសង្គ្រោះបន្ទាន់នៅកម្ពុជា ។ ដូចនេះតាមសំណើដោយផ្ទាល់ខ្លួនរបស់ប្រធានាធិបតី ជីមមី ហេសប៊ឺក និងមេដឹកនាំសាសនានិងមនុស្សធម៌ចំនួន៣៥រូប បានមកជួបប្រជុំជាមួយលោកនៅឯសេតវិមាន ។ លោកប្រធានាធិបតីបានប្រាប់ទៅមេដឹកនាំទាំងនោះថា លោកកំពុងតែចាត់ចំណាយថវិកា៣លានដុល្លារបន្ថែមទៀត សម្រាប់ជាជំនួយសង្គ្រោះបន្ទាន់តាមរយៈអង្គការ យូនីសេហ្វ និងគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ ហើយថាលោកនឹងជំរុញឲ្យសភាអនុម័តផ្តល់ថវិកាចំនួន២០លានដុល្លារបន្ថែមទៀតនៅជារបស់ប្រើប្រាស់ដល់កម្ពុជា "ដោយភ្ជាប់លក្ខខណ្ឌតែមួយគត់ គឺការធានាឲ្យប្រាកដថា ជំនួយនោះនឹងបំពេញភាពខ្វះខាតរបស់អ្នកទាល់ក្រតែប៉ុណ្ណោះ" ។ សរុបមកឃើញថា រដ្ឋការ ជីមមី ខាតធ័រ ឥឡូវនេះកំពុងតែស្នើបញ្ជាចំណាយថវិកា៣០លានដុល្លារ (ក្នុងនោះ៧លានបានច្បាប់អនុញ្ញាតរួចហើយ) សម្រាប់ជំនួយសង្គ្រោះដល់កម្ពុជាជាមួយនឹងថវិកា៩លានបន្ថែមឲ្យដល់សេវាជំនួយកាតូលិកនិងកម្មវិធីរបស់សហប្រជាជាតិដែលកំពុងជួយជនភៀសខ្លួនខ្មែរនៅប្រទេសថៃ ។

ហេសប៊ើក និងអ្នកផ្សេងទៀតមានការពេញចិត្ត ហើយនៅថ្ងៃបន្ទាប់បានចេញសេចក្តីប្រកាសពត៌មានគាំទ្រ ជីមមី ខាតធ័រ ហើយជំរុញឲ្យសភាព្រមទាំងសាធារណជនបង្កើនជំនួយដល់កម្ពុជាជាប្រទេសដែលខ្លួននិយាយថា "បានបាត់បង់ប្រជាជនពាក់កណ្តាលទៅហើយក្នុងចំណោមប្រជាជនសរុបចំនួន៨លាននាក់" ។ ក្រៅពី

ការប្រកាសអំពីជំនួយបន្ថែម ប្រធានាធិបតី ជីមមី ខាតធ័រ បានបញ្ជូនលិខិតទៅកាន់ប្រទេសផ្តល់ជំនួយសំខាន់ៗ ដោយជំរុញឲ្យបណ្តាប្រទេសទាំងនោះជួយបង្កើនវិភាគទានរបស់ខ្លួនឲ្យច្រើនជាងមុន ។ លោកក៏បានបង្កើតក្រុមអន្តរភ្នាក់ងារដើម្បីសហការគ្នាលើកិច្ចការផ្តល់ជំនួយសង្គ្រោះបន្ទាន់ ដោយដាក់ឈ្មោះ ឌីក ក្លាក ដើម្បីឲ្យប្រមូលជាក្រុម ហើយបានលើកអំពីសេចក្តីប្រកាសរបស់ប្រធា-នាធិបតីអំពាវនាវដល់ជនជាតិអាមេរិកកាំងទាំងអស់ឲ្យចូលរួមដោយសប្បុរសធម៌ក្នុងការផ្តល់ជំនួយសង្គ្រោះ ។ រួមសេចក្តីមកវាគឺជាកិច្ចខិតខំប្រឹងប្រែងដ៏ធំមួយរបស់រដ្ឋការប្រធានាធិបតីជីមមី ខាតធ័រ ។ សូម្បីតែសម្តេចព្រះរាជអគ្គមហេសី មុនីនាថ សីហនុក៏សព្វព្រះរាជហឫទ័យដែរ ។ សម្តេចព្រះរាជអគ្គមហេសីទ្រង់ព្រះលិខិតកោតសរសើរនូវ“សប្បុរសធម៌របស់ប្រជាជនអាមេរិកនិងទង្វើប្រកបដោយកិត្តិគុណរបស់លោកប្រធានាធិបតី” ។

ក្រោយពេលសមាជិកព្រឹទ្ធសភា ចន ដានហ្វស ផ្តល់នូវរបាយការណ៍មួយទៅសហការីរបស់លោកទាក់ទងនឹងដំណើរទស្សនកិច្ចថ្មីៗរបស់លោកនៅទីក្រុងភ្នំពេញ ដែលពេលនោះគណៈប្រតិភូលោកឃើញប្រជាជនកម្ពុជា“ស្លាប់ស្រស់ៗនៅចំពោះមុខ” សហសភាអាមេរិកក៏អនុម័តថវិកា៣០លានដុល្លារបន្ថែម “ដោយសំឡេងយល់ព្រមភ្លូកទឹកភ្លូកដី” ។ សហសភាស្ទើរតែបង្កើនថវិកាដល់រដ្ឋការនេះរហូតទៅដល់ពីរដងឯណោះ ។

ទោះជាមានកិច្ចគាំទ្រដ៏ច្រើនពីសាធារណជនទូទៅចំពោះជំនួយនោះក៏ដោយ បញ្ហានៅត្រង់ថាតើរដ្ឋាភិបាលអាមេរិកថ្មីដែលនឹងចូលមកជំនួសមានជំហរយ៉ាងដូចម្តេចចំពោះការបញ្ជូនចំណាយនៅក្នុងប្រទេសកម្ពុជា(មិនមែននៅតាមព្រំដែន) នៅតែមានលក្ខណៈមិនច្បាស់លាស់នៅឡើយ ។ បញ្ហានយោបាយនៅតែជាចំណុចស្នូលនៅឡើយ ។ ជាក់ស្តែងដូចជានៅថ្ងៃទី១០ ខែតុលា ពោលគឺពីរថ្ងៃបន្ទាប់ពី ស៊ីរីស វ៉ាន បានជំរុញឲ្យប្រធានាធិបតីជីមមី ខាតធ័រ ផ្តល់នូវជំនួយសង្គ្រោះដល់ប្រទេសកម្ពុជា ប៊ីល ហ៊ើរ៉ិតដែលតំណាងឲ្យអង្គការ Church World Service បានឡើងថ្លែងនៅចំពោះមុខអនុគណៈកម្មាធិការទទួលបន្ទុកកិច្ចការអាស៊ីនិងប៉ាស៊ីហ្វិកថា ក្រសួងហិរញ្ញវត្ថុមិនទាន់បានអនុម័តតាមសំណើរបស់អង្គការនេះ (ដែលធ្វើឡើងនៅខែមិថុនាមុន)ក្នុងការបញ្ជូនមុងគិតជាទឹកប្រាក់១សែនដុល្លារមកកម្ពុជាដើម្បីជួយទប់ស្កាត់ជំងឺគ្រុនចាញ់ទេ ។ នៅថ្ងៃទី២៩ ខែតុលា អ្នកសរសេរអត្ថបទឲ្យកាសែតវ៉ាស៊ីនតោន ជែក អាន់ឌឺសុន បានចោទប្រកាន់ដោយគ្មានភ័ស្តុតាងថាមន្ត្រីក្រសួងការបរទេសអាមេរិកបាន“បំផ្លាញដោយចេតនា”នូវកិច្ចខិតខំប្រឹងប្រែងផ្តល់ជំនួយសង្គ្រោះដោយមានលក្ខខណ្ឌថាជំនួយនេះអាចផ្តល់បានតែក្នុងប្រទេសកម្ពុជាប៉ុណ្ណោះ ។ លោកបានចោទថា មាន“ភាពលម្អៀងចេញពីអ្នកប្រឆាំងវៀតណាមដែលស្ថិតក្នុងតំណែងយ៉ាងយូរនៅក្រសួងការបរទេសសហរដ្ឋអាមេរិក” ពោលជាសេចក្តីលម្អៀងដែលស្តែងឲ្យឃើញ“តាមរយៈការបោះឆ្នោតគួរឲ្យអាម៉ាស់ក្នុងការ ផ្តល់អាសនៈដល់របប ប៉ុល ពត ប្រចាំនៅអង្គការសហប្រជាជាតិ ។ អាន់ដឺសុន អាចនឹងបំផ្លើសការរារាំងបន្ទុចបន្ទាក់របស់ក្រសួងការបរទេសសហរដ្ឋអាមេរិកនិងបំប៉ោងសម្តីរបស់លោកអំពីមនោសញ្ចេតនាប្រឆាំងនឹងវៀតណាមដែលយ៉ាងហោចណាស់សំដៅដល់ក្រុមប្រឹក្សាសន្តិសុខជាតិ ប៉ុន្តែទោះជាទីតាំងអ្វីក៏ដោយការសង្ស័យទៅលើវៀតណាមនិងសាធារណរដ្ឋប្រជាមានិតកម្ពុជាបានប៉ះពាល់ដល់គោលនយោបាយអាមេរិកចំពោះតំបន់ ហើយ សហរដ្ឋអាមេរិកមានការព្រួយបារម្ភហួសប្រមាណអំពីការប្រើជំនួយដែលខ្លួនបញ្ជូនមកក្នុងប្រទេស






កម្ពុជាក្នុងខណៈដែលខ្លួនព្រួយបារម្ភតិចតួចបំផុតអំពីអ្វីដែលបានកើតឡើងចំពោះជំនួយដែលផ្តល់នៅក្នុងប្រទេសថៃនិងនៅតាមព្រំដែន ។ សរុបមក ទោះបីជារដ្ឋការនេះបានចាត់វិធានការសំខាន់ដើម្បីបង្កើនជំនួយដល់កម្ពុជាក៏ដោយ ឆន្ទៈរបស់រដ្ឋការនេះក្នុងការដោះស្រាយសោកនាដកម្មតាមវិធីប្រើកម្លាំងនៅតែមានលក្ខណៈគួរឲ្យសង្ស័យនៅឡើយ ។ ដូចដែលបុគ្គលិករបស់អនុប្រធានាធិបតី ម៉ុនដល បានសរសេរនៅ ក្នុងលិខិតមួយជូនអគ្គសេនាធិការរបស់ ជីមមី គឺ ហាមមីលតុន ចដិន "វាមិនសូវសមហេតុផលសោះថា រដ្ឋការនេះបានធ្វើការដោយម៉ឺងម៉ាត់ ។ និយាយជាលក្ខណៈសីលធម៌វិញ ហេតុផលមនុស្សធម៌និងនយោបាយគួរតែមានសភាពផ្សេងពីនេះ" ។

បន្តិចក្រោយពី ហូលប្រ៊ុក ប្រាប់ទស្សនាវដ្តី "*Far Eastern Economic Review*"ដែលថា សហរដ្ឋអាមេរិកនឹង"យកបញ្ហានយោបាយជាបញ្ហាបន្ទាប់បន្សំ"ដើម្បីនាំយកស្បៀងអាហារមកឲ្យប្រជាជនកម្ពុជា ប៉ុន្តែបញ្ហានយោបាយបេះតែកើនឡើងនៅក្នុងកម្មវិធីជំនួយអាមេរិក ។ សហរដ្ឋអាមេរិកបន្តចោទប្រកាន់រដ្ឋា-ភិបាលវៀតណាមនិងកម្ពុជាថាជាអ្នករារាំងមិនឲ្យអំណោយទៅដល់ដៃប្រជាជនដែលអត់ឃ្លាន ។ សូវៀតដែលជាអ្នកគាំទ្ររបបនេះក៏ជាផ្នែកសំខាន់មួយនៃបញ្ហានេះដែរ ។ រដ្ឋការអាមេរិកបានចោទប្រកាន់លើបញ្ហានេះក្នុងលក្ខណៈស្ងៀមស្ងាត់ពីមុនមក ប៉ុន្តែភាពកញ្ច្រោលឡើងនៃសមានចិត្តសាធារណៈទៅលើប្រជាជនកម្ពុជាដែលអត់បាយហូប មានទម្ងន់លើសលប់ទៅលើមនោសញ្ចេតនាមិនពេញចិត្តនេះ ហើយសហសភាបានរៀបចំខ្ទង់ចំណាយរាប់លានដុល្លារជាជំនួយបន្ទាន់ដល់កម្ពុជា ដែលផ្តល់មកតាមរយៈអង្គការយូនីសេហ្វនិងអង្គការកាកបាទក្រហមអន្តរជាតិ ប៉ុន្តែនៅចុងខែវិច្ឆិកា ឆ្នាំ១៩៧៩ ឥស្សរជននៅក្នុងជួររដ្ឋការប្រធានាធិបតី ជីមមី ដែលចង់ឲ្យមាននយោបាយសាធារណៈខ្លាំងមួយក្នុងការស្តីបន្ទោសទីក្រុងហាណូយ សាធារណរដ្ឋប្រជាមានិតកម្ពុជា និងសហភាពសូវៀត មានអារម្មណ៍ថាខ្លួនមានចិត្តលុះ (ប្រហែលដោយសារវិបត្តិចំណាប់ខ្មាំងអ៊ីរ៉ង់នាពេលថ្មីៗ បានបង្វែរការយកចិត្តទុកដាក់ចេញពីសោកនាដកម្មកម្ពុជាផងក៏មិនដឹង) ។

ប៊ីនីវ ហ្សេហ្ស៊ីនស្គី ដឹកនាំការចោទប្រកាន់នេះ ។ បុគ្គលិកក្រុមប្រឹក្សាសន្តិសុខជាតិបានធ្វើសេចក្តីព្រាងសេចក្តីថ្លែងការណ៍វាយប្រហារមួយដោយចោទប្រកាន់វៀតណាមដែលមានសូវៀតនៅពីក្រោយខ្នងថា"បានធ្វើសង្គ្រាមដណ្តើមជ័យ"ដោយគ្រប់គ្រង"ប្រទេសទាំងមូល" ។ ដោយសារតែគេបដិសេធមិនឲ្យភ្នាក់ងារជំនួយសង្គ្រោះចូលដល់ប្រជាជនរាប់សែននាក់គេអាច"ទទួលបន្ទុកដ៏ធ្ងន់ធ្ងរចំពោះមុខប្រវត្តិសាស្ត្រចំពោះភាពខ្វះមេត្តា និងការមិនគោរពជីវិតមនុស្សដែលជាការនាំមកនូវអំពើប្រល័យពូជសាសន៍ដល់ជនរងគ្រោះដោយសោកនាដកម្ម" ។ ប៊ីនីវ ហ្សេហ្ស៊ីនស្គី បញ្ជូនសេចក្តីព្រាងនេះទៅឲ្យក្រសួងការបរទេសដោយប្រាប់ ស៊ីរ៉ុស វ៉ាន ថាគេនឹង"ត្រូវទទួលរងនូវការរិះគន់យ៉ាងខ្លាំង ប្រសិនបើយើងមិនបញ្ចេញប្រតិកម្មកាន់តែមានលក្ខណៈសាធារណៈចំពោះឧបសគ្គរបស់សូវៀត-វៀតណាមដល់ជំនួយសម្រាប់ប្រទេសកម្ពុជា" ។ លោកសង្ឃឹមថារដ្ឋមន្ត្រីក្រសួងការបរទេសនឹងយល់ព្រម ព្រមទាំងចេញនូវសេចក្តីប្រកាសព្រាងនេះមិនខាន ។

ទម្រាំតែចេញសេចក្តីប្រកាសនេះត្រូវស៊ីពេលអស់១០ថ្ងៃ ។ សេចក្តីប្រកាសនេះបញ្ជាក់អំពីការខ្វែងគំនិតផ្ទៃក្នុងយ៉ាងសំខាន់ ។ ស៊ីរ៉ុស វ៉ាន ហាក់បីដូចជាមិនស្របទៅនឹងសេចក្តីព្រាងនេះឡើយ ។ ទោះជាយ៉ាងនេះក៏ដោយ វាពិបាកក្នុងការគាំទ្រការចោទប្រកាន់ថាវៀតណាមដែលបានសង្គ្រោះប្រទេសកម្ពុជាចេញពីក្រញាំអ្នកប្រព្រឹត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ជាក់ស្តែងនោះ (ប៉ុល ពត) បែរជាត្រូវទទួលទោសកំហុសពីគោលនយោបាយបែបនេះទៅវិញ ។

ទន្ទឹមនឹងពេលនេះដែរក៏មានសញ្ញាជំទាស់គ្នាចេញពីរដ្ឋការប្រធានាធិបតី ជីមមី ខាតធ័រ ។ នៅឯសន្និសីទសារពត៌មានដែលប្រកាសការតែងតាំង រីកទ័រ ប៉ាល់មៀរី ជាឯកអគ្គរដ្ឋទូតគោចរទទួលបន្ទុកកិច្ចការជនភៀសខ្លួន, មន្ត្រីក្រុមប្រឹក្សាសន្តិសុខ ម៉ាត់នីមមីត បានទាញការចាប់អារម្មណ៍ឲ្យគិតអំពីបញ្ហានៃការចែកគ្រឿងផ្គត់ផ្គង់នៅក្នុងរង្វង់ប្រទេសកម្ពុជា ។ ស្បៀងអាហារឡើងគរដូចភ្នំ ប៉ុន្តែឯក្បួនរថយន្តមិនបានទទួលអនុញ្ញាតឲ្យចូលទៅចែកចាយនៅក្នុងប្រទេសទេ ។

**(នៅមានត)**

**ខេនតុន ក្លេម៉រ**

# ករណីយុត្តិសាស្ត្រនៅក្នុងតុលាការយូហ្គោស្លាវី

តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (អាយស៊ីធីវ៉ាយ) និងសម្រាប់រ៉ូន់ដា (អាយស៊ីធីអា) មិនត្រឹមតែបានចេញដីកាចោទប្រកាន់ ចាប់ខ្លួន ជំនុំជម្រះក្តី និងដាក់ទោសចារីប្រព្រឹត្តអំពើឃោរឃៅជាច្រើនប៉ុណ្ណោះទេ ប៉ុន្តែតុលាការនេះថែមទាំងបានចេញសេចក្តីសម្រេចសំខាន់មួយចំនួនដែលបង្កើតបានជាករណីយុត្តិសាស្ត្រសម្រាប់ការស្វែងរកយុត្តិធម៌នៅទូទាំងពិភពលោក ។ សេចក្តីសម្រេចទាំងនោះរួមមានការកាត់សេចក្តីថ្មីៗ នៅក្នុងតុលាការអន្តរជាតិទៅលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ការរំលោភ និងទាសភាព ។ វិធានដ៏សំខាន់ទាំងនេះធ្វើឡើងដើម្បីការពារដល់ជនរងគ្រោះនិងសាក្សី ដែលជួបប្រទះនឹងគ្រោះថ្នាក់នៅពេលដែលខ្លួនចេញមុខឆ្លើយបំភ្លឺនៅចំពោះតុលាការ ហើយបច្ចេកវិទ្យាត្រូវបានយកមកប្រើប្រាស់ដើម្បីលាក់មុខនិងបំភ្លៃសម្លេងមិនឲ្យដឹងជាសាធារណៈ ។ តុលាការទាំងនេះបានអនុម័តនូវវិធានការទូលំទូលាយដើម្បីធ្វើឲ្យមានតុល្យភាពរវាងសិទ្ធិរបស់ជនរងគ្រោះជាមួយនឹងសិទ្ធិរបស់ជនជាប់ចោទ ។

## តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី

តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី បង្កើតនៅឆ្នាំ១៩៩៣ ដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិតាមជំពូកទី៧ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ ។ តុលាការនេះផ្តល់នូវសិទ្ធិតាមលក្ខន្តិកៈរបស់ខ្លួនក្នុងការកាត់សេចក្តី "ការរំលោភធ្ងន់ធ្ងរ"ដល់អនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ (មាត្រា២) ការរំលោភច្បាប់ ឬទំនៀមទម្លាប់ធ្វើសង្គ្រាម (មាត្រា៣) ការប្រល័យពូជសាសន៍ (មាត្រា៤) និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (មាត្រា៥) ។ តុលាការនេះមានអំណាចដាក់ឲ្យទទួលខុសត្រូវចំពោះជនជាប់ចោទពីបទព្រហ្មទណ្ឌប្រសិនបើជននោះបាន"រៀបចំផែនការ ញុះញង់ បញ្ជា ប្រព្រឹត្ត ឬជួយជ្រោមជ្រែងក្នុងការរៀបចំផែនការរៀបចំសកម្មភាព ឬការចាប់អនុវត្តបទល្មើសដែលស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការ(មាត្រា៧(១)" ។ តុលាការនេះក៏អាចកាត់សេចក្តីទៅលើមេបញ្ជាការ ឬអ្នកបង្គាប់ ប្រសិនបើអ្នកនៅក្រោមបង្គាប់បានប្រព្រឹត្តបទឧក្រិដ្ឋដែលច្បាប់បានកំណត់ ហើយអ្នកបង្គាប់"ដឹងឬមានហេតុផលក្នុងការដឹងថាអ្នកនៅ ក្រោមបង្គាប់ហៀបនឹងប្រព្រឹត្តបទល្មើសបែបនោះ ឬបានប្រព្រឹត្ត អំពើនោះ...ហើយខកខានមិនបានទប់ស្កាត់ ឬផ្តន្ទាទោស ចារី" (មាត្រា៧(៣)) ។

ការជំនុំជម្រះជាឯកត្តនាមឬជារួមត្រូវបានធ្វើឡើងចំពោះជនស៊ីវិលនិងយោធាមកពីក្រុមជនជាតិនីមួយៗនៃក្រុមជនជាតិទាំងបីធំៗដែលមានការពាក់ព័ន្ធនៅក្នុងជម្លោះបាល់កង់ ។ បុគ្គលដែលទទួលការចោទប្រកាន់ដោយតុលាការមានចាប់ពីប្រជាពលរដ្ឋសាមញ្ញដែលត្រូវចោទថាបានប្រព្រឹត្តបទល្មើសជាប់ទាក់ទងនឹងជម្លោះរហូតដល់មន្ត្រីនយោបាយនិងមន្ត្រីយោធាជាន់ខ្ពស់ ។ សាលក្រមសម្រេចទោសមានចាប់ពី៧ឆ្នាំដល់៤៥ឆ្នាំ ។ មកទល់នឹងពេលនេះ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីបានចេញសាលក្រមនៅក្នុងអង្គជំនុំជម្រះ១១មកលើជនជាប់ចោទ ២១នាក់ ។ សំណុំរឿងមួយចំនួនកំពុងតែត្រូវបានប្តឹងទៅសាលាឧទ្ធរណ៍បន្តទៀត ។ ករណីសង្ខេបខាងក្រោមបង្ហាញជូននូវការឈានទៅមុខដ៏សំខាន់នៅក្នុងច្បាប់អន្តរជាតិ ។

## រដ្ឋអាជ្ញាជាមួយនឹង ឌូសាន តាឌិក

ការជំនុំជម្រះក្តីលើកទីមួយដែលធ្វើឡើងដោយតុលាការយូហ្គោស្លាវីបានដោះស្រាយបញ្ហាយុត្តាធិការមួយចំនួន ហើយសេចក្តីសម្រេចរបស់តុលាការនេះក៏គូសបញ្ជាក់ជាទូទៅអំពីវិសាលភាពនៃឧក្រិដ្ឋកម្មភាគច្រើនដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការនេះ ។ ជនជាប់ចោទឈ្មោះ ឌូសាន តាឌិក គឺជាជនជាតិស៊ើបប៊ូស្នៀ ដែលមានសិទ្ធិចេញចូលដោយសេរីទៅក្នុងជំរំអូម៉ាស់កា យើរ៉ាតធើម និង ត្រូជូល ជាកន្លែងដែលល្បីខាងអំពើឃោរឃៅដែលប្រព្រឹត្តមកលើជនជាតិមូស្លីមប៊ូស្នៀ និង ក្រូអាតដែលជាប់ឃុំឃាំងនៅទីនោះ ។ បទចោទប្រកាន់លើបទឧក្រិដ្ឋចម្បងនីមួយៗ (លើកលែងតែបទចោទប្រកាន់អំពីការប្រល័យពូជសាសន៍) ផ្តល់ឱកាសដល់តុលាការនេះក្នុងការកំណត់បញ្ហាដូចជា

សារជាតិនៃជម្លោះប្រដាប់អាវុធថាតើចរិតនៃជម្លោះនេះមានលក្ខណៈជាអន្តរជាតិ ឬជាលក្ខណៈផ្ទៃក្នុង ឬចម្រុះទាំងពីរដែលទាំងនេះសុទ្ធតែទាក់ទងទៅនឹងការអនុវត្តបទចោទប្រកាន់នៃការរំលោភធ្ងន់ធ្ងរព្រមទាំងវិសាលភាពនៃបទឧក្រិដ្ឋក្រោមបទបញ្ញត្តិដែលបានចែងនៅក្នុងលក្ខន្តិកៈច្បាប់ទាក់ទងនឹងការរំលោភទៅលើច្បាប់ឬទម្លាប់នៃការធ្វើសង្គ្រាមនិងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។

នៅក្នុងដំណាក់កាលដំបូងនៃដំណើរការនីតិវិធីតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីជាការសំខាន់ក្នុងការដោះស្រាយបញ្ហានៃការកំណត់ជម្លោះថាមានលក្ខណៈជា“ផ្ទៃក្នុង” ឬ“អន្តរជាតិ” ។ ប្រការនេះជាការសំខាន់ ពីព្រោះនិយមន័យបែបនេះនឹងកំណត់ច្បាស់ថាច្បាប់ណាដែលអាចយកមកអនុវត្តបាននៅក្នុងតុលាការ ។ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនស្តីអំពីការប្តឹងឧទ្ធរណ៍អំពីយុត្តាធិការ (ថ្ងៃទី២ ខែតុលា ឆ្នាំ១៩៩៥) សាលាឧទ្ធរណ៍បានកំណត់ជម្លោះប្រដាប់អាវុធថា កើតមានឡើង“នៅពេលណាដែលមានការងាកមកប្រើកម្លាំងប្រដាប់អាវុធរវាងរដ្ឋនិងរដ្ឋ ឬអំពើឃោរឃៅអូសបន្លាយប្រដាប់ដោយអាវុធរវាងអាជ្ញាធររដ្ឋាភិបាលនិងក្រុមអង្គការចាត់តាំងប្រដាប់ដោយអាវុធ ឬរវាងក្រុមទាំងនេះជាមួយនឹងរដ្ឋ” ។ នៅក្នុងបរិបទនេះ តុលាការនេះបានយល់ស្របចំពោះការត្រួតលើគ្នារវាងច្បាប់អនុវត្តចំពោះជម្លោះប្រដាប់អាវុធលក្ខណៈអន្តរជាតិនិងលក្ខណៈផ្ទៃក្នុង ។

ដោយពិចារណាទៅលើការរំលោភទៅលើមាត្រា៣នៃលក្ខន្តិកៈ សាលាឧទ្ធរណ៍សម្រេចថាមានលក្ខខណ្ឌបួនយ៉ាងដើម្បីចាត់ទុកថាជាការរំលោភលើច្បាប់ ឬទម្លាប់នៃការធ្វើសង្គ្រាមដែលនាំឲ្យមានការទទួលខុសត្រូវចំពោះមុខច្បាប់ ។ លក្ខខណ្ឌខាងក្រោមនេះអនុវត្តដោយមិនគិតថាតើការរំលោភនេះបានកើតឡើងនៅក្នុងបរិបទជម្លោះប្រដាប់អាវុធជាលក្ខណៈអន្តរជាតិឬផ្ទៃក្នុងទេ÷

១) ការរំលោភត្រូវតែជាការរំលោភទៅលើវិធាននៃច្បាប់មនុស្សធម៌អន្តរជាតិ ។

២) វិធាននោះត្រូវតែមានលក្ខណៈជាទម្លាប់ ឬប្រសិនបើវាស្ថិតនៅក្នុងច្បាប់សន្ធិសញ្ញា តម្រូវឲ្យធ្វើតាមលក្ខខណ្ឌដែលកំណត់ ។

៣) ការរំលោភត្រូវតែ“ធ្ងន់ធ្ងរ”... ។

៤) ការរំលោភទៅលើវិធាននោះត្រូវតែនាំឲ្យមានការទទួលខុសត្រូវជាបុគ្គលដែលរំលោភនោះតាមច្បាប់ទម្លាប់ ឬច្បាប់អនុសញ្ញា ។

មាត្រា៣នៃអនុសញ្ញាទីក្រុងហ្សឺណែវ១៩៤៩ដែលមានចែងនៅក្នុងមាត្រា៣នៃលក្ខន្តិកៈនេះ មានបំណងអនុវត្តជាពិសេសទៅលើសង្គ្រាមស៊ីវិល ប៉ុន្តែសាលាឧទ្ធរណ៍រកឃើញថា ការប្រព្រឹត្តដែលកំណត់ដោយមាត្រា៣នៃអនុសញ្ញាទីក្រុងហ្សឺណែវក៏ជាផ្នែកមួយនៃច្បាប់ទម្លាប់អន្តរជាតិដែរ ហេតុដូចនេះអាចអនុវត្តបានទាំងចំពោះជម្លោះប្រដាប់អាវុធជាលក្ខណៈផ្ទៃក្នុង និងលក្ខណៈអន្តរជាតិ ។ ការសម្រេចបែបនេះដែលឈានទៅដល់ការការពារដូចដែលធានានៅក្នុងអនុសញ្ញាទីក្រុងហ្សឺណែវនោះ បានបង្រួមយ៉ាងច្រើននូវការអនុវត្តជាលក្ខណៈប្រវត្តិសាស្ត្រនៃការចាត់ទុកការប្រព្រឹត្តខុសៗគ្នាដោយផ្អែកទៅតាមប្រការដែលថាតើសង្គ្រាមមួយត្រូវបានចាត់ទុកជាលក្ខណៈផ្ទៃក្នុងឬជាអន្តរជាតិនោះ ។

សាលាឧទ្ធរណ៍ក៏បានកត់សម្គាល់ដែរថា តាមច្បាប់ទម្លាប់អន្តរជាតិ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិអាចត្រូវបានប្រព្រឹត្តឡើងនៅពេលសង្គ្រាមឬពេលសន្តិភាព ។ ហេតុដូចនេះ បើលក្ខន្តិកៈនេះមិនចែងផ្សេងពីនោះទេ ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិវាមិនមែនជាការចាំបាច់ក្នុងការកំណត់ថាមានជម្លោះប្រដាប់អាវុធនៅពេលនោះ ។

នៅពេលដែលបញ្ហាយុត្តាធិការត្រូវបានដោះស្រាយ ការជំនុំជម្រះក្តីរកខុសត្រូវបានដំណើរការទៅមុខ ។ ជាថ្មីម្តងទៀត ការកំណត់ទាក់ទងនឹងថាតើច្បាប់អន្តរជាតិអាចយកមកអនុវត្តបានដែរឬទេនោះវាមានលក្ខណៈច្បាស់លាស់ហើយ ។ នៅក្នុងការចេញសាលក្រមរបស់ខ្លួន (នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៩៥) មតិភាគច្រើននៃអង្គជំនុំជម្រះក្តីសម្រេចថាការរំលោភធ្ងន់ធ្ងរ (ទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ) មិនត្រូវបានចាត់ទុកជាផ្នែកមួយនៃច្បាប់ទម្លាប់អន្តរជាតិទេនៅពេលប្រព្រឹត្តបទល្មើស ។ ជាពិសេសមតិភាគច្រើនយល់ឃើញថាការរំលោភធ្ងន់ធ្ងរត្រូវបានកំណត់ចំពោះជម្លោះនានាដែលមានចរិតអន្តរជាតិ ហើយរដ្ឋអាជ្ញាមិនបានបង្ហាញថាបទឧក្រិដ្ឋដែលលើកមកនិយាយនេះត្រូវបានប្រព្រឹត្តនៅអំឡុងពេលមានជម្លោះប្រដាប់អាវុធអន្តរជាតិ ។ ហេតុដូចនេះហើយបានជាបទចោទប្រកាន់ទាំងប៉ុន្មានដែលធ្វើឡើងទៅតាមមាត្រា២នៃលក្ខន្តិកៈច្បាប់មិនត្រូវបានយកមកគិតឡើយ ។ ជាលទ្ធផល តាឌិក ត្រូវបានរកឃើញថាមានកំហុសនៅក្នុងបទ

ចោទប្រកាន់ចំនួន៩ ក្នុងចំណោមបទចោទប្រកាន់ចំនួន៣៨និងមានកំហុសដោយផ្អែកនៅលើបទចោទប្រកាន់ពីរផ្សេងទៀត ពោលគឺ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនិងការរំលោភច្បាប់ទម្លាប់សង្គ្រាម ។ បញ្ហាជាច្រើនត្រូវបានប្តឹងទៅសាលាឧទ្ធរណ៍ដោយមេធាវីការពារចុងចោទនិងរដ្ឋអាជ្ញា ។

សាលដីការបស់សាលាឧទ្ធរណ៍ (ថ្ងៃទី១៥ ខែកក្កដាឆ្នាំ១៩៩៩) មិនស្របគ្នាជាមួយហេតុផលរបស់អង្គជំនុំជម្រះទៅលើជម្លោះអន្តរជាតិដោយកំណត់ថា ជម្លោះប្រដាប់អាវុធមានលក្ខណៈជាអន្តរជាតិមិនចាំបាច់ដល់ថាវាកើតឡើងជាមួយរដ្ឋពីរ ឬច្រើនទេ ។ ជម្លោះប្រដាប់អាវុធផ្ទៃក្នុងក៏អាចក្លាយជាជម្លោះអន្តរជាតិដែរឬកើតឡើងស្របជាមួយនឹងជម្លោះផ្ទៃក្នុងប្រសិនបើរដ្ឋមួយទៀតចូលអន្តរាគមន៍ដោយកងទ័ព ឬអ្នកចូលរួមខ្លះនៅក្នុងជម្លោះផ្ទៃក្នុងធ្វើសកម្មភាពឲ្យរដ្ឋផ្សេងទៀត ។ សាលាឧទ្ធរណ៍បានបន្តលើកឡើងនូវលក្ខណៈវិនិច្ឆ័យតាមផ្លូវច្បាប់ក្នុងការកំណត់ថា នៅពេលណាជម្លោះប្រដាប់អាវុធផ្ទៃក្នុងអាចក្លាយទៅជាជម្លោះប្រដាប់អាវុធអន្តរជាតិ ។ នៅក្នុងការយកច្បាប់ទៅអនុវត្តចំពោះអង្គហេតុ សាលាឧទ្ធរណ៍យល់ឃើញថាពេលវេលានិងទីកន្លែងដែលព្រឹត្តិការណ៍នោះបានកើតឡើងដែលបានចេញនៅលើដីកាចោទប្រកាន់ជម្លោះនោះពិតជាមានលក្ខណៈអន្តរជាតិ ហេតុដូចនេះហើយបានជាការរំលោភធ្ងន់ធ្ងរត្រូវបានទាត់ចេញដោយមិនសមរម្យពីសំណាក់អង្គជំនុំជម្រះសាលាដំបូង ។ (គួរកត់សម្គាល់ថា អង្គជំនុំជម្រះមិនបានកំណត់ថាសង្គ្រាមទាំងមូលនៅបាល់កង់មានលក្ខណៈជាជម្លោះអន្តរជាតិនោះទេ អង្គជំនុំជម្រះគ្រាន់តែបញ្ជាក់ថា នៅអំឡុងពេលនៃការចោទប្រកាន់ពិសេសទាក់ទងនឹង តាឌិក ជម្លោះនោះអាចត្រូវបានចាត់ទុកថាមានលក្ខណៈអន្តរជាតិ) ។

សាលាឧទ្ធរណ៍បានបំណកស្រាយដ៏សំខាន់មួយទៀតទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ។ មាត្រា៤ ការពារជនស៊ីវិលដែលដឹងថាខ្លួនកំពុងតែ“ស្ថិតនៅក្នុងកណ្តាប់ដៃរបស់ភាគីមួយនៅក្នុងជម្លោះ ឬអាជ្ញាធរដែលចូលមកកាន់កាប់ដែលមិនមែនជាជនជាតិនៃទឹកដីដែលត្រូវបានកាន់កាប់” ។ អនុសញ្ញាទីក្រុងហ្សឺណែវត្រូវបានចងក្រងដើម្បីធ្វើនិយតកម្មទៅលើសង្គ្រាមរវាងប្រជាជាតិនានា ហើយនេះជាវិធីដែលត្រូវបានប្រើប្រាស់ជាប្រពៃណី ប៉ុន្តែយោងតាមសាលាឧទ្ធរណ៍របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី នៅក្នុងកាលៈទេសៈមួយចំនួន មាត្រា៤ អាចបញ្ចូលជនរងគ្រោះដែលមានសញ្ជាតិដូចគ្នាជាមួយចារីប្រព្រឹត្តឧក្រិដ្ឋកម្ម ។ និយាយម្យ៉ាងទៀត ជម្លោះអាចមានភាពសាហាវពេករហូតទៅដល់កម្ទេចចំណងសញ្ជាតិបាន ។ ជាលទ្ធផល ជនរងគ្រោះមូស្លីម-ប៊ូស្នៀត្រូវបានចាត់ទុកថាជាមនុស្សដែល“ការពារ”ដោយអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ បើទុកជាឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើងដោយជនជាតិស៊ែប-ប៊ូស្នៀក៏ដោយ ។ ហេតុដូចនេះ ការការពារមិនឲ្យមានការរំលោភធ្ងន់ធ្ងរដែលអនុសញ្ញាបានចែងគួរតែយកមកអនុវត្តឲ្យបាន ។

សាលដីការបស់សាលាឧទ្ធរណ៍ក៏បានសង្កត់ធ្ងន់ថា ក្រោមច្បាប់ទម្លាប់ទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការកាត់សេចក្តីអាចធ្វើឡើងចំពោះមូលហេតុជាបុគ្គលពិតៗ ។ សាលដីកាសង្កត់ធ្ងន់ទៀតថា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនចាំបាច់បង្ហាញអំពីចេតនារើសអើងទេ ពោលគឺ ការធ្វើទុក្ខបុកម្នេញដោយហេតុផលជាតិសាសន៍ ជាតិពន្ធុ ឬសាសនា លើកណាលក្ខន្តិកៈច្បាប់នេះមិនបានកំណត់ថាត្រូវមានធាតុផ្សំចេតនាទេនោះ ។

## រដ្ឋអាជ្ញា ជាមួយ អឺឌីម៉ូវិក

ករណីនេះផ្តោតសំខាន់ជាពិសេសទៅលើលក្ខណៈវិនិច្ឆ័យសម្រាប់ទទួលការឆ្លើយសារភាពកំហុស និងធម្មានុរូបក្នុងការអះអាងអំពីការបង្ខិតបង្ខំជាការការពារទៅនឹងការចោទប្រកាន់អំពីបទ ឧក្រិដ្ឋសង្គ្រាម ឬឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ ចុងចោទដ្រាហ្សិន អឺឌីម៉ូវិក សមាជិកនៃកងទ័ពស៊ែប-ប៊ូស្នៀជាប់ចោទពីបទបានចូលរួមនៅក្នុងការសម្លាប់យុវជនមូស្លីម-ប៊ូស្នៀដែលគ្មានអាវុធរាប់ពាន់នាក់ក្រោយពីអង្គភាពរបស់គាត់កាន់កាប់បាននូវ “ជម្រកសុវត្ថិភាព”របស់អង្គការសហប្រជាជាតិនៅតំបន់ស្រ៊ីប្រេនីកា ។ ជនជាប់ចោទរូបនេះត្រូវបានចោទពីបទមនុស្សឃាតដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬការរំលោភទៅលើច្បាប់និងទម្លាប់ធ្វើសង្គ្រាម ។ អឺឌីម៉ូវិក សារភាពថាពិតជាបានប្រព្រឹត្តអំពើមនុស្សឃាតប្រឆាំងមនុស្សជាតិពិតមែន ប៉ុន្តែធ្វើនេះគឺស្ថិតនៅក្រោមការបង្ខិតបង្ខំប៉ុណ្ណោះ ។ គាត់បញ្ជាក់ថា ប្រសិនបើខ្លួនខកខានមិនបានសម្លាប់ជនជាតិមូស្លីម-ប៊ូស្នៀតាមបញ្ជាទេ គាត់មិនត្រឹមតែមិនអាចការពារការកាប់សម្លាប់នោះទេ ប៉ុន្តែគាត់ថែមទាំងត្រូវអ្នកផ្សេងសម្លាប់ចោលទៀតផង ។ នៅក្នុង

សាលក្រមសាលាជម្រះដំបូង (ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៦) ការសារភាពទទួលកំហុសរបស់គាត់ត្រូវបានទទួលយក ហើយតុលាការកាត់សេចក្តីឲ្យគាត់ជាប់ពន្ធនាគារចំនួន១០ឆ្នាំ ។ អើឌីម៉ូវិក បានប្តឹងឧទ្ធរណ៍ដោយផ្តល់ទល្លីករណ៍ថាការឆ្លើយសារភាពកំហុសដែលគាត់បានធ្វើ មិនត្រូវបានគេប្រាប់ដំណើរទំនងឲ្យបានច្បាស់លាស់គ្រប់គ្រាន់ទេ ពោលគឺគាត់មិនយល់ច្បាស់អំពីភាពផ្សេងគ្នាក្នុងការសារភាពកំហុសចំពោះបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិជាមួយនឹងការសារភាពកំហុសចំពោះបទឧក្រិដ្ឋសង្គ្រាម ។ គាត់ក៏បានបញ្ជាក់ទៀតថា ការបង្ខិតបង្ខំមិនត្រូវបានតុលាការយកទៅពិចារណាថាជាការការពារខ្លួនឬបន្ធូរបន្ថយទោសទេ ។ នៅក្នុងសាលដីការបស់សាលាឧទ្ធរណ៍ (ថ្ងៃទី៧ ខែតុលា ឆ្នាំ១៩៩៥) មតិភាគច្រើននៃសាលាឧទ្ធរណ៍យល់ស្របថា ការឆ្លើយសារភាពកំហុសមិនត្រូវបានតុលាការជម្រាបឲ្យដឹងពិតមែន ហើយសាលាឧទ្ធរណ៍បានសម្រេចបញ្ជូនរឿងឲ្យជម្រះសាជាថ្មីនៅសាលាដំបូង ដើម្បីអនុញ្ញាតឲ្យ អឺឌីម៉ូវិក មានឱកាសសារភាពកំហុសសាជាថ្មី និងដើម្បីកំណត់ចេញនូវសាលក្រមកំណត់ទោសសមរម្យមួយ ។ ក្នុងការកំណត់លក្ខណៈវិនិច្ឆ័យសម្រាប់ទទួលយកនូវការសារភាពកំហុស សាលាឧទ្ធរណ៍បានកំណត់ថា បុព្វលក្ខខណ្ឌបីយ៉ាងត្រូវតែធ្វើឲ្យបានគឺៈ ការសារភាពកំហុសត្រូវតែធ្វើឡើងដោយស្ម័គ្រចិត្ត មានការជូនពត៌មានត្រឹមត្រូវ និងច្បាស់លាស់គ្មានមន្ទិល ។

សាលាឧទ្ធរណ៍ក៏សម្រេចដែរថា តាមមតិភាគច្រើន "ការបង្ខិតបង្ខំមិនអាចជាការការពារពេញលេញបានទេចំពោះយុទ្ធជនដែលជាប់ចោទពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និង/ឬឧក្រិដ្ឋសង្គ្រាមដែលមានការសម្លាប់មនុស្សគ្មានទោស" ។ មតិយោបល់រួមគ្នាផ្សេងមួយរបស់ចៅក្រម ម៉ែកដូណាល់ និង វ៉ូរ៉ាស់ បានសង្កត់ធ្ងន់ថា បើទោះជាគ្មានការអះអាងបញ្ជាក់អំពីការបង្ខិតបង្ខំក៏ដោយ ក៏សាលាដំបូងត្រូវតែយកការបង្ខិតបង្ខំនេះគិតគូរពិចារណាដើម្បីផ្តល់នូវការសម្រាលទោស ។

អឺឌីម៉ូវិក ក៏បានសារភាពកំហុសបន្តបន្ទាប់ថា បានប្រព្រឹត្តមនុស្សឃាតដែលជាឧក្រិដ្ឋសង្គ្រាមនៅចំពោះមុខសាលាជម្រះផ្សេងមួយទៀត ។ សាលក្រមនិងការប្រកាសទោសរបស់សាលាជម្រះថ្មីនេះ (ថ្ងៃទី៥ ខែមីនាឆ្នាំ ១៩៩៨) បានយកមកគិតពិចារណាទាំងសារជាតិនៃឧក្រិដ្ឋកម្មនិងការបង្ខិតបង្ខំ ហើយបានដាក់ទោសគាត់ឲ្យជាប់ពន្ធនាគារចំនួន៥ឆ្នាំ ។ មតិភាគច្រើននៃសាលាជម្រះនេះសម្រេចថាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមានភាពធ្ងន់ធ្ងរជាងឧក្រិដ្ឋកម្មសង្គ្រាម ។ (ការសម្រេចពិសេសបែបនេះដែលជាការកំណត់នូវឋានានុក្រមបទឧក្រិដ្ឋ ត្រូវបានអង្គតុលាការមួយចំនួនបដិសេធចោល ហើយបញ្ហានេះនៅមិនទាន់ដោះស្រាយបាននៅឡើយទេ) ។

## វឌ្ឍអាដ្វា និង ជីឡាលិក ព្រមទាំងអ្នកដទៃទៀត

នេះគឺជាជាការជំនុំជម្រះលើកដំបូងនៅក្នុងសាលាក្តីដែលចោទប្រកាន់ចុងចោទពីបទទទួលខុសត្រូវដោយការបញ្ជា ។ នៅក្នុងករណីនេះ ជនជាតិមូស្លីម-ប៊ូស្នៀ និង ក្រូអាត ចំនួន៤នាក់ដែលមានតួនាទីផ្សេងៗគ្នានៅក្នុងក្របខណ្ឌអាជ្ញាធរនៅក្នុងជំរំគុកសេឡេប៊ីស៊ី ដែលជាកន្លែងឃុំឃាំងដែលល្បីថាមានអំពើឃោរឃៅកើតឡើងមកលើជនជាតិស៊ើប-ប៊ូស្នៀដែលគេឃុំខ្លួនត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋសង្គ្រាមផ្សេងៗគ្នា ។ មានម្នាក់ត្រូវបានលើកលែងការចោទប្រកាន់ទាំងអស់ ហើយបីនាក់ផ្សេងទៀតត្រូវបានកាត់ឲ្យជាប់ទោសពីបទបានប្រព្រឹត្តឧក្រិដ្ឋកម្មដោយខ្លួនឯង ឬ ទទួលខុសត្រូវក្នុងឋានៈជាអ្នកដាក់បញ្ជាឲ្យកូនចៅអនុវត្ត ។

សាលាជម្រះក្តីបានសម្រេចថាទោះជាអ្នកដាក់បញ្ជានោះជាយោធាឬស៊ីវិលក្តី សុទ្ធតែអាចទទួលខុសត្រូវព្រហ្មទណ្ឌចំពោះសកម្មភាពរបស់អ្នកនៅក្រោមបង្គាប់ដោយឈរលើមូលហេតុនៃតួនាទីជា អាជ្ញាធរដែលមានអំណាចតាមព្រឹត្តន័យឬអំណាចតាមច្បាប់ ។ ក្នុងការកំណត់សម្រេចសាលក្រមសាលាជម្រះ (ថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨) បញ្ជាក់ថា អ្នកដាក់បញ្ជាត្រូវតែ "មានមធ្យោបាយគ្រប់គ្រងដោយប្រសិទ្ធភាពទៅលើជនដែលប្រព្រឹត្តអំពើឃោរឃៅដែលបានលើកឡើង ដែលរំលោភច្បាប់មនុស្សធម៌អន្តរជាតិនៅក្នុងន័យដែលមានលទ្ធភាពខាងសម្ភារៈគ្រប់គ្រាន់ក្នុងការទប់ស្កាត់និងផ្តន្ទាទោសការប្រព្រឹត្តបទល្មើស" ។ អង្គជំនុំជម្រះរកឃើញថា អ្នកដាក់បញ្ជាអាចទទួលរងនូវការទទួលខុសត្រូវព្រហ្មទណ្ឌតែនៅពេលណាដែលជនជាប់ចោទម្នាក់មានការដឹងឮពិតប្រាកដថាអ្នកនៅក្រោមបង្គាប់ខ្លួនកំពុងតែប្រព្រឹត្តឬហៀបតែនឹងប្រព្រឹត្តឧក្រិដ្ឋកម្ម (ដែលអាចកំណត់បានតាមរយៈភស្តុតាងផ្ទាល់ឬភស្តុតាងប្រយោល) ឬ"នៅពេលដែលគាត់មានពត៌មានអំពីសារជាតិនៃស្ថានការណ៍នោះដែលយ៉ាងហោច

ណាស់ធ្វើឲ្យគាត់ដឹងនូវហានិភ័យនៃបទល្មើសដែលតម្រូវឲ្យមានការស៊ើបអង្កេតបន្ថែម» ។

សាលាជម្រះក្តីសន្និដ្ឋានថា អ្នកដាក់បញ្ជាមិនអាចចេះតែ «ធ្វើគេធ្វើពុលតាមតែចិត្តឯង»ចំពោះអំពើរបស់អ្នកនៅក្រោមបង្គាប់នោះទេ ហើយមិនអាចធ្វើមិនដឹងមិនឮចំពោះពត៌មានដែលបញ្ជាក់ប្រាប់ថាកូនចៅរបស់ខ្លួនអាចនឹងប្រព្រឹត្តអំពើឧក្រិដ្ឋនោះឡើយ ។ សាលាជម្រះក្តីសន្និដ្ឋានចុងក្រោយថា អ្នកដាក់បញ្ជាអាចទទួលខុសត្រូវព្រហ្មទណ្ឌប្រសិនបើ«ពត៌មានជាក់លាក់មួយចំនួនត្រូវគាត់ទទួលបាន» ធ្វើឲ្យគាត់ដឹងនូវពត៌មានអំពីបទល្មើសដែលប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់ ។ ពត៌មានមិនចាំបាច់មានលក្ខណៈយ៉ាងប្រាកដប្រជាទេ ។ ប្រសិនបើពត៌មានចង្អុលបង្ហាញពត៌មានបន្ថែមដែលមានលក្ខណៈចាំបាច់ក្នុងការរកឲ្យឃើញថាតើឧក្រិដ្ឋកម្មនោះត្រូវបាន (ឬហៀបតែនឹង) ប្រព្រឹត្តដោយកូនចៅនៅក្រោមបង្គាប់នោះ ប្រការនេះមានន័យគ្រប់គ្រាន់តម្រូវឲ្យអ្នកដាក់បញ្ជាធ្វើការស៊ើបអង្កេត ។

សាលដីការបស់សាលាឧទ្ធរណ៍ (ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ ២០០១) យល់ស្រចជាមួយនឹងការវាយតម្លៃរបស់សាលាជម្រះទៅលើការទទួលខុសត្រូវនៃការបញ្ជា ។ បន្ថែមពីលើនេះទៀត សាលដីកា បានពិចារណាថាតើវាជាការសមស្របដែរឬទេក្នុងការសម្រេចចោទប្រកាន់ទៅលើចុងចោទទាំងបីតាមមាត្រាជាច្រើននៃលក្ខន្តិកៈច្បាប់ពីបទឧក្រិដ្ឋប្រឆាំងប្រជាជនដូចគ្នាដោយផ្អែកលើសកម្មភាពដូចគ្នា ឧទាហរណ៍ ចំពោះមនុស្សឃាតជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (មាត្រា៥ក) និងឃាតកម្មដោយចេតនាជាការរំលោភធ្ងន់ធ្ងរ (មាត្រា២ក) ។ សាលាឧទ្ធរណ៍សម្រេចថា «ការចោទប្រកាន់ជាច្រើនក្រោមបទបញ្ញត្តិផ្សេងៗគ្នា ប៉ុន្តែដែលផ្អែកលើទង្វើតែមួយអាចអនុញ្ញាតបានតែក្នុងករណីបទបញ្ញត្តិតាមច្បាប់កំណត់មានធាតុផ្សំសម្ភារៈផ្សេងគ្នាដែលមិនមានចែងនៅក្នុងបទបញ្ញត្តិច្បាប់ផ្សេងទៀត ។ ធាតុផ្សំមួយមានលក្ខណៈសម្ភារខុសគ្នាពីធាតុផ្សំមួយទៀតប្រសិនបើធាតុផ្សំនោះតម្រូវឲ្យមានភស្តុតាងអង្គហេតុដែលធាតុផ្សំមួយទៀតមិនតម្រូវឲ្យមាន» ។ ឧទាហរណ៍ ទារុណកម្មអាចជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផង (ផ្នែកមួយនៃការវាយប្រហារដោយទ្រង់ទ្រាយធំ ឬជាប្រព័ន្ធមកលើប្រជាជនស៊ីវិល) និង«ជាការរំលោភធ្ងន់ធ្ងរ»ផង

ទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ប៉ុន្តែបុគ្គលដែលត្រូវចោទប្រកាន់តាមច្បាប់ទាំងពីរនេះនឹងទទួលទោសនៅពេលតែមួយមិនមែនទទួលទោសចប់មួយ ហើយត្រូវទទួលទោសមួយដំណាក់ទៀតទៅតាមបទល្មើសពីរនោះទេ ។

### រដ្ឋអាជ្ញា និង ហ្វ៊ុរុនហ្សីចា

ការជំនុំជម្រះនេះកំណត់នូវធាតុផ្សំនៃការរំលោភនៅក្នុងច្បាប់អន្តរជាតិ ។ រឿងក្តីនេះផ្តោតសំខាន់ទៅលើមេបញ្ជាការថ្នាក់មូលដ្ឋាននៃអង្គភាពកងអាវុធហត្ថក្រូអាត-ប៊ូស្នៀដែលត្រូវចោទប្រកាន់តាមមាត្រា៣នៃច្បាប់នេះ ជាមួយនឹងទារុណកម្ម ព្រមទាំង «ការប្រមាថជាទម្ងន់ទៅលើសេចក្តីថ្លៃថ្នូររបស់បុគ្គល» ចំពោះការសួរចម្លើយស្ត្រីមួយរូបខណៈដែលសហការីម្នាក់កំពុងតែរំលោភផ្លូវភេទលើស្ត្រីនោះម្តងហើយម្តងទៀត ។ ក្រោយពីធ្វើការស្ទាបស្ទង់យ៉ាងទូលំទូលាយទៅលើច្បាប់ក្នុងស្រុក និងច្បាប់ទម្លាប់ និងបទដ្ឋាននានា អង្គជំនុំជម្រះបានចេញសាលក្រមរបស់ខ្លួន (ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៩៨) ដោយប្រកាសនូវធាតុផ្សំនៃបទល្មើសរំលោភក្នុងច្បាប់អន្តរជាតិដូចខាងក្រោមនេះ

**១) ការដាក់បញ្ចូលទោះជាបន្តិចក៏ដោយ:**

ក) ទៅក្នុងអង្គជាតិប្រដាប់ភេទរបស់ជនរងគ្រោះដោយអង្គជាតិរបស់ចារីឬវត្ថុផ្សេងទៀតដែលចារីបានប្រើ ឬ ខ) ទៅក្នុងមាត់របស់ជនរងគ្រោះដោយអង្គជាតិរបស់ចារី

**២) ដោយបង្ខំ ឬដោយប្រើកម្លាំង ឬការគម្រាមកំហែងមកលើជនរងគ្រោះឬបុគ្គលទីបី ។**

ធាតុផ្សំទាំងនេះមានការរំលោភតាមផ្លូវយោនីឬតាមទ្វារធំនិងការបៀមឬជញ្ជក់លិង្គ ហើយរួមទាំងការរំលោភរបស់បុរស ។ វាក៏ជាការសំខាន់ដែរដែល ហ្វ៊ុរុនហ្សីចា មិនបានរំលោភដោយផ្ទាល់ទៅលើជនរងគ្រោះ ។ ដោយរកឃើញថា ស្ត្រីជាជនរងគ្រោះត្រូវបានធ្វើទារុណកម្មដោយការរំលោភ ហ្វ៊ុរុនហ្សីចា ត្រូវបានតុលាការរកឃើញថាមានកំហុសក្នុងឋានៈជាសហចារីប្រព្រឹត្តទារុណកម្មនិងជាអ្នកជ្រោមជ្រែងឲ្យប្រព្រឹត្តបទរំលោភ ពីព្រោះវត្តមានរបស់ ហ្វ៊ុរុនហ្សី ចាពាក្យសម្តី និងអំពើអកមរបស់គាត់ត្រូវបានតុលាការសម្រេចថាបានជួយបង្កលក្ខណៈងាយស្រួលដល់អំពើហិង្សាផ្លូវភេទបែបនេះ ។ សេចក្តីវិនិច្ឆ័យនេះត្រូវប្តឹងឧទ្ធរណ៍ (នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០០) ។

### រដ្ឋអាជ្ញា និង គូណារ៉ាក់ ព្រមទាំងអ្នកដទៃទៀត

នេះគឺជាការជំនុំជម្រះដោយតុលាការកំពូលអន្តរជាតិលើកដំបូងទាក់ទងនឹងអំពើទាសភាពជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ មេបញ្ជាការឬមេបញ្ជាការរងទាហានប៉ារ៉ាស៊ើប-ប៊ូស្នៀ ត្រូវបានចោទប្រកាន់ពីអំពើហិង្សាលើផ្លូវភេទជាច្រើនទម្រង់ផ្សេងគ្នាមកលើស្ត្រីជនជាតិមូស្លីមនិងយុវនារីរស់នៅទីក្រុងហ្វូកានៅអំឡុងពេលមានជម្លោះ ។ មេបញ្ជាការពីរនាក់ត្រូវបានកាត់ឲ្យជាប់ចោទពីបទរំលោភ និងអំពើទាសភាពជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិចំពោះអំពើដែលនាំទៅដល់ទាសភាពផ្លូវភេទ ។ នៅក្នុងសាលក្រមរបស់ខ្លួន (ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០០១) សាលាជម្រះក្តីសម្រេចថា "អំពើពិរុទ្ធទាសភាព" គឺជាការអនុវត្តនូវអំណាចខ្លះឬអំណាចទាំងអស់នៃសិទ្ធិរបស់បុគ្គល ។ បំណងឧក្រិដ្ឋនៃការរំលោភមាននៅក្នុងការអនុវត្តដោយចេតនាទៅលើអំណាចនោះ" ។ អង្គជំនុំជម្រះនេះបានឲ្យឧទាហរណ៍អំពីកត្តាមួយចំនួន ដូចជារយៈពេលនៃការជាប់ទោសនិងកម្រិតនៃការគ្រប់គ្រងដែលអាចយកមកគិតគូរក្នុងការកំណត់ថាតើទាសភាពត្រូវបានប្រព្រឹត្តដែរឬទេ ។

**ខេលលី អាសគីន**

**កម្មវិធីឧក្រិដ្ឋកម្មសង្គ្រាម**

# លិខិតចំហទីពីររបស់ខៀវសំផន




### ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៣

ដូចបងប្អូនរួមជាតិជ្រាបស្រាប់ហើយក្នុងរយៈបីទសវត្សរ៍កន្លងមកនេះ ប្រទេសយើងបានឆ្លងកាត់សភាពការណ៍បត់បែនស្មុគស្មាញប្រកបទៅដោយគ្រោះថ្នាក់និងទុក្ខសោកវេទនាក្រៃលែង ។

បងប្អូនរួមជាតិយើងភាគច្រើនក៏ជ្រាបផងដែរថា នៅផ្លូវបត់និមួយៗដែលប្រកបទៅដោយគ្រោះថ្នាក់នៃប្រវត្តិសាស្ត្ររបស់ប្រទេសយើង ក្នុងរយៈពេលនោះខ្ញុំបានឈរនៅខាងកម្លាំងដែលខ្ញុំសំឡឹងមើលទៅឃើញថា ទោះបីមានទំនាស់ដ៏ធ្ងន់ធ្ងរក្នុងអំពើប្រព្រឹត្តរបស់កម្លាំងនោះ ឬរបស់បុគ្គល ឬក្រុមដឹកនាំរបស់កម្លាំងនោះក៏ដោយ ក៏ស្ថិតនៅជាកម្លាំងជាតិជាមូលដ្ឋាន ពីព្រោះកម្លាំងនោះខិតខំតស៊ូដើម្បីការពារអធិបតេយ្យនិងបូរណភាពដែនដីកម្ពុជា ។

ប៉ុន្តែប្រទេសយើងបានទទួលមត៌កមួយដ៏ធ្ងន់ធ្ងរពោរពេញទៅដោយគំនិតគំគួននិងសេចក្តីតក់ស្លុតបន្សល់ទុកដោយចលនាបដិវត្តមួយដែលបានប្រែប្រួលជាចលនាមួយជ្រុលហួសប្រព្រឹត្តអំពើហឹង្សាខ្លាំងក្លាលើសពីចលនាបដិវត្តដែលគេធ្លាប់ស្គាល់ហូរហែមកនៅក្នុងសកលលោកទៅទៀត បណ្តាលឲ្យស្លាប់បាត់បង់ជីវិតនិងឈឺចាប់ខ្លោចផ្សារកទីបំផុតគ្មាន ។

នៅក្នុងព្រឹត្តិការដ៏អណោចអធ័មនេះតើខ្ញុំរួមទទួលខុសត្រូវកំរិតណា? តើខ្ញុំបានធ្វើអ្វីខ្លះដើម្បីរស់នៅពេលដែលគេទាំងអស់គ្នាផ្សេងទៀតស្លាប់អស់ជាច្រើនទៅហើយនោះ? នៅចំពោះមុខសំនួរនេះ ខ្ញុំសូមបងប្អូនរួមជាតិស្រាវជ្រាវពិនិត្យឲ្យបានល្អិតល្អន់ហើយវិនិច្ឆ័យមកលើរូបខ្ញុំចុះ ។

នៅពេលនេះ ខ្ញុំសូមបងប្អូនរួមជាតិអនុញ្ញាតិឲ្យខ្ញុំជំរាបបន្ថែម

លើសំបុត្រចំហរបស់ខ្ញុំចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០១ដូចតទៅៈ

ដោយការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងបាន ធ្វើឲ្យខ្ញុំរន្ធត់ចិត្តស្មុគស្មាញនិងទំនាស់ក្នុងខ្លួនរកគិតអ្វីមិនឃើញ ខ្ញុំក៏ពុំអាចហាមាត់និយាយស្តីអ្វីបានទេដើម្បីប្រឆាំងនិងអំពើហិង្សាដែលបានប្រព្រឹត្តទៅយ៉ាងនេះក្នុងនាមខ្ញុំ ប៉ុន្តែអ្វីដែលខ្ញុំអាចជម្រាបបងប្អូនរួមជាតិបាន គឺនៅពេលនោះខ្ញុំមិនបានបណ្តោយខ្លួនឲ្យធ្លាក់ទៅក្នុងឱកាសនិយមដ៏គួរឲ្យខ្ពើមរអើមដោយរកតែឱកាស“បានឡើងបុណ្យ”លើគំនរសាកសពបងប្អូនរួមជាតិស្លូតត្រង់ផ្សេងទៀតនោះទេ ។ ដូចខ្ញុំបានជម្រាបហើយ ខ្ញុំមិនមែនទទួលងារជាប្រធានមានតែឈ្មោះនៃកម្ពុជាប្រជាធិបតេយ្យដោយរីករាយពេញចិត្តនោះទេ ប៉ុន្តែសតិសម្បជញ្ញៈរបស់ខ្ញុំបញ្ជាឲ្យខ្ញុំរួមចំណែកការពារសិទ្ធិរបស់ប្រទេសខ្ញុំក្នុងឋានៈជាជាតិមួយអធិបតេយ្យក្នុង“ព្រំដែនបច្ចុប្បន្នរបស់ខ្លួន”តែប៉ុណ្ណោះ តាមលទ្ធភាពនិងសភាពការណ៍ជាក់ស្តែងរបស់ខ្ញុំ ។

ម្យ៉ាងទៀត ខ្ញុំសូមជំរាបជូនបងប្អូនរួមជាតិបន្ថែមទៀតថា ទោះបីខ្ញុំតំណាងឲ្យការតស៊ូនៅក្នុងប្រទេស ហើយបន្ទាប់មកទៀតខ្ញុំជាប្រធានកម្ពុជាប្រជាធិបតេយ្យក៏ដោយ ខ្ញុំរស់នៅតែមួយកន្លែងក្នុងវង្វង់មួយចង្អៀតស្ទើរតែទាំងស្រុងមិនត្រឹមតែនៅក្នុងរយៈពេលដែលខ្ញុំត្រូវលាក់ខ្លួនពួនអាត្មាដើម្បីកុំឲ្យប៉ូលីសចាប់ខ្ញុំបានប៉ុណ្ណោះទេ ប៉ុន្តែក្រោយជ័យជំនះរបស់ខ្មែរក្រហមថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ក៏នៅតែដូច្នេះដែរ ។ ការដែលខ្ញុំសុខចិត្តទទួលគោរពវិន័យដែលនាំឲ្យខ្ញុំស្ថិតនៅដាច់ពីគេឯងមិនបានដឹងរឿងពិតទាំងប៉ុន្មានដែលបានកើតមាននៅក្នុងប្រទេសនៅពេលនោះ អាចនាំឲ្យបងប្អូនរួមជាតិយើងខ្លះលើកសំនួរមកខ្ញុំដូចតទៅៈ“លោកមិនបានដឹងរឿងអ្វីជាការពិតមែនហើយ តែនេះគឺមកពីលោកមិនបានរកដឹងរកពុ” ។ ខ្ញុំសូមជូនចម្លើយឬហេតុផលរបស់ខ្ញុំដូចតទៅៈ

ហេតុផលទី១គឺមកពីការមើលឃើញរបស់ខ្ញុំចំពោះចលនាខ្មែរក្រហម ។ ខ្ញុំសង្ឃឹមថាខ្ញុំនឹងមានឱកាសជំរាបជូនឲ្យបានល្អិតជាងនេះអំពីការករកើតនិងរីកលូតលាស់របស់ចលនានេះ ដែលខ្ញុំបានឃើញក្រោយព្រឹត្តិការណ៍ឆ្នាំ១៩៦៧បានបង្ខំឲ្យខ្ញុំរត់គេចខ្លួនពីទីក្រុងភ្នំពេញមកនៅក្រោមកិច្ចការពាររបស់ចលនានេះ ។ នៅពេលនេះ ខ្ញុំគ្រាន់តែសុំជំរាបថា ជ័យជំនះរបស់ខ្មែរក្រហមនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បានបញ្ជាក់ចំពោះខ្ញុំអំពីលក្ខណៈស្នេហាជាតិដ៏ពិតៗនៃចលនានេះ និងសមត្ថភាពចលនានេះរៀបចំនិងអនុវត្តយុទ្ធសាស្ត្រសមស្របនៅចំពោះមុខកម្លាំងដ៏ធំធេងដែលប្រឆាំងនឹងសំណូមពរចង់រក្សាការពារឯករាជ្យអធិបតេយ្យភាពរបស់ប្រទេសយើង ។ នៅក្នុងយុទ្ធសាស្ត្រនេះការរៀបចំកម្លាំងនៅជនបទមានតួនាទីសំខាន់ណាស់ ។ នៅចំពោះមុខអ្នកដែលបានរៀបចំឲ្យទទួលបានជ័យជំនះយ៉ាងនេះ-ជ័យជំនះដែលពុំអាចនឹកស្មានបានបើគេគិតទៅដល់ការប្រៀបធៀបកម្លាំងនៅពេលដែលត្រូវតស៊ូទល់នឹងវិទ្ធានុភាពដ៏ធំធេងនៃសហរដ្ឋអាមេរិកផងនិងឆន្ទៈរបស់វៀតណាមចង់ត្រួតត្រាកម្ពុជាផងនោះ-ខ្ញុំយល់ឃើញថាខ្ញុំត្រូវតែសុភាពរាបសារ ។

មួយផ្នែកទៀត ទោះបីខ្ញុំមិនសូវបានដើរនៅក្នុងឆ្នាំ៧៥-៧៩ ក៏ដោយ ខ្ញុំក៏បានឃើញផ្ទាល់នឹងភ្នែកនូវសមិទ្ធិខ្លះដែលខ្ញុំរមែងចង់បានយូរមកហើយ ដូចជាការស្រោចស្រពជនបទដោយបង្វែរទឹកចេញពីអាងត្រពាំងថ្ម (ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ) និងកំពីងពួយ (ខាងលិចបាត់ដំបង) ព្រមទាំងវាលស្រែរៀបស្មើជាក្រឡាឈើត្រង់ដាច់កន្ទុយភ្នែក ។ ទាំងអស់នេះហើយដែលនាំឲ្យខ្ញុំជឿទុកចិត្តលើរបបនេះ ហើយគោរពដល់វិញ្ញាណខណ្ឌរបស់យុទ្ធជនរាប់សែននាក់ដែលបានពលិកម្មទៅព្រមទាំងគោរពដល់បងប្អូនទាំងអស់ដែលកំពុងខិតខំនឿយហត់ធ្វើការតាមការដ្ឋាន ។ ឯផ្ទាល់ខ្លួនខ្ញុំមិនដែលបានទៅនឿយហត់នឹងគេ ខ្ញុំយល់ឃើញថាខ្ញុំត្រូវខិតខំធ្វើអ្វីដែលខ្ញុំអាចធ្វើបាន ដើម្បីរួមចំណែកជាមួយគេដូចជា ខិតខំសន្សំសំចៃក្នុងការរស់នៅប្រចាំថ្ងៃ ហើយយ៉ាងហោចណាស់ក៏ខិតខំជៀសវាងមិនធ្វើអ្វីទាំងអស់ដែលអាចនាំឲ្យអំពល់រំខានដល់គេ ឬរារាំងដល់ការខិតខំប្រឹងប្រែងរបស់គេ ។

ទាំងអស់នេះហើយដែលនាំឲ្យបញ្ញាជនមួយរូបដូចជារូបខ្ញុំសុខចិត្តទទួលគោរពវិន័យដែលតម្រូវឲ្យម្នាក់ៗរស់នៅដាច់ពីគ្នា ហើយខិតខំបំពេញភារៈកិច្ចរបស់ខ្លួនរៀងៗខ្លួន ដោយនឹកស្មានថាវិន័យដ៏តឹងរឹងរបៀបនេះគ្រាន់តែជាបណ្តោះអាសន្នប៉ុណ្ណោះ ក្នុងសភាពការណ៍ដែលប្រទេស យើងត្រូវខ្ទេចខ្ទាំដោយសារសង្គ្រាមតម្រូវអោយអ្នកណានៅកន្លែងណានៅកន្លែងនោះសិន ហើយវិន័យនេះនឹងត្រូវបានបន្ធូរមកវិញជាបណ្តើរៗនៅពេលដែលសភាពការណ៍កាន់តែបានប្រសើរឡើងវិញជាបណ្តើរៗ ។

ម្យ៉ាងទៀត ខ្ញុំយល់ឃើញថា កាលពីខ្ញុំធ្វើតំណាងរាស្ត្រ

ខ្ញុំបានខិតខំអស់ពីចិត្តពីថ្ងៃធ្វើការដើម្បីកសិករ ប៉ុន្តែខ្ញុំមិនចេះធ្វើការជាមួយកសិករដូចដែលខ្មែរក្រហមគេបានធ្វើទេ ។ ខ្ញុំយល់ឃើញថា ធ្វើការជាមួយកសិករជាវិធីតែមួយគត់ដែលអាចគាស់ឲ្យចេញជាចលនាកសិករមួយពិតប្រាកដដើម្បីកសិករចេះរួបរួមគ្នាការពារផលប្រយោជន៍របស់គេដោយខ្លួនគេទាំងខាងផ្នែកសេដ្ឋកិច្ចទាំងខាងផ្នែកសង្គម ។ នេះហើយដែលខ្ញុំគោរពសរសើរដល់អ្នកដែលគេចេះគាស់ឲ្យចេញជាកំលាំងដែលប្រយុទ្ធបានដើម្បីការពារឯករាជ្យជាតិ- ហើយជាការសង្ឃឹមរបស់ខ្ញុំនៅពេលនោះផងដែរ ដើម្បីឲ្យប្រទេសរីកចំរើនទៅមុខបាន ។

ទោះបីខ្ញុំគិតដូច្នេះក៏ដោយ ក៏ខ្ញុំមានមនោសញ្ចេតនាព្រួយបារម្ភដែរដោយសម្លឹងមើលទៅឃើញថា វាសនារបស់ប្រទេសត្រូវស្ថិតនៅក្នុងកណ្តាប់ដៃរបស់មនុស្សមួយក្រុមតូចយ៉ាងដូច្នេះ ។ ប៉ុន្តែអ្វីដែលនាំអោយខ្ញុំមានការកក់ក្តៅគឺមកពីខ្ញុំឃើញថា ប៉ុល ពត បានបូជាអស់មួយជីវិតរបស់គាត់ដើម្បីរ៉ាប់រងការទទួលខុសត្រូវនេះ ។ ដង្ហើមចិញ្ចូលរបស់គាត់គឺដើម្បីតែការតស៊ូនេះ ។ ឥឡូវនេះ ពេលនេះជាការងាយស្រួលទេក្នុងការបន្ទោសខ្ញុំ ។ ប៉ុន្តែរកផ្លូវដើរឲ្យបានត្រូវក្នុងសភាពការណ៍នៃប្រវត្តិសាស្ត្រជាតិយើងនាពេលនោះពិតជាលំបាកណាស់ ។

ទោះបីខ្ញុំបានខិតខំគោរពវិន័យប៉ុណ្ណឹងហើយ ក៏មានកម្មាភិបាលខ្លះសើចចំអកខ្ញុំ ដោយចាត់ទុកខ្ញុំថាខ្ញុំ«ដាច់ពីចលនា»«ដាច់ពីមហាជន» (តើចលនា? តើមហាជន? ខ្ញុំនៅមិនទាន់យល់ច្បាស់លាស់នៅឡើយទេ) ។ ឧទាហរណ៍ ជំហររស្មោកស្មើររបស់ខ្ញុំចំពោះការជម្លៀសប្រជាជនចេញពីទីក្រុងត្រូវគេចាត់ទុកថាជាភស្តុតាងបញ្ជាក់ច្បាស់អំពីធាតុបញ្ញាជន«អនុធន»របស់ខ្ញុំ ហើយថាខ្ញុំមិនងាយយល់ចលនាតស៊ូរបស់មហាជនទេ ។ ហើយសូម្បីតែពេលនោះ លើបញ្ហាជាក់ស្តែងនេះ ក៏ខ្ញុំនៅតែគោរពវិន័យរួមដែលហាមមិនឲ្យនិយាយហួរហែដោយ«មិនទទួលខុសត្រូវ» ។ ពេលនោះ ខ្ញុំគិតយ៉ាងណាៗ ព្រួយបារម្ភយ៉ាងណាៗ ខ្ញុំនិយាយតែជាមួយ«អង្គការ»គឺ ប៉ុល ពត តែប៉ុណ្ណោះ ។

សុំជំរាបដោយត្រង់ទៅ រហូតមកដល់ពេលថ្មីៗនេះខ្ញុំមិននឹកស្មានថារបបនេះប្រើតែកម្លាំងកំរោលយ៉ាងនេះសោះ ។ ពីមុនខ្ញុំនឹកស្មានថាអាចមានការប្រហូកប្របល់ដោយជៀសមិនផុត ពីព្រោះទើបតែចេញពីសង្គ្រាមតឹងតែងយ៉ាងនេះ វាតែងតែមានសតិអារម្មណ៍ខ្លាចខ្លាំងធ្វើវិច្ឆេទកម្មអញ្ចឹងហើយ តែម្យ៉ាងទៀតក៏មកពីការប្រញាប់ប្រញាល់ចាត់តាំងសហករណ៍នាំឲ្យឆៅទៀត ក្នុងន័យថាគ្មានពេលវេលាគ្រប់គ្រាន់ដើម្បីអប់រំកសាងជ្រើសរើសប្រធានសហករណ៍ឲ្យបានហ្មត់ចត់ផង ក៏ស្រាប់តែប្រគល់អំណាចដ៏ធំសម្បើមឲ្យអ្នកទាំងនោះ ។ ឥឡូវនេះខ្ញុំនៅតែយល់ថាកត្តាទាំងនេះជាកត្តាសំខាន់ដែលនាំឲ្យកើតចេញជារឿងចោទប្រកាន់មនុស្សនិងសម្លាប់មនុស្សដោយផុយៗយ៉ាងនេះ ។ ប៉ុន្តែខ្ញុំសុំសារភាពថា ខ្ញុំទើបតែឃើញលក្ខណៈជាខ្សែសង្វាក់នៃការរាតត្បាតចាប់ចងនៅពេលថ្មីៗនេះទេ ហើយខ្ញុំនិយាយឲ្យច្បាស់តែម្តងទៅគឺនៅពេលដែលខ្ញុំមើលខ្សែភាពយន្តរបស់លោក រិទ្ធី ប៉ាន់ ដែលមានចំណងជើងថា «ស២១កន្លែងខ្មែរក្រហមសម្លាប់មនុស្ស» ។ នៅឆ្នាំ១៩៧៥-៧៨ខ្ញុំមិនដែលស្គាល់ ហើយក៏មិនដែលឮនិយាយពី«ស២១»ទាល់តែសោះទេ ។ ប៉ុន្តែរឿងនេះវាជារឿងមួយទេ ។ ឥឡូវនេះខ្ញុំយល់ថា ស២១នេះជាស្ថាប័នរបស់រដ្ឋដែលមានទីតាំងនៅភ្នំពេញ ។ ដូច្នេះមិនអាចនិយាយពីការ«ក្រឡាប់»រឺជាការចៃដន្យទេ ។ វាពិតជាផ្នែកមួយនៃរបបនេះ ។

*****

តទៅនេះ ខ្ញុំសុំជម្រាបបន្ថែមខ្លះទៀត ។ រឿងនេះទាក់ទងដល់បងប្អូនរួមជាតិយើងភាគច្រើនផង ព្រមជាមួយនេះក៏អាចទាក់ទងដល់មនុស្សជាច្រើនទៀតឆ្ងាយពីកម្ពុជាផងដែរ ។

នៅក្នុងរយៈពេលបីទសវត្សរ៍កន្លងមកនេះ- ហើយខ្ញុំនិយាយយ៉ាងនេះមិនមានន័យថាខ្ញុំមើលស្រាលទិដ្ឋភាពផ្ទៃក្នុងនៃបញ្ហាដែលបានកើតមាននៅក្នុងប្រទេសយើងនោះទេ- ទុក្ខសោកវេទនារបស់ប្រទេសយើងមួយចំណែកធំក៏មកពីការខិតខំប្រឹងប្រែងដើម្បីឲ្យប្រទេសយើងបានរស់នៅជាប្រទេសឯករាជអធិបតេយ្យក្នុងបូរណភាពដែនដីរបស់ខ្លួនផងដែរ ។

ទិដ្ឋភាពនៃសភាពការណ៍ដែលអធិបតេយ្យភាពរបស់ប្រទេសយើងត្រូវគំរាមកំហែងពីសំណាក់សហរដ្ឋអាមេរិកផង ពីសំណាក់វៀតណាមផងនោះ មានតួនាទីមួយសំខាន់ក្នុងការជំរុញឲ្យចលនាខ្មែរក្រហមមានលក្ខណៈដាច់ខាតយ៉ាងនេះ ។ ឆ្នាំ១៩៧៣អាចជាដំណាក់កាលមួយសំខាន់នៃការប្រែប្រួលនេះ ។ នៅឆ្នាំនោះខ្មែរក្រហមត្រូវជួបប្រទះនិងបញ្ហាមួយដ៏ធ្ងន់ធ្ងរដូចតទៅៈ

ពេលនោះបើខ្មែរក្រហមសុខចិត្តឈប់បាញ់ហើយចរចា

ជាមួយ លន់ ណុល ពួកកុម្មុយនីស្តវៀតណាមចង់បានគឺខ្មែរក្រហមត្រូវដើរតាមកន្ទុយពួកកុម្មុយនីស្តវៀតណាមរហូតហើយ គឺដូចជាប្រគល់វាសនាប្រទេសកម្ពុជាទៅក្នុងកណ្តាប់ដៃវៀតណាមដូច្នេះឯង ។ ម្យ៉ាងទៀតផ្នែកមួយសំខាន់នៃយុទ្ធសាស្ត្ររបស់អាមេរិក នៅពេលដែលគេចុះហត្ថលេខាលើកិច្ចព្រមព្រៀងឈប់បាញ់គឺរក្សាទុកកម្ពុជាឲ្យនៅក្នុងវង្វង់ឥទ្ធិពលរបស់គេ ដោយរក្សាការពារលន់ ណុល ឲ្យនៅកាន់អំណាចតទៅទៀត ។ ដូច្នេះបានជាអាមេរិកទម្លាក់គ្រាប់បែកយ៉ាងសាហាវលើប្រទេសកម្ពុជានៅក្នុងឆមាសទី១នៃឆ្នាំ១៩៧៣នោះ ។

ការទម្លាក់គ្រាប់បែកយ៉ាងនេះបានធ្វើឲ្យកម្លាំងខ្មែរក្រហមខូចខាតជាទម្ងន់ តែព្រមជាមួយនេះក៏បានធ្វើឲ្យសេដ្ឋកិច្ចជនបទខ្មែរខ្ទេចខ្ទីដែលនាំឲ្យខ្មែរក្រហមមានឱកាសប្រែប្រួលសហករណ៍កម្រិតទាបដែលគេបានចាត់តាំងតាំងពីចុងឆ្នាំ១៩៧១ និងពេញមួយឆ្នាំ១៩៧២រួចមកហើយ នៅក្នុងតំបន់ដែលគេកាន់កាប់នោះឲ្យទៅជាសហករណ៍ហៅថា "កំរិតខ្ពស់" ដើម្បីធ្វើជាឧបករណ៍រដ្ឋអំណាចរបស់គេក្នុងការប្រមូលទាំងកម្លាំងមនុស្ស ទាំងកម្លាំងសេដ្ឋកិច្ច ទាំងកម្លាំងមនោគមន៍វិជ្ជា ដើម្បីយកឈ្នះសង្គ្រាម ។

ជ័យជំនះខ្មែរក្រហមថ្ងៃ១៧ មេសា ១៩៧៥ បានពង្រឹងជំនឿរបស់ ប៉ុល ពត ថាផ្លូវតែមួយគត់ដើម្បីចលនាខ្មែរក្រហមរស់ ហើយតាមរយៈនេះ កម្ពុជារស់ចំពោះមុខគ្រោះអាសន្នមកពីខាងវៀតណាម (គ្រោះអាសន្នដែលគេយល់ថាកាន់តែធ្ងន់ធ្ងរលើសពេលណាៗទាំងអស់ក្រោយពីវៀតណាមត្រូវបានបង្រួបបង្រួមហើយនោះ) មានតែជំរុញ"បដិវត្តសង្គមនិយមនិងកសាងសង្គមនិយម"ឲ្យបានឆាប់រហ័សថែមទៀត ។

ប៉ុន្តែចំពោះខ្ញុំដែលគ្មានតួនាទីអ្វីទាំងអស់ក្នុងក្រុមដឹកនាំចលនាខ្មែរក្រហម ហើយក៏គ្មានតួនាទីអ្វីទាំងអស់ក្នុងការសំរេចខាងលើនេះ ក៏ស្រាប់តែឋិតនៅចំពោះមុខបញ្ហាមួយដូចតទៅនេះ ហើយខ្ញុំយល់ឃើញថាបញ្ហានេះក៏អាចចោទនៅតំបន់ផ្សេងទៀតក្នុងសកលលោកផងដែរ ពិតមែនតែតាមរូបភាពផ្សេងៗគ្នានិងក្នុងកាលៈទេសៈផ្សេងៗគ្នា គឺថាៈ

តើចំពោះពលរដ្ឋមួយរូបដូចជារូបខ្ញុំគោរពសិទ្ធិមនុស្សនិងរួមចំណែកការពារមាតុភូមិ តើករណីយកិច្ចទាំងពីរនេះវាចេះតែស្របគ្នារៀងរហូតឬទេ? តើគេអាចសង្ឃឹមបានទេថាឲ្យតែការពារមាតុភូមិបាននោះប្រជាជននឹងអាចរកមធ្យោបាយដើម្បីដោះស្រាយកំហុសរបស់អ្នកដឹកនាំបាន? ប៉ុន្តែបញ្ហាក៏ត្រូវចោទសួរភ្លាមទៀតដែរថា បើដូច្នេះមែន តើប្រជាជននឹងត្រូវបង់ថ្លៃប៉ុន្មានទៅ? ឬមួយក៏ត្រូវបន្ទុកបណ្តាក់ឲ្យអន្តរជាតិមកជួយដោះស្រាយ? ប៉ុន្តែសហគមន៍អន្តរជាតិមិនទាន់កំណត់ឲ្យបានច្បាស់នៅឡើយទេ ថាតើ ត្រូវឈរលើមូលដ្ឋានអ្វីទើបការអន្តរាគមន៍របស់គេអាចកំណត់បានថាត្រឹមត្រូវ សមហេតុសមផល ដើម្បីធានាឲ្យមានការគោរពអធិបតេយ្យភាពជាតិនិមួយៗ ហើយបង្ការកុំឲ្យមានការរំលោភបំពានពីមហាអំណាចឬពីសំណាក់ប្រទេសជិតខាងដែលធំជាងគេបានផង?

ខ្ញុំមិនទាន់រកឃើញចម្លើយឲ្យបានពេញចិត្តខ្ញុំនៅឡើយទេ ។ ខ្ញុំគ្រាន់តែមានជំនឿជឿថា ត្រូវតែរំលេចបញ្ហានេះឡើយឲ្យច្បាស់យ៉ាងហោចណាស់ក៏ដើម្បីជាការគោរពសិទ្ធិរបស់យុវជនជំនាន់ក្រោយរៀនសូត្រពិនិត្យពិចារណាពីប្រវត្តិសាស្ត្រប្រទេសរបស់គេឲ្យបានជ្រៅជ្រះ ដោយមិនគ្រាន់តែទទួលស្គាល់ពាក្យស្លោកឬរូបមន្តស្រាប់ៗឬប្រវត្តិសាស្ត្រដែលគេកាត់យកពីនេះមួយដុំពីនោះមួយដុំតែប៉ុណ្ណោះទេ ។ ពិតមែនហើយ អ្នកដែលគិតគូរដល់ស្រុកទេសជំនាន់ខ្ញុំ ដោយរួមទាំងរូបខ្ញុំផងដែរ បើនិយាយពីទឹកចិត្តស្នេហាជាតិវិញគ្មានអ្នកណាអាចប្រកែកបានទេ តែក៏បានជាខុសជាមូលដ្ឋានទៅហើយ ។ សព្វថ្ងៃខ្ញុំមិនដឹងថាត្រូវណែនាំកូនរបស់ខ្ញុំយ៉ាងណាផងទេ ។ ខ្ញុំគិតថាទុកឲ្យវាជ្រើសរើសផ្លូវដើររបស់វាដោយផ្ទាល់ខ្លួនវាទៅចុះ ។ ប៉ុន្តែដើម្បីជៀសវាងកុំឲ្យវាវង្វេងវង្វាន់ ខ្ញុំយល់ឃើញថាគួរខិតខំដោះស្រាយភាពច្របូកច្របល់ដែលកំពុងមានសព្វថ្ងៃនេះ ស្តីពីប្រវត្តិសាស្ត្រជាតិយើងថ្មីៗនេះ ដោយម្នាក់ៗខំបញ្ចេញមតិរបស់ខ្លួន ទោះបីមតិនោះវាមិនទាន់ស្របគ្នាយ៉ាងណាក៏ដោយ ដើម្បីយុវជនយកទៅពិនិត្យពិចារណា ហើយគិតគូរជ្រើសរើសផ្លូវដើរក្នុងជីវិតរបស់ខ្លួនតទៅមុខទៀត ។

លំដាប់ណាខ្ញុំរកចម្លើយមិនទាន់ឃើញជាជម្រៅចិត្តរបស់ខ្ញុំ ខ្ញុំនៅតែគិតថា ទិសដែលបានតំរង់ខ្ញុំក្នុងមួយជីវិតរបស់ខ្ញុំកន្លងមកនេះ គឺថារួមចំណែកការពារអធិបតេយ្យភាពជាតិរបស់ខ្លួននៅតែជាការត្រឹមត្រូវជាមូលដ្ឋាន ហើយចាំបាច់នៅគ្រប់កន្លែងនិងនៅគ្រប់ពេលវេលា ។

# ការវិវឌ្ឍន៍ថ្មីៗនៃដំណើរការតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម

***អង្គការសហប្រជាជាតិមហាសន្និបាតអង្គការសហប្រជា***
***A/៥៨/៦១៧***
***ថ្ងៃទី៣ ខែធ្នូ ឆ្នាំ ២០០៣***
***ភាសាដើមៈ អង់គ្លេស***
***សម័យប្រជុំទី៥៨***
***របៀបវារៈ១១៧(ខ)***

បញ្ហាសិទ្ធិមនុស្សៈ បញ្ហាសិទ្ធិមនុស្សរួមទាំងវិធីសាស្ត្រផ្សេងៗ ក្នុងការលើកកម្ពស់ការទទួលបានដោយប្រសិទ្ធភាពនូវសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន

របាយការណ៍របស់អគ្គលេខាធិការស្តីអំពីតុលាការខ្មែរក្រហម (របាយការណ៍បណ្តោះអាសន្ននេះគឺមិនទាន់សម្រេចនៅឡើយទេ នៅរង់ចាំការវាយតម្លៃពីដំណើរទស្សនកិច្ចរបស់ក្រុមមួយនៅទីក្រុងភ្នំពេញដែលមានរយៈពេលពីខែវិច្ឆិកា ដល់ខែធ្នូ ឆ្នាំ ២០០៣ ។)

### សេចក្តីសង្ខេប

កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានចុះហត្ថលេខាដោយភាគីទាំងពីរ ហើយសព្វថ្ងៃនេះកំពុងតែរង់ចាំការផ្តល់សច្ចាប័នតាមរយៈអង្គការនីតិបញ្ញត្តិ ។ ទន្ទឹមពេលគ្នានេះដែរ ក្រុមបច្ចេកទេសអង្គការសហប្រជាជាតិនឹងមកដល់ប្រទេសកម្ពុជាដើម្បីរៀបចំគំនិតព្រាងប្រតិបត្តិការប្រមូលការវាយតម្លៃជាក់លាក់ទៅលើថវិកាដែលត្រូវចំណាយសម្រាប់អង្គជំនុំជម្រះ ព្រមទាំងបញ្ជាក់ឲ្យបានច្បាស់លាស់អំពីអគារនិងសម្ភារៈប្រើប្រាស់គ្រប់បែបយ៉ាង ។

មហាសន្និបាតអង្គការសហប្រជាជាតិត្រូវបានស្នើឲ្យកត់ត្រានូវរបាយការណ៍បណ្តោះអាសន្ននេះ ។ របាយការណ៍ពេញលេញនឹងត្រូវដាក់ជូនដោយផ្អែកទៅលើការរកឃើញរបស់ក្រុមបច្ចេកទេស ។

### សេចក្តីផ្តើម

តាមរយៈសេចក្តីសម្រេចរបស់ខ្លួនលេខ៥៧/២២៨B ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៣ មហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តទៅលើសេចក្តីព្រាងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងនៅអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងជំរុញឲ្យអគ្គលេខាធិការនិងរដ្ឋាភិបាលកម្ពុជាចាត់វិធានការចាំបាច់នានាដើម្បីឲ្យកិច្ចព្រមព្រៀងនេះចូលជាធរមាន ហើយចាប់ផ្តើមប្រតិបត្តិតែម្តង ។ មហាសន្និបាតថែមទាំងបានសម្រេចទៀតថា ការចំណាយរបស់អង្គជំនុំជម្រះវិសាមញ្ញនឹងត្រូវចេញប្រាក់ដោយអង្គការសហប្រជាជាតិដោយថវិកាស្ម័គ្រចិត្តពីសហគមន៍អន្តរជាតិ ។ មហាសន្និបាតស្នើសុំឲ្យខ្ញុំរាយការណ៍ជូននៅក្នុងសម័យប្រជុំលើកទី៥៨ ស្តីអំពីការអនុវត្តន៍សេចក្តីសម្រេចនេះ ។

### ដំណើរការផ្តល់សច្ចាប័ន

◆ កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជាត្រូវបានចុះហត្ថលេខា នៅក្នុងទីក្រុងភ្នំពេញនាថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ ដោយទេសរដ្ឋមន្ត្រី សុខ អាន ក្នុងនាមរដ្ឋាភិបាលកម្ពុជានិងទីប្រឹក្សាច្បាប់ក្នុងនាមអង្គការសហប្រជាជាតិ ។

◆ យោងតាមមាត្រា៣០នៃកិច្ចព្រមព្រៀងនេះ ឥឡូវនេះគឺចាំបាច់ឲ្យមានសច្ចាប័នពីអាជ្ញាធរច្បាប់ដែលពាក់ព័ន្ធនៅក្នុងប្រទេសកម្ពុជា ។ នៅក្នុងមាត្រាដដែលនេះ រដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចិត្តខិតខំធ្វើឲ្យបាននូវការផ្តល់សច្ចាប័នមួយឆាប់បំផុត ។

◆ នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៣ កម្ពុជាបានធ្វើការបោះឆ្នោតជ្រើសតាំងរដ្ឋសភា ។ គណបក្សប្រជាជនទទួលបានសម្លេងឆ្នោតភាគច្រើន ប៉ុន្តែមិនទទួលបានអាសនៈគ្រប់គ្រាន់សម្រាប់បង្កើតរដ្ឋាភិបាលដោយខ្លួនឯងបាន ។ នៅពេលកំពុងសរសេររបាយការណ៍នេះ ការចរចាកំពុងតែបន្តរវាងគណបក្សបីធំៗដើម្បីបង្កើតរដ្ឋាភិបាលចម្រុះ ប៉ុន្តែមកដល់ពេលនេះ ដំណើរការនីតិបញ្ញត្តិមិនទាន់ចាប់ផ្តើមនៅឡើយ ។ ស្ថិតក្រោមស្ថានភាពបែបនេះ យើងមិនអាចព្យាករណ៍ទុកជាមុនបានថាពេលណាទើបកិច្ចព្រមព្រៀងនេះទទួលបានសច្ចាប័នពី រដ្ឋសភានោះទេ ។

## ទស្សនកិច្ចវាយតម្លៃបច្ចេកទេស

◆ ការរៀបចំផ្សេងៗ បេះតែបន្តនៅក្នុងអគ្គលេខាធិការដ្ឋាន ដើម្បីធានានិងរៀបចំជំនួយដែលអង្គការសហប្រជាជាតិនឹងត្រូវផ្តល់ដល់រដ្ឋាភិបាលកម្ពុជា ទៅតាមលក្ខខណ្ឌដែលបានចែងនៅក្នុងកិច្ចព្រមព្រៀង ។ ដើម្បីឈានទៅសម្រេចគោលដៅនេះ អ្នកសម្របសម្រួលមួយរូបត្រូវបានតែងតាំងឡើង ។ កិច្ចការដំបូងរបស់លោក គឺត្រូវរៀបចំក្រុមទស្សនកិច្ចវាយតម្លៃបច្ចេកទេសមកទីក្រុងភ្នំពេញ ។ ក្រុមនេះនឹងប្រមូលពត៌មានចាំបាច់នានាក្នុងការបង្កើតគំនិតមួយសម្រាប់អនុវត្តនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ និងស្ថាប័នពាក់ព័ន្ធនានា ព្រមទាំងនឹងរៀបចំផែនការចំណាយថវិកាទូទៅដែលនឹងក្លាយជាមូលដ្ឋានសម្រាប់អំពាវនាវដល់ប្រទេសម្ចាស់ជំនួយ ។ ក្រុមនេះក៏នឹងត្រូវពិនិត្យមើលទីតាំងទាំងឡាយដែលស្នើឡើងដោយរដ្ឋាភិបាលសម្រាប់ដំណើរការអង្គជំនុំជម្រះវិសាមញ្ញពិនិត្យមើលអគារនិងសម្ភារៈប្រើប្រាស់ព្រមទាំងសេវាកម្មនានាដែលរដ្ឋាភិបាលត្រូវផ្តល់ដូចដែលមានចែងនៅក្នុងមាត្រា១៨ នៃកិច្ចព្រមព្រៀង ។ ពិនិត្យមើលតម្លៃប្រើប្រាស់ទឹក ភ្លើង ទូរស័ព្ទ អ៊ីនធឺណែត និងសេវាកម្មនានា ដែលត្រូវផ្តល់ដោយអង្គការសហប្រជាជាតិដោយយោងតាមមាត្រា១៧(ខ) រកមើលការរៀបចំអំពីសុវត្ថិភាពនិងសន្តិសុខដែលជាការទទួលខុសត្រូវរបស់អង្គការសហប្រជាជាតិ ដូចដែលមានចែងនៅក្នុងមាត្រា១៧(ង) និងកំណត់ជំនួយដែលអង្គការសហប្រជាជាតិអាចនឹងត្រូវការផ្តល់តាមមាត្រា១៧(ច) ដើម្បីធានាឲ្យបាននូវការស៊ើបអង្កេតនិងការកាត់សេចក្តីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញកុំឲ្យមានបញ្ហាកើតឡើង ។ ដូច្នេះ មកទល់នឹងពេលនេះ ថវិកាស្ម័គ្រចិត្តគឺមានត្រឹមតែគ្រប់គ្រាន់សម្រាប់ដំណើរទស្សនកិច្ចមួយនេះប៉ុណ្ណោះ ។

◆ តាមរយៈលិខិតចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៣ ក្រុមទស្សនកិច្ចវាយតម្លៃបច្ចេកទេសបានស្នើដល់រដ្ឋាភិបាលកម្ពុជាថា ទស្សនកិច្ចនេះគួរតែធ្វើឡើងនៅក្នុងសប្តាហ៍ទី២ នៃខែវិច្ឆិកា ឆ្នាំ២០០៣ ។ តាមរយៈលិខិតចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៣ រដ្ឋាភិបាលបានផ្តល់យោបល់ទៅដល់អគ្គលេខាធិការដ្ឋានថា ដោយសារមានការពិបាកក្នុងការកំណត់ថ្ងៃទស្សនកិច្ច រដ្ឋាភិបាលស្នើថា ដំណើរទស្សនកិច្ចវាយតម្លៃនេះគួរតែធ្វើឡើងក្រោយថ្ងៃទី៧ ខែធ្នូឆ្នាំ២០០៣ ។ យោងតាមការរៀបចំនេះ ក្រុមទស្សនកិច្ចវាយតម្លៃបច្ចេកទេសឥឡូវនេះកំពុងតែរៀបចំកម្មវិធីសម្រាប់ដំណើរទស្សនកិច្ចរបស់ខ្លួនពីថ្ងៃទី៨ដល់ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៣ ។

◆ ក្រោយពីការវិលត្រឡប់របស់ក្រុមទស្សនកិច្ចវាយតម្លៃបច្ចេកទេស ខ្ញុំនឹងដាក់ជូននូវរបាយការណ៍កាន់តែមានលក្ខណៈលម្អិតជូនចំពោះមហាសន្និបាត ។ ខ្ញុំនឹងសុំឲ្យសមាជិកអង្គការសហប្រជាជាតិផ្តល់នូវឈ្មោះបេក្ខជនសម្រាប់ឲ្យរដ្ឋាភិបាលកម្ពុជាជ្រើសរើសជាសហព្រះរាជអាជ្ញា អន្តរជាតិសហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងចៅក្រមអន្តរជាតិ ។ ខ្ញុំនឹងអំពាវនាវដល់រដ្ឋជាសមាជិកឲ្យផ្តល់វិភាគទានស្ម័គ្រចិត្តចូលខ្ទង់ថវិកាអាណាព្យាបាលភាពដែលបានបង្កើតឡើងដើម្បីធ្វើហិរញ្ញប្បទានរបស់អង្គការសហប្រជាជាតិគាំទ្រដល់អង្គជំនុំជម្រះវិសាមញ្ញ ។ ដូចដែលបានលើកឡើងពីខាងដើម ដំណើរការបង្កើតអង្គជំនុំជម្រះអាចចាប់ផ្តើមបានលុះត្រាណាមានថវិកាគ្រប់គ្រាន់សម្រាប់ផ្តល់ដល់បុគ្គលិកនិងប្រតិបត្តិការក្នុងរយៈពេលមួយសមស្រប ។ ខ្ញុំសូមគិតថា លក្ខខណ្ឌដែលត្រូវបំពេញគឺនៅពេលដែលមានការសន្យាឲ្យមានប្រតិបត្តិការរយៈពេល៣ឆ្នាំរបស់អង្គជំនុំជម្រះវិសាមញ្ញក៏ដូចជាវិភាគទានជាក់ស្តែងសម្រាប់ប្រតិបត្តិការឆ្នាំដំបូង ។

### សេចក្តីសន្និដ្ឋាន

ខ្ញុំមានការព្រួយបារម្ភណាស់អំពីការពន្យារពេលក្នុងការប្រតិបត្តិកិច្ចព្រមព្រៀងនេះ ហើយសូមអំពាវនាវដល់រដ្ឋាភិបាលកម្ពុជាឲ្យធានាឲ្យបានច្បាស់លាស់ថាកិច្ចព្រមព្រៀងនេះនឹងក្លាយជារបៀបវារៈអាទិភាពសម្រាប់ការផ្តល់សច្ចាប័នពីសំណាក់រដ្ឋសភាបង្កើតថ្មី ។ ទន្ទឹមពេលគ្នានេះដែរ ខ្ញុំក៏សូមអំពាវនាវដល់រដ្ឋាភិបាលកម្ពុជាឲ្យបំពេញទៅតាមផែនការដាក់ស្តែងចាំបាច់នានា និងរៀបចំកិច្ចការប្រតិបត្តិការនៃអង្គជំនុំជម្រះវិសាមញ្ញនិងស្ថាប័នពាក់ព័ន្ធដោយសហការយ៉ាងជិតស្និទ្ធជាមួយអង្គការសហប្រជាជាតិ និងសហគមន៍អ្នកផ្តល់ជំនួយ ។ ទាក់ទងនឹងបញ្ហានេះដែរ វាជាការសំខាន់ណាស់ដែលការិយាល័យរដ្ឋបាលការិយាល័យព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតឲ្យមានឆាប់ៗតាមដែលអាចធ្វើទៅបានក្រោយពីការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ។

### កំណត់សម្គាល់

មាត្រា៣២ នៃកិច្ចព្រមព្រៀងចែងថា កិច្ចព្រមព្រៀងនេះចូលជាធរមាននៅថ្ងៃបន្ទាប់ពីភាគីទាំងពីរជូនដំណឹងប្រាប់គ្នាទៅវិញទៅមកជាលាយលក្ខណ៍អក្សរថា តម្រូវការចូលជាធរមានតាមផ្លូវច្បាប់ត្រូវបានបំពេញរួចហើយ ។

# អន្តរទំនាក់ទំនងរវាងយុត្តិធម៌និងការផ្សះផ្សាជាតិៈ បទពិសោធរបស់អាហ្វ្រិកខាងត្បូងស្តីអំពី យុត្តិធម៌សម័យអន្តរកាលសម្រាប់របបអាប៉ាថេត

**(តចប់)**

សាស្ត្រាចារ្យ កាន់ដឺរ អាស្មាល់ បានព្យាយាមបង្កើតមធ្យោបាយទីបីនៅក្នុងអំឡុងពេលអន្តរកាលនយោបាយ មធ្យោបាយដែលជាចំណុចកណ្តាលរវាងភាពមិនប្រាកដនិយមនិងប្រាកដនិយម នយោបាយ ។ តាមរយៈទស្សនៈនេះ គាត់បានបង្ហាញថា បទពិសោធន៍នៅប្រទេសអាហ្វ្រិកខាងត្បូងជាគំរូ ។ នៅក្នុងការពិភាក្សាវែកញែកអន្តរជាតិអំពីយុត្តិធម៌សម័យអន្តរកាល បទពិសោធន៍របស់ប្រទេសអាហ្វ្រិកខាងត្បូងត្រូវមើលឃើញថាជាគំរូដ៏ល្អនិងស្មុគស្មាញដែលត្រូវតែយកមករៀនតាម ទោះជាគំរូនេះមានគុណវិបត្តិខ្លះក៏ដោយ ។

នៅប្រទេសអាហ្វ្រិកខាងត្បូង គណៈកម្មការស្វែងរកការពិតបានកាត់ទោសជនល្មើសមួយចំនួន ហើយនឹងកាត់ទោសបន្ថែមទៀតនៅថ្ងៃអនាគត ។ ការកាត់ទោសខ្លះក្នុងចំណោមនោះបានបរាជ័យ(ដូចជាការកាត់ទោសឧត្តមសេនីយ៍ មេកនីស ម៉ាឡាន់ និងសហការីរបស់លោក២១នាក់ទៀតនៅទសវត្សរ៍ឆ្នាំ៨០) ចំណែកការកាត់ទោសផ្សេងទៀតបានទទួលជោគជ័យ (ដូចករណីការកាត់ទោសឧក្រិដ្ឋជន យូជីន ដឺ ខក់) ។ ប៉ុន្តែគណៈកម្មការស្វែងរកការពិតក៏បានគិតថា ការពឹងផ្អែកហួសហេតុពេកទៅលើតុលាការ គឺជាការប្រើប្រាស់ធនធានរដ្ឋបាលនិងនយោបាយយ៉ាងឥតប្រយោជន៍, ការកាត់ទោសនឹងធ្វើឲ្យប៉ះទង្គិចដល់អាហ្វ្រិកខាងត្បូងនិងធ្វើឲ្យប៉ះពាល់ដល់ការបែងចែកអំណាចនិងធនធានជាថ្មី ។ ដូច្នេះគណៈកម្មការស្វែងរកការពិតបានទាមទារយល់ព្រមឲ្យមានការលើកលែងទោស ប៉ុន្តែក៏បានបដិសេធផ្តល់ការលើកលែងទោសដោយគ្មានការស្វែងរកការពិតដែរ ។ គណៈកម្មការស្វែងរកការពិតបានភ្ជាប់ការលើកលែងទោសមកជាមួយការពិតនិងទាមទារឲ្យមានការលាតត្រដាងទាំងស្រុងនូវការធ្វើខុសពីអតីតកាល ។ នៅទីបញ្ចប់ គណៈកម្មការស្វែងរកការពិតបានទទួលស្គាល់ភាពស្របច្បាប់របស់ការតស៊ូប្រឆាំងនឹងការប្រកាន់ពូជសាសន៍ និងភាពមិនស្របច្បាប់ទាំងស្រុងរបស់របបអាប៉ាថេត និងយុត្តិកម្មបម្រើខ្លួនឯង ផ្សេងៗដែលរបបនេះ បានធ្វើឡើងដើម្បីខ្លួនឯង (ជាក់ស្តែងថារបបអាប៉ាថេតជារនាំងរាំងស្កាត់ការប្រយុទ្ធប្រឆាំង "កុម្មុយនិស្តនិយម") ។ ផ្លូវទីបីរបស់គណៈកម្មការស្វែងរកការពិតសំដៅទៅកាន់យុត្តិធម៌សម័យអន្តរកាលបានធ្វើឲ្យមានសុពលភាពការយល់ស្របអស់រយៈពេលជាច្រើនទសវត្សរ៍ក្នុងសហគមន៍អន្តរជាតិអំពីសារជាតិនិងឋានៈរបស់របបអាប៉ាថេត ។ ដូចគ្នាដែរ ការកើតឡើងបែបនេះនៅក្នុងប្រទេសអាហ្វ្រិកខាងត្បូងត្រូវតែយកទៅដាក់នៅក្នុងទស្សនៈអន្តរជាតិមួយ ។ ការកាត់ទោសនិងការដាក់ទោសដោយប្រព័ន្ធក្នុងស្រុកបានជះឥទ្ធិពលនឹងត្រូវទទួលឥទ្ធិពលពីហេតុការណ៍ជុំវិញពិភពលោក ។ នៅក្នុងការកសាងសន្តិភាពនិងកាត់បន្ថយសង្គ្រាម គណៈកម្មការស្វែងរកការពិតត្រូវគិតរបៀបក្នុងស្រុកហើយគួរបៀបអន្តរជាតិ ។ តាមរយៈមធ្យោបាយនេះ នៅទីបំផុតគណៈកម្មការស្វែងរកការពិតអាចដាស់ឲ្យភ្ញាក់នូវអ្វីដែល យៀត ហៅថា "ការដេកស្ងៀមដូចថ្មអស់រយៈពេលដ៏យូរ" ។ តាមមធ្យោបាយនេះ គណៈកម្មការស្វែងរកការពិតប្រហែលអាចបង្រៀនខ្លួនឯងឲ្យមានក្តីសង្ឃឹមឡើងវិញចំពោះសុទិដ្ឋិនិយមដែលមិនបំបែកដោយការជឿងងល់ ។ ឧត្តមគតិនិយមមិនត្រូវការភ័យព្រួយនៅក្នុងលទ្ធិបដិវត្តប្តូរក្នុងគុណធម៌ក្លែងក្លាយតទៅទៀតទេ ។ នៅពេលនោះ ជាមួយ សៀមមឹស ហៀនី គណៈកម្មការស្វែងរកការពិតអាចទន្ទឹងចាំចំពោះឱកាសដ៏កម្រនោះ"នៅពេលដែលក្តីសង្ឃឹមនិងប្រវត្តិសាស្ត្រដើរទន្ទឹមគ្នា" ។

### សេចក្តីសន្និដ្ឋាន

នៅក្នុងសុន្ទរកថាបញ្ចប់កម្មវិធី លោកប្រធានាធិបតីស៊ីស ហ្គោរន ជើសុន បានលើកឡើងថា"ការលាតត្រដាងការពិតត្រូវការពេលវេលា ។ ការនាំយកយុត្តិធម៌ត្រូវការពេលវេលា ។ ការផ្សះផ្សាជាតិជាដំណើរការមួយដែលត្រូវការរយៈពេលមួយរយឆ្នាំ" ។

គ្រប់រដ្ឋាភិបាលទាំងអស់យល់ស្របថា ការផ្សះផ្សាគួរផ្តល់ជាឱកាសមួយដើម្បីឲ្យជនដែលនៃការរំលោភសិទ្ធិមនុស្សអាចអង្គុយក្បែរជនរងគ្រោះនិងមេដឹកនាំសហគមន៍ ។ យើងសូមគាំទ្រចំពោះដំណើរការផ្សះផ្សារមួយដែលយុត្តិធម៌ត្រូវបានទទួល ហើយមិនបន្សល់ឲ្យមានការសងសឹក ការមិនពេញចិត្ត និងការស្អប់ខ្ពើម ។

ដំណើរការផ្សះផ្សាត្រូវមានសមភាពផលប្រយោជន៍ៈ ប្រយោជន៍យុត្តិធម៌និងប្រយោជន៍របស់សហគមន៍ដែលទទួលរងទុក្ខដោយសារដើរតាមមេដឹកនាំដែលមិនហ៊ានងាកក្រោយដោយខ្លាចការកាត់ទោស ។ ការផ្តល់យុត្តិធម៌តែងតែត្រូវបានមើលឃើញថាជាកត្តាចាំបាច់ដើម្បីបំពេញយុត្តិធម៌ស្ថាប័ននិងការផ្សះផ្សាមួយដែលអាចយកជាការបាន ។

ទោះតាមរយៈវិធានការដែលបានគ្រោងទុកកាន់តែប្រុងប្រយ័ត្នក៏ដោយ សម្រាប់ការប៉ះប៉ូវការខូចខាតការបូកបញ្ចូលដំណើរការកាត់ទោសកាន់តែប្រសើរជាងមុន ការប្រើប្រាស់វិធីសាស្ត្រសម្រាប់ការផ្លាស់ប្តូរក្នុងស្ថាប័នប្តូកម្រិតមួយធំទៀតនៃការរៀបចំយូរអង្វែង និងការពង្រឹងសមត្ថភាពជាមួយអង្គភាពសង្គមស៊ីវិល ដែលមានសារសំខាន់សម្រាប់កសាងឡើងវិញនូវយុត្តិសាស្ត្រសង្គមនៃយុត្តិធម៌សម័យអន្តរកាលនៅក្នុងសង្គមផ្សេងទៀត ដើម្បីឲ្យគណៈកម្មការស្វែងរកការពិតអាចពង្រីកសមត្ថភាពរបស់ប្រទេសអាហ្វ្រិកខាងត្បូងក្នុងការនាំមកនូវការផ្សះផ្សាយូរអង្វែង ។

នៅក្រោយរបបអាប៉ាថេត សច្ចធម៌បានក្លាយជាតម្រូវការផ្នែកច្បាប់សម្រាប់ការចូលរួមក្នុងដំណើរកាផ្សះផ្សាប្តុព្យាបាល ។ អ្នកដែលមិនបានរៀបចំខ្លួនទទួលស្គាល់បទឧក្រិដ្ឋរបស់ខ្លួនដោយស្មោះត្រង់ មិនបានចូលរួមនៅក្នុងដំណើការផ្សះផ្សាទេ ។ ការលេចឡើងនូវមូលដ្ឋានសង្គមនិងសីលធម៌របស់ជាតិមួយបានលេចឡើងជាក់ស្តែងភ្លាមៗដែរ ។ តាមរយៈការបង្ហាញអំពីការយកចិត្តទុកដាក់ទៅលើអភិវឌ្ឍន៍ធនធានមនុស្ស ប្រទេសអាហ្វ្រិកខាងត្បូងកំពុងតែដើរតួនាទីជាអ្នកដឹកនាំសីលធម៌នៅក្នុងតំបន់ ។ នៅទីបំផុតប្រទេសអាហ្វ្រិកខាងត្បូងប្រហែលជាអាចក្លាយជាប្រទេសឈានមុខក្នុងពិភពលោកផ្នែកកិច្ចការសន្តិភាពនិងមនុស្សធម៌ ។

ដើម្បីផ្តោតការយកចិត្តទុកដាក់ទៅលើឧបសគ្គដែលប្រទេសអាហ្វ្រិកខាងត្បូងជួបប្រទះនៅក្នុងកិច្ចខិតខំប្រឹងប្រែងកសាងការផ្សះផ្សាយូរអង្វែងបន្ទាប់ពីការចាប់ដំណើរការរបស់គណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សា វាមិនទាមទារផ្តល់ការវិភាគរិះគន់ទៅលើគណៈកម្មការនេះទេ គឺគ្រាន់តែជាយន្តការណ៍មួយក្នុងចំណោមយន្តការណ៍ផ្សេងទៀតសម្រាប់នាំមកនូវយុត្តិធម៌សម័យអន្តរកាលនៅក្នុងប្រទេសអាហ្វ្រិកខាងត្បូង ហើយវាជាជំហានចាំបាច់មួយសម្រាប់កសាងការផ្សះផ្សានៅក្នុងប្រទេសអាហ្វ្រិកខាងត្បូង ។

ការវាយតម្លៃដ៏ត្រឹមត្រូវទៅលើប្រសិទ្ធភាពរបស់យន្តការណ៍យុត្តិធម៌សម័យអន្តរកាលផ្សេងៗនៅក្នុងប្រទេសអាហ្វ្រិកខាងត្បូង ហើយប្រហែលនៅទីកន្លែងផ្សេងទៀត(នៅក្នុងពិភពលោក) ត្រូវឋិតនៅក្នុងបរិបទជាក់លាក់នៃការកែប្រែទម្រង់នៃអំពើហិង្សាផ្នែកនយោបាយនិងព្រហ្មទណ្ឌ និងឧបសគ្គដ៏ធំជាច្រើន ដែលការវាយតម្លៃនេះនាំមកសម្រាប់កិច្ចការកែប្រែ ពិសេសគឺស្ថាប័នយុត្តិធម៌ស្នងពីរបបមុនដែលប្រតិបត្តិការនៅក្នុងកាលៈទេសៈបែបនោះនៅក្នុងប្រជាធិបតេយ្យថ្មីមួយ ។ តាមការពិត ទស្សនៈនេះទាមទារថា គណៈកម្មការស្វែងរកការពិតបានបង្វែរការជជែកវែកញែកអំពីយុត្តិធម៌សម័យអន្តរកាលពីការគិតគូរតែអំពីភាពអយុត្តិធម៌ពីអតីតកាលទាំងស្រុង ទៅកាន់ការដោះស្រាយជាយុត្តិសាស្ត្រចំពោះបញ្ហាទាំងឡាយដែលស្ថាប័នយុត្តិធម៌ប្រឈមមុខនៅក្នុងសង្គមប្រជាធិបតេយ្យដែលទើបតែលេចមុខថ្មីៗនៅពេលដែលទម្រង់នៃអំពើហិង្សានិងជម្លោះសង្គមផ្លាស់ប្តូរខុសពីមុន ។ ទស្សនៈនេះទាមទារឲ្យមានការពិនិត្យទៅលើអតីតកាលនិងអនាគតកាល ហើយវាមិនត្រឹមតែតម្រូវឲ្យមានការវិភាគអំពីយុត្តិធម៌សម័យអន្តរកាលទេ ប៉ុន្តែថែមទាំងអំពើឃោរឃៅនៅក្នុងសម័យនេះផង ។

ដោយសារគណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សាត្រូវបានមើលឃើញថាជាចលនាបង្កើតជាតិថ្មីមួយរបស់ប្រទេសអាហ្វ្រិកខាងត្បូង, ដោយគណៈកម្មការនេះត្រូវបានយល់ថាជាយន្តការណ៍ចម្បងសម្រាប់ដោះស្រាយជម្លោះអតីតកាលនិងបញ្ចប់អំពើហិង្សានិងដោយគណៈកម្មការនេះត្រូវបានតែងតាំងជាឧបករណ៍សំខាន់មួយដើម្បីការផ្សះផ្សាគណៈកម្មកាទើបតែបានចាប់ផ្តើមដំណើរការមួយដែលនៅតែប្រឈមមុខនឹងឧបសគ្គមួយចំនួន ។

យ៉ាងហោចណាស់ក៏អាចបកស្រាយថា បរិបទនយោបាយដែលបាន ធ្វើឲ្យកើតឡើងនូវការប៉ុនប្រសប់និងការបង្កើតថ្មីនៃគណៈកម្មការ ស្វែងរកការពិតនិងការផ្សះផ្សា ទោះជាយ៉ាងណាអាចជាវិភាគទាន ក្នុងការធ្វើឲ្យយល់អំពីការផ្សះផ្សាផ្អែកទៅលើទស្សនៈអំពីសារជាតិ នៃជម្លោះហិង្សានៅក្នុងប្រទេសអាហ្វ្រិកខាងត្បូង ។

រដ្ឋាភិបាលអាហ្វ្រិកខាងត្បូងថ្មីចង់ផ្សះផ្សាអតីតកាលជាមួយ បច្ចុប្បន្ននិងអនាគតកាលតាមរយៈការប្រឈមមុខអំពើហិង្សា សិទ្ធិមនុស្ស ។ ប្រសិនបើប្រទេសអាហ្វ្រិកខាងត្បូងត្រូវឋិតនៅជារដ្ឋ ដែលមានសុពលភាពនិងរក្សាឧត្តមភាពនៅក្នុងតំបន់ ភាពចលាចល សង្គមនិងអស្ថិរភាពត្រូវតែចៀសវាង ។ ទោះជាមានបញ្ហាជា ច្រើនទាក់ទិនទៅនឹងការឆ្លងពីរបបអាប៉ាថេត ការព្យាបាលអារម្មណ៍ ត្រូវតែធ្វើឡើងជាមួយសកម្មភាពអន្តរកាលផ្សេងទៀតនៅក្នុង តំបន់ ។ រដ្ឋាភិបាលបានពិចារណាគំរូជាច្រើនសម្រាប់ការផ្សះផ្សា មុនពេលសម្រេចចិត្តកែច្នៃគំរូរបស់ប្រទេសឈីលីមកប្រើប្រាស់ នៅអាហ្វ្រិកខាងត្បូង ។

ប្រឈមមុខទល់នឹងអំពើហិង្សាទៅលើសិទ្ធិមនុស្សកើតឡើង នៅក្នុងរបបអាប៉ាថេតដើម្បីការផ្សះផ្សានៅក្នុងប្រទេសអាហ្វ្រិកខាង ត្បូងមានចំណុចជាក់ស្តែងខ្លះៗលើកឡើងដោយលោក ម៉ៃឃើល អេវីរេស ដូចខាងក្រោម÷

◆ ប្រសិនបើការជំរុញឲ្យមានការគោរពសិទ្ធិមនុស្សក៏ដូចជា ការបង្កើតស្ថាប័នប្រជាធិបតេយ្យនិងរដ្ឋាភិបាលបន្តជាគោលដៅ សំខាន់របស់សហរដ្ឋអាមេរិក ដំណើរស្វែងរកការពិតនិងការ ផ្សះផ្សានៅក្នុងប្រទេសអាហ្វ្រិកខាងត្បូងគួរទទួលការគាំទ្រការត្រួត ពិនិត្យនិងការវាយតម្លៃជាប់មិនដាច់ ។

◆ ខុសពីករណីអតីតប្រទេសយូហ្គោស្លាវី ប្រទេសអាហ្វ្រិកខាង ត្បូងកំពុងតែធ្វើដំណើរចាកចេញពីការគាបសង្កត់ទៅកាន់លទ្ធិ ប្រជាធិបតេយ្យដោយគ្មានការធ្វើអន្តរាគមន៍ពីបរទេស ឬការ ប្រើប្រាស់កងទ័ពរក្សាសន្តិភាព ។

◆ ប្រធានាធិបតី ណែលសុន ម៉ាន់ដេឡា គឺជាស្ថាបនិកនៃការ ផ្សះផ្សានៅក្នុងប្រទេសអាហ្វ្រិកខាងត្បូង ប៉ុន្តែបន្ទុកនៃការស្វែងរក ការពិតគឺឋិតនៅលើប្រជាជនអាហ្វ្រិកខាងត្បូង ។ មេដឹកនាំមួយ ចំនួននៃរដ្ឋាភិបាលចាស់និងមេដឹកនាំចលនាប្រឆាំងនឹងរបបអាប៉ា ថេត ក៏ដូចជាមេដឹកនាំបច្ចុប្បន្នត្រូវតែផ្សះផ្សាជាមួយយុត្តិធម៌ ។

◆ ការពិភាក្សាដ៏ជោគជ័យរវាងប្រទេសអាហ្វ្រិកខាងត្បូង និងសហរដ្ឋអាមេរិក មានទំនាក់ទំនងដោយប្រយោលទៅនឹង ជោគជ័យនៃដំណើរការផ្សះផ្សា ។ ស្ថិរភាពនិងការរីកចម្រើនអាច ជំរុញឲ្យមានការវិនិយោគទុនពីបរទេសនិងការបង្កើតទីផ្សារសេរី នៅក្នុងប្រទេសអាហ្វ្រិកខាងត្បូង ។

◆ គោលបំណងរបស់ដំណើរការស្វែងរកការពិតនិងការ ផ្សះផ្សាគឺបង្កើតវប្បធម៌មួយដែលឲ្យតម្លៃខ្លាំងទៅលើសិទ្ធិមនុស្ស ដើម្បីទប់ស្កាត់ការកើតឡើងនូវភាពអយុត្តិធម៌និងការរងទុក្ខវេទនា ពីអតីតកាល ។ ដើម្បីទទួលបានជោគជ័យ ការព្យាបាលសង្គម តម្រូវ ឲ្យមានការលះបង់និងការតស៊ូដោយអតីតជនគាបសង្កត់ជន ដៃដល់និងជនរងគ្រោះ ។

បើគ្មានការពិត យុត្តិធម៌និងសំណងជនរងគ្រោះសហគមន៍ ជនរងគ្រោះនឹងមានអារម្មណ៍ថា ការគ្រប់គ្រងថ្មី បានធ្វើឲ្យជន រងគ្រោះបរាជ័យ ។ ដោយគ្មានការផ្សះផ្សាពិតប្រាកដជនរងគ្រោះ ពីអតីតកាលអាចក្លាយទៅជាជនដៃដល់ក្នុងពេលបច្ចុប្បន្នបានដោយ ងាយ ។ ទោះជាយ៉ាងណាក៏ដោយ យើងទាំងអស់គ្នា អង្គការក្រៅ រដ្ឋាភិបាលនិងសហគមន៍អន្តរជាតិអាចជួយបានត្រឹមតែផ្តល់ឲ្យនូវ ដំណើរការនៃការផ្សះផ្សាមួយប៉ុណ្ណោះ ។ ប្រជាជនទាំងអស់ត្រូវ បេះដូងផ្តើមដោយខ្លួនឯងក្នុងការផ្សះផ្សារវាងបុគ្គលម្នាក់ទៀត ។

**ថ្លង សុភារិទ្ធ**

## ដំណឹងស្វែងរកគ្រួសារ

នាងខ្ញុំឈ្មោះ ទេស ស្រេង អាយុ៥២ឆ្នាំ ឪពុកឈ្មោះ ទេស (ស្លាប់) និងម្តាយឈ្មោះ ម៉ម វ៉ិន (ស្លាប់) មានស្រុកកំណើតនៅភូមិ ក្រាំង ឃុំក្រាំងយ៉ូវ ស្រុកស្អាង ខេត្តកណ្តាល ។ បច្ចុប្បន្ននេះរស់នៅ ក្នុងភូមិពាមសាលា ឃុំស្អាងភ្នំ ស្រុកស្អាង សូមស្វែងរកប្អូនពីរនាក់ ឈ្មោះ÷ ១) ទេស ទុយ ភេទប្រុស ចេញពីផ្ទះនៅក្នុងឆ្នាំ១៩៧២ ចូលធ្វើជាយោធា ។ ២) ទេស តែម ចេញពីផ្ទះនៅក្នុងឆ្នាំ១៩៧២ ដើម្បីចូលកងកុមារ ។

កាលពីឆ្នាំមុនធ្លាប់មានដំណឹងថាឈ្មោះទាំងពីរនេះរស់ នៅអន្លង់វែង ។ ប្រសិនបើអស់លោក លោកស្រីបានដឹងពីពត៌មាន ទាក់ទងនឹងឈ្មោះខាងលើនេះ សូមផ្តល់ពត៌មានមកមជ្ឈមណ្ឌល ឯកសារកម្ពុជាតាមរយៈប្រអប់សំបុត្រលេខ១១១០ ភ្នំពេញ ឬ តាមទូរស័ព្ទលេខ(៨៥៥) ០២៣២១១៨៧៥ ។

# ដំណោះស្រាយក្រោយជម្លោះនៅប្រទេសសេរ៉ាឡេអូន

## សេចក្តីផ្តើម

ខាងក្រោមនេះគឺជាអត្ថបទស្តីអំពីករណីប្រទេសសេរ៉ាឡេអូន ដែលផ្តល់នូវដំណោះស្រាយក្រោយពេលមានជម្លោះ ។ អត្ថបទនេះចែកចេញជាបីផ្នែកសំខាន់ៗ ។ ដំបូងខ្ញុំសូមលើកមកនិយាយអំពីការផ្ទុះឡើងនូវសង្គ្រាមស៊ីវិលនិងការរំលោភសិទ្ធិមនុស្សដែលប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលមានជម្លោះ ។ ក្នុងតួសេចក្តីខ្ញុំពិនិត្យនូវមធ្យោបាយផ្សេងៗដែលរដ្ឋាភិបាលសេរ៉ាឡេអូនប្រកាន់យកដើម្បីដោះស្រាយមរតកបន្សល់ទុកដោយការរំលោភសិទ្ធិមនុស្សជាមូលដ្ឋានសម្រាប់និរន្តរភាពនៃសន្តិភាពនិងការផ្សះផ្សាជាតិ ។ នៅសេចក្តីសន្និដ្ឋានខ្ញុំទាញហេតុផលថាដំណើរការស្វែងរកសន្តិភាពនិងផ្សះផ្សាជាតិនៅសេរ៉ាឡេអូនពិតជាមាននិរន្តរភាព ហើយជាការចាំបាច់ណាស់ត្រូវមានកិច្ចសហ- ប្រតិបត្តិការនិងការគាំទ្រជាអន្តរជាតិ ។

គោលបំណងនៃការសិក្សានេះគឺដើម្បីឆ្លុះបញ្ចាំងចំណុចខ្លាំងនិងចំណុចខ្សោយនៃយុទ្ធសាស្ត្រដែលរដ្ឋាភិបាលសេរ៉ាឡេអូនប្រកាន់យកដើម្បីដោះស្រាយការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរ ។ មេរៀននេះមានសារសំខាន់ណាស់សម្រាប់ប្រទេសនានានៅជុំវិញពិភពលោក ដែលកំពុងតែតស៊ូពុះពារស្វែងរកសន្តិភាពនិងការផ្សះផ្សាជាតិប្រកបដោយនិរន្តរភាព ជាពិសេសប្រទេសកម្ពុជារបស់ខ្ញុំ ។

ប្រទេសសេរ៉ាឡេអូនត្រូវបានអង់គ្លេសដាក់អាណានិគមនៅឆ្នាំ១៧៨៧ ដែលជាដំណោះស្រាយមួយឲ្យជនជាតិអាហ្វ្រិកចាកផុតពីទាសភាព ។ នៅឆ្នាំ១៨៩៦ អាណាព្យាបាលអង់គ្លេសត្រូវបានប្រកាសជាសាធារណៈថាជាតំបន់ដាច់ឆ្ងាយពីទីក្រុង ។ នៅថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៦១ ប្រទេសសេរ៉ាឡេអូនក្លាយជារដ្ឋឯករាជ្យស្ថិតនៅក្នុងសម្ព័ន្ធចក្រភពអង់គ្លេស ។ ក្រោយពីទទួលបានឯករាជ្យ លទ្ធិប្រជាធិបតេយ្យដែលនៅមានលក្ខណៈផុយស្រួយនៅឡើយ ត្រូវបានបំផ្លាញដោយលទ្ធិផ្តាច់ការនិងអំពើពុករលួយដែលនាំដល់ការរំដើបរំដួលផ្នែកនយោបាយ វិបត្តិសេដ្ឋកិច្ចនិងការគ្រប់គ្រងដោយអំណាចយោធា ។ ពេញទសវត្សរ៍ឆ្នាំ១៩៧០និងដើមទសវត្សរ៍ឆ្នាំ១៩៨០ សេរ៉ាឡេអូនធ្លាក់ក្នុងអំណាចផ្តាច់ការរបស់លោកប្រធានាធិបតី ស៊ីអាកា ស្ទីវិន និងប្រធានាធិបតី ចូសេហ្វ សេខូ ។ ការចាត់ចែងមិនត្រឹមត្រូវនិងអំពើពុករលួយបានកើតមានឡើងគ្រប់កន្លែង ហើយរដ្ឋនោះក៏ត្រូវបានបែងចែកបក្សគ្នារវាងបក្ខពួកខាងរបបសមាជប្រជាជននិងគួរប្រកួតប្រជែងដូរបត់ផ្នែកនយោបាយនិងជំនួញ ។ សេរ៉ាឡេអូនក៏ក្លាយជាប្រទេសដែលពឹងផ្អែកលើជំនួយអន្តរជាតិទាំងស្រុង ។

នៅខែមីនា ឆ្នាំ១៩៩១ រណសិរ្សរួបរួមបដិវត្តន៍ដឹកនាំដោយអតីតនាយកទេដែលមិនសូវល្បីឈ្មោះចេញពីជួរកងទ័ពជាតិសេរ៉ាឡេអូន ហ្វូដេ សាយបាណា សានកុស បានឆ្លងពីលីបេរីយ៉ាកាត់ទន្លេម៉ៅចូលទៅក្នុងស្រុកពូចេហ៊ុន នៅភាគខាងត្បូងដើម្បីវាយប្រហារភូមិស្រុកនានានៅតាមព្រំប្រទល់ ។ ចេតនារបស់រណសិរ្សរួបរួមបដិវត្តន៍គឺដើម្បីផ្តួលរំលំរដ្ឋាភិបាលពុករលួយរបស់របបសមាជប្រជាជនចេញពីអំណាច ដាក់បញ្ចូលនូវលទ្ធិប្រជាធិបតេយ្យពហុបក្សនិងបញ្ចប់អាជីវកម្មលើធនធានធម្មជាតិ ប៉ុន្តែការវាយប្រហារលើកដំបូងរបស់រណសិរ្សរួបរួមបដិវត្តន៍ហាក់ដូចជាមានគោលដៅរយៈពេលខ្លីមួយចំនួន ពោលគឺ បំផុសបំផុលបង្ខំឲ្យយុវជនយុវនារីចូលរួមក្នុងរណសិរ្សរួបរួមបដិវត្តន៍លួចប្លន់ស្បៀងដើម្បីជួបឧបត្ថម្ភដល់កម្លាំងប្រយុទ្ធ សម្លាប់ឥស្សរជនជាអាជ្ញាធរមូលដ្ឋាន រួមទាំង មន្ត្រីរដ្ឋការ បុគ្គលិក និងថ្នាក់ដឹកនាំដែលជ្រើសរើសដោយប្រជាជន ព្រមទាំងសម្លាប់អ្នកជំនួញហុលឡង់និងម៉ាន់ឌីងហ្គោ ។ អ្នកចូលថ្មីនិងអ្នកដែលក្លាយជាទាសករត្រូវបានដឹកនាំចូលទៅក្នុងព្រៃដើម្បីបំពាក់បំប៉នមនោគមវិជ្ជារបស់ចលនានេះ ។ កលយុទ្ធមួយដែលមេបញ្ជាការរណសិរ្សរួបរួមបដិវត្តន៍យកមកប្រើដើម្បីការពារកុំឲ្យអ្នកទាំងនោះរត់ត្រឡប់ទៅកាន់មូលដ្ឋានវិញនោះ គឺត្រូវបង្ខំឲ្យអ្នកទាំងនោះសម្លាប់ឬធ្វើកាយវិកលកម្មមន្ត្រីថ្នាក់ដឹកនាំសហគមន៍ ឬសមាជិកគ្រួសារអ្នកភូមិ ។

ខណៈដែលអ្នកភូមិមួយចំនួនរត់គេចខ្លួនឬលាក់ខ្លួនពីការបះបោររបស់រណសិរ្សរួបរួមបដិវត្តន៍ មានអ្នកផ្សេងទៀតឆ្លៀតឱកាសនេះសងសឹកដោយមូលហេតុផ្ទាល់ខ្លួនឬមូលហេតុនយោបាយ ឬដើម្បីយកចំណេញខាងសេដ្ឋកិច្ច ។ យុវជន សេរ៉ាឡេអូន បានចូលជាមួយរណសិរ្សរួបរួមបដិវត្តន៍ដើម្បីធ្វើសង្គ្រាមដែលទង្វើនេះផ្តល់ឲ្យយុវជនទាំងនោះនូវសេចក្តីសង្ឃឹមនិងឱកាសច្រើនជាងពេលមានស្ថិរភាព ។ ចំណែកឯនិស្សិតទើបបញ្ចប់ការសិក្សាថ្នាក់វិទ្យាល័យហាក់ដូចជាគ្មានអនាគតដោយសារវិបត្តិយាយីដល់សេដ្ឋកិច្ច ។ អ្នកដទៃទៀត ជាពិសេស ប្រជាជននៅស្រុកពូចេហ៊ុនភាគខាងត្បូងបានចូលរួមជាមួយក្រុមបះបោរដោយសារការគាបសង្កត់របស់រដ្ឋាភិបាលនិងការសម្លាប់នៅក្នុងស្រុកនៅអំឡុងយុទ្ធនាការស្វែងរកសំឡេងឆ្នោតឆ្នាំ១៩៨២ ដែលក្នុងពេលនោះ អ្នកគាំទ្រគណបក្សប្រជាជនសេរ៉ាឡេអូនដែលជាគណបក្សប្រឆាំងត្រូវបានសម្លាប់ចោលនិងគាបសង្កត់ ។ រណសិរ្សរួបរួមបដិវត្តន៍បានទាក់ទាញយុវជនយុវនារីដែលត្រូវរំលោភបំពានឲ្យចេញពីគំនាបអាជ្ញាធរឬដែលគ្មានឱកាសពិតប្រាកដក្នុងការទទួលការអប់រំឬការធ្វើការងារ ក៏ដូចជាអ្នកជីកត្បូងនៅជំរំជីករ៉ែគ្មានច្បាប់នៅភាគខាងកើតនិងខាងត្បូងប្រទេស ។

នៅពេញមួយអំឡុងពេលធ្វើសង្គ្រាម រណសិរ្សរួបរួមបដិវត្តន៍បានផ្លាស់ប្តូរពីក្រុមប្រឆាំងដែលមានមួយក្តាប់តូចមានអាវុធមិនសូវសម្បូរ មកជាក្រុមទ័ពព្រៃចល័តនិងបំផ្លិចបំផ្លាញ ។ រណសិរ្សនេះបានបំផ្លិចបំផ្លាញជនស៊ីវិលដែលបង្កឲ្យមានការផ្លាស់ប្តូរលំនៅដ្ឋានដ៏ច្រើនសន្ធឹកសន្ធាប់ ។ ក៏ដូចជាការកាប់សម្លាប់ដែរ អំពើឃោរឃៅផ្សេងៗដូចជាការកាត់អវៈយវៈ កាត់ស្លឹកត្រចៀក បបូរមាត់ កាត់ក្បាល យកដែកដុតមករុក និងការរំលោភជាក្រុមមកលើស្ត្រីនិងកុមារ បានរាតត្បាតពាសពេញប្រទេស ។ កេរដំណែលមួយទៀតនៃសង្គ្រាមគឺការកើនឡើងនូវជំងឺឆ្លងពេស្យាចារនិងការរើសអើងមកលើជនរងគ្រោះដែលត្រូវបានរំលោភ ព្រមទាំងស្ត្រីនិងក្មេងស្រីផ្សេងទៀតដែលមានការពាក់ព័ន្ធជាមួយយុទ្ធជនផ្សេងៗ ។

នៅខែមេសា ឆ្នាំ១៩៩២ អនុសេនីយ៍ឯក វ៉ាឡិនទីន ស្ត្រាសឺ បានធ្វើរដ្ឋប្រហារយោធាមួយដោយសន្យាថានឹងបញ្ចប់សង្គ្រាមនិងធ្វើឲ្យប្រទេសស្អាតស្អំខាងនយោបាយ ។ បន្ទាប់មកទៀត នៅខែមករា ឆ្នាំ១៩៩៦ ជូលីស ម៉ាដា ក៏បានទម្លាក់លោក វ៉ាឡិនទីន ពីអំណាចដោយចោទថា វ៉ាឡិនទីន ខកខានមិនបានធ្វើតាមការសន្យារបស់ខ្លួន ។ ចាប់ពីឆ្នាំ១៩៩៥ ចលនារណសិរ្សរួបរួមបដិវត្តន៍ក៏បានបាត់បង់ប្រជាប្រិយភាពជាបន្តបន្ទាប់ ទោះបីជាខ្លួននៅតែគ្រប់គ្រងផ្នែកមួយនៃប្រទេសក៏ដោយ ។ នៅខែសីហា ឆ្នាំ១៩៩៥ មានបាតុកម្មធំៗដង្ហែតាមផ្លូវជាច្រើននៅទីក្រុង ហ្វ្រីថោន ដែលរៀបចំដោយអង្គការសង្គមស៊ីវិលដែលសុំឲ្យមានការបោះឆ្នោតនិងដំណោះស្រាយសន្តិភាព ។ ជាលទ្ធផល រដ្ឋាភិបាលចាប់ផ្តើមបង្ហាញអំពីឆន្ទៈចង់ចរចាជាមួយរណសិរ្សរួបរួមបដិវត្តន៍ ហើយបានសន្យាថានឹងរៀបចំការបោះឆ្នោត ។ ចុងបញ្ចប់ នៅអំឡុងពេលនៃការបោះឆ្នោតជម្រុះជ្រើសរើសប្រធានាធិបតីនៅ ថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៦ ក្រុមប្រឹក្សាគ្រប់គ្រងជាតិបណ្តោះអាសន្នបានចាញ់ឆ្នោតបក្សប្រជាជនសេរ៉ាឡេអូន ។ អាល់ហាជី អាម៉េដ តេចាន កាបាស់ ក្លាយជាប្រធានាធិបតីប្រទេសសេរ៉ាឡេអូន ប៉ុន្តែមួយឆ្នាំក្រោយមក កាបាស់ ត្រូវបានទម្លាក់ពីអំណាចដោយរដ្ឋប្រហារយោធាដែលដឹកនាំដោយវរសេនីយ៍ត្រី ចននី ផូល កូរ៉ូម៉ា ។ កាន់អំណាចមិនបានយូរប៉ុន្មានផង កូរ៉ូម៉ា អញ្ជើញឲ្យសាន់កុស ចូលរួមរបបយោធារបស់ខ្លួនដោយជ្រកក្រោមផ្លាក "កងទ័ពប្រជាជន" ។ អំពើឃោរឃៅ ឃាតកម្ម និងការរំលោភរីករាលដាលគ្រប់ទីកន្លែង ។ ជនរងគ្រោះស៊ីវិល បុរស ស្ត្រី និងកូនក្មេងតូចៗត្រូវកាត់ជើង កាត់ដៃ កាត់ត្រចៀក យ៉ាងឃោរឃៅ ។ អ្នកផ្សេងទៀតត្រូវចាប់ពង្រត់ឲ្យបម្រើជាយុទ្ធជនធ្វើការដោយបង្ខំ ឬបង្ខំឲ្យធ្វើជាទាសករផ្លូវភេទ ។ មុននឹងសម្លាប់ អ្នកទាំងនោះភាគច្រើនត្រូវបានធ្វើទារុណកម្មនិងរំលោភផ្លូវភេទ ហើយមានអ្នកខ្លះទៀតគេយកទៅដុតចោលទាំងគ្រួសារតែម្តង ។

នៅខែកុម្ភៈ ឆ្នាំ១៩៩៨ ក្រុមជនជាតិនីហ្សេរីយ៉ា និងក្រុមយោធាត្រួតពិនិត្យបទឈប់បាញ់នៃសហគមន៍សេដ្ឋកិច្ចរបស់រដ្ឋអាហ្វ្រិកខាងលិច(ECOMOG)បានផ្តួលរំលំរបបយោធានិយម ហើយលើកបន្តុប កាបាស ឲ្យកាន់អំណាច ប៉ុន្តែក្រុមសម្ព័ន្ធមិត្តរណសិរ្សរួបរួមបដិវត្តន៍ ក្រុមប្រឹក្សាកងទ័ពបដិវត្តន៍ (RUF-AFRC) បានវាយប្រហារមកលើហ្វ្រីថោនសាជាថ្មីនៅខែមករា ឆ្នាំ១៩៩៩ ។ ការប្រយុទ្ធនោះឆក់យកជីវិតមនុស្សអស់ចំនួន ៥ពាន់នាក់ ហើយផ្ទះសម្បែង១ភាគ៤ត្រូវបានកម្ទេច ។ ការវាយប្រហាររបស់ក្រុមឧទ្ទាមបានផ្លាស់ប្តូរទស្សនៈនយោបាយរបស់ជាតិ

យ៉ាងច្រើន ក៏ដូចជាធ្វើឲ្យប្រែប្រួលដល់ការឆ្លើយតបរបស់អន្តរជាតិចំពោះស្ថានការណ៍នៅក្នុងប្រទេសនេះ ។ នៅផ្ទៃក្នុងប្រទេសមានការបែងចែកក្រុម បក្សពួក រដ្ឋាភិបាល និងសភា ។ ដំបូងឡើយមានកិច្ចព្រមព្រៀងមួយស្តីអំពីការរុញច្រានយុទ្ធជន RUF-AFRC ចេញពីទីក្រុង ។ នៅចុងបញ្ចប់មានការមិនចុះសម្រុងគ្នាទៅលើបញ្ហាថា តើនៅពេលណាទើបបញ្ចប់ការវាយបករបស់ក្រុម ECOMOG ហើយចាប់ផ្តើមការពិភាក្សាគ្នាជាមួយ RUF-AFRC ។ រដ្ឋាភិបាលអន្តរជាតិនិងអង្គការអន្តរជាតិក៏បានដាក់សម្ពាធលើរដ្ឋាភិបាលលោក កាបាស់ ឲ្យដោះស្រាយជម្លោះដោយសន្តិវិធី ។ ក្រុមសម្ព័ន្ធមិត្ត RUF-AFRC ក៏ស្ថិតក្នុងស្ថានភាពស្រដៀងគ្នានេះដែរ ។ ការលុកលុយបានធ្វើឲ្យខូចមុខមាត់ក្រុមខុទ្ទាម ហើយបន្តឲ្យមានរលកនៃការថ្កោលទោសពីសំណាក់ជាតិនិងអន្តរជាតិទៅលើអំពើឃោរឃៅដែលក្រុមនេះប្រព្រឹត្ត ។ និយាយខាងផ្ទៃក្នុងវិញ ខាងក្រុម AFRC និង RUF កាន់តែខ្សោយទៅៗ ហើយអតីតយុទ្ធជនមួយចំនួនចង់វិលត្រឡប់មកមូលដ្ឋានរបស់ខ្លួនជួបជុំគ្រួសារវិញ ។ ទីបំផុត កាបាស់ និង សានកុស ក៏ព្រមព្រៀងជាមួយគ្នាចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងឡូមេនាខែកក្កដា ឆ្នាំ១៩៩៩ ។ ព្រឹត្តិការណ៍នេះបានធ្វើឲ្យប្រជាជនសេរ៉ាឡេអូនពេញចិត្តយ៉ាងខ្លាំង ។

នៅខែឧសភា ឆ្នាំ២០០០ សឹងតែមួយឆ្នាំក្រោយការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាព ក៏ស្រាប់តែមានការប្រយុទ្ធគ្នាថ្មីមួយទៀត ។ កងរក្សាសន្តិភាពរបស់បេសកកម្មអង្គការសហប្រជាជាតិនៅប្រទេសសេរ៉ាឡេអូនត្រូវបានចាប់ជាចំណាប់ខ្មាំង ហើយអ្នកដើរទាមទារសន្តិភាពចំនួន១៩នាក់ត្រូវបានសម្លាប់ដោយកម្លាំង RUF នៅក្រៅផ្ទះរបស់ សាន់កុស នៅទីក្រុងហ្វ្រីថោន ។ សាន់កុស ត្រូវឃុំឃាំងឲ្យនៅក្នុងផ្ទះ ។

ពេញអំឡុងពេលជិតមួយទសវត្សរ៍នៃសង្គ្រាម មនុស្សចំនួន ១សែននាក់ត្រូវបានរាយការណ៍ថាបានបាត់បង់ជីវិត ។ ប្រជាជនជិត១លាននាក់ក្លាយជាជនភៀសខ្លួន ហើយជាងពីរលាននាក់ត្រូវបង្ខំចិត្តផ្លាស់លំនៅដ្ឋានជ្រកកោន ។ សង្គ្រាមនេះក៏បានបន្សល់ទុកនូវជនពិការ យុទ្ធជនកុមាររាប់ពាន់នាក់ និងប្រជាជនប្រមាណ ៩០ភាគរយរស់នៅក្នុងភាពក្រីក្រ ។ ជាងនេះទៅទៀត ជនរងគ្រោះបានទទួលរងការប៉ះទង្គិចយ៉ាងខ្លាំងផ្នែកចិត្តសាស្ត្រដោយសារសង្គ្រាម ។

## យុទ្ធសាស្ត្រក្នុងការដោះស្រាយបញ្ហាដែលបន្សល់ទុកដោយការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ

ក្រោយពីបានពិពណ៌នាអំពីប្រវត្តិនៃជម្លោះ ព្រមទាំងការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរដែលត្រូវបានប្រព្រឹត្តឡើងនៅសម័យនោះ អត្ថបទនេះនឹងផ្តោតសំខាន់ទៅលើយុទ្ធសាស្ត្រដែលរដ្ឋាភិបាលសេរ៉ាឡេអូនប្រកាន់យកដើម្បីដោះស្រាយចំពោះបញ្ហាដែលបន្សល់ទុកដោយសារការរំលោភសិទ្ធិមនុស្សជាមូលដ្ឋាននៃសន្តិភាពនិងការផ្សះផ្សាប្រកបដោយនិរន្តរភាព ។

ក្រោយពេល ជម្លោះបញ្ចប់ភ្លាម រដ្ឋាភិបាលសេរ៉ាឡេអូនប្រកាន់យកនូវយុទ្ធសាស្ត្រចំនួន៥ ។ យុទ្ធសាស្ត្រទី១ បំពេញសេចក្តីត្រូវការជាមូលដ្ឋានរបស់ប្រជាជននិងការធ្វើវិលត្រឡប់មកវិញនៃជនភៀសខ្លួន ។ យុទ្ធសាស្ត្រទី២ ការចាប់ខ្លួន សាន់កុស ។ យុទ្ធសាស្ត្រទី៣ ការដកអាវុធ រំសាយទ័ព និងសមាហរណកម្មកងទ័ព ។ យុទ្ធសាស្ត្រទី៤ រៀបចំបោះឆ្នោតទូទៅនៅខែឧសភា ឆ្នាំ២០០២ ។ យុទ្ធសាស្ត្រទី៥ បង្កើតនូវតុលាការពិសេសនិងគណៈកម្មការស្វែងរកការពិតនិងផ្សះផ្សា ។

### ១) បំពេញសេចក្តីត្រូវការជាមូលដ្ឋានរបស់ប្រជាជន និងការធ្វើវិលត្រឡប់មកវិញនៃជនភៀសខ្លួន

មុនពេលសន្តិភាពនិងការផ្សះផ្សាអាចកើតឡើងបាន សំខាន់បំផុត គឺត្រូវឆ្លើយតបតាមតម្រូវការចាំបាច់សម្រាប់របបមួយកើតឡើងបន្ទាប់ពីមានដំណោះស្រាយក្រោយជម្លោះ ។ ចំពោះព្រៃ ស្កុរី យល់ថា តម្រូវការចាំបាច់របស់ប្រជាជនក្រោយពីមានជម្លោះគឺផ្ទះសម្បែងនិងដីធ្លីសម្រាប់ជនភៀសខ្លួនដែលទើបត្រឡប់មករស់នៅសង្គមជាតិវិញ ការរួមរស់ជួបជុំគ្រួសារ សន្តិសុខ ការបែងចែកស្បៀងអាហារនិងការចាប់កសាងជីវិតថ្មីឡើងវិញ ។ ក្រោយពីតម្រូវការចាំបាច់ត្រូវបានបំពេញហើយ នោះនឹងឈានដល់កម្មវិធីស្វែងរកសន្តិភាពនិងការផ្សះផ្សាប្រកបដោយនិរន្តរភាព ។ លោកមានប្រសាសន៍ថា«លទ្ធិប្រជាធិបតេយ្យនិងការអភិវឌ្ឍន៍សន្តិភាពនិងសន្តិសុខ ត្រូវតែមាននូវផ្ទះ មាននៅក្នុងបេះដូង និងនៅក្នុងចិត្តរបស់មនុស្ស...» ។

សម្រាប់ប្រទេសសេរ៉ាឡេអូន តម្រូវការចាំបាច់បំផុតដែលលើកឡើងខាងលើត្រូវបានបំពេញរួចហើយ ។ ឧទាហរណ៍ ត្រឹមតែ

មួយឆ្នាំកន្លះក្រោយពីជម្លោះត្រូវបញ្ចប់ មានជនភៀសខ្លួនចំនួន ២សែននាក់ក្នុងចំណោម៤សែននាក់នៅក្នុងតំបន់បានវិលត្រឡប់មករួមរស់ជាមួយសង្គមជាតិវិញយ៉ាងសុវត្ថិភាព ។ រដ្ឋាភិបាលនិងទីភ្នាក់ងារទទួលបន្ទុកជនភៀសខ្លួនរបស់អង្គការសហប្រជាជាតិកំពុងតែរួមគ្នាបើកយុទ្ធនាការផ្ដល់ព័ត៌មានក្នុងគោលបំណងបញ្ចុះបញ្ចូលជនភៀសខ្លួន៣ម៉ឺន៥ពាន់នាក់នៅប្រទេស ហ្គីនេ និងនៅជុំវិញប្រទេសឲ្យវិលត្រឡប់មករស់នៅភូមិកំណើតវិញ ។ បញ្ហានេះអាចដោះស្រាយបាននៅដំណាច់ឆ្នាំ ២០០៤ ។

គួរកត់សម្គាល់ថា ជនភៀសខ្លួនចំនួន២០ភាគរយមិនចង់វិលត្រឡប់មកលំនៅឋានវិញទេ ។ ជនភៀសខ្លួនទាំងនោះមានការព្រួយបារម្ភអំពីតម្រូវការចាំបាច់ជាមូលដ្ឋាននិងសន្តិសុខ ប្រសិនបើគេវិលត្រឡប់មកប្រទេសសេរ៉ាឡេអូនវិញ ។ អ្នកខ្លះប្រហែលជាពិបាកវិលត្រឡប់មកវិញណាស់ដោយហេតុថា គេមានទ្រព្យសម្បត្តិច្រើន មានសត្វចិញ្ចឹមច្រើន និងបានរស់នៅយ៉ាងសប្បាយនៅលើទឹកដីថ្មី ។

### ២) ការចាប់ខ្លួន សាន់កុស

រដ្ឋាភិបាលសេរ៉ាឡេអូនក៏ព្រួយបារម្ភអំពីសន្តិសុខនិងសន្តិភាពដែរ ។ ឧបទ្ទវហេតុដែលកើតឡើងនៅពេលបាតុករទាមទារសន្តិភាពត្រូវបានសម្លាប់នៅខាងក្រៅផ្ទះលោក សាន់កុស បានធ្វើឲ្យរដ្ឋាភិបាលព្រួយបារម្ភយ៉ាងខ្លាំង ហើយនាំទៅដល់ការតាមរកលោក សាន់កុស រហូតទាល់តែចាប់ខ្លួនបាន ។ ការចាប់ខ្លួនលោក សាន់កុស ជាសញ្ញាបង្ហាញប្រាប់ថារដ្ឋាភិបាលយកចិត្តទុកដាក់ទៅលើសម្លេងនិងតម្រូវការរបស់ប្រជាជន ។ ប្រជាជនចាប់ផ្ដើមមើលឃើញថាប្រទេសរបស់ខ្លួនកំពុងតែត្រូវបានគ្រប់គ្រងដោយច្បាប់ ហើយគោរពសិទ្ធិមនុស្ស ។ ប្រសិនបើគ្មានការចាប់ខ្លួន សាន់កុស និងការវិលត្រឡប់មកវិញនូវសន្តិសុខនិងសណ្ដាប់ធ្នាប់ក្រោយពីខែឧសភា ឆ្នាំ២០០០ ម៉្លេះប្រជាជននឹងកំពុងតែរស់នៅដោយការភ័យខ្លាចមិនដល់រឿងឈឺចាប់ពីអតីតកាលនិងមិនអាចឈប់វិលវល់ទៀតឡើយ ។

### ៣) កម្មវិធីដកអាវុធរំសាយទ័ពនិងសមាហរណកម្ម

យុទ្ធសាស្ត្រមួយទៀត គឺការដកអាវុធ ការរំសាយទ័ព និងសមាហរណកម្ម ។ កម្មវិធីនេះរៀបចំឡើងដើម្បីទាក់ទាញយុទ្ធជនពីគ្រប់និន្នាការទាំងអស់ឲ្យប្រមូលផ្ដុំនៅមណ្ឌលដកអាវុធនិងរំសាយទ័ព ដែលនៅទីនោះ យុទ្ធជនទាំងនោះទម្លាក់អាវុធដោយស្ម័គ្រចិត្តទទួលបាននូវការប្រឹក្សានិងអប់រំឡើងវិញមុនពេលទទួលកញ្ចប់សមាហរណកម្ម ។ កម្មវិធីនេះទទួលបានជោគជ័យណាស់នៅ៣ឆ្នាំចុងក្រោយ ។ ការដកអាវុធចេះតែកើនឡើងចាប់ពី ១ម៉ឺន៧ពាន់ដើមនៅខែមីនា ឆ្នាំ២០០០ ដល់ ៤ម៉ឺន៧ពាន់ដើមនៅខែមីនា ឆ្នាំ២០០៣ ។

សារសំខាន់នៃកម្មវិធីនេះគឺមិនត្រឹមតែដកអាវុធពីយុទ្ធជនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើសមាហរណកម្មអតីតយុទ្ធជនទាំងនេះឲ្យរួមរស់នៅក្នុងសង្គមជាតិវិញ និងផ្ដល់នូវការហ្វឹកហ្វឺនបណ្ដុះបណ្ដាលជំនាញផ្សេងៗអមជាមួយនឹងកញ្ចប់ជំនួយហិរញ្ញវត្ថុ ។ ហេតុដូចនេះ យុទ្ធជនទាំងនេះអាចរកការងារធ្វើដើម្បីចិញ្ចឹមខ្លួនផងនិងផ្គត់ផ្គង់ក្រុមគ្រួសារផង ។ នេះគឺជាសញ្ញាប្រាប់ទៅយុទ្ធជនដែលកំពុងនៅក្នុងព្រៃថា ក្រៅពីសន្តិភាពនិងការសន្តោសប្រណីទោសប្រទេសសេរ៉ាឡេអូននៅមានរបស់ផ្សេងទៀតដើម្បីផ្ដល់ឲ្យយុទ្ធជនដែលវិញមករកសង្គមវិញ ។

ទោះបីជាទូតទៅ កម្មវិធីនេះជាទូទៅទទួលបានជោគជ័យក៏ដោយ ចំណុចខ្សោយមួយគឺការមិនសូវសង្កត់ធ្ងន់ទៅលើសមាហរណកម្ម ។ អ្នកខ្លះគិតថាគ្រឿងលើកទឹកចិត្តសម្រាប់យុទ្ធជនទាំងនេះឲ្យចេញពីព្រៃដើម្បីជ្រើសរើសយកសន្តិភាពនោះ មិនមានលក្ខណៈគ្រប់គ្រាន់ឡើយ ។ ចំណុចខ្សោយមួយទៀតរបស់កម្មវិធីនេះ គឺការមិនរាប់បញ្ចូលនូវដៃគូដ៏សំខាន់នៅក្នុងដំណើរការនេះពោលគឺ មេស្រុក មេភូមិ និងមេបញ្ជាការរបស់ភាគីបដិបក្ខ ។

### ៤) ការបោះឆ្នោតសកល

ការបោះឆ្នោតសកលនៅខែឧសភា ឆ្នាំ២០០២ គឺជាយុទ្ធសាស្ត្រមួយទៀតដើម្បីធ្វើឲ្យប្រទេសនេះមានស្ថិរភាព ។ ការបោះឆ្នោតផ្ដល់នូវឱកាសសម្រាប់ប្រជាជនសេរ៉ាឡេអូនគ្រប់ៗរូបរួមទាំងអតីតយុទ្ធជន ជនភៀសខ្លួន និងអ្នកផ្លាស់លំនៅឋាន ឲ្យមកបោះឆ្នោតជ្រើសរើសមេដឹកនាំរបស់ខ្លួនដោយសេរី ។ ដូចដែលមន្ត្រីទំនាក់ទំនងសាធារណៈរបស់រណសិរ្សរួបរួមបដិវត្តន៍ អេលជ្រេដ កូលីន បានលើកឡើងថា "មុនពេលបោះឆ្នោតយុទ្ធជនរបស់រណសិរ្សរួបរួមបដិវត្តន៍បានចូលគណបក្សនយោបាយផ្សេងៗគ្នា ។ អ្នកទាំងនោះចូលបក្សផ្សេងដោយសារគាត់មិនពេញចិត្តនឹងការដឹកនាំរបស់បក្សខ្លួន ។ យុទ្ធជនម្នាក់ៗតែងតែចង់បាននូវមេដឹកនាំ

ពិតប្រាកដ ។ ខ្ញុំជឿលើលទ្ធិប្រជាធិបតេយ្យពិតប្រាកដ ។ អ្នកណាមានអារម្មណ៍ថា ចង់ចេញពីបក្សរបស់គាត់ក៏ចេញទៅចុះនេះជាសិទ្ធិរបស់គាត់» ។

ការបោះឆ្នោតនេះធ្វើឲ្យប្រជាជនជាច្រើន ជាពិសេសអ្នកស្រុកអ្នកភូមិមានការព្រួយបារម្ភអំពីសន្តិសុខ និងលទ្ធភាពនៃការវាយប្រយុទ្ធគ្នាសាជាថ្មី ។ បើទុកជាការបោះឆ្នោតនេះត្រូវបានរដ្ឋាភិបាលប្រកាសថាជាការបោះឆ្នោតដោយសេរី និងយុត្តិធម៌ក៏ដោយ ក៏គណបក្សប្រឆាំង ពោលគឺ រណសិរ្សរួបរួមដើម្បីវាត្គន៍ និង *AFRC* មិនបានយល់ព្រមចំពោះលទ្ធផលនៃការបោះឆ្នោតនេះឡើយ ហើយភាពមិនប្រក្រតីត្រូវបានរាយការណ៍ថាបានកើតឡើង ។

ក្រោយពីប្រជាជនបោះឆ្នោតជូនជាលើកទីពីរ ប្រធានាធិបតីកាបាស់ បានចាប់ផ្តើមនាំមកនូវសន្តិភាព និងការផ្សះផ្សានាពេលអនាគត ដោយពង្រឹងនូវសិទ្ធិមនុស្សនិងការកសាងនីតិរដ្ឋ ក៏ដូចជាផ្សះរបួសកាលពីអតីតកាល ។ យុទ្ធសាស្ត្រនានាដើម្បីសម្រេចគោលដៅនេះគឺការបង្កើតតុលាការពិសេសនិងគណៈកម្មការស្វែងរកការពិតនិងផ្សះផ្សា ។ តុលាការនេះគឺជាតុលាការឧក្រិដ្ឋសង្គ្រាមដែលមានលក្ខណៈជម្រុះ ដែលមានការចូលរួមពីចៅក្រមសេរ៉ាឡេអូន និងចៅក្រមអន្តរជាតិ ហើយមានអាណត្តិកាត់ទោសជនទាំងឡាយណាដែលមានការទទួលខុសត្រូវខ្លាំងបំផុតចំពោះអំពើឃោរឃៅដែលកើតឡើងនៅប្រទេសសេរ៉ាឡេអូននៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៦ ដល់ឆ្នាំ២០០០ ។

**អៀ ម៉េងទ្រី**

## ស្តាប់ប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតដែលចាក់ផ្សាយរៀងរាល់ថ្ងៃពុធនិងព្រហស្បតិ៍ វេលាម៉ោង៣ះ៣០-៣ះ៤៥នាទី តាមរយៈវិទ្យុ១០២ MHz របស់មណ្ឌលពត៌មានស្ត្រីកម្ពុជា ។

**ផាត់ រចនា និង លី សុផល**

## សេចក្តីជូនដំណឹងរបស់សមាគមអ្នកនិពន្ធខ្មែរ

សមាគមអ្នកនិពន្ធខ្មែរសូមជម្រាបដល់ប្រជាជនកម្ពុជាគ្រប់រូបថា សមាគមបានរៀបចំ «**វេទិកាថែរក្សាប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ**» ក្រោមកិច្ចសហការជាមួយមជ្ឈ-មណ្ឌលឯកសារកម្ពុជា ។ វេទិកានេះមានគោលបំណងសំខាន់ៗដូចជា៖

◆ រួមជាចំណែកថែរក្សាប្រវត្តិសាស្ត្រទុកសម្រាប់កូនចៅជំនាន់ក្រោយឲ្យបានដឹងនិងសិក្សារៀនសូត្រ ។

◆ ជាវិធីមួយដើម្បីរំងាប់អារម្មណ៍ដោយយកហេតុការណ៍សេចក្តីទុក្ខ ការខឹងគុំកួនមកតម្កល់ជាឯកសារប្រវត្តិសាស្ត្រដើម្បីបម្រើដល់ការស្រាវជ្រាវតទៅអនាគត ។

◆ ការចងចាំ គឺជាសន្តិវិធីមួយក្នុងការទប់ស្កាត់មិនឲ្យអំពើប្រល័យពូជសាសន៍កើតឡើងជាថ្មីម្តងទៀត នៅក្នុងសង្គមមនុស្ស ។

◆ ជួយដល់ការស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជាដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហមនិងជួយលើកកម្ពស់ការគោរពសិទ្ធិមនុស្សនៅកម្ពុជា ។

សមាគមអ្នកនិពន្ធខ្មែរសូមអំពាវនាវដល់ប្រជាជនកម្ពុជាចូលរួម សរសេរអត្ថបទទាំងឡាយអំពី៖ ១) រឿងរ៉ាវផ្ទាល់ខ្លួន ២) ព្រឹត្តិការណ៍ដែលលោកអ្នកធ្លាប់បានជួបប្រទះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនិង ៣) ផ្តល់ដំណោះស្រាយចំពោះបញ្ហាប្រវត្តិសាស្ត្រនេះ ។ ប្រធានបទខាងលើនេះតម្រូវឲ្យលោកអ្នកសរសេរបែបប្រវត្តិសាស្ត្រចាប់ពី១០ទំព័រឡើងទៅ ។

សមាគមអ្នកនិពន្ធខ្មែរនិងមជ្ឈមណ្ឌលឯកសារកម្ពុជានឹងមានកិត្តិយសដោយចុះផ្សាយស្នាដៃរបស់លោកអ្នកនៅលើទំព័រទស្សនាវដ្តី «*ស្វែងរកការពិត*» ព្រមទាំងផ្តល់ថវិកាដល់ម្ចាស់អត្ថបទដែលនឹងត្រូវសរសេរថែមទៀត ដើម្បីបោះពុម្ពជាសៀវភៅ ។ ការចូលរួមរបស់លោកអ្នកគឺជាការរួមចំណែកលើកស្ទួយតម្លៃនៃការសរសេរនិងចំណេះដឹង ។

សូមផ្ញើអត្ថបទរបស់លោកអ្នកមកសមាគមអ្នកនិពន្ធខ្មែរ ទីស្នាក់ការៈ វត្តបទុមវតី ភ្នំពេញ ឬទាក់ទងតាមទូរស័ព្ទលេខ ០១២ ៨៨៣ ០៧២ ។ ពេលផ្សាយដំណឹងនេះរហូតដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៤ ។

**យូ បូ**
**ប្រធានសមាគមអ្នកនិពន្ធខ្មែរ**

# ដើមផ្លាំនិងបដិវត្តន៍វប្បធម៌របស់ប្រទេសចិន

ក្នុងចំណោមផ្លែឈើទាំងអស់នៅលើពិភពលោក ខ្ញុំចូលចិត្តផ្លែផ្លាំជាងផ្លែឈើណាៗទាំងអស់ (ផ្លាំជាដំណាំហូបផ្លែមួយប្រភេទដុះនៅប្រទេសចិន) ។ ខ្ញុំមានចំណូលចិត្តលម្អៀងបែបនេះតាំងតែពីខ្ញុំនៅជាសិស្សបឋមសិក្សាម្ល៉េះ គឺនៅក្នុងសម័យបដិវត្តន៍វប្បធម៌នៅប្រទេសចិន ។

កាលខ្ញុំនៅជាកុមារ នៅក្នុងសួនដំណាំមុខផ្ទះខ្ញុំមានដើមផ្លាំចំនួនប្រាំដើម ។ ខ្ញុំមិនចាំថាតើដើមឈើទាំងនេះមានអាយុប៉ុន្មានឆ្នាំទេ ប៉ុន្តែក្រោយមកខ្ញុំបានដឹងថា ឪពុករបស់ខ្ញុំបានដាំដើមផ្លាំទាំងនេះតាំងតែពីគាត់មានវ័យជំទង់ ហើយវាមានផ្លែតាំងពីមុនខ្ញុំកើតម្ល៉េះ ។

នៅដើមទសវត្សឆ្នាំ១៩៧០ បដិវត្តន៍វប្បធម៌បានឈានដល់ចំណុចកំពូលនៅក្នុងប្រទេសចិន ។ នៅក្នុងអំឡុងពេលនេះមិនសូវមានអំពើហិង្សានិងការវាយតប់គ្នាតាមដងវិថីដូចនៅដំណាក់កាលដំបូងនៃចលនាបដិវត្តន៍វប្បធម៌ទេ ។ ក្នុងពេលនេះ បដិវត្តន៍វប្បធម៌បង្វែរទិសដៅមកអប់រំចិត្តនិងគំនិតរបស់ប្រជាជនចិនវិញម្តង ។ ចលនានេះមានពាក្យស្លោកមួយដែលពោលថា "កាត់កន្ទុយមូលធននិយម" ។ មូលហេតុនៃការធ្វើបដិវត្តន៍មនោគមវិជ្ជានេះគឺកម្ចាត់"កម្ទេចមូលធននិយម"ឲ្យអស់ពីប្រទេសចិន ។ គោលបំណងនេះត្រូវបានយល់យ៉ាងច្បាស់ដោយប្រជាជនចិនជាច្រើនដែលមាន"សតិអារម្មណ៍វណ្ណៈ(យល់អំពីបញ្ហាវណ្ណៈ)" ។ ភាពចលាចលនិងការភាន់ច្រឡំក៏លេចឡើងជាញឹកញយក្នុងពេលជាមួយគ្នានោះដែរ ។

ដូចនៅតំបន់ផ្សេងៗនៃប្រទេសចិន ភូមិរបស់ខ្ញុំត្រូវបានលិចលង់ទៅដោយជំនន់នៃគំនិតថ្មីនិងភាពច្របូកច្របល់ ។ ទោះជាអ្នកភូមិភាគច្រើនចាប់ផ្តើមធុញទ្រាន់នឹងចលនា ដែលមានរយៈពេលយូរនេះក៏ដោយ ក៏គ្រប់គ្នានៅតែត្រូវបង្ខំឲ្យចូលរួមដែរ ។ ភារកិច្ចទីមួយគឺអ្នកភូមិគ្រប់រូបត្រូវស្វែងរកធាតុមូលធននិយមនៅក្នុងភូមិហើយកម្ចាត់វាចោល ។ គួរឲ្យសោកស្តាយណាស់ក្រោយពីការបោសសម្អាតអស់រយៈពេលជាច្រើនឆ្នាំ អ្នកភូមិស្ទើរតែទាំងអស់បានបាត់បង់អ្វីៗពីខ្លួនអស់រលីងជាមនោគមន៍វិជ្ជានិងជាឧបករណ៍ ។ ដំណាក់កាលថ្មីនៃចលនាបានត្រឹមតែធ្វើឲ្យជីវិតរបស់ប្រជាជនក្រីក្រកាន់តែដុនដាបប៉ុណ្ណោះ ។

ក្នុងនាមជាកសិករម្នាក់នៅក្នុងសហករណ៍ ឪពុករបស់ខ្ញុំបានធ្វើការបម្រើសហករណ៍ពេញមួយឆ្នាំ ប៉ុន្តែគាត់ស្ទើរតែរកចំណូលមិនបានសោះ លើកលែងតែគ្រាប់ធញ្ញជាតិដូចជាពោតដែលសហករណ៍បែងចែកឲ្យគ្រួសារនីមួយៗ ។ ចំណូលដ៏តិចតួចស្តួចស្តើងជាប្រាក់របស់គ្រួសារខ្ញុំមានប្រភពមកពីការលក់ផលិតផលដំណាំដែលដាំនៅក្នុងសួនដ៏តូចនៅខាងមុខផ្ទះ និងពងមាន់ដែលយើងចិញ្ចឹម ។ មានតែក្នុងរដូវបុណ្យទាននារដូវផ្ការីកនិងនៅក្នុងឱកាសពិសេសៗប៉ុណ្ណោះទើបគ្រួសារខ្ញុំទិញសាច់ខ្លះពីផ្សារ ។ ជាធម្មតា យើងអាចបរិភោគបានតែអ្វីដែលយើងដាំនៅក្នុងសួនដំណាំប៉ុណ្ណោះ ។ យើងមិនមានប្រាក់គ្រប់គ្រាន់ដើម្បីទិញផ្លែឈើពីហាងទេ ប៉ុន្តែយើងក៏មិនចាំបាច់ទិញដែរ ។ រហូតមកទល់បច្ចុប្បន្នស្រុកកំណើតរបស់ខ្ញុំមានឈ្មោះល្បីខាងការដាំដំណាំហូបផ្លែគ្រប់ប្រភេទដូចជា ប៉ោម សារី ផ្លាំ ។ ខ្ញុំមានសំណាងណាស់ដែលត្រូវបានអនុញ្ញាតឲ្យញ៉ាំផ្លែឈើនៅក្នុងសួនបន្លែ ។ បងប្អូនជីដូនមួយរបស់ខ្ញុំមិនមានសំណាងដូច្នោះទេ ពីព្រោះពូរបស់ខ្ញុំមានបំណងចង់លក់ផ្លែឈើទាំងអស់ដែលដាំបាននៅឯផ្សារ ដើម្បីសន្សំប្រាក់ទិញអំបិលនិងទឹកស៊ីអ៊ីវ ។

ឪពុករបស់ខ្ញុំគឺជាកសិករដ៏ស្ទាត់ជំនាញមួយរូប និងមានការប៉ិនប្រសប់ក្នុងការថែទាំដំណាំហូបផ្លែ ។ ដើមផ្លាំទាំងប្រាំដើមចេញផ្លែយ៉ាងស្កុកស្កះពីមួយឆ្នាំទល់មួយឆ្នាំ ។ ជាញឹកញយ ខ្ញុំសាកភ្លក់ផ្លែផ្លាំនៅក្នុងខែកក្កដា នៅពេលដែលវាមានពណ៌បៃតង និងមានរសជាតិជូរ (ពេលចុងក្រោយដែលខ្ញុំបានធ្វើដូចនេះគឺកាលខ្ញុំ

មានអាយុដប់ឆ្នាំ) ហើយជួនកាលបានបេះផ្លែផ្លាំទុំក្រហមនៅចុងរដូវដែលលាក់កំបាំងនៅក្រោមស្លឹកនៅខែតុលា ។

នៅរដូវផ្ការីកឆ្នាំ១៩៧៣ ពេលដែលខ្ញុំមានអាយុ១១ឆ្នាំ "ចលនាកាត់កន្ទុយមូលធននិយម" បានរាលដាលដល់ភូមិរបស់ខ្ញុំ ហើយខិតកាន់តែជិតមកក្រុមគ្រួសារខ្ញុំ ។ ចលនានេះត្រូវបានរៀបចំឡើងដើម្បីបំបាត់ចោលទាំងស្រុងនូវអ្វីៗទាំងអស់នៃសេដ្ឋកិច្ចទីផ្សារដែលនៅសេសសល់ក្នុងប្រទេសចិន ។ ចាប់ពីពេលនេះតទៅ ការលក់ដូរផលដំណាំនៅក្នុងសួនបានក្លាយទៅជាអំពើល្មើសច្បាប់ ។ អ្វីៗទាំងអស់ដែលអាចប្រើប្រាស់បានក្នុងការរកប្រាក់ចំណូលនឹងត្រូវកម្ទេចចោល ។

ទោះជាឋិតនៅក្នុងបរិកាសនយោបាយដ៏តានតឹង ដើមផ្លាំទាំងប្រាំនៅក្នុងសួនដាំណាំបានចេញផ្កាសក្បុសពេញដើមគួរឲ្យគយគន់ ដែលមើលពីចម្ងាយដូចជាព្រិលគ្របដណ្ដប់ដើម ។ នៅពេលព្រឹកព្រលឹម ខ្ញុំចូលចិត្តដើរមកជិតដើម ហើយស្រូបយកក្លិនផ្កាដែលសាយភាយ ។ នៅពេលរសៀល ពេលខ្ញុំមកពីរៀនវិញខ្ញុំរកមើលត្រួយថ្មីពណ៌បៃតងដែលទើបនឹងដុះចេញពីមែក ។ ខ្ញុំមានអារម្មណ៍កៀកកើយនឹងដើមនេះណាស់ វាហាក់បីដូចជាមិត្តរបស់ខ្ញុំដូច្នោះដែរ ។ ហេតុនេះហើយ ខ្ញុំមានទុក្ខសោកជាខ្លាំងនៅពេលដែលខ្ញុំបាត់បង់ដើមផ្លាំទាំងប្រាំដើមនៅក្នុងរដូវផ្ការីកឆ្នាំ១៩៧៣ ។ ខាងក្រោមនេះជាអ្វីដែលបានកើតឡើងនៅរដូវផ្ការីកនោះ÷

ព្រឹកមួយ លោកជាំង ដែលជាលេខារបស់គណៈកម្មាធិការបក្សកុម្មុយនិស្តប្រចាំភូមិ បានមកផ្ទះរបស់ខ្ញុំ ។ លេខាជាំង បាននិយាយទៅកាន់ឪពុកខ្ញុំថា«លោកត្រូវកាប់ដើមផ្លាំទាំងអស់នៅក្នុងសួនថ្ងៃនេះ ។ ដូចលោកដឹងហើយថា ក្រុមអធិការកិច្ចសហករណ៍នឹងមកភូមិរបស់យើងថ្ងៃស្អែកហើយ ។ ខ្ញុំមិនចង់ឲ្យគេមានអារម្មណ៍ថាភូមិយើងនៅមានកន្ទុយមូលធននិយមទេ» ។ ឪពុករបស់ខ្ញុំភ្ញាក់ផ្អើលនឹងអ្វីដែលលេខាជាំងនិយាយ ប៉ុន្តែគាត់មិនបានឆ្លើយតបវិញទេ ។ គាត់គ្រាន់តែងក់ក្បាលទាំងមិនពេញចិត្តប៉ុណ្ណោះ ។ ខ្ញុំដឹងថាឪពុកខ្ញុំមានការអាក់អន់ចិត្តជាខ្លាំង ទោះជាគាត់ខំប្រឹងលាក់កំបាំងអារម្មណ៍នេះយ៉ាងណាក៏ដោយ ហើយខ្ញុំក៏ដឹងថាសម្ដីរបស់លេខាជាំង បានធ្វើឲ្យគាត់ខឹងប៉ុនណាដែរ ។ អ្វីដែលធ្វើឲ្យខ្ញុំឆ្ងើងឆ្ងល់នោះគឺមូលហេតុដែលឪពុកខ្ញុំដែលធ្លាប់ជាមនុស្សឆេវឆាវមួយរូបក្នុងភូមិបានយល់ព្រមតាមសំណើមិនសមហេតុផលរបស់លេខាជាំង ។ ពីព្រោះខ្ញុំត្រូវបានទូន្មានជាច្រើនលើកច្រើនសាថាកុំរំខានចាស់ទុំពិភាក្សាគ្នា ខ្ញុំមិនបាននិយាយអ្វីទាំងអស់ទៅ លេខាជាំង ហើយក៏មិនបានសួរឪពុកខ្ញុំពីមូលហេតុដែរ ប៉ុន្តែព្រឹកនោះខ្ញុំបានទៅសាលាទាំងអារម្មណ៍មិនល្អ ។

ថ្ងៃដដែលនោះ នៅពេលដែលខ្ញុំត្រឡប់មកពីរៀនដើម្បីហូបអាហារថ្ងៃត្រង់ ខ្ញុំបានឃើញ លេខាជាំង មកកាន់ផ្ទះខ្ញុំជាលើកទីពីរ ។ គាត់ឈរនៅក្នុងបន្ទប់ទទួលភ្ញៀវហើយនិយាយខ្លាំងៗទៅកាន់ឪពុករបស់ខ្ញុំ ។ ម្ដាយរបស់ខ្ញុំកំពុងចម្អិនអាហារនៅក្នុងផ្ទះបាយ ។ លេខាជាំង បានពោលទាំងខឹងថា «លោកត្រូវកាប់ដើមឈើប៉ុន្មានដើមនោះក្នុងថ្ងៃនេះភ្លាម បើមិនដូច្នោះទេ ខ្ញុំនឹងបញ្ជូនមនុស្សមកកាប់ជំនួស ហើយមិនទុកឈើឲ្យលោកធ្វើអុសថែមទៀត» ។ ឪពុកខ្ញុំបានឆ្លើយថា «លោកឲ្យគេមកកាប់ជំនួសខ្ញុំចុះ ពីព្រោះខ្ញុំមិនអាចកាប់ដើមឈើដែលខ្ញុំបានដាំដោយផ្ទាល់ដៃបានទេ» ។ ដោយក្ដីអស់សង្ឃឹមនឹងការឆ្លើយតបរបស់ឪពុកខ្ញុំ លេខាជាំង ពោលថា«លោករឹងទទឹងណាស់ លោកមិនចេះកែប្រែអ្វីទេ» ។ ឪពុកខ្ញុំនៅស្ងៀមចំពោះការរិះគន់នេះ ប៉ុន្តែខ្ញុំទ្រាំមិនបានចំពោះលេខាជាំង ក៏ងើបមុខឡើងហើយនិយាយទៅគាត់ថា «វាមិនសមហេតុផលទេ បើយើងកាប់ដើមឈើហូបផ្លែយកធ្វើអុសនោះ យើងមានអុសគ្រប់គ្រាន់ហើយ» ។

ខ្ញុំស្គាល់លោកជាំង ។ តាមការពិតខ្ញុំត្រូវហៅគាត់ថាពូ (នៅក្នុងប្រទេសចិន ពិសេសនៅតាមភូមិ ដោយហេតុផលខ្លះម្នាក់ៗជាសាច់ញាតិនឹងគ្នាទោះជាអាចមិនមានទំនាក់ទំនងខាងសាច់ឈាមដោយផ្ទាល់ក៏ដោយ) ។ លោកជាំង មានរូបរាងទាប ហើយស្គមមានកម្ពស់ត្រឹមស្មាឪពុករបស់ខ្ញុំ ប៉ុន្តែគាត់ជាមនុស្សឈ្លាសវៃ ។ នៅក្នុងសម័យបដិវត្តន៍វប្បធម៌ ម្នាក់ៗសង្ស័យគ្នាទៅវិញទៅមក ពីព្រោះ ម៉ៅ សេទុង បានថ្លែងប្រាប់ប្រជាជនថា អ្នកដែលនៅជិតខ្លួនអ្នកអាចមានធាតុមូលធននិយមក្រាស់ឬជាសត្រូវរបស់ប្រជាជន ។ ក្នុងតួនាទីជាលេខាធិការ លោកជាំង ត្រូវបានស្គាល់ពីគំនិតនិងទង្វើប្លែករបស់គាត់នៅក្នុងភូមិ ។ ដោយមូលហេតុនេះមនុស្សជាច្រើននៅក្នុងភូមិស្អប់គាត់ ប៉ុន្តែគ្មាននរណាម្នាក់ធ្វើអ្វីចំពោះគាត់បានទេ ។ សូម្បីតែឪពុករបស់ខ្ញុំដែលមិនចេះខ្លាចអ្វីសោះនោះ បានចៀសវាងមិនប្រឈមមុខជាមួយនឹងគាត់ឡើយ ។ ដូច្នេះ នៅពេលដែលគាត់ឮអ្វីដែលខ្ញុំនិយាយទៅ លេខាជាំង គាត់

សុំទោសភ្លាមដោយអាកប្បកិរិយាឱនលំទោន ។

គាត់ពោលថា “ខ្ញុំសុំទោស លេខាជាំង វាគ្រាន់តែជាក្មេង មិនដឹងអីប៉ុណ្ណោះ ហើយមិនចេះធ្វើអាកប្បកិរិយាសមរម្យទេ ។ ខ្ញុំ សន្យាថាខ្ញុំនឹងពិន័យវា” ។ លេខាជាំង មានការអាម៉ាស់និងខឹង ចំពោះ“ភាពព្រហើន”របស់ខ្ញុំជាខ្លាំង ។ គាត់មិនរវល់ចំពោះការ សុំទោសរបស់ឪពុកខ្ញុំឡើយ ហើយនិយាយថា “ការពិន័យរបស់ លោកនឹងមិនកែប្រែវាបានទេ ។ វានិយាយចេញពីខួក្បាលរបស់ វា ។ គឺគំនិតមូលធននិយមដែលធ្វើឲ្យវាគិតខុសឆ្គងបែបនេះ ។ វាគួរតែត្រូវរិះគន់និងទូន្មាននៅសាលារហូតដល់វាសារភាពអំពីគំនិត មូលធនរបស់វា” ។ និយាយចប់គាត់ងាកមករកខ្ញុំ ហើយនិយាយ ថា“ខ្ញុំធ្លាប់ឮថាឯងជាសិស្សល្អមួយរូប ។ ឥឡូវនេះខ្ញុំដឹងហើយ ថា ឯងជាសិស្សល្អប្រភេទណា ។ ខ្ញុំនឹងទៅប្រាប់នាយកសាលានិង គ្រូឯងអំពីអាកប្បកិរិយារបស់ឯងនៅថ្ងៃនេះហើយ” ។ និយាយ ចប់ គាត់ក៏ចេញទៅទាំងមិនបានលាឪពុកខ្ញុំ ។

ខ្ញុំមានអារម្មណ៍សោកស្តាយចំពោះឪពុកខ្ញុំដែលបានទទួល ភាពអាម៉ាស់បែបនេះ ។ ក្នុងពេលជាមួយគ្នានេះ ខ្ញុំឈឺចាប់ជាខ្លាំង ដែលឪពុកខ្ញុំមិនបានកាន់ជើងខ្ញុំ ។ ខ្ញុំគោរពនិងស្រលាញ់ឪពុកខ្ញុំ ទោះជាជួនកាលដូចដែលម្តាយខ្ញុំតែងនិយាយថាគាត់តឹងរ៉ឹងនឹងខ្ញុំ ពេកក៏ដោយ ។ ដោយសារខ្ញុំតែងតែគិតថាគាត់ជាមនុស្សក្លាហាន មួយរូប ខ្ញុំខកចិត្តជាខ្លាំងដែលគាត់ឱននៅចំពោះមុខ លេខាជាំង ។ ជាច្រើនឆ្នាំក្រោយមក ទើបខ្ញុំដឹងថាឪពុកខ្ញុំក៏ជាបុរសដ៏ឆ្លាតមួយ រូប ។ គាត់ដឹងថា ការប្រឈមមុខនឹង លោកជាំង នៅក្នុងស្ថានភាព បែបនោះ បានត្រឹមតែនាំបញ្ហាដល់គ្រួសារប៉ុណ្ណោះ ។ ថ្ងៃនោះ ឪពុកខ្ញុំមិនបានពិន័យខ្ញុំតាមការសន្យារបស់គាត់នោះទេ ។

បន្ទាប់ពីអាហារថ្ងៃត្រង់ ខ្ញុំបានទៅសាលាដូចរាល់ដង ប៉ុន្តែ នៅតែមានអារម្មណ៍ខឹងអំពីការជួបជាមួយ លោកជាំង ពីថ្ងៃត្រង់ ។ ខ្ញុំមិនដឹងថាខ្ញុំនឹងមានបញ្ហាធ្ងន់ធ្ងរទេមុនពេលដែលត្រូវហៅឲ្យទៅ ជួបអ្នកគ្រូរបស់ខ្ញុំនៅការិយាល័យរបស់គាត់ ។ មុនពេលរៀបរាប់ ពីអ្វីដែលបានកើតឡើងបន្ទាប់ ខ្ញុំសូមជម្រាបដោយសង្ខេបអំពី អ្នកគ្រូថ្នាក់ទីប្រាំរបស់ខ្ញុំ គឺអ្នកគ្រូលី ។ អ្នកគ្រូលីបានមក បង្រៀននៅក្នុងភូមិរបស់ខ្ញុំភ្លាមៗក្រោយពីគាត់បានបញ្ចប់ថ្នាក់ វិទ្យាល័យនៅក្នុងទីក្រុងមួយដែលមានទីតាំងនៅជិតភូមិ ។ គាត់ បានមកបង្រៀននៅក្នុងភូមិរបស់ខ្ញុំដោយសារប្តីរបស់គាត់មាន ស្រុកកំណើតនៅក្នុងភូមិនេះ ។ គាត់បានជួបប្តីគាត់នៅវិទ្យាល័យ ហើយបានស្រលាញ់គ្នា ។ អ្នកគ្រូលីជា“ស្ត្រីទីក្រុង”ទីមួយដែល មករស់នៅក្នុងភូមិរបស់ខ្ញុំ ។ អស់រយៈពេលជាច្រើនឆ្នាំ គាត់គឺជា អ្នកចេះដឹងនិងជាគ្រូដ៏ល្អម្នាក់ក្នុងភូមិ ។ ក្រៅពីនេះគាត់តែងតែ មានសន្តានចិត្តល្អនិងមានភាពអត់ធ្មត់ចំពោះសិស្សរបស់គាត់ ។ ខ្ញុំដឹងថាគាត់ចូលចិត្តខ្ញុំពីព្រោះខ្ញុំជាសិស្សល្អ ហើយជាមិត្តនឹងកូន របស់គាត់ឈ្មោះ ឈុន សេង ដែលរៀនក្នុងថ្នាក់ជាមួយគ្នា ។

អ្នកគ្រូលីមានទឹកមុខព្រួយបារម្ភនៅពេលដែលគាត់ជួបខ្ញុំ រសៀលថ្ងៃនោះ ប៉ុន្តែសម្តីរបស់គាត់នៅតែទន់ភ្លន់ចំពោះខ្ញុំដដែល ។ គាត់សួរខ្ញុំថា“ឯងជាសិស្សយ៉ាងម៉េច? តើឯងបានធ្វើអ្វីខ្លះថ្ងៃ ត្រង់នេះពេលទៅញ៉ាំបាយនៅឯផ្ទះ?” ដំបូងខ្ញុំភ្ញាក់ព្រើត ក្រោយមកក៏ដឹងថាខ្ញុំមានបញ្ហាធំហើយ ។ ខ្ញុំគិតថា លេខាជាំង គ្រាន់តែគំរាមខ្ញុំដោយនិយាយថាគាត់នឹងមកប្តឹងអ្នកគ្រូលី ប៉ុណ្ណោះ ។ គាត់ប្រាកដជាបានមកប្រាប់អ្នកគ្រូលីនិងលោកនាយកសាលាអំពី អ្វីៗអស់ហើយ ។ “ខ្ញុំបានតមាត់ជាមួយ លេខាជាំង ប៉ុន្តែខ្ញុំបាន និយាយការពិត” ខ្ញុំឆ្លើយ ។ អ្នកគ្រូលី គំហក “កុំដោះសាចំពោះ កំហុសខ្លួនឯង” ។ ខ្ញុំមិនដែលឃើញគាត់ខឹងដូចនេះទេពីមុនមក ។ បន្ទាប់មកគាត់ក៏និយាយដោយសម្តីទន់ភ្លន់វិញថា“លេខាជាំង បានប្រាប់លោកនាយកអំពីអ្វីដែលឯងបាននិយាយទៅកាន់គាត់ ហើយបានបញ្ជាឲ្យលោកនាយកបើកការប្រជុំមួយដើម្បីរិះគន់គំនិត មូលធនរបស់ឯង ។ ឥឡូវនេះឯងត្រូវសរសេរបាយការណ៍ សារភាពមួយច្បាប់ ហើយអាននៅចំពោះមុខសិស្សទាំងអស់នៅ ក្នុងអង្គប្រជុំនាពេលរសៀលនេះ” ។ រំពេចនោះ ខ្ញុំក៏មានអារម្មណ៍ អាម៉ាស់និងភិតភ័យ ។ ទាំងខំប្រឹងទប់ទឹកភ្នែកខ្ញុំនិយាយថា “ខ្ញុំ មិនដឹងថាត្រូវសរសេរបាយការណ៍នេះបែបណាទេ” ។ បន្ទាប់ពី ទុកឲ្យខ្ញុំសម្រួលអារម្មណ៍ អ្នកគ្រូលី ក៏លួងលោមខ្ញុំថា “ខ្ញុំដឹងថាវា ពិបាកបន្តិចចំពោះឯង ប៉ុន្តែឯងត្រូវតែសរសេរបាយការណ៍នេះ ។ បើមិនដូច្នោះទេ ទាំងនាយកសាលានិងអ្នកគ្រូនឹងមានរឿងរ៉ាវ មិនខាន ។ ឯងមិនត្រូវខ្លាចទេ ។ វាមិនពិបាកសរសេរទេ” ។ សម្តី នេះបានធ្វើឲ្យខ្ញុំភ្លេចការភិតភ័យអស់ ។ ការសរសេរបាយការណ៍ នេះងាយស្រួលណាស់ គឺដូចជាការតែងសេចក្តីដែរ ។ អ្នកគ្រូលី បានជួយខ្ញុំក្នុងការសរសេររិះគន់ខ្លួនឯងនេះដូចដែលគាត់ធ្លាប់ បានធ្វើនៅក្នុងថ្នាក់ ។

សាលារបស់ខ្ញុំជាសាលាបឋមសិក្សាដ៏តូចមួយដែលមានសិស្សប្រហែលជា១២០នាក់ ។ កាលនោះខ្ញុំកំពុងរៀនថ្នាក់ទី៥ ។ ដូច្នោះខ្ញុំជារៀមច្បងម្នាក់ក្នុងសាលា ទោះជាខ្ញុំទើបតែមានអាយុដប់មួយឆ្នាំក៏ដោយ ។ បញ្ហាដ៏ធំបំផុតនោះគឺថាអ្នកភូមិទាំងអស់ស្គាល់គ្នាទៅវិញទៅមក ហើយខ្ញុំមានអារម្មណ៍ថាខ្ញុំបានធ្វើឲ្យគ្រួសារនិងមិត្តភក្តិរបស់ខ្ញុំអាម៉ាស់ ។

ការប្រជុំបានធ្វើឡើងនៅលើទីលានតូចមួយនៅមុខសាលារៀន ។ ខ្ញុំបានឃើញ លេខាជាំង និយាយជាមួយលោកនាយកសាលានៅមាត់ទ្វារការិយាល័យរបស់គាត់ ដែលធ្វើឲ្យខ្ញុំភិតភ័យនិងមានការខ្មាសអៀនឡើងវិញ ។ ខ្ញុំបានយំ ហើយទឹកភ្នែកខ្ញុំបានហូរកាត់ថ្ពាល់របស់ខ្ញុំនៅពេលដែលខ្ញុំអានរបាយការណ៍សារភាពនៅចំពោះមុខអង្គប្រជុំ ។ ខ្ញុំចាំមិនច្បាស់ថាខ្ញុំបានសរសេរអ្វីខ្លះនៅក្នុងរបាយការណ៍នេះទេ ប៉ុន្តែចំណុចសំខាន់ គឺខ្ញុំនិយាយថា ខ្ញុំខុសដែលបាននិយាយទៅកាន់លេខាជាំងដោយសម្តីមិនសមរម្យ ។ នៅពេលដែលខ្ញុំបានបញ្ចប់ការរិះគន់ខ្លួនឯង លេខាជាំង បានចាប់ផ្តើមសុន្ទរកថាមួយដ៏វែងអន្លាយនិងបែរទៅកាន់ហ្វូងកុមារដែលភាគច្រើនមានអាយុតិចជាងដប់មួយឆ្នាំ ។ នៅទីបញ្ចប់គាត់ពោលថា “ការ ឈីងក្វ មានបញ្ហាធ្ងន់ធ្ងរនៅក្នុងចិត្តរបស់វា ប៉ុន្តែវាបានសារភាពកំហុសដោយស្មោះត្រង់ ។ ការយំរបស់វាមិនមែនមានន័យថា វាបានបំបាត់ចោលទស្សនៈមូលធននិយមឲ្យអស់ពីខ្លួននោះទេ ហើយខ្ញុំសង្ឃឹមថា ក្មួយៗទាំងអស់គ្នានឹងអាចជួយកែប្រែវានៅពេលអនាគត ។ ក្មួយៗទាំងអស់ត្រូវប្រុងប្រយ័ត្នជាប់ជានិច្ច មិនត្រូវបណ្តែតបណ្តោយខ្លួនឲ្យប្រឡូកប្រឡាក់នឹងគំនិតមូលធននិយមទេ…” ។

ល្ងាចនោះ ពេលត្រឡប់មកពីសាលារៀនវិញ ខ្ញុំមើលផ្ទះខ្ញុំស្ទើរតែពុំស្គាល់ ។ ផ្ទះរបស់ខ្ញុំមានសភាពខុសប្លែកពីមុន ។ ដើមផ្លាំទាំងប្រាំបាត់អស់ហើយ ។ ខ្ញុំរត់ទៅសួនដំណាំមុនចូលទៅក្នុងផ្ទះខំប្រឹងស្វែងរកសំណល់នៃដើមឈើនេះ ។ សូម្បីតែមែកមួយធាងក៏មិនឃើញដែរ ។ ខ្ញុំឃើញតែរណ្តៅទើបជីកថ្មីៗចំនួនប្រាំនៅកន្លែងដែលដើមផ្លាំដុះ ។ ខ្ញុំឃើញតែកម្ទេចផ្កាប្រឡាក់ទៅដោយដីដែលប្រាកដជាបានជាន់ឈ្លីដោយអ្នកដែលត្រូវបញ្ជូនឲ្យមកកាប់ហើយ ។ ខ្ញុំយំ ។

អស់រយៈកាលជាង២០ឆ្នាំហើយតាំងពីព្រឹត្តិការណ៍នោះបានកើតឡើង ។ បដិវត្តន៍វប្បធម៌នៅក្នុងប្រទេសចិនបានកន្លងផុតទៅហើយ ហើយបានក្លាយទៅជាផ្នែកមួយនៃប្រវត្តិសាស្រ្តសម័យ ទំនើបរបស់ប្រទេសចិន ទោះជាយើងពេញចិត្តឬមិនពេញចិត្តវាក៏ដោយ ។ មានរឿងរ៉ាវជាច្រើនបានកើតឡើងនៅក្នុងប្រទេសចិននៅក្នុងរយៈពេលបីទសវត្សរ៍មុន ។ ប្រហែលជាខ្ញុំជាមនុស្សដែលមានមនោសញ្ចេតនាពេកហើយមើលទៅ ។ ខ្ញុំនឹកដើមផ្លាំទាំងប្រាំដើមណាស់ នៅពេលដែលខ្ញុំគិតអំពីអ្វីដែលបានកើតឡើងនៅក្នុងរដូវផ្ការីកឆ្នាំនោះ ។ ក្រោយពីបដិវត្តន៍វប្បធម៌ត្រូវបញ្ចប់ ឪពុកខ្ញុំបានដាំដើមផ្លាំថ្មីចំនួន៥ដើមជាជំនួសដើមផ្លាំដែលត្រូវកាប់ ។ ដើមផ្លាំថ្មីៗនេះបានចេញផ្លែជាច្រើនឆ្នាំមកហើយ ។ ខ្ញុំមិនដែលមានឱកាសភ្លក្សរសជាតិផ្លែផ្លាំថ្មីទាំងនេះទេ ពីព្រោះខ្ញុំបានរស់នៅក្នុងទីក្រុងមួយឆ្ងាយពីស្រុកកំណើត ហើយទៅលេងផ្ទះតែក្នុងរដូវរងាតែប៉ុណ្ណោះ ។ ឪពុកខ្ញុំបានប្រាប់ខ្ញុំថា ផ្លែផ្លាំ លើកក្រោយនេះមានរសជាតិផ្អែមដូចដើមមុនអ៊ីចឹង ។

លេខាជាំង បានសុំទោសចំពោះអ្វីដែលគាត់បានធ្វើមកលើគ្រួសារខ្ញុំនៅពេលដែលគាត់មករកឪពុកខ្ញុំឲ្យជួយបង្ហាត់គាត់ដាំនិងថែទាំដើមឈើហូបផ្លែ ។ ឪពុកខ្ញុំបានប្រាប់ខ្ញុំថា គាត់មិនប្រកាន់លោកជាំង ទេ ពីព្រោះពេលនោះគ្រាន់តែជាសម័យដ៏ឆ្កួតលេលាមួយនៅក្នុងប្រទេសចិនប៉ុណ្ណោះ ។ គ្មាននរណាម្នាក់មិនឆ្កួតទេនៅក្នុងសម័យបដិវត្តន៍វប្បធម៌! គាត់មិនដែលសុំទោសខ្ញុំដោយផ្ទាល់ទេ ប៉ុន្តែខ្ញុំដឹងថាគាត់មានការសោកស្តាយនៅពេលដែលខ្ញុំនិយាយជាមួយគាត់ជាច្រើនឆ្នាំក្រោយមក ។ បច្ចុប្បន្នគាត់គ្រាន់តែជាពូជរាម្នាក់នៅក្នុងភូមិតែប៉ុណ្ណោះ ។

ភាពអាម៉ាស់និងកំហឹងទាំងអស់នៅក្នុងសម័យបដិវត្តន៍វប្បធម៌ ឥឡូវនេះមានតែនៅក្នុងការចងចាំដ៏ស្រពេចស្រពិលរបស់ខ្ញុំប៉ុណ្ណោះ ហើយកាន់តែបាត់បន្តិចម្តងៗទៅតាមពេលវេលា ។ ផ្ទុយទៅវិញ ខ្ញុំនៅចាំដើមផ្លាំទាំងប្រាំដើមច្បាស់ក្រឡែតដូចកាលពី៣០ឆ្នាំមុន ។ ទោះជាខ្ញុំបានភ្លក្សផ្លែឈើជាច្រើនប្រភេទនៅជុំវិញពិភពលោកតាំងពីខ្ញុំបានចាកចេញពីភូមិក៏ដោយ ខ្ញុំនឹងមិនអាចបំភ្លេចឱជារសរបស់ផ្លែផ្លាំនៅក្នុងសួនដំណាំរបស់ខ្ញុំឡើយ ។ វាមានរសជាតិល្វីងបន្តិចនៅរដូវក្តៅនិងផ្អែមឆ្ងាញ់នៅរដូវស្លឹកឈើជ្រុះ ។

**ការ ឈីងក្វ**

# ទស្សនាវដ្ដីស្វែងរកការពិត ឆ្នាំ២០០៣



៣៧



៣៨



៣៩



៤០



៤១



៤២



៤៣



៤៤



៤៥



៤៦



៤៧



៤៨

*ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា*

*ទស្សនាវដ្ដីចំនួន១០០០ច្បាប់ជារៀងរាល់លេខនឹងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ មួយច្បាប់ក្នុងតម្លៃ ៧០០០រៀល*

*មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្ដីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្ដីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!*

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@online.com.kh. Thank you.



**Funded by Norway, Sweden, The Netherlands, and USA.**